# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យកសិកម្ម ២០១៤-២០១៨

ខែមិថុនា ឆ្នាំ២០១៥

អាសយដ្ឋាន លេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៩ / ៧២៦ ១២៨ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០ គេហទំព័រ: http://www.maff.gov.kh

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីជំរុញការអនុវត្ត "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២" និងសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនភាពនាពេលកន្លងមក។ ក្នុងអាណត្តិទី៥នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣" និង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨" ហើយនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ដោយបានកំណត់យ៉ាងច្បាស់ថា វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាតាមអភិក្រម និងក្នុងវិសាលភាពនិងល្បឿនថ្មី ដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម (បើកទូលាយ) ពោលគឺពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់ (ធនធានដីនិងធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ឈានទៅរកដំណាក់កាលថ្មី ដែលផ្ដោតលើផលិតកម្មតាមបែបប្រពលវប្បកម្ម (ស៊ីជម្រៅ) ពោលគឺពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី ការស្រាវជ្រាវនិងការអភិវឌ្ឍយន្តូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មមុខដំណាំ និងផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វនិងវារីវប្បកម្មផង ដោយគិតគូរផងដែរ អំពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព និងការធានាចីរភាពបរិស្ថាន និងធនធានធម្មជាតិ។

ក្នុងន័យនេះ ដើម្បីសម្រេចបាននូវទិសដៅអភិវឌ្ឍន៍វិស័យកសិកម្មក្នុងអាណត្តិទី៥នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់ទិសដៅគោលនយោបាយជាយុទ្ធសាស្ត្រគឺ "ជំរុញកំណើនក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម និងការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព"។

ដើម្បីអនុវត្តនិងសម្រេចបាន នូវទិសដៅគោលនយោបាយដែលបានកំណត់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកសាងនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ដែលត្រូវបានចាត់ទុកជាឯកសារផែនការយុទ្ធសាស្ត្រដ៏សំខាន់មួយ ក្នុងការកំណត់និងតម្រង់ទិសដៅសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មរយៈពេលមធ្យម។

ជាការពិត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ គឺត្រូវបានរៀបចំឡើងស្របតាមទិសដៅ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលមានចែងយ៉ាងច្បាស់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ដែលនឹងអាចចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវទិសដៅគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងក្របខណ្ឌនៃការអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី៥នេះ។

បន្ថែមលើនេះទៀត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ដែលបានរៀបចំមកនេះ ក៏មានលក្ខណៈសង្គតិភាពផងដែរ ទៅនឹងឯកសារគោលនយោបាយស្តីពី **"ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ"** ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ ដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងស្របជាមួយឯកសារគោលនយោបាយពាក់ព័ន្ធផ្សេងទៀតផងដែរ។

ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយទាំងអស់ខាងលើ គឺមានកិច្ចការជាច្រើននឹងត្រូវអនុវត្ត និងត្រូវសម្រេចឱ្យបាននាពេលខាងមុខ។ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងអនុវិស័យនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតែខិតខំអនុវត្តឱ្យបានសកម្ម និងខ្លាំងក្លា នូវបណ្តាសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្តេជ្ញាយ៉ាងមុតមាំក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ដោយប្រែក្លាយផែនការសកម្មភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនេះ ឱ្យទៅជាការអនុវត្តជាក់ស្តែង តាមរយៈការខិតខំបង្កើនធនធានក្នុងស្រុក និងកៀរគរធនធានពីបណ្តាដៃគូអភិវឌ្ឍន៍នានា ក៏ដូចជាការធ្វើសមាហរណកម្មឲ្យតួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ពិតជានឹងចូលរួមសហការអនុវត្តសកម្មភាពការងារ ពិសេសសហគមន៍អន្តរជាតិ នឹងបន្តផ្តល់ជំនួយទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកជួយទ្រទ្រង់ដល់ដំណើរការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ ឱ្យទទួលបានលទ្ធផលផ្លែផ្កាជាវិជ្ជមាន និងប្រកបដោយភាពស័ក្តិសិទ្ធិតាមការរំពឹងទុក។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ដល់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ដែលបានចូលរួមយ៉ាងសស្រាក់សស្រាំ ក្នុងដំណើរកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ និងប្តេជ្ញាចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអនុវត្ត ដើម្បីសម្រេចបានគោលដៅកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលអនាគតប្រកបដោយជោគជ័យ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ[illegible] ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

# មាតិកា

**អារម្ភកថា** **ទំព័រ**

## ផ្នែកទី ១

## សមិទ្ធផល និងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣


I- សេចក្តីផ្តើម .................................................................................................. ៥
II- សមិទ្ធផលសម្រេចបាននិងបញ្ហាប្រឈមចម្បងៗក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ៦
ក- ស្ថានភាពទូទៅ .................................................................................................. ៦
ខ- សមិទ្ធផល និងការរីកចម្រើននៃវិស័យកសិកម្មតាមផ្នែក.......................................... ៩
១- ការធ្វើឱ្យប្រសើរឡើងផលិតភាព និងពិពិធកម្មកសិកម្ម .............................. ១១
២- ផលិតកម្មដំណាំកៅស៊ូ .......................................................................... ១៦
៣- ផលិតកម្មសត្វនិងបសុព្យាបាល .............................................................. ១៨
៤- អាជីវកម្ម និងកំណែទម្រង់ផ្នែកជលផល ...................................................... ២១
៥- ការអនុវត្ត និងកំណែទម្រង់ផ្នែកព្រៃឈើ....................................................... ២៣
៦- សេវាកម្មគាំទ្រផលិតកម្មកសិកម្ម............................................................... ២៦
គ- ការវាយតម្លៃ និងសន្និដ្ឋាន .............................................................................. ២៨
១- ភាពខ្លាំង បញ្ហាប្រឈម និងឧបសគ្គ ........................................................... ២៨
២- ការវាយតម្លៃ និងសន្និដ្ឋាន ..................................................................... ៣២


## ផ្នែកទី ២

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨


I- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ...................................... ៣៤
ក- សេចក្តីផ្តើម...................................................................................................... ៣៤
ខ- ចក្ខុវិស័យ ........................................................................................................ ៣៦
គ- បេសកកម្ម ........................................................................................................ ៣៦
ឃ- ទិសដៅគោលនយោបាយ......................................................................................... ៣៧
ង- កម្មវិធីទាំង៥របស់ក្រសួង .................................................................................... ៣៩
ច- អនុកម្មវិធីនិងគម្រោងសកម្មភាពតាមបណ្តាអនុវិស័យជំនាញ....................... ៥០
ឆ- ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់អន្តរវិស័យ ................................................ ១០៤

ជ- ផែនការថវិកាសម្រាប់ដំណើរការអនុវត្ត ........................................................ ១២២
ឈ- ការពិនិត្យតាមដាន និងវាយតម្លៃ ........................................................ ១២៤
ញ- សេចក្តីសន្និដ្ឋាន ........................................................ ១២៥

IV- **ឧបសម្ព័ន្ធ** ........................................................
ឧបសម្ព័ន្ធ១៖ តារាងសូចនាករសំខាន់ៗ ក្នុងផែនការយុទ្ធសាស្រ្តជាតិ ២០១៤-២០១៨ ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យកសិកម្ម
ឧបសម្ព័ន្ធ២៖ តារាងម៉ាទ្រិចនៃសកម្មភាពសម្រាប់អនុវត្តផែនការយុទ្ធសាស្រ្ត អភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨

# ផ្នែកទី ១
# សមិទ្ធផល និងបញ្ហាប្រឈមចម្បងៗ
# ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣

## I- សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្មនៅឡើយ ហើយមានប្រជាពលរដ្ឋប្រមាណ៨០%រស់នៅជនបទ ក្នុងនោះភាគច្រើនប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបែបនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងចាត់ទុកថា កសិកម្មគឺជាវិស័យមួយដែលមានអាទិភាពខ្ពស់ នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រទេសជាតិ។

ការរីកចម្រើននៃវិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដែលវិស័យនេះបានចូលរួមចំណែកយ៉ាងច្រើនក្នុងកំណើនផលិតផលសរុបក្នុងស្រុក (GDP) និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ បច្ចុប្បន្ននេះ វិស័យកសិកម្មបានទ្រទ្រង់ដល់ការអភិវឌ្ឍជាតិ និងបានធ្វើឱ្យមានស្ថេរភាពដោយសារការរីកចម្រើននូវប្រព័ន្ធធារាសាស្ត្រ ការចាប់យកនូវបច្ចេកវិជ្ជាកសិកម្ម ការខិតខំប្រឹងប្រែងនានា ពិសេសសកម្មភាពស្រាវជ្រាវកសិកម្មដើម្បីបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ។ ទន្ទឹមនោះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានខិតខំធ្វើកិច្ចការយ៉ាងច្រើន សំដៅពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីកៀរគរធនធានពីខាងក្រៅ សម្រាប់ជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិ ដោយផ្តោតទៅលើការលើកស្ទួយវិស័យកសិកម្មនិងជនបទ ការកាត់បន្ថយភាពក្រីក្រឱ្យបានក្នុងកម្រិតមួយសមស្រប តាមរយៈការបង្កើនផលិតភាពកសិកម្ម ធានានូវសន្តិសុខស្បៀងបង្កើតការងារ និងបង្កើនចំណូលគ្រួសារកសិករ។ ជាការកត់សម្គាល់នាពេលកន្លងមក វិស័យនេះអាចធានាបាននូវអតិរេកនៃផលិតផលកសិកម្ម បម្រើឱ្យការនាំចេញច្រើនទៀតផង។ ជាមួយការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាទាំងនេះ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣ ត្រូវបានវាយតម្លៃថា បានឆ្លើយតបនឹងទិសដៅគោលនយោបាយយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ គឺជាឯកសារផែនការគោលនយោបាយ និងយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យម និងជាផែនទីបង្ហាញផ្លូវ ដែលបានបង្ហាញអំពីទិសដៅអភិវឌ្ឍន៍វិស័យកសិកម្ម ជាមួយនឹងគោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាព របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តក្នុងរយៈពេល ៥ឆ្នាំពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ និងបានឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេស

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ សំដៅរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើឱ្យប្រសើរឡើង និងការបង្កើនផលិតភាព ពិពិធកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ត្រូវបានរៀបចំសម្រាប់អនុវត្ត សំដៅធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា តាមអភិក្រមក្នុងវិសាលភាពនិងល្បឿនថ្មី ដើម្បីជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

## II- សមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈមចម្បងៗ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣

### ក. ស្ថានភាពទូទៅ

ជាការពិតណាស់ថា វិស័យកសិកម្មមានសារសំខាន់បំផុត ក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ ព្រោះវិស័យនេះអាចផ្តល់នូវប្រភពស្បៀងអាហារសម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ជាប្រភពផ្គត់ផ្គង់វត្ថុធាតុដើមចម្បងសម្រាប់ការអភិវឌ្ឍផ្នែកកសិ-ឧស្សាហកម្ម និងជាប្រភពចំណូលជាតិសំខាន់ ដែលទទួលបានពីការធ្វើផលិតកម្ម និងការនាំចេញផលិតផលកសិកម្មចូលទៅក្នុងទីផ្សារអន្តរជាតិ។ នេះគឺជាចំណុចគន្លឹះចម្បងបំផុត ដែលអាចបញ្ជាក់បានថាវិស័យកសិកម្មមានតួនាទីក្នុងការជំរុញការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច។

ការលើកស្ទួយវិស័យកសិកម្ម គឺជាមុំមួយដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិ។ ការលើកកម្ពស់ផលិតភាពនិងពិពិធកម្មកសិកម្ម ការកែទម្រង់ដីធ្លីនិងបោសសម្អាតមីន ការកែទម្រង់វិស័យជលផល និងការកែទម្រង់វិស័យព្រៃឈើ គឺជាមុខព្រួញស្នូលដើម្បីចូលរួមជំរុញសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយបាននូវការលំបាកផ្សេងៗ ដែលរួមមាន កត្តាអវិជ្ជមាននៃធម្មជាតិ ពិសេសគ្រោះរាំងស្ងួតដោយសារឥទ្ធិពលកូនរដូវប្រាំង និងគ្រោះទឹកជំនន់ដោយទឹកភ្លៀងដែលតែងតែកើតមានជារៀងរាល់ឆ្នាំ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញផលិតកម្មកសិកម្ម លើគ្រប់មុខព្រួញជាពិសេស ការបង្កបង្កើនផលដំណាំជាយុទ្ធសាស្ត្រជាអាទិ៍ ដំណាំស្រូវ កៅស៊ូ ដំណាំស្បៀង និងដំណាំកសិ-ឧស្សាហកម្ម ការចិញ្ចឹមសត្វ និងនេសាទ មិនត្រឹមតែអាចឆ្លើយតបបានទៅនឹងតម្រូវការស្បៀងក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងអាចនៅសល់ស្បៀងសម្រាប់នាំចេញទៀតផង។ នៅពេល

ដែលពិភពលោកកំពុងជួបប្រទះវិបត្តិស្បៀង និងការធ្លាក់រូញចុះនៃសេដ្ឋកិច្ចនាពេលកន្លងមក កម្ពុជាបានខិតខំបង្កើននូវផលិតកម្មដំណាំស្បៀង សំដៅរួមចំណែកដោះស្រាយបញ្ហានេះ ដោយសារយើងមានសក្តានុពលអំណោយផលយ៉ាងធំធេងរបស់វិស័យកសិកម្មនេះ ជាពិសេសផលិតកម្មដំណាំស្រូវអាចពង្រីកសក្តានុពលផលិតកម្មនិងការនាំចេញ លើកស្ទួយជីវភាពប្រជាពលរដ្ឋតាមជនបទ និងបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

លើសពីនេះទៀតនោះ គោលនយោបាយនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ក៏នៅតែបន្តជំរុញការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ការកែទម្រង់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព ដែលជាមុខព្រួញស្នូលដើម្បីចូលរួមជំរុញសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

រយៈពេល៥ឆ្នាំកន្លងទៅនេះ ប្រជាពលរដ្ឋគ្រប់តំបន់និងទីប្រជុំជន បានខិតខំប្រកបមុខរបរយ៉ាងមមាញឹក ប្រកបដោយលក្ខណៈប្រកួតប្រជែង ក្នុងបរិបទនៃពាណិជ្ជូបនីយកម្មកសិកម្ម ដែលធ្វើឱ្យវិស័យកសិកម្មកាន់តែមានភាពសកម្ម និងមានសារសំខាន់ក្នុងជីវភាពសង្គម ក៏ដូចជាការគាំទ្រសេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបាននិងកំពុងបង្កើនផ្តោតការយកចិត្តទុកដាក់ និងវិនិយោគកាន់តែខ្លាំងក្លាលើវិស័យកសិកម្មនេះ។

ការរីកចម្រើននៃវិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដែលបានរួមចំណែកយ៉ាងច្រើន ក្នុងកំណើនផលិតផលសរុបក្នុងស្រុក (GDP) និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ ដំណើរការអភិវឌ្ឍគ្រប់វិស័យ ការគ្រប់គ្រងបែងចែក និងការប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ រួមនឹងការខិតខំដោះស្រាយនូវរាល់បញ្ហាដែលមានចំពោះមុខ និងការទប់ស្កាត់សកម្មភាពរំលោភបំពានយកដីដោយខុសច្បាប់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រកសិកម្មនិងទឹក សំដៅជំរុញលើកកម្ពស់បង្កើនផលិតភាពកសិកម្ម ធានាឱ្យបាននូវបរិមាណនិងគុណភាព ធានាសន្តិសុខស្បៀង និងទីផ្សារក្នុងនិងក្រៅប្រទេស។ មិនតែប៉ុណ្ណោះ វិស័យកសិកម្មបាននិងកំពុងស្រូបទាញបាននូវទុនវិនិយោគ ទាំងពីអ្នកវិនិយោគក្នុងនិងក្រៅប្រទេស កាន់តែច្រើនឡើងជាលំដាប់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

បន្ថែមលើនេះ ក្រោយពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពី "**ការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ**" បរិមាណអង្ករនាំចេញបានកើនឡើងជាលំដាប់ ទៅកាន់ទីផ្សារអន្តរជាតិ និងអង្ករពូជស្រូវផ្ការំដួល ត្រូវបានចាត់ទុកថាមានគុណភាពល្អជាងគេក្នុងពិភពលោក។

វិស័យកសិកម្មបានចូលរួមចំណែកប្រហែល៣១,៦% (ថ្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៣នេះ។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ២៤,១% និងវិស័យសេវាកម្មប្រហែល៣៨,៥%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម

គឺអាស្រ័យទៅនឹងការរីកលូតលាស់ នៃផ្នែកពីរសំខាន់ផ្សេងទៀតក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មបានថយចុះពី៣៣,៩%-៣១,៦% ក្នុងចន្លោះឆ្នាំ២០១០-២០១៣ ដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម មានការកើនឡើង បន្ទាប់ពីឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក។

តម្លៃបន្ថែមសរុបនៃផលិតផលកសិកម្ម (Gross Value Added-GVA) បានកើនឡើងពី៥.៥៩៦ ពាន់លានរៀលនៅឆ្នាំ២០០៤ រហូតដល់៧.១៧៤ពាន់លានរៀលនៅឆ្នាំ២០០៧ (កើនប្រហែលជាង២៨%) និងបានបន្តកើនថែមទៀតដល់៩.០៨៧ពាន់លានរៀលឆ្នាំ២០១៣នេះ (គិតតាមថ្លៃស្ថេរឆ្នាំ២០០០)។

ជារួមកំណើន (%) នៃវិស័យកសិកម្ម មានការកើនឡើងជាមធ្យមប្រចាំឆ្នាំប្រមាណជាពី៣% ទៅ៤% (ចន្លោះឆ្នាំ២០០៩-២០១៣)។ កំណើនមានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ហើយការប្រែប្រួលនេះ មានពាក់ព័ន្ធទៅនឹងស្ថានភាពអាកាសធាតុនៃឆ្នាំនីមួយៗ។ ដូចនេះ វិស័យកសិកម្មគឺពឹងផ្អែកច្រើននៅឡើយលើកត្តាធម្មជាតិ ដែលជះឥទ្ធិពលដល់ផលិតកម្មកសិកម្ម។ នៅឆ្នាំ២០០៩ កំណើនក្នុងវិស័យនេះមានប្រមាណ៥,៤% និងឆ្នាំ២០១០ កំណើនមានប្រហែល៤% ដោយឡែកឆ្នាំ ២០១១ កំណើនបានធ្លាក់ចុះប្រមាណជាង៣,១% និងនៅឆ្នាំ២០១៣ កំណើនមានប្រមាណ១,៧% ដែលនេះគឺបណ្តាលមកពីឥទ្ធិពលនៃគ្រោះធម្មជាតិ ពិសេសគ្រោះទឹកជំនន់។

គួរកត់សម្គាល់ថា ផ្នែកផលិតកម្មដំណាំមានការកើនឡើងយ៉ាងខ្លាំង ដែលសមាសភាគរបស់ផ្នែកនេះមានចំនួន៥២,៩% នៅឆ្នាំ២០០៩ និងមាននិន្នាការកើនឡើងដល់៥៤,៨% នៅឆ្នាំ២០១២ និងឆ្នាំ២០១៣ សមាសភាគផ្នែកនេះមានការប្រែប្រួលធ្លាក់ចុះបន្តិច គឺមានត្រឹមតែ៥៤,២% ដោយសារផលិតកម្មដំណាំជួបបញ្ហាគ្រោះធម្មជាតិ និងទីផ្សារកសិផលមានការប្រែប្រួលថ្លៃ។ សមាសភាគនៃផ្នែកផលិតកម្មដំណាំនេះ បានកើនប្រមាណ២,៤៦% បើប្រៀបធៀបនឹងឆ្នាំ២០០៩។ ចំពោះសមាសភាគផ្នែកជលផលមានការប្រែប្រួលពី២៥,២%នៅឆ្នាំ២០០៩ កើនរហូតដល់២៦,៤៥% នាឆ្នាំ ២០១៣។ ដោយឡែកសមាសភាគចូលរួមផ្នែកអាជីវកម្មព្រៃឈើ មានការថយចុះជាបន្តបន្ទាប់ បើធៀបនឹងឆ្នាំ២០០៩ ពី៦,៦%មកត្រឹមតែ៥,៧%នៅឆ្នាំ២០១២ និង៥,៤៩%នៅឆ្នាំ២០១៣។ រីឯសមាសភាគផ្នែកផលិតកម្មសត្វមានការប្រែប្រួលនិងថយចុះ បើធៀបរយៈពេល៥ឆ្នាំកន្លងទៅនេះ (១៥,៥%នាឆ្នាំ២០០៩ ថយមកត្រឹម១២,៨%ឆ្នាំ២០១០ មានការកើនឡើង១៥%ឆ្នាំ២០១១ ថយចុះមកត្រឹម១៤,១%ឆ្នាំ២០១២ និង១៣,៨៧%ក្នុងឆ្នាំ២០១៣)។

ជាការកត់សម្គាល់ អ្នកវិនិយោគក្នុងនិងក្រៅប្រទេស បានមើលឃើញនូវសក្តានុពលនៃវិស័យនេះ និងបានដាក់ទុនវិនិយោគជាច្រើនក្នុងផ្នែកកសិ-ឧស្សាហកម្ម ស្របពេលជាមួយនឹងរបាំងពាណិជ្ជកម្មត្រូវបានកាត់បន្ថយ។ ម្យ៉ាងវិញទៀត វេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន ក៏បានចូលរួមចំណែកដោះស្រាយនូវរាល់បញ្ហាប្រឈមនានា សំដៅសម្រួលដល់ការវិនិយោគឯកជន។ យន្តការនៃក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ត្រូវបានអនុវត្តយ៉ាងសកម្ម ដើម្បីជួយសម្របសម្រួលជា

មួយដៃគូអភិវឌ្ឍន៍ក្នុងកិច្ចដំណើរការអភិវឌ្ឍវិស័យកសិកម្ម។ ជាទិសដៅនៃការអភិវឌ្ឍវិស័យកសិកម្ម ការពង្រីកផ្ទៃដីថ្មីសម្រាប់ដាំដុះដំណាំកសិកម្មនឹងត្រូវបានគិតគូរពិចារណា ដោយត្រូវរក្សាតុល្យភាព នៃការអភិវឌ្ឍនិងការអភិរក្ស។

## ខ. សមិទ្ធផល និង ការរីកចម្រើននៃវិស័យកសិកម្មតាមផ្នែក

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំអនុវត្តកិច្ចការជាច្រើន ដើម្បីជំរុញការអភិវឌ្ឍវិស័យទាំងមូល ពិសេស ការធ្វើពាណិជ្ជូបនីយកម្មកសិកម្ម និងផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីធានាផល ប្រយោជន៍ដល់ប្រជាកសិករ និងដោះស្រាយបានបញ្ហាទីផ្សារ ដោយការពង្រឹងសមត្ថភាពផលិត របស់សហគមន៍កសិកម្ម។ ទន្ទឹមនឹងនោះ ការនាំចេញផលិតផលកសិកម្ម ត្រូវបានមើលឃើញថា មានការវិវត្តឈានឡើង អាស្រ័យដោយមានការសម្រួលនីតិវិធីនាំចេញ តាមយៈការបង្កើតច្រកចេញ ចូលតែមួយ និងការអនុវត្តបទដ្ឋានអនាម័យនិងភូតគាមអនាម័យមានលក្ខណៈប្រសើរជាងមុន។

### ការរៀបចំសហគមន៍កសិកម្ម និងសេវាផ្សព្វផ្សាយកសិកម្ម៖

គោលដៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជួយដល់សហគមន៍កសិកម្មបង្កើននិង ប្រមូលផ្ដុំការផលិត សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងទ្រង់ទ្រាយធំ ចែករំលែកចំណេះដឹង បទពិសោធន៍ក្នុង ផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាព និងសហការជិតស្និទ្ធជាមួយក្រុមពាណិជ្ជករ តាមរយៈការអនុវត្ត ផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីទទួលបាននូវភាពប្រកួតប្រជែងពេញលេញក្នុងបរិបទទីផ្សារសេរី។

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ ដល់ការបង្កើនវិនិយោគ ក្នុងការលើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម។ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មបាន ខិតខំបណ្ដុះបណ្ដាលដល់កសិករ និងសហគមន៍កសិកម្ម អំពីបច្ចេកទេសគ្រប់គ្រងដំណាំ ការកែលម្អដី ជាតិដី ការជ្រើសរើសមុខដំណាំសមស្រប ការគាំទ្រលើការងារគ្រប់គ្រងសហគមន៍ ការពង្រីកទីផ្សារ ការទទួលបានផ្នែកហិរញ្ញវត្ថុ និងការអភិវឌ្ឍកសិ-ពាណិជ្ជកម្ម។ ជាការកត់សម្គាល់ សេចក្ដីត្រូវការសេវាកម្ម ផ្សព្វផ្សាយរបស់កសិករមានការកើនឡើង ដែលទាមទារឱ្យមានការពង្រីកបន្ថែមទៀត នូវហេដ្ឋារចនាសម្ព័ន្ធ សេវាគាំទ្រដល់សហគមន៍មូលដ្ឋាន។ មកទល់បច្ចុប្បន្ននេះ នៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុប ចំនួន៥៥៦សហគមន៍ មានសមាជិកសរុបចំនួន៦៤.៦៦២នាក់ (ស្ត្រីចំនួន៣៩.៨៥០នាក់ ឬស្មើនឹង៦១,៦%) ហើយមានទុនសរុបចំនួន២៦.៩៧០លានរៀល។

គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ព្រមទាំងបានឆ្លុះបញ្ចាំងផងដែរ ពីកិច្ចពិគ្រោះយោបល់យ៉ាងទូលំទូលាយ ប្រកបដោយ ការយកចិត្តទុកដាក់ជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មាន ឆន្ទៈនិងការតាំងចិត្តយ៉ាងមុតមាំ ក្នុងការដឹកនាំការអនុវត្តគោលនយោបាយនេះ និងសូមអំពាវនាវ

ព្រមទាំងលើកទឹកចិត្តដល់អ្នកផ្តល់សេវាផ្សព្វផ្សាយកសិកម្មទាំងអស់ ទាំងនៅក្នុងវិស័យសាធារណៈ និងនៅក្នុងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ កសិករនិងសហគមន៍កសិករ រួមគ្នាគាំទ្រ និងចូលរួមអនុវត្ត គោលនយោបាយផ្សព្វផ្សាយកសិកម្មឲ្យទទួលបានលទ្ធផលជាផ្លែផ្កា និងមានប្រសិទ្ធភាពខ្ពស់ សំដៅរួមចំណែកលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្ម សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា និងរួមចំណែកសម្រេចគោលដៅនៃកំណែទម្រង់ ដើម្បីចីរភាពនៃការអភិវឌ្ឍ។

យោងអនុក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទឆ្នាំ២០០៧ ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ និងអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើឆ្នាំ២០០៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតសហគមន៍នេសាទចំនួន៥១៦ និងសហគមន៍ព្រៃឈើចំនួន៤៥៧ ហើយសហគមន៍ទាំងនេះត្រូវការសេវាកម្មគាំទ្រទាំងផ្នែកបច្ចេកទេស និងផ្នែកគ្រប់គ្រងសហគមន៍បន្ថែមទៀត។ ការចុះបញ្ជីនិងការគាំទ្រដល់សហគមន៍ គឺជាការងារចាំបាច់ ដែលទាមទារនូវជំនាញបច្ចេកទេសអភិវឌ្ឍន៍សហគមន៍ក៏ដូចជាការបង្កើនប្រាក់ចំណូល និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ ទន្ទឹមនឹងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានធ្វើការជំរុញការងារអភិវឌ្ឍសហគមន៍ផលិតកៅស៊ូផងដែរ។

### សមត្ថភាពអនាម័យនិងភូតគាមអនាម័យ និងការសម្រួលការនាំចេញៈ

ដើម្បីទាញយកអត្ថប្រយោជន៍ពីសក្តានុពលនៃការនាំចេញផលិតផលកសិកម្ម កម្ពុជាត្រូវមានប្រព័ន្ធត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យ ដែលមានការទទួលស្គាល់ជាអន្តរជាតិ និងមានយន្តការច្បាស់លាស់ដើម្បីសម្រួលបែបបទពាណិជ្ជកម្ម។ បើគ្មានយន្តការសម្របសម្រួលទាំងនេះទេ នោះវិនិយោគិននឹងមិនបង្កើនការដាក់ទុនវិនិយោគក្នុងផលិតកម្មកសិកម្ម ការកែច្នៃកសិផល ឡូជីស្ទីក និងកសិ-ពាណិជ្ជកម្មឡើយ។

ការសម្រួលដល់ការនាំចេញផ្លូវការ ត្រូវបានវាយតម្លៃថាមានការកែលម្អគួរជាទីពេញចិត្ត។ យន្តការច្រកចេញចូលតែមួយសម្រាប់ការនាំចេញអង្ករ ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព កាត់បន្ថយពេលវេលាក្នុងការពិនិត្យពាក្យស្នើសុំនាំចេញ ពិសេសការចេញវិញ្ញាបនប័ត្របញ្ជាក់អនាម័យនិងភូតគាមអនាម័យ ការធ្វើធូបទកម្ម ការធ្វើចំណាត់ថ្នាក់ផលិតផល ការបញ្ជាក់ពីគុណភាព បរិមាណ ទម្ងន់ និងការធ្វើប្រតិវេទន៍គយ។

ទោះជាយ៉ាងនេះក្តី លិខិតបទដ្ឋានគតិយុត្តផ្នែកអនាម័យនិងភូតគាមអនាម័យ តម្រូវឱ្យមានការធ្វើបច្ចុប្បន្នភាព ឱ្យស្របតាមគោលការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក។ ឆ្លើយតបនឹងការតម្រូវនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការការពារដំណាំ និងភូតគាមអនាម័យ និងនីតិវិធីមួយចំនួនដែលពាក់ព័ន្ធដល់ការត្រួតពិនិត្យភូតគាមអនាម័យ។ បន្ថែមលើនេះ សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វកំពុងត្រូវបានរៀបចំ។ ការគ្រប់គ្រងផ្នែកចត្តាឡីស័កត្រូវបានយកចិត្តទុកដាក់កែលម្អ។ ទីផ្សារសហភាពអឺរ៉ុបទាមទារនូវបទដ្ឋាន

អនាម័យ និងភូតគាមអនាម័យខ្ពស់ សម្រាប់ផលិតផលកសិកម្ម និងមិនមានប្រើប្រាស់សារធាតុសំពាង្គកាយកែច្នៃពន្ធុ។ ដោយសហភាពអឺរ៉ុបបានផ្ដល់ភាពអនុគ្រោះពន្ធ លើការនាំចេញគ្រប់ផលិតផលលើកលែងតែអាវុធ កម្ពុជាត្រូវបង្ហាញសមត្ថភាពក្នុងការអនុវត្តតាមគោលការណ៍ទាំងនេះ។

## ១. ការធ្វើឱ្យប្រសើរឡើងផលិតភាព និងពិពិធកម្មកសិកម្ម

ក្នុងរយៈពេល៥ឆ្នាំកន្លងមក ផ្ទៃដីដាំដុះសម្រាប់ពង្រីកផលិតកម្មដំណាំ ពិសេសកៅស៊ូនិងដំណាំកសិ-ឧស្សាហកម្ម ត្រូវបានពង្រីកលើផ្ទៃដីដែលកន្លងមកមិនបានប្រើប្រាស់ និងផ្ទៃដីព្រៃរេចរិល។ ជាទិសដៅក្នុងការអភិវឌ្ឍបន្ត ការធ្វើប្រពលវប្បកម្មសំដៅបង្កើនទិន្នផលដំណាំ គឺជាអភិក្រមសមស្របសម្រាប់អភិវឌ្ឍន៍វិស័យនេះ។

ជាការកត់សម្គាល់ ផ្ទៃដីដាំដុះមានការកើនឡើង បន្ទាប់ពីមានការវិនិយោគលើផ្នែកធារាសាស្ត្រ ពោលគឺបង្កើននូវលទ្ធភាពស្រោចស្រព ដែលអាចធ្វើឱ្យការដាំដុះកើនរហូតពី២ទៅ៣ដងក្នុងមួយឆ្នាំ។ ការស្ដារឡើងវិញ និងការកសាងថ្មីនៃប្រព័ន្ធធារាសាស្ត្រ បានធ្វើឱ្យផ្ទៃដីស្រោចស្រពកើនបានចំនួន៣៨៧,៩ពាន់ហិកតានៅចន្លោះឆ្នាំ២០០៩-២០១៣ ក្នុងនោះផ្ទៃដីស្រោចស្រពស្រូវរដូវវស្សាមានចំនួន២៩៦ពាន់ហិកតា និងផ្ទៃដីស្រោចស្រពស្រូវរដូវប្រាំងមានចំនួន៩១,៩ពាន់ហិកតា។ ផលិតកម្មដំណាំដែលប្រើប្រាស់ប្រព័ន្ធស្រោចស្រពនៅរដូវប្រាំងទទួលបានទិន្នផលខ្ពស់ និងការផលិតភាគច្រើនតម្រង់ទិសទៅរកការធ្វើពាណិជ្ជកម្ម។ គិតមកទល់ឆ្នាំ២០១៣ ផ្ទៃដីស្រោចស្រពមានចំនួន១,៤៨លានហិកតា ស្មើនឹង៣០%នៃផ្ទៃដីដាំដុះទូទាំងប្រទេស ក្នុងនោះផ្ទៃដីស្រោចស្រពរដូវវស្សាមានចំនួន១,០៥លានហិកតា និងរដូវប្រាំងមានចំនួន០,៤៣លានហិកតា។

កំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាល បានផ្ដោតជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រងបែងចែកនិងប្រើប្រាស់ដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិដី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការដាក់ចេញនូវវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនបានប្រើប្រាស់និងមិនផលិត។ ការងារកែទម្រង់ដីធ្លីក៏មានសារសំខាន់ផងដែរ ក្នុងការពង្រីកនិងការបែងចែកដីធ្លីកសិកម្ម ក្នុងក្របខណ្ឌដីសម្បទានសង្គមកិច្ច សំដៅលើកកម្ពស់បង្កើនផលិតភាពនិងពិពិធភាវូបនីយកម្ម និងការកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ របស់ប្រជាកសិករ។ ការចុះបញ្ជីដីធ្លីត្រូវបានវាយតម្លៃថា មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសការអនុវត្តគោលនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី (ប័ណ្ណកម្មសិទ្ធិចំនួន៣៨០ពាន់ប័ណ្ណត្រូវបានផ្ដល់និងបានចុះបញ្ជី)។ ទោះជាយ៉ាងនេះក្ដី កិច្ចការនេះទាមទារឱ្យមានការជំរុញ និងពង្រីកបន្ថែមទៀតសំដៅជួយដល់កសិករ ដើម្បីទទួលបានកម្មសិទ្ធិដីធ្លីត្រឹមត្រូវនិងស្របច្បាប់។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម និងកំពុងស្វែងរកធនធានសម្រាប់ការរៀបចំកំណត់តំបន់ដាំដុះ និងផែនទីប្រើប្រាស់ដីកសិកម្ម។

ការចូលរួមរបស់ផ្នែកឯកជនក្នុងវិស័យកសិកម្ម គឺជាចលករសំខាន់សម្រាប់ការអភិវឌ្ឍផ្នែកកសិ-ឧស្សាហកម្ម ដែលទាមទារឱ្យមានការដាក់ទុនវិនិយោគច្រើនថែមទៀត។ ដីសម្បទានសេដ្ឋកិច្ចត្រូវបានផ្ដល់ជូនក្រុមហ៊ុនឯកជន ដើម្បីដាំដុះដំណាំកសិ-ឧស្សាហកម្ម ពិសេសកៅស៊ូ ដូងប្រេង ស្វាយចន្ទី អំពៅ និងឈើដាំគ្រប់ប្រភេទ។ គិតត្រឹមឆ្នាំ២០១៤នេះ កិច្ចសន្យាវិនិយោគចំនួន១២១

កំពុងនៅមានសុពលភាពអនុវត្តក្នុងខេត្តចំនួន១៨ លើផ្ទៃដីសរុបតាមកិច្ចសន្យាចំនួនជាង១,៣លានហិកតា (ផ្ទៃដីដែលអាចធ្វើអាជីវកម្មបានមានចំនួន០,៨១លានហិកតា) និងផ្ទៃដីដាំដុះជាក់ស្តែងមានចំនួន០,២៨លានហិកតា។ ក្រុមហ៊ុនបានសាងសង់ផ្លូវដឹកជញ្ជូនក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចបានប្រវែងជាង១០ពាន់គីឡូម៉ែត្រ និងប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន៥៣.៦៧០នាក់។ ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាចំនួន៦,២២លានដុល្លារអាមេរិក ត្រូវបានតម្កល់នៅធនាគារជាតិនៃកម្ពុជា។

ក្នុងដំណើរការនៃការអនុវត្តកិច្ចសន្យាវិនិយោគ ក្រុមហ៊ុនដែលមិនបានអនុវត្តសកម្មភាពដាំដុះតាមផែនការមេ និងមិនអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា ត្រូវប្រឈមនឹងការដកហូតដីសម្បទានសេដ្ឋកិច្ចមកវិញ។ ដើម្បីពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាបានចេញបទបញ្ជាលេខ០១បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ ដោយបានបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ចថ្មីទៀត លើកលែងតែក្រុមហ៊ុនបានទទួលគោលការណ៍វិនិយោគមុនការចេញបទបញ្ជានេះ។ នៅខែសីហា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យវាស់វែងនិងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច។ នីតិវិធីនិងគោលការណ៍ស្បែកខ្លាត្រូវបានអនុវត្ត សំដៅបញ្ចៀសនូវផលប៉ះពាល់អវិជ្ជមានដល់សហគមន៍មូលដ្ឋាន និងតំបន់ព្រៃរក្សាទុក។ មកទល់ពេលនេះ ក្រុមហ៊ុនចំនួន៦៩ត្រូវបានលុបគោលការណ៍ និងកិច្ចសន្យាលើផ្ទៃដី០,៥៨លានហិកតា។

### ១.១ ផលិតកម្មដំណាំស្រូវ

ផ្ទៃដីផលិតកម្មដំណាំស្រូវអនុវត្តបានចំនួន២,៧២លានហិកតានាឆ្នាំ២០០៩ និងបានកើនដល់៣,០៥លានហិកតានាឆ្នាំ២០១៣ (កើនលើសឆ្នាំ២០០៩ ប្រមាណ១២,២៦%)។ ផ្ទៃដីអាចប្រមូលផលបានកើនពី២,៦៧លានហិកតានាឆ្នាំ២០០៩ ដល់ជិត២,៩៧លានហិកតានាឆ្នាំ២០១៣ និងទិន្នផលជាមធ្យមប្រចាំឆ្នាំទទួលបាន៣,១៦៣តោន/ហិកតា កើនលើសឆ្នាំ២០០៩ប្រមាណ១១,៥២% (ទិន្នផលស្រូវឆ្នាំ២០០៩ ទទួលបានត្រឹមតែ២,៨៣៦តោន/ហិកតា)។ ផលិតកម្មដំណាំស្រូវតែងតែទទួលរងដោយគ្រោះធម្មជាតិ ពិសេសគ្រោះទឹកជំនន់ទន្លេមេគង្គ ជំនន់ទឹកភ្លៀង រាំងស្ងួត និងសត្វល្អិតបំផ្លាញជាដើម។

តែទោះជាយ៉ាងណាក្តី នាឆ្នាំ២០១៣កន្លងទៅនេះ កម្ពុជាអាចទទួលបានបរិមាណផលស្រូវប្រមាណជាង៩,៣៨លានតោន កើនលើសឆ្នាំ២០០៩ ប្រមាណជាង២៣,៧៨% (ឆ្នាំ២០០៩ សម្រេចបានត្រឹមតែ៧,៥៨លានតោន) និងអាចសល់ស្បៀងជាអង្ករសរុបចំនួនជាង៣,០៩លានតោន ឬគិតជាស្រូវនៅសល់ប្រមាណជាង៤,៨២លានតោន (កើនលើសឆ្នាំ២០០៩ប្រមាណជាង៣៧,៦៨% ដែលស្រូវនៅសល់មានតែប្រមាណជាង៣,៥លានតោន)។ ជាការកត់សម្គាល់ និន្នាការកើនឡើងនៃផលិតកម្ម និងតម្លៃស្រូវក្នុងរយៈពេលកន្លងមកនេះ បានធ្វើឱ្យកសិករទទួលបានប្រាក់ចំណូលច្រើនជាងមុន និងរួមចំណែកកាត់បន្ថយភាពក្រីក្រផងដែរ។

### តារាងទី១៖ ប្រៀបធៀបកំណើនផលិតកម្មដំណាំស្រូវឆ្នាំ២០០៩-២០១៣

| បរិយាយ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ប្រៀបធៀប កំណើន ២០១៣/២០០៩ |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហត) | 2,719,080 | 2,795,892 | 2,968,529 | 3,007,545 | 3,052,420 | 12.26% |
| ផ្ទៃដីប្រមូលផល (ហត) | 2,674,603 | 2,777,323 | 2,766,617 | 2,980,297 | 2,968,967 | 11.01% |
| ទិន្នផល (តោន/ហត) | 2.836 | 2.97 | 3.173 | 3.117 | 3.163 | 11.52% |
| បរិមាណផល (តោន) | 7,585,870 | 8,249,452 | 8,779,365 | 9,290,940 | 9,389,961 | 23.78% |
| អតិរេកអង្ករ (លានតោន) | 2,244,598 | 2,516,752 | 2,780,328 | 3,031,017 | 3,090,452 | 37.68% |
| គិតជាស្រូវសល់ (លានតោន) | 3,507,185 | 3,932,425 | 4,344,263 | 4,735,964 | 4,828,832 | 37.68% |

ផ្អែកលើសមិទ្ធផលខាងលើបានបញ្ជាក់ច្បាស់ថា ផលិតកម្មដំណាំស្រូវមាននិន្នាការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ទាំងផ្ទៃដីដាំដុះ ទិន្នផល និងបរិមាណផល។ បើប្រៀបធៀបលទ្ធផលសម្រេចបានជាមួយនឹងសូចនាករកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានបង្ហាញថា ផ្ទៃដីដាំដុះសម្រេចបានលើសផែនការកំណត់តាមឆ្នាំនីមួយៗ។ ជាក់ស្តែងនាឆ្នាំ២០០៩ ផ្ទៃដីដាំដុះដំណាំស្រូវសម្រេចបាន១០៣%នៃផែនការ និងប្រមាណ១១៥%នៅឆ្នាំ២០១៣។ ទិន្នផលស្រូវមាននិន្នាការកើនឡើង និងសម្រេចបានលើសផែនការកំណត់ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ឆ្នាំ២០០៩សម្រេចបាន១០២%នៃផែនការ និងនៅឆ្នាំ២០១៣ សម្រេចបានលើសផែនការប្រមាណ១០៥%)។ ចំពោះបរិមាណផលក៏មាននិន្នាការកើនឡើងដូចគ្នា ពោលគឺសម្រេចបាន១០៤% លើសផែនការឆ្នាំ២០០៩ និង១១៨%លើសផែនការឆ្នាំ២០១៣។

### តារាងទី២៖ ប្រៀបធៀបលទ្ធផលសម្រេចបាននិងផែនការជាតិផ្នែកដំណាំស្រូវឆ្នាំ២០០៩-២០១៣

| បរិយាយ | ២០០៩ | | | ២០១០ | | | ២០១១ | | | ២០១២ | | | ២០១៣ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផែន | ព ស | % | ផែន | ព ស | % | ផែ | ព ស | % | ផែន | ព ស | % | ផែន | ព ស | % |
| ផ្ទៃដីដាំដុះស្រូវ (ពាន់ហត) | 2,630 | 2,719 | 103 | 2,650 | 2,796 | 106 | 2,650 | 2,968 | 112 | 2,650 | 3,007 | 113 | 2,650 | 3,052 | 115 |
| ទិន្នផល (តោន/ហត) | 2.77 | 2.836 | 102 | 2.80 | 2.97 | 106 | 2.83 | 3.173 | 112 | 2.87 | 3.117 | 109 | 3.00 | 3.163 | 105 |
| បរិមាណផល (ពាន់តោន) | 7,280 | 7,586 | 104 | 7,420 | 8,249 | 111 | 7,500 | 8,779 | 117 | 7,600 | 9,291 | 122 | 7,950 | 9,390 | 118 |

ឯកសារគោលនយោបាយស្តីពី **"ការជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ"** ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ កន្លងទៅនេះ ហើយគ្រប់ភាគីដែលពាក់ព័ន្ធក្នុងកិច្ចការនេះ ត្រូវរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាព ដើម្បី

សម្រេចបាននូវទិសដៅធ្វើយ៉ាងណាឱ្យកម្ពុជាមានអតិរេកស្រូវប្រមាណជាង៤លានតោន និងមានលទ្ធភាពនាំចេញអង្ករជាផ្លូវការជាង១លានតោននៅឆ្នាំ២០១៥។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំនូវផែនការសកម្មភាពលម្អិតរបស់ខ្លួនសំដៅឆ្លើយតបនិងសម្រេចបាននូវចំណុចទិសដៅគោលនយោបាយដែលបានកំណត់នេះ។ ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ បានកំណត់ច្បាស់នូវចំណុចវិធានការគោលនយោបាយសំខាន់ៗ ទៅតាមដំណាក់កាលនីមួយៗគឺៈ (ទី១) វិធានការគោលនយោបាយដែលពាក់ព័ន្ធនឹងផលិតកម្ម (ទី២) ពាក់ព័ន្ធនឹងការប្រមូលទិញនិងការកែច្នៃ (ទី៣) ពាក់ព័ន្ធនឹងប្រព័ន្ធសម្រួលការនាំចេញ និង (ទី៤) គឺវិធានការគោលនយោបាយដែលពាក់ព័ន្ធនឹងការស្វែងរកទីផ្សារ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តនូវបណ្តាសកម្មភាពធំៗមួយចំនួន ដូចជាៈ

**(ទី-១) វិធានការពាក់ព័ន្ធនឹងផលិតកម្មស្រូវៈ**

ការពង្រីកផ្ទៃដីដាំដុះថ្មី មានការកើនឡើងក្នុងកម្រិតមួយតិចតួច។ ការបង្កើនផលិតកម្ម ត្រូវបានផ្តោតការយកចិត្តទុកដាក់លើការបង្កើនទិន្នផល តាមវិធានការប្រពលវប្បកម្ម។ ការផ្សព្វផ្សាយពូជទាំង១០ត្រូវបានជំរុញឱ្យអនុវត្ត និងផលិតយ៉ាងខ្លាំងក្លា ពិសេសពូជដែលទីផ្សារត្រូវការ និងបន្ស៊ាំការប្រែប្រួលអាកាសធាតុ។ ការសម្រួលនីតិវិធីនៃការនាំចូលពូជស្រូវ ជី ធាតុចូលកសិកម្មផ្សេងៗទៀត ជាមួយនឹងច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្មត្រូវបានអនុវត្ត។ ក្រសួងបានពង្រឹងនិងពង្រីកសមត្ថភាពវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ស្ថានីយពិសោធន៍ មណ្ឌលអភិវឌ្ឍន៍កសិកម្ម ក៏ដូចជាការពិនិត្យឡើងវិញនូវក្របខណ្ឌនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការរៀបចំគម្រោងផែនការដើម្បីពង្រឹងរចនាសម្ព័ន្ធ និងតួនាទីរបស់អង្គការកសិករ ពិសេសការលើកកម្ពស់សមត្ថភាពរបស់កសិករ និងសហគមន៍កសិកម្ម ក្នុងការខ្ចីនិងការប្រើប្រាស់ឥណទានពីស្ថាប័នហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព។ ការរៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើប្រាស់ដីកំពុងត្រូវបានគិតគូរ និងស្វះស្វែងរកធនធានដើម្បីអនុវត្ត។ ច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម កំពុងដំណើរការរៀបចំកសាងយ៉ាងសកម្ម។

**(ទី-២) វិធានការពាក់ព័ន្ធនឹងការប្រមូលទិញនិងការកែច្នៃស្រូវៈ**

យន្តការដើម្បីផ្សារភ្ជាប់ទំនាក់ទំនងផលិតកម្មនិងពាណិជ្ជកម្ម រវាងកសិករជាមួយអ្នកកែច្នៃ ឬអ្នកប្រមូលទិញមិនទាន់មានដំណើរការពេញលេញនៅឡើយ។ ជាគោលដៅរួមរបស់ក្រសួងគឺត្រូវធ្វើយ៉ាងណាឱ្យផលិតកម្ម និងការផ្គត់ផ្គង់មានលក្ខណៈប្រមូលផ្តុំ ជាមួយនឹងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងសហគមន៍កសិកម្មនិងអ្នកកែច្នៃឬអ្នកប្រមូលទិញ។ ច្បាប់ស្តីពីសហគមន៍កសិកម្ម និងអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ត្រូវបានអនុម័តនិងកំពុងអនុវត្ត។ ជាមួយគ្នានេះ ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់សហគមន៍កសិកម្មត្រូវបានពង្រឹង។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ការអនុវត្តច្បាប់និងអនុក្រឹត្យនេះ ទាមទារឱ្យមានការពង្រឹងបន្ថែមទៀត ទាំងសមត្ថភាពបច្ចេកទេស និងធនធានថវិកា។ លើសពីនេះទៀត កង្វះធនធានសម្រាប់ការប្រមូលទិញ និងស្តុកទុកស្រូវរបស់ផ្នែកឯកជនគឺជាបញ្ហាប្រឈមដែលត្រូវដោះស្រាយ។

### (ទី-៣) វិធានការពាក់ព័ន្ធនឹងប្រព័ន្ធសម្រួលការនាំចេញអង្ករៈ

ការនាំចេញអង្ករផ្លូវការបានកើនឡើងពី១២,៦១ពាន់តោននៅឆ្នាំ២០០៩ ដល់៣៧៨,៨៥ពាន់តោន នៅឆ្នាំ២០១៣។ នៅឆ្នាំ២០១៤ ការនាំចេញអង្ករសម្រេចបាន៣៨៧ពាន់តោន (កើន២,២% ធៀបនឹងឆ្នាំ ២០១៣)។ ការសម្រេចឱ្យបាននូវការនាំចេញអង្ករជាផ្លូវការ ចំនួន១លានតោននៅឆ្នាំ២០១៥ អាចនឹង សម្រេចបាន ប្រសិនបើសមត្ថភាពកែច្នៃ លទ្ធភាពប្រមូលទិញស្រូវស្តុកទុក និងប្រព័ន្ធឡជីស្ទីកត្រូវ បានបង្កើននិងកែលម្អ។ ការបង្កើនការនាំចេញ ទាមទារឱ្យមានការវិនិយោគកាន់តែច្រើនឡើងលើ សមត្ថភាពកែច្នៃស្របតាមស្តង់ដារគុណភាពអន្តរជាតិ និងការធ្វើឱ្យប្រសើរឡើងផ្នែកអនាម័យ និង ភូតគាមអនាម័យ។ យន្តការច្រកចេញចូលតែមួយសម្រាប់ការនាំចេញអង្ករ ត្រូវបានដំណើរការយ៉ាង សកម្ម និងមានប្រសិទ្ធភាព ពិសេសកាត់បន្ថយពេលវេលាពិនិត្យឯកសារស្នើសុំនាំចេញ ក៏ដូចជាការ ចេញវិញ្ញាបនប័ត្របញ្ជាក់អនាម័យនិងភូតគាមអនាម័យ ធូបទកម្ម បរិមាណនិងគុណភាព និងបែបបទ ប្រតិវេទន៍គយ។ អង្ករផ្ការំដួលត្រូវបានចាត់ទុកជាអង្ករមានរសជាតិឆ្ងាញ់ជាងគេបំផុតលើពិភពលោក រយៈពេលបីឆ្នាំជាប់ៗគ្នា ពីឆ្នាំ២០១២រហូតដល់ឆ្នាំ២០១៤។ សហព័ន្ធអ្នកនាំចេញអង្ករត្រូវបានបង្កើត ឡើងនៅខែកក្កដា ឆ្នាំ២០១២។ សហព័ន្ធនេះគឺជាដៃគូសហការយ៉ាងជិតស្និទ្ធ ជាមួយរាជរដ្ឋាភិបាល ក្នុង ការជំរុញការនាំចេញអង្ករ និងធ្វើការងារជាមួយក្រុមការងារផ្នែកស្រូវអង្ករ នៃវេទិការាជរដ្ឋាភិបាល-ផ្នែក ឯកជន។

### (ទី-៤) វិធានការស្វែងរកទីផ្សារៈ

ក្រសួងបានផ្សព្វផ្សាយព័ត៌មានតម្លៃស្រូវ-អង្ករក្នុងស្រុកនិងទីផ្សារអន្តរជាតិ តាមវិទ្យុ ទូរស្សន៍ សារជាអក្សរ ព្រឹត្តិបត្រ គេហទំព័រព័ត៌មានទីផ្សារកសិកម្ម ធ្វើអង្កេតអំពីលំហូរពាណិជ្ជកម្ម និងចរាចរ ស្រូវ-អង្ករ និងវិភាគអំពីស្ថានការទីផ្សារតំបន់និងអន្តរជាតិ។ ពិពណ៌អង្ករជាលក្ខណៈអន្តរជាតិត្រូវបាន រៀបចំជាបន្តបន្ទាប់ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ការចែករំលែកព័ត៌មាន ទីផ្សារក្នុងសហគមន៍កសិកម្មត្រូវបានជំរុញ សំដៅបង្កើនអំណាចតថ្លៃជាមួយអ្នកប្រមូលទិញ។

## ១.២ ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម

ផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្ម ដូចជា ពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង មានការប្រែប្រួលចុះឡើងទៅតាមប្រភេទដំណាំនីមួយៗ ហើយក៏អាស្រ័យទៅតាមឥទ្ធិពលនៃកត្តាថ្លៃនិង ទីផ្សារ។ ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងឧស្សាហកម្មទូទាំងប្រទេសសម្រាប់ឆ្នាំ២០១៣ សម្រេចបានប្រមាណ ជាង៩៤១ពាន់ហិកតា កើនលើសឆ្នាំ២០០៩ ប្រមាណ៤០%។ ការកើនឡើងភាគច្រើនគឺទៅលើដំណាំ ដំឡូងមីនិងពោត។

### តារាងទី៣៖ សូចនាករសម្រេចបាននៃផលិតកម្មដំណាំរួមផ្សំនិងឧស្សាហកម្មឆ្នាំ២០០៩-២០១៣

| ដំណាំរួមផ្សំនិងឧស្សាហកម្ម | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | (%) ២០១៣/២០០៩ |
|---|---|---|---|---|---|---|
| ពោត | 221,287 | 213,622 | 174,257 | 216,330 | 239,748 | 8 |
| ដំឡូងឈើ | 160,326 | 206,226 | 391,714 | 361,854 | 421,375 | 163 |
| ដំឡូងជ្វា | 9,283 | 11,452 | 8,204 | 10,428 | 7,432 | -20 |
| បន្លែ | 50,278 | 52,732 | 52,830 | 76,495 | 52,449 | 4 |
| សណ្តែកបាយ | 49,599 | 69,206 | 68,111 | 66,850 | 54,312 | 10 |
| សណ្តែកដី | 16,474 | 20,041 | 16,287 | 18,048 | 19,954 | 21 |
| សណ្តែកសៀង | 96,388 | 103,198 | 70,584 | 71,337 | 80,688 | -16 |
| ល្ង | 43,206 | 48,299 | 42,599 | 36,722 | 34,136 | -21 |
| អំពៅ | 13,533 | 17,207 | 22,614 | 48,586 | 23,810 | 76 |
| ក្រចៅ | 347 | 594 | 342 | 286 | 243 | -30 |
| ថ្នាំជក់ | 9,269 | 10,062 | 8,318 | 5,947 | 6,881 | -26 |
| សរុបរួម (ហ.ត) | 669,990 | 752,639 | 855,860 | 912,883 | 941,028 | 40 |
| សរុបបរិមាណផល (តោន) | 5,425,310 | 5,728,175 | 6,138,532 | 10,859,806 | 10,536,742 | 94 |

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ (២០០៩-២០១៣) ដំណាំឈើហូបផ្លែ ដូចជា ចេក ដូង មៀន ស្វាយ ទឹកដោះ ល្មុត ធូរេន ខ្នុរ ទៀប ក្រូច សាវម៉ាវ ត្របែក ម្នាស់ និងដំណាំអចិន្ត្រៃយ៍ (ស្វាយចន្ទី ដូងប្រេង ម្រេច ... ។ល។) មាននិន្នាការរីកចម្រើនលូតលាស់គួរឱ្យកត់សម្គាល់ដែរ។ ជាក់ស្តែង ផ្ទៃដីដាំដុះឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍សម្រេចបានសរុបចំនួន១៨៣ពាន់ហិកតាក្នុងឆ្នាំ២០១៣ កើនលើសឆ្នាំ២០០៩ប្រមាណ៥% (ឆ្នាំ២០០៩ សម្រេចបានចំនួន១៧៤ពាន់ហិកតា)។

## ២. ផលិតកម្មដំណាំកៅស៊ូ

## ២.១ ការវិវឌ្ឍផលិតកម្មកៅស៊ូ

ដំណាំកៅស៊ូជាប្រភេទដំណាំកសិ-ឧស្សាហកម្មរយៈពេលវែង ដែលមានតួនាទីយ៉ាងសំខាន់និងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ សង្គម និងបានចូលរួមចំណែកយ៉ាងសកម្ម នៅក្នុងការការពារបរិស្ថានធម្មជាតិប្រកបដោយចីរភាព ដោយបង្កើតជាគម្របបៃតង រក្សាលំនឹងធម្មជាតិ និងការពារការហូរច្រោះដី។

នៅឆ្នាំ២០១៣ ផ្ទៃដីដំណាំកៅស៊ូសរុបមានចំនួន៣២៨.៧៧១ហិកតា ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) មានចំនួន៥៥.៩០៨ហិកតា ផ្ទៃដីចម្ការកៅស៊ូសម្បទានសេដ្ឋកិច្ចមានចំនួន១៣៥.៤៤៦ហិកតា និងផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន១៣៧.៤១៧ហិកតា។

**ក្រាហ្វិកទី១៖ បង្ហាញវឌ្ឍនភាពនៃការអភិវឌ្ឍដំណាំកៅស៊ូឆ្នាំ២០០៩-២០១៣**




សន្ទុះនៃការអភិវឌ្ឍកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយកត្តាថ្លៃ និងការគួបផ្សំស្ថានភាពនយោបាយសន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយសេរីភាវូបនីយកម្ម លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក ជាពិសេសមានការចូលរួមពីផ្នែកឯកជនដែលបានធ្វើវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងផ្នែកកៅស៊ូគ្រួសារ ដោយបានធ្វើឱ្យផ្ទៃដីដំណាំកៅស៊ូកើនឡើងគួរជាទីមោទនៈ។

ផ្ទៃដីដំណាំកៅស៊ូមាននិន្នាការកើនពី១៣០ពាន់ហិកតានាឆ្នាំ២០០៩ រហូតដល់៣២៨,៧៧ពាន់ហិកតានាឆ្នាំ២០១៣ គឺបានកើនឡើងប្រមាណ១៥៣% ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ។ កៅស៊ូគ្រួសារមានសន្ទុះកើនឡើងខ្លាំងគួរឱ្យកត់សម្គាល់ គឺបានកើនពី៦៣ពាន់ហិកតានាឆ្នាំ២០០៩ ដល់ជាង១៣៧ពាន់ហិកតានាឆ្នាំ២០១៣ (កើនប្រមាណ១១៧%ក្នុងរយៈពេល៥ឆ្នាំ)។ ផ្ទៃដីកៅស៊ូរបស់ក្រុមហ៊ុនវិនិយោគឯកជនលើដីសម្បទានសេដ្ឋកិច្ច បានកើនពីជាង២៣ពាន់ហិកតានាឆ្នាំ២០០៩ ដល់ជាង១៣៥ពាន់ហិកតានាឆ្នាំ២០១៣ ដែលសន្ទុះនៃការកើនមានកម្រិតគួរឱ្យកត់សម្គាល់ក្នុងរយៈពេល៥ឆ្នាំនេះ។ ចំពោះផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) ការកើនឡើងផ្ទៃដីដាំដុះថ្មីមិនមានការប្រែប្រួលខ្លាំងគួរឱ្យកត់សម្គាល់ទេ គឺធ្វើការដាំដុះតែលើផ្ទៃដីកៅស៊ូចាស់ កាប់ និងដាំឡើងវិញតែប៉ុណ្ណោះ ពោលគឺមានការកើនឡើងប្រមាណជាង២៨% បើប្រៀបធៀបឆ្នាំ២០០៩ (ឆ្នាំ២០០៩ មានចំនួន៤៣,៧ពាន់ហិកតា និងកើនដល់ជាង៥៥,៩ពាន់ហិកតាឆ្នាំ២០១៣)។

ជារួមលទ្ធផលសម្រេចបានផ្នែកផលិតកម្មដំណាំកៅស៊ូ ធៀបនឹងសូចនាករកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានបញ្ជាក់ថា ការអនុវត្តដំណាំកៅស៊ូសម្រេចបានគ្រប់ផែនការឆ្នាំ២០០៩ គឺសម្រេចបាន១២៨ពាន់ហិកតា (អនុវត្តបាន១០០%នៃផែនការ) ឆ្នាំ២០១០សម្រេចបាន២៧%លើសផែនការ ឆ្នាំ២០១១សម្រេចបានលើស៣៥% ឆ្នាំ២០១២សម្រេចបានលើស៦២% និងឆ្នាំ២០១៣សម្រេចបានលើស៧៥%។

**តារាងទី៤៖ ប្រៀបធៀបលទ្ធផលសម្រេចបាននិងផែនការជាតិផ្នែកផលិតកម្មកៅស៊ូឆ្នាំ២០០៩-២០១៣**

| បរិយាយ | ២០០៩ | | | ២០១០ | | | ២០១១ | | | ២០១២ | | | ២០១៣ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផែន | ព ស់ | % | ផែ | ទ ពឹ ស | % | ការ ផែន | ទ ពឹ | % | ផែន | ទ ពឹ ស | % | ផែន | ទ ពឹ ស | % |
| ផ្ទៃដីកៅស៊ូសរុប (ពាន់ហាត) | 128.4 | 129.9 | 101 | 143.4 | 181.4 | 127 | 158.4 | 213.1 | 135 | 173.4 | 280.4 | 162 | 188.4 | 328.8 | 175 |
| ផ្ទៃដីចៀរជ័រ (ពាន់ហាត) | 38.5 | 34.1 | 89 | 49.5 | 38.4 | 78 | 63 | 45.1 | 72 | 78 | 55.4 | 71 | 97.5 | 78.5 | 81 |

## ២.២. សមិទ្ធផលកៅស៊ូ

- ផ្ទៃដីចៀរជ័រកៅស៊ូនៅឆ្នាំ២០១៣ សម្រេចបានចំនួន៧៨.៩៩៣ហិកតា ក្នុងនោះ ផ្ទៃដីចៀរជ័រកៅស៊ូគ្រួសារចំនួន៥២.៥១៦ ហិកតា
- ផលិតផលកៅស៊ូនៅឆ្នាំ២០១៣ សម្រេចបានចំនួន៨៥.២៨៨តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន៥៩.៩៨៩តោន
- ផលិតផលកៅស៊ូបានកើនឡើងប្រហែល១២៨% បើប្រៀបធៀបរយៈពេល៥ឆ្នាំ (កើនពី៣៧.៣៨០តោន នាឆ្នាំ២០០៩ ដល់៨៥.២៨៨តោន នាឆ្នាំ២០១៣)
- ការនាំចេញកៅស៊ូនៅឆ្នាំ២០១៣ សម្រេចបានចំនួន៨៦.០៥២តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន៥៩.៩៨៩តោន។ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ការនាំចេញកៅស៊ូមានសន្ទុះរីកចម្រើនគួរជាទីមោទនៈ ពោលគឺបានកើនប្រមាណជាង១៣៥%។

## ៣. ផលិតកម្មសត្វ និង បសុព្យាបាល

ជារួមផលិតកម្មសត្វជាលក្ខណៈគ្រួសារ និងជាលក្ខណៈពាណិជ្ជកម្មនៅកម្ពុជា ជាពិសេសគោក្របី ជ្រូក និងបក្សីមានការវិវឌ្ឍគួរឲ្យកត់សម្គាល់ទាំងចំនួនសត្វ ទាំងបែបផែនផលិតកម្ម ដែលផលិតកម្មនេះអាចធានាការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុកនាពេលកន្លងមក ហើយមានសត្វនិងផលិតផលមានដើមកំណើតពីសត្វមួយចំនួន ត្រូវបាននាំចេញទៅបរទេស។

ពិនិត្យជារួមផលិតកម្មសត្វគោក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៣នេះ មានការប្រែប្រួលថយចុះប្រមាណ៩,២% ដោយបានថយចុះពី៣,៦លានក្បាលនាឆ្នាំ២០០៩ មកត្រឹម៣,៩លានក្បាលនាឆ្នាំ២០១៣។ រីឯក្របីក៏មានការប្រែប្រួលថយចុះប្រមាណ១៦,៩% គឺថយចុះពីចំនួន៧៩០ពាន់ក្បាលនាឆ្នាំ២០០៩ មកត្រឹម៦១៩ពាន់ក្បាលនាឆ្នាំ២០១៣។ ការថយចុះចំពោះផលិតកម្មចិញ្ចឹមសត្វគោក្របីនេះ គឺជាការថយចុះគោ ក្របីអូសទាញ មូលហេតុបណ្តាលមកពីកសិករកាន់តែច្រើនឡើងៗ បោះបង់ការភ្ជួររាស់ដោយគោ ក្របី មកប្រើប្រាស់សេវាគ្រឿងយន្ត (៧០% នៃផ្ទៃដីដាំដុះដំណាំស្រូវត្រូវបានអនុវត្តដោយគ្រឿងយន្ត) កង្វះកម្លាំងពលកម្មនៅជនបទ (ចំណាកស្រុក) មានការលំបាកក្នុងការស្វែងរក

តំបន់មានទឹក និងចំណីគ្រប់គ្រាន់ សម្រាប់ការចិញ្ចឹមសត្វគោ ក្របី។ ទន្ទឹមនឹងការថយចុះគោអូសទាញនេះ កសិករបានងាកមកចិញ្ចឹមគោមេនិងគោយកសាច់ និងជាមួយគ្នានោះ ក៏មានការចាប់ផ្តើមការវិនិយោគឯកជនចិញ្ចឹមគោសាច់វិញផងដែរ។

ការចិញ្ចឹមជ្រូកមានការប្រែប្រួលកើនឡើងក្នុងអំឡុងពេល៥ឆ្នាំកន្លងទៅនេះ ពោលគឺផលិតកម្មជ្រូកបានកើនប្រមាណ១៥% ដោយបានកើនឡើងពី២,១លានក្បាលនាឆ្នាំ២០០៩ ដល់ចំនួនជាង ២,៤លានក្បាលនាឆ្នាំ២០១៣ ដោយសារមានការវិនិយោគ បង្កើតកសិដ្ឋានចិញ្ចឹមសត្វខ្នាតមធ្យម និងខ្នាតធំ។ ចំណែកផលិតកម្មចំណីសត្វ មានការវិនិយោគបង្កើតរោងចក្រចំណីសត្វ សម្រាប់ផ្គត់ផ្គង់ក្នុងស្រុក។ ដោយឡែក ប្រជាកសិករមានការចូលរួមយ៉ាងសកម្ម ក្នុងការផលិតដំណាំចំណីសត្វ និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចយ៉ាងផុលផុស។ ទោះជាយ៉ាងនេះក្តី ចំណី និងថ្នាំសត្វនៅមានតម្លៃខ្ពស់នៅឡើយ។

**ក្រាហ្វិកទី២៖ បង្ហាញអំពីការវិវឌ្ឍសត្វនៅកម្ពុជាពីឆ្នាំ២០០៩-២០១៣**




ការចិញ្ចឹមសត្វស្លាប (មាន់ ទា) មានការកើនឡើងយ៉ាងខ្លាំងរហូតដល់៣៥,២៨% ក្នុងនោះការចិញ្ចឹមជាលក្ខណៈគ្រួសារអំឡុងពេល៥ឆ្នាំ (ឆ្នាំ២០០៩ដល់២០១៣) បានកើនពីជាង២០,១៩លានក្បាលឆ្នាំ២០០៩ ដល់ជិត២៧,៣២លានក្បាល នាឆ្នាំ២០១៣។ ជាមួយគ្នានោះ នៅឆ្នាំ២០១៣ ផលិតកម្មសត្វស្លាបមានការកើនឡើងប្រមាណ១៨,២៦% បើប្រៀបធៀបនឹងឆ្នាំ២០១២។ នេះបញ្ជាក់ឲ្យឃើញថាមានកំណើនការវិនិយោគក្នុងការចិញ្ចឹមសត្វស្លាប។

**ក្រាហ្វិកទី៣៖ បង្ហាញអំពីការវិវឌ្ឍផលិតកម្មសត្វស្លាបពីឆ្នាំ២០០៩-២០១៣**



ប្រជាកសិករមានការយល់ដឹងបណ្តើរៗនូវបច្ចេកទេសចិញ្ចឹមសត្វ តាមគោលការណ៍ជីវសុវត្ថិភាព និងការយល់ដឹងអំពីវិធានការទប់ស្កាត់ជំងឺឆ្លង។ ការបង្ការ ការពារសុវត្ថិភាពមនុស្សសត្វ ក៏ត្រូវបានអនុវត្ត និងទទួលបានលទ្ធផលល្អប្រសើរ ដោយអត្រាឈឺស្លាប់សត្វទាប។ ជំងឺផ្តាសាយបក្សីត្រូវបានទប់ស្កាត់។ ការត្រួតពិនិត្យអនាម័យសត្វ ផលិតផលសត្វ ត្រូវបានយកចិត្តទុកដាក់ ដោយអនុវត្តចាប់ផ្តើមពីកសិដ្ឋាន កន្លែងពិឃាដដល់ទីផ្សារ ជាពិសេសការត្រួតពិនិត្យអនាម័យ ក្នុងការនាំចេញ នាំចូល នាំឆ្លងកាត់សត្វ និងផលិតផលមានដើមកំណើតពីសត្វ។

ទន្ទឹមនឹងនោះ កម្ពុជាត្រូវបន្តធ្វើការងារជាច្រើន ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តជាអន្តរជាតិ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការអនុវត្តបទដ្ឋានអនាម័យសម្រាប់ផលិតផលសត្វ និងពង្រឹងការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យសត្វ ដើម្បីការពារនិងប្រយុទ្ធប្រឆាំងជំងឺឆ្លង ការពារសុខភាពសាធារណៈ តាមរយៈការការពារជំងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ និងបង្កើតសត្តឃាតដ្ឋានទំនើប ដើម្បីការពារសុខភាពសាធារណៈ និងជួយសម្រួលពាណិជ្ជកម្ម។

ចំពោះការកែលម្អពូជ គឺកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរផងដែរ ព្រោះប្រជាកសិករភាគច្រើន កាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វ ជាកត្តាសំខាន់ដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ ហើយនឹងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។

ជាមួយនោះ ការផ្សព្វផ្សាយបច្ចេកទេសក្នុងជួរកសិករ ត្រូវបានអនុវត្តយ៉ាងសកម្ម និងមានប្រសិទ្ធភាព ដែលជាលទ្ធផលចំនួនសត្វស្លាបមានការកើនឡើង និងធានាបាននូវការផ្គត់ផ្គង់សាច់ស៊ុត នៅក្នុងប្រទេស ហើយកសិដ្ឋានផលិតកម្មមានលក្ខណៈពាណិជ្ជកម្ម កំពុងរីកចម្រើនជាបណ្តើរៗហើយដែរ។

ដោយមានការអភិវឌ្ឍវិស័យចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វ ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរលើការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិ បាននិងកំពុងអនុវត្តយ៉ាងសកម្មផុសផុល ដែលមកទល់ពេលនេះ ឡជីវឧស្ម័នសរុបចំនួន២០.៣៣៨ឡ ត្រូវបានសាងសង់ឡើង។

## ៤. ផលិតកម្ម និងកំណែទម្រង់ផ្នែកជលផល

ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាស្បៀង អាហារូបត្ថម្ភ និងផ្តល់នូវប្រាក់ចំណូលដល់ប្រជាជនកម្ពុជារាប់លាននាក់។ ត្រីចូលរួមចំណែកប្រមាណ៨០ភាគរយនៃប្រូតេអ៊ីន ដែលបានមកពីសាច់សត្វសម្រាប់ប្រជាជនកម្ពុជា ហើយមានប្រជាជនប្រមាណ៤,៥លាននាក់ បាននិងកំពុងចូលរួមដោយផ្ទាល់នៅក្នុងវិស័យជលផលនេះ។ ផ្អែកទៅលើស្ថិតិជលផល ផលត្រីសរុបបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសពីផ្នែកវារីវប្បកម្ម និងផលចាប់ពីវាលស្រែ។ ការកែទម្រង់ស៊ីជម្រៅវិស័យ

ជលផលត្រូវបានអនុវត្តយ៉ាងសកម្ម និងមានប្រសិទ្ធភាព។ ការធ្វើកំណែទម្រង់នេះ បាននាំឲ្យមានការវិវឌ្ឍ និងអភិវឌ្ឍក្នុងផ្នែកជលផល និងត្រូវបានវាយតម្លៃថាបានបោះជំហ៊ានទៅមុខយ៉ាងខ្លាំង។

ក្នុងអំឡុងពេល៥ឆ្នាំកន្លងមក ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញភារកិច្ចយ៉ាងសកម្ម ដោយបានសម្រេចលទ្ធផលគ្រប់ផ្នែកលើវិស័យនេះ ក្នុងនោះមានការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងនិងបង្កើតកន្លែងអភិរក្សជលផល ការបង្ក្រាបបទល្មើសនេសាទ ការអភិវឌ្ឍវារីវប្បកម្ម ការបង្កើតស្រះជម្រកត្រី ការសិក្សាស្រាវជ្រាវនិងការផ្សព្វផ្សាយ ។ល។ ត្រូវបានអនុវត្ត និងធានាដល់ការគ្រប់គ្រងផ្នែកជលផលប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះ កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា ត្រូវបានបង្កើន ពិសេសក្នុងការរៀបចំផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការអភិរក្សធនធានជលផល ដែលជាកត្តាជោគជ័យបន្ថែមទៀត ដល់ការគ្រប់គ្រងផ្នែកជលផល។

កំណែទម្រង់ស៊ីជម្រៅផ្នែកជលផលដំណាក់កាលទី២របស់រាជរដ្ឋាភិបាល ដែលបានសម្រេចលុបឡូត៍នេសាទទាំងអស់ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែងអភិរក្សជលផល កំពុងបានផ្តល់ផលជាវិជ្ជមានដល់ប្រជាពលរដ្ឋទូទាំងប្រទេស និងមានការកើនឡើងផលនេសាទតាមគ្រួសារ។ លទ្ធផលសំខាន់ៗដែលសម្រេចបានអំឡុងពេល៥ឆ្នាំ (ឆ្នាំ២០០៩ដល់ឆ្នាំ២០១៣) រួមមាន៖

- **អាជីវកម្មនេសាទទឹកសាប៖** អាជីវកម្មទឹកសាបសម្រេចបាននៅឆ្នាំ២០១៣ សរុបចំនួន ៥២៨.០០០តោន កើនលើសឆ្នាំមុនប្រមាណ៣,៧៣% និងមានកំណើនប្រមាណ៣៥% ក្នុងអំឡុងពេល៥ឆ្នាំ (ឆ្នាំ២០០៩-២០១៣) ពោលគឺកើនបានពី៣៩០.០០០តោន នាឆ្នាំ ២០០៩ ដល់៥២៨.០០០តោននាឆ្នាំ២០១៣។
- **អាជីវកម្មនេសាទសមុទ្រ៖** អាជីវកម្មសមុទ្រសម្រេចបាននៅឆ្នាំ២០១៣ សរុបចំនួន ១១០.០០០តោន កើនលើសឆ្នាំមុនប្រមាណ៤៦,៦៧% និងមានកំណើនប្រមាណ៤៧% ក្នុងអំឡុងពេល៥ឆ្នាំ (ឆ្នាំ២០០៩-២០១៣) ពោលគឺកើនបានពី៧៥.០០០តោន នាឆ្នាំ ២០០៩ ដល់១១០.០០០តោននាឆ្នាំ២០១៣។
- **ការអភិវឌ្ឍវារីវប្បកម្ម៖** ការចិញ្ចឹមត្រី បង្គា គ្រប់ប្រភេទឆ្នាំ២០១៣ សម្រេចបានចំនួន ៩០.០០០តោន កើនលើសឆ្នាំមុនប្រមាណ២២% និងមានកំណើនប្រមាណ៨០% ក្នុងអំឡុងពេល៥ឆ្នាំ (ឆ្នាំ២០០៩-២០១៣) ពោលគឺកើនបានពី៥០.០០០តោន នាឆ្នាំ២០០៩ ដល់៩០.០០០តោន នាឆ្នាំ២០១៣។ នៅក្នុងឆ្នាំ២០១៣ ការចិញ្ចឹមក្រពើសម្រេចបានចំនួន៣២០ពាន់ក្បាល និងការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន១៥០លានក្បាល។ ទន្ទឹមនឹងនោះ កន្លែងភ្ញាស់កូនត្រីនៅទូទាំងប្រទេសចំនួន៣០៥កន្លែង ត្រូវបានបង្កើត ដែលក្នុងនោះចំនួន២៩២កន្លែង ជារបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់បច្ចេកទេសពី

មន្ត្រីរដ្ឋបាលជលផល និងបានបង្កើតស្រះជម្រកត្រីសហគមន៍បានចំនួន៧៧៥កន្លែង។ បន្ថែមលើសកម្មភាពនេះ ផលត្រីតាមវាលស្រែត្រូវបានវាយតម្លៃថា បានកើនឡើងប្រមាណពី៤ទៅ៦ដង នេះបញ្ជាក់បានថា ប្រជាកសិករនិងប្រជានេសាទ បានទទួលយកនូវបច្ចេកទេសវារីវប្បកម្ម ដែលក្រសួងបានអនុវត្តផ្សព្វផ្សាយកន្លងមក។

- **ការអភិវឌ្ឍសហគមន៍៖** ការពង្រឹងសហគមន៍នេសាទ ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ពោលគឺមកទល់នឹងឆ្នាំ២០១៣នេះ សហគមន៍នេសាទចំនួន៥១៦ ត្រូវបានបង្កើតឡើង ក្នុងនោះ សហគមន៍នេសាទទឹកសាបចំនួន៤៧៧ និងសហគមន៍នេសាទសមុទ្រចំនួន៣៩។ ក្នុងចំណោមសហគមន៍ទាំងនេះ មានសហគមន៍នេសាទចំនួន៣៦០ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួង និងបានបង្កើតធនាគារក្តាមមានចំនួន៣២កន្លែងផងដែរ។
- **ការអភិរក្សជលផល៖** ការអភិរក្សជលផលត្រូវបានរៀបចំនិងអនុវត្តយ៉ាងពេញទំហឹង ទាំងនៅទឹកសាបនិងសមុទ្រ រួមមាន ការអភិរក្សថ្កាថ្ម ស្មៅសមុទ្រ ដាំព្រៃលិចទឹក ព្រៃកោងកាង និងអន្លង់ត្រីមេពូជ។ លើសពីនេះទៀត ការរៀបចំលែងកូនត្រី កូនបង្កង និងត្រីមេពូជត្រូវបានប្រារព្ធធ្វើជារៀងរាល់ឆ្នាំ។
- **ការបង្រ្កាបបទល្មើសជលផល៖** ការបង្ក្រាបបទល្មើសក្នុងអំឡុងពេល៥ឆ្នាំកន្លងទៅនេះ ត្រូវបានអនុវត្តយ៉ាងសកម្ម ដើម្បីទប់ស្កាត់អំពើល្មើស និងការពារធនធានជលផលប្រកបដោយចីរភាព ជាក់ស្តែងបទល្មើសនេសាទចំនួន៣.៨២៦ករណី ត្រូវបានបង្ក្រាបក្នុងឆ្នាំ២០១៣ (ទឹកសាប៣.៧២៤ករណី និងសមុទ្រ១០២ករណី)។

**ក្រាហ្វិកទី៤៖ អាជីវកម្មនេសាទទឹកសាប សមុទ្រ និងការអភិវឌ្ឍវារីវប្បកម្មឆ្នាំ២០០៩-២០១៣**




បន្ថែមលើនេះ ស្តង់ដារគុណភាពផលិតផលជលផល (ប្រហុក ត្រីងៀត បង្គារបង្កករហ័ស) ត្រូវបានរៀបចំនិងអនុវត្ត សំដៅបង្កើនតម្លៃបន្ថែមផលិតផលជលផល និងសុវត្ថិភាពចំណីអាហារ។

សមាគមអ្នកកែច្នៃផលិតផលត្រីចំនួន១៦ ក៏ត្រូវបានរៀបចំបង្កើតឡើង។ ការវិនិយោគលើផ្នែកនេះ ទាមទារឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀតជាចាំបាច់។

លទ្ធផលទទួលបានក្នុងផ្នែកជលផលកន្លងមក គឺអាស្រ័យដោយការបង្កើនកិច្ចសហការរវាងក្រសួងជាមួយដៃគូអភិវឌ្ឍន៍ ការទំនាក់ទំនងល្អជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា ដើម្បីគាំទ្រដល់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ផ្នែកជលផល។ សហគមន៍នេសាទដែលបានបង្កើតឡើងទទួលបាននូវផលប្រយោជន៍ និងបានជួយដល់ការលើកកម្ពស់ជីវភាពរស់នៅ កាន់តែប្រសើរឡើងជាលំដាប់នាពេលកន្លងមក។

## ៥. ការអនុវត្តកំណែទម្រង់ផ្នែកព្រៃឈើ

រាជរដ្ឋាភិបាលកម្ពុជាបានផ្ដោតការយកចិត្តទុកដាក់ លើកម្មវិធីកំណែទម្រង់ផ្នែកព្រៃឈើ ដោយខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសយកចិត្តទុកដាក់ជាសំខាន់ លើការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង លើការធ្វើអាជីវកម្មព្រៃឈើ សំដៅរក្សាការពារ និងធានានិរន្តរភាពព្រៃឈើ។ ច្បាប់ស្ដីពីព្រៃឈើ គឺជាត្រីវិស័យនិងក៏ជាឧបករណ៍ដ៏សំខាន់សម្រាប់ការគ្រប់គ្រងវិស័យព្រៃឈើជាតិ។

កម្មវិធីព្រៃឈើជាតិត្រូវបានរៀបចំឡើង និងបានទទួលការអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា កាលពីខែតុលា ឆ្នាំ២០១០ កន្លងទៅនេះ។ កម្មវិធីព្រៃឈើជាតិ កំពុងត្រូវបានអនុវត្តយ៉ាងពេញទំហឹង ដើម្បីឈានទៅសម្រេចបាន តាមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ដែលបានកំណត់ថាត្រូវថែរក្សាគម្របព្រៃឈើឱ្យបាន៦០ភាគរយនៃផ្ទៃដីសរុបនៅឆ្នាំ២០១៥។ កម្មវិធីព្រៃឈើជាតិនេះ បានផ្ដោតជាពិសេសលើការពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ បង្កើនអភិបាលកិច្ចល្អ ការជំរុញល្បឿននៃការកំណត់ដែនព្រៃឈើ ការលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងការអភិរក្សព្រៃឈើនិងសត្វព្រៃ ការជំរុញការអភិវឌ្ឍសហគមន៍ព្រៃឈើ ការបង្កើនការដាំនិងស្ដារព្រៃឈើឡើងវិញ ការកសាងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយអំពីព្រៃឈើ និងការស្វែងរកប្រភពហិរញ្ញវត្ថុផ្សេងៗទៀត។

ទិសដៅនៃកិច្ចអភិវឌ្ឍនៅក្នុងកំណែទម្រង់ផ្នែកព្រៃឈើ គឺដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានព្រៃឈើតាមរបៀបមួយដែលមានចីរភាព សំដៅទាញយកប្រយោជន៍ឱ្យបានច្រើនបំផុត ពីការរួមចំណែករបស់វិស័យនេះ នៅក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច។ នៅក្នុងដំណើរការនៃការគ្រប់គ្រង ការរក្សាការពារ ការត្រួតពិនិត្យ និងការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការប្រើប្រាស់ធនធានដ៏មានតម្លៃនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តវិធានការជាច្រើន ហើយសម្រេចបានជោគជ័យគួរឱ្យកត់សម្គាល់ នូវសមិទ្ធផលធំៗមួយចំនួន ក្នុងរយៈពេល៥ឆ្នាំ (២០០៩ ដល់ ២០១៣) ដូចជា៖

ការធ្វើអាជីវកម្មព្រៃគុបរបស់ក្រុមហ៊ុនព្រៃសម្បទានដែលបានផ្តល់ឱ្យរួចហើយ ត្រូវបានផ្អាកសកម្មភាព។ សកម្មភាពដាំដុះដើមឈើនិងព្រៃឈើឡើងវិញ មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ ហើយក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏បានចែងអំពីវិធានប្រើប្រាស់ដីព្រៃរបស់រដ្ឋ សម្រាប់ការដាំឈើដើម្បីបង្កលក្ខណៈសមស្រប និងជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋសហគមន៍ និងផ្នែកឯកជនឱ្យចូលរួមក្នុងសកម្មភាពនេះ។

ជាក់ស្តែង ក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០០៩ដល់២០១៣ សកម្មភាពដាំឈើជាចម្ការដោយរដ្ឋបាលព្រៃឈើ ក្រុមហ៊ុនវិនិយោគឯកជន និងគ្រួសារឯកជនខ្នាតតូចអនុវត្តបាន៨៧.០២៨ហិកតា ក្នុងនោះដាំដោយរដ្ឋបាលព្រៃឈើចំនួន៣.៣៨៨ហិកតា ក្រុមហ៊ុនដៃគូសហការជាមួយរដ្ឋបាលព្រៃឈើចំនួន៨៤៥ហិកតា ដាំជាលក្ខណៈគ្រួសារបានចំនួន៤.០៨២ហិកតា រុក្ខទិវាចំនួន៣៥៨ហិកតា និងក្រុមហ៊ុនឯកជនចំនួន៧៨.៣៥៤ហិកតា។ ទន្ទឹមនឹងនេះ ការងារបណ្តុះកូនឈើនៅតាមបណ្តាថ្នាលបណ្តុះកូនឈើនៅគ្រប់កន្លែងក្នុងប្រទេស សម្រេចបានចំនួនជាង៨លានដើមជារៀងរាល់ឆ្នាំ សម្រាប់ចែកជូនដល់ប្រជាពលរដ្ឋដាំតាមភូមិដ្ឋាន និងដាំតាមទីសាធារណៈ។

**តារាងទី-៥៖ លទ្ធផលការដាំឈើរយៈពេល៥ឆ្នាំ២០០៩-២០១៣**

| ឆ្នាំ / ផ្ទៃដីដាំដុះ (ហត) | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
|---|---|---|---|---|---|---|
| រដ្ឋបាលព្រៃឈើ | 1.000 | 1.020 | 530 | 488 | 350 | 3.388 |
| ក្រុមហ៊ុនដៃគូ | 0 | 0 | 0 | 0 | 845 | 845 |
| គ្រួសារ | 0 | 974 | 315 | 2.793 | 0 | 4.082 |
| រុក្ខទិវា | 69 | 66 | 68 | 84 | 72 | 358 |
| ក្រុមហ៊ុនឯកជន | 17.924 | 26.775 | 3.590 | 13.400 | 16.665 | 78.354 |
| **សរុបរួម** | 18.993 | 28.835 | 4.503 | 16.765 | 17.932 | 87.028 |

សហគមន៍ព្រៃឈើត្រូវបានជំរុញឱ្យបង្កើតឡើង តាមប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើដែលបានអនុម័តនៅដើមឆ្នាំ២០០៦។ ជាលទ្ធផល សហគមន៍ព្រៃឈើនៅទូទាំងប្រទេសបានកើនពី៤០២សហគមន៍នាឆ្នាំ២០០៩ ដល់៤៥៧សហគមន៍នាឆ្នាំ២០១៣ ដែលបានគ្រប់គ្រងលើផ្ទៃដីព្រៃឈើប្រមាណ៤០០ពាន់ហិកតា។

រដ្ឋបាលព្រៃឈើ បានពង្រឹកការអនុវត្តកម្មវិធីសហគមន៍ព្រៃឈើជាតិ ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនៅក្នុងទូទាំងប្រទេស និងបានរៀបចំផែនការអភិវឌ្ឍន៍និងគម្រោងសំណើនានា ដើម្បីស្វែងរកនិងទទួលបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់ដំណើរការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ឱ្យកាន់តែល្អប្រសើរឡើង ពិសេសតាមរយៈយន្តការក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន។

## ក្រាហ្វិកទី៥៖ បង្ហាញអំពីសហគមន៍ព្រៃឈើពីឆ្នាំ២០០៩-២០១៣




រដ្ឋបាលព្រៃឈើដែលបានទទួលភារកិច្ច លើការងាររៀបចំចាត់ចែងលក់កាបូនក្នុងប្រទេសកម្ពុជា បានធ្វើការតាមដាននិងសិក្សាស្រាវជ្រាវស៊ីជម្រៅនិងទាន់ពេលវេលា អំពីសភាពការណ៍អន្តរជាតិស្តីពីបញ្ហាព្រៃឈើលើពិភពលោក ដូចជាកាលានុវត្តភាពនៃទីផ្សារឥណទានកាបោនព្រៃឈើដែលសហគមន៍ពិភពលោកទាំងមូលកំពុងយកចិត្តទុកដាក់ ជាមួយបញ្ហាប្រែប្រួលអាកាសធាតុ និងការកើនកំដៅនៃភពផែនដីនេះ។ ជាទស្សនៈរួមរបស់ក្រសួងគឺ ត្រូវការពារព្រៃឈើរបស់យើង ដោយឈប់ធ្វើអាជីវកម្មកាប់ឈើនាំចេញ មកជាការលក់ខ្យល់បរិសុទ្ធ (ឥណទានកាបោន) វិញ ដែលកើតឡើងពីព្រៃឈើរបស់យើង ហើយប្រើប្រាស់ចំណូលទាំងនេះ មកជួយថែរក្សាព្រៃឈើ និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនសហគមន៍មូលដ្ឋាន។ កន្លងមក ការដាំដុះព្រៃឈើត្រូវបានជំរុញ និងបង្កើនសកម្មភាពខ្លាំងក្លា ជាពិសេសការដាំដុះដើមឈើនៅតំបន់ដែលមិនសូវសម្បូរណ៍ព្រៃ តំបន់ភ្នំរេចរិល និងតំបន់ទីជម្រាលដែលមានការហូរច្រោះខ្លាំង។ រដ្ឋបាលព្រៃឈើបានខិតខំនិងសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិនិងអន្តរជាតិនានា ដោយបានរៀបចំគម្រោងបង្កើតឥណទានកាបូនលើសហគមន៍ព្រៃឈើមួយចំនួន។

ជាការកត់សម្គាល់ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ សកម្មភាពនានាដែលទាក់ទងទៅនឹងយន្តការអភិវឌ្ឍន៍ស្អាត និងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរិលព្រៃឈើត្រូវបានគាំទ្រនិងជំរុញយ៉ាងខ្លាំងក្លា។ បន្ថែមលើនេះទៀត កិច្ចសហការជាមួយសមត្ថកិច្ចមូលដ្ឋានត្រូវបានបង្កើន ក្នុងការរៀបចំបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដោយសម្រេចបាននៅឆ្នាំ២០១៣ចំនួន៨១៧បង្គោល លើដីប្រវែង៩៧គីឡូម៉ែត្រ។

លើសពីនេះទៀតនោះ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ រដ្ឋបាលព្រៃឈើ បានធ្វើការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនិងសត្វព្រៃ ហើយចាត់ថ្នាក់ទៅតាមប្រភេទបទល្មើសបានជាច្រើនករណីជារៀងរាល់ឆ្នាំ។ ការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃឈើ ត្រូវបានអនុវត្តដូចភ្លៀងរលឹម សំដៅកាត់បន្ថយបទល្មើស។ ជាមួយគ្នានេះដែរ ការចុះរុះរើដុតបំផ្លាញ និងការបញ្ឈប់សកម្មភាពរោងម៉ាស៊ីនអារ

ឈើល្មើសច្បាប់ និងរឹបអូសមធ្យោបាយសម្ភារ បម្រើឱ្យសកម្មភាពល្មើសច្បាប់ជាច្រើនទៀត ត្រូវបានអនុវត្តដោយទទួលបានជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ។

## ៦. សេវាកម្មគាំទ្រផលិតកម្មកសិកម្ម

ជាមួយនឹងសមិទ្ធផលទាំងឡាយដែលសម្រេចបានជាវិជ្ជមាន ដូចបានបរិយាយខាងលើ ក៏នៅមានផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗទៀត ដែលទទួលបានលទ្ធផលល្អប្រសើរ តាមត្រីវិស័យដែលបង្ហាញយ៉ាងប្រត្យក្ស ដោយប្រមុខដ៏ឆ្នើមនៃរាជរដ្ឋាភិបាលកម្ពុជា។ ការវិនិយោគសាធារណៈ ការវិនិយោគផ្នែកឯកជន ក៏ដូចជាការយកចិត្តទុកដាក់ពីដៃគូអភិវឌ្ឍន៍នានា រួមទាំងអង្គការជាតិ អន្តរជាតិ កំពុងតែតម្រង់ទិសយ៉ាងរស់រវើក ទៅរកការជួយទ្រទ្រង់ដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការរៀបចំឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍន៍កសិកម្ម ក៏ដូចជាការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ និងការរៀបចំច្បាប់ពាក់ព័ន្ធផ្សេងៗទៀត កំពុងតែដំណើរការយ៉ាងសកម្ម។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញទិសដៅជាយុទ្ធសាស្ត្រ នៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០ ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗ ពីការផ្តោតលើធាតុចូលនិងមជ្ឈការទៅរកប្រព័ន្ធថវិកាថ្មី គឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្មនិងវិមជ្ឈការ។ ផ្អែកតាមទិសដៅនៃកម្មវិធីកំណែទម្រង់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាក្រសួងមួយក្នុងចំណោមក្រសួង១០ ដែលត្រូវបានដាក់ឲ្យអនុវត្តថវិកាកម្មវិធីពេញលេញ ដោយមានការវិភាជថវិកា និងការគ្រោងធ្វើប្រតិភូកម្មសិទ្ធិអំណាច ក្នុងការអនុវត្តចំណាយថវិកាដល់បណ្តាអង្គភាពថវិកាមួយចំនួន ដែលនឹងគ្រោងបង្កើតឡើងនាឆ្នាំ២០១៥។ ផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរៀបចំស្របតាមខ្លឹមសារនៃសារាចរណែនាំ របស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំផែនការថវិកា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកែសម្រួលនូវសមាសភាពក្រុមការងារចំនួន២គឺៈ (១)ក្រុមការងាររៀបចំថវិកា និង (២)ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង។

ចំពោះការងារសហប្រតិបត្តិការអន្តរជាតិ កិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី ការងារផ្នែកអាស៊ាន ការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការនានា បានប្រព្រឹត្តទៅដោយទទួលបានលទ្ធផលជាផ្លែផ្កា ជាពិសេសការរៀបចំកិច្ចប្រជុំលើកទី៣៥ នៃរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន និងបានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងកម្មវិធី ជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី និងអាស៊ាន និងអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀងស្តីពីការទិញលក់ផ្លាស់ប្តូរទំនិញ និងសេវាពាណិជ្ជកម្ម នៅតំបន់ព្រំដែនរវាងកម្ពុជានិងវៀតណាម ការធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំអាស៊ាន ដូចជាៈ កិច្ចប្រជុំលើកទី១០ នៃក្រុមការងារបមាណីអាស៊ាន

ស្តីពីផលិតផលសាកវប្បកម្មនិងកិច្ចប្រជុំពាក់ព័ន្ធ កិច្ចប្រជុំលើកទី១៦ នៃក្រុមការងារជំនាញការ កិច្ចប្រជុំលើកទី២១ នៃក្រុមការងារដំណាំអាស៊ាន និងកិច្ចប្រជុំលើកទី១៧ នៃឧត្តមមន្ត្រីព្រៃឈើអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ រួមទាំងរៀបចំទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីសហគមន៍កសិកម្មអាស៊ានផងដែរ។

ការគ្រប់គ្រងនិងការអភិវឌ្ឍន៍ធនធានមនុស្ស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពការងារប្រកបដោយសមធម៌ និងជាគោលដៅចម្បង ក្នុងការលើកស្ទួយសមត្ថភាពធនធានមនុស្ស ស្របតាមជំនាញបច្ចេកទេសនិងវិទ្យាសាស្ត្រ ដើម្បីរួមចំណែកលើកស្ទួយការអភិវឌ្ឍប្រទេសដែលជាជ្រុងមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំយកចិត្តទុកដាក់ក្នុងការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ជាពិសេស ការងារគ្រប់គ្រងមន្ត្រីរាជការ ការងាររៀបចំមន្ត្រីកាន់មុខតំណែង ការងាររៀបចំរចនាសម្ព័ន្ធ ការងាររៀបចំបៀវត្សរ៍ ប្រាក់ធានារ៉ាប់រងសង្គម ការងាររៀបចំដំឡើងថ្នាក់ ការងាររៀបចំដាក់មន្ត្រីគ្រប់អាយុឱ្យចូលនិវត្តន៍ និងការងារអភិវឌ្ឍន៍ធនធានមនុស្ស ឱ្យស្របទៅតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋាននានា។

បច្ចុប្បន្នដំណើរការផលិតកម្មកសិកម្ម បាននិងកំពុងវិវឌ្ឍតាមរបត់នៃទីផ្សារសេរី ដូចនេះ រចនាសម្ព័ន្ធតួនាទី និងភារកិច្ចនៃអង្គភាពនីមួយៗ ចាំបាច់ត្រូវតែកែលម្អ ឱ្យសមស្របតាមសភាពការណ៍ជាក់ស្តែង។ វិស័យកសិកម្មអាចអភិវឌ្ឍទៅបាន គឺតម្រូវឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ និងធនធានមនុស្សមានសមត្ថភាពសមស្រប នៅតាមបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលកិច្ចការទាំងអស់នេះ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនាពេលកន្លងមក។

សាកលវិទ្យាល័យភូមិន្ទកសិកម្ម សម្រេចបាននូវលទ្ធផលការងារសំខាន់ៗជាច្រើន ជាពិសេស ការងារអប់រំបណ្តុះបណ្តាលធនធានមនុស្ស ការងារស្រាវជ្រាវវិទ្យាសាស្ត្រ ការងារផ្សព្វផ្សាយ និងការងារសហប្រតិបត្តិការជាតិនិងអន្តរជាតិលើផ្នែកអប់រំកសិកម្ម។ ជាក់ស្តែងនៅឆ្នាំ២០១៣កន្លងមកនេះ មាននិស្សិតសរុបចំនួន៥.៩៧៣នាក់ ក្នុងនោះនារី១.៤០៣នាក់ (ស្មើនឹង២៣%នៃនិស្សិតសរុប) កំពុងសិក្សាថ្នាក់បរិញ្ញារង បរិញ្ញា បរិញ្ញាជាន់ខ្ពស់ និងបណ្ឌិត នៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម លើមុខជំនាញ១០ ដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងវិទ្យាសាស្ត្រកៅស៊ូ។ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបណ្តុះបណ្តាលនិស្សិតដោយជោគជ័យបានចំនួន១.៦៣៩នាក់ (នារី ៣៧៦នាក់)។ សាលាជាតិកសិកម្មចំនួន២ទៀតគឺ សាលាជាតិកសិកម្មព្រែកលៀបមាននិស្សិតសរុបចំនួន១.៥៦២នាក់ (នារី ៥០២នាក់) និងសាលាជាតិកសិកម្មកំពង់ចាមមាននិស្សិតសរុបចំនួន១.៥៥៩នាក់ (នារី៦០៨នាក់) ក៏មានការបណ្តុះបណ្តាលជំនាញផ្នែកកសិកម្មនេះ និងបានវាយតម្លៃថាមានការវិវឌ្ឍគួរជាទីពេញចិត្ត។

## គ. ការវាយតម្លៃ និង សន្និដ្ឋាន

## ១. ភាពខ្លាំង បញ្ហាប្រឈម និង ឧបសគ្គ

### ១.១ ភាពខ្លាំង និងកាលានុវត្តភាព

- សក្តានុពលផ្នែកផលិតកម្មកសិកម្ម ពិសេសធនធានដីនិងទឹកនៅមានលទ្ធភាពអាចបង្កើនបានគ្រប់គ្រាន់ ដែលជាមូលដ្ឋានគ្រឹះ សំដៅធានាដល់ការរីកលូតលាស់ផ្នែកផលិតកម្មកសិកម្ម។ តម្រូវការប្រើប្រាស់ផលិតផលកសិកម្ម ក្នុងរយៈពេល៥ឆ្នាំខាងមុខ សង្ឃឹមថានឹងនៅតែកើនឡើង សម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញ។ សេវាកម្មរបស់ផ្នែកឯកជនក្នុងវិស័យកសិកម្ម ពិសេស យន្តូបនីយកម្ម ធាតុចូលកសិកម្ម កំពុងមានការរីកចម្រើន។
- ប្រជាកសិករបានខិតខំប្តូរទម្លាប់ពី «**ការធ្វើកសិកម្មដើម្បីចិញ្ចឹមឆ្នាំង**» ទៅជា «**ការធ្វើកសិកម្មសម្រាប់លក់ដូរ**» ដែលនេះពិតជារបត់ថ្មីមួយជួយជំរុញការអភិវឌ្ឍក្នុងវិស័យកសិកម្មកម្ពុជា។ ការកើនឡើងនៃផលិតភាពដំណាំ ការប្រើប្រាស់ធាតុចូលកសិកម្ម និងគ្រឿងយន្តកសិកម្ម ជាទឡ្ហីករណ៍បញ្ជាក់យ៉ាងជាក់លាក់។
- គោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា បានតម្រង់ទិសដៅដាក់ឱ្យអនុវត្តច្បាស់លាស់ក្នុងការអភិវឌ្ឍកសិកម្ម និងអ្នកពាក់ព័ន្ធទាំងអស់មានការប្តេជ្ញាចិត្ត និងទទួលស្គាល់នូវសារសំខាន់នៃវិស័យកសិកម្មនេះ ទាំងផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងប្រជាកសិករ។
- រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ ដល់ការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈការបង្កើនការវិនិយោគលើការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បម្រើឱ្យផ្នែកកសិកម្ម ពិសេសប្រព័ន្ធធារាសាស្ត្រ ផ្លូវជនបទ ព្រមទាំងការបង្កើនសមត្ថភាព ការផ្តល់សេវាបច្ចេកទេស ការប្រើប្រាស់ធាតុចូលកសិកម្មសមស្រប ការគ្រប់គ្រងដីធ្លីកសិកម្ម ឥណទានជនបទ ការអភិវឌ្ឍសហគមន៍កសិករ និងទីផ្សារកសិកម្ម។
- សហគមន៍កសិកម្ម ត្រូវបានបង្កើតឡើង ដែលជាមូលដ្ឋានគ្រឹះក្នុងការប្រមូលផ្តុំការផលិត បង្កើនអំណាចក្នុងការចរចាថ្លៃ និងងាយស្រួលក្នុងការទទួលបាននូវសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ក៏ដូចជាឥណទាន សម្រាប់ពង្រីកអាជីវកម្មសហគមន៍។
- មានការអភិវឌ្ឍផ្នែកកសិ-ពាណិជ្ជកម្ម ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងទាញយកឱកាសនៃការផ្គត់ផ្គង់ផលិតផលកសិកម្ម។ តម្រូវការប្រើប្រាស់ផលិតផលកសិកម្មមាននិន្នាការកើនឡើងនៅលើពិភពលោក ដែលនេះជាកាលានុវត្តភាពទីផ្សារមួយសម្រាប់កម្ពុជា ក្នុងការបង្កើនផលិតកម្មនិងការប្រជែងទីផ្សារ។
- ការកើនឡើងនូវការប្រើប្រាស់គ្រឿងយន្តកសិកម្ម នឹងអាចធ្វើឲ្យកសិករ អ្នកចិញ្ចឹមសត្វបង្កើនការតម្រង់ទិសទៅរកការចិញ្ចឹមបែបពាណិជ្ជកម្ម នៅពេលដែលតម្រូវការប្រើ

ប្រាស់សាច់កាន់តែកើនឡើង។ រចនាសម្ព័ន្ធដែលមានស្រាប់របស់ "ភ្នាក់ងារសុខភាពសត្វភូមិ" ជាយន្តការរឹងមាំមួយ សម្រាប់ផ្តល់សេវាសុខភាពសត្វ ដល់កសិករនៅមូលដ្ឋាន។

- សក្តានុពលផ្នែកវារីវប្បកម្មនៅមានទំហំធំធេងក្នុងទូទាំងប្រទេស ក្នុងខណៈដែលការចាប់ពីធម្មជាតិមិនអាចបង្កើនបាន។ សហគមន៍នេសាទដែលបានបង្កើត នឹងអាចជួយបានច្រើនក្នុងការអភិរក្សធនធានជលផល។

## ១.២ បញ្ហាប្រឈម និង ឧបសគ្គ

បញ្ហាប្រឈមចំពោះមុខនៅក្នុងការអភិវឌ្ឍវិស័យនេះរួមមាន៖

- ការបង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម ពិសេសនៅក្នុងផលិតកម្មដំណាំស្រូវ និងដំណាំផ្សេងៗទៀត នៅជួបបញ្ហាប្រឈមមួយចំនួននៅឡើយ ទោះបីជាសកម្មភាពដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានអនុវត្ត ដែលទាំងនេះទាមទារឱ្យមានការបង្កើនបន្ថែមទៀត នូវធនធាន ទាំងផ្នែកបច្ចេកទេសនិងថវិកា ព្រមទាំងការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញនិងបង្កើនលទ្ធភាពទទួលបាន នូវសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ឥណទានបម្រើផលិតកម្មកសិកម្ម និងធាតុចូលកសិកម្ម។ ការដោះស្រាយទឹកស្រោចស្រពក្នុងការបង្កបង្កើនផល គឺជាបញ្ហាដែលត្រូវបន្តយកចិត្តទុកដាក់ ដែលទាមទារឱ្យមានការបង្កើនការវិនិយោគបន្ថែម ដើម្បីបង្កើនការស្រោចស្រពឲ្យបានសមស្របតាមតម្រូវការ
- ពូជស្រូវ១០មុខដែលត្រូវបានជ្រើសរើសសម្រាប់ជំរុញនិងបង្កើនផលិតភាព នៅមិនទាន់ផ្សព្វផ្សាយចូលជ្រៅដល់ស្រទាប់កសិករនៅឡើយ ពិសេសទៀតនោះ បរិមាណពូជទាំង១០មុខនេះ មិនមានគ្រប់គ្រាន់សម្រាប់កសិករប្រើប្រាស់នៅឡើយ។ ដូច្នេះ ការរៀបចំបង្កើតសហគមន៍កសិករផលិតពូជ នឹងត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមទៀត។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់អំពីការផលិតពូជផ្សេងៗទៀត ដែលមានសក្តានុ-ពលសម្រាប់តម្រូវការទីផ្សារផងដែរ
- ការធានាឱ្យមាននូវអត្ថប្រយោជន៍កាន់តែប្រសើរជាងមុនសម្រាប់កសិករ តាមរយៈការរកទីផ្សារលក់ផលិតផល គឺជាបញ្ហាដែលត្រូវបន្តអនុវត្តបន្ថែមទៀត ព្រោះថាកសិករនៅមានការលំបាកក្នុងការស្វែងរកទីផ្សារលក់កសិផល និងលំបាកក្នុងការប្រកួតប្រជែងទីផ្សារក្នុងបរិបទនៃសេដ្ឋកិច្ចទីផ្សារសេរី។ សេវាផ្តល់ព័ត៌មានទីផ្សារកសិកម្ម នឹងត្រូវពង្រឹងបន្ថែមសម្រាប់ជួយដល់កសិករ
- ការយល់ដឹងរបស់កសិករក្នុងការប្រើប្រាស់សម្ភារកសិកម្ម ឱ្យបានត្រឹមត្រូវតាមបច្ចេកទេស និងការគ្រប់គ្រងជីជាតិដី ក៏នៅតែជាបញ្ហាប្រឈមនៅឡើយ ដែលសកម្មភាពនានាពាក់ព័ន្ធនឹងបញ្ហានេះ នឹងត្រូវយកចិត្តទុកដាក់អនុវត្តបន្តឱ្យបានខ្លាំងក្លា។ ទន្ទឹមនឹងនោះ

លិខិតបទដ្ឋានគតិយុត្ត និងសមត្ថភាពបច្ចេកទេស ក្នុងការអនុវត្តលើការគ្រប់គ្រងធនធានដី និងដីជាតិដីកសិកម្មនៅខ្វះខាត ដែលទាមទារឱ្យមានច្បាប់ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មសម្រាប់អនុវត្តនាពេលខាងមុខ

- ការកែលម្អការគ្រប់គ្រងក្រោយពេលប្រមូលផលហាក់នៅមានកម្រិតនៅឡើយ ការជំរុញផ្នែកកសិឧស្សាហកម្ម រួមទាំងការកែច្នៃក្រោយពេលប្រមូលផល ការកែលម្អគុណភាពស្របតាមស្តង់ដារកសិផល គឺត្រូវបានវាយតម្លៃថានៅមានកម្រិត។ សមត្ថភាពបច្ចេកទេសផ្នែកអនាម័យនិងភូតគាមអនាម័យ នឹងត្រូវបង្កើននិងពង្រឹងបន្ថែមទៀត
- ការបង្កើតសហគមន៍កសិកម្មក្នុងគោលបំណងដើម្បីបង្កើនអំណាចតថ្លៃ ការទទួលបាននូវសេវាបច្ចេកទេសនិងឥណទាន និងការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវធនធាន គឺត្រូវបានអនុវត្ត ប៉ុន្តែក៏អាចទទួលស្គាល់ថានៅមិនទាន់គ្រប់គ្រាន់ ដែលត្រូវបន្តពង្រឹងឱ្យបានប្រសើរជាងនេះ។ សហគមន៍កសិករដាំកៅស៊ូនៅមិនទាន់ត្រូវបានពង្រីកនៅឡើយ ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់លើកិច្ចការនេះ
- ការលើកទឹកចិត្តឱ្យមានការចូលរួមរបស់ផ្នែកឯកជន ក្នុងការអភិវឌ្ឍវិស័យកសិកម្ម គឺជាកត្តាចាំបាច់ សំដៅបង្កើនការវិនិយោគក្នុងវិស័យនេះ។ កន្លងមក មានក្រុមហ៊ុនវិនិយោគជាច្រើនបានបណ្តាក់ទុនវិនិយោគ លើផលិតកម្មដំណាំកសិ-ឧស្សាហកម្មតាមរូបភាពសម្បទានដីសេដ្ឋកិច្ច ហើយមានករណីមួយចំនួនដែលជាបញ្ហារាំងស្ទះដល់ការអនុវត្ត និងទាមទារដោះស្រាយ។ ប៉ុន្តែក៏មានករណីដែលវិនិយោគិនខ្លះមិនបានអនុវត្តកិច្ចសន្យា ដោយទុកដីឱ្យនៅទំនេរមិនបានដាំដុះ និងប្រឈមនឹងការដកហូតមកវិញ។ សកម្មភាពត្រួតពិនិត្យការអនុវត្តកិច្ចសន្យា នឹងត្រូវបង្កើនឱ្យបានខ្លាំងក្លានាពេលខាងមុខ
- ដោយឡែក ការប្រឈមដែលជាតម្រូវការក្នុងការជួយទ្រទ្រង់ដល់វិស័យនេះ ឱ្យសម្រេចជោគជ័យ គឺការបង្កើតក្របខណ្ឌច្បាប់បន្ថែម រួមទាំងសមត្ថភាពអនុវត្តច្បាប់នៅគ្រប់កម្រិត ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង្កើតនិងអភិវឌ្ឍន៍សមត្ថភាពអង្គភាពជំនាញកសិកម្មថ្នាក់មូលដ្ឋាន ដែលមានសមត្ថភាពបម្រើសេវាកម្មបច្ចេកទេសដល់កសិករផ្ទាល់ និងការជំរុញកម្មវិធីផ្សព្វផ្សាយនៅក្នុងមូលដ្ឋាន។ មន្ត្រីជំនាញកសិកម្ម នេសាទ និងព្រៃឈើ នឹងទាមទារឲ្យត្រូវបង្កើនបន្ថែមទៀត សម្រាប់បម្រើការនៅថ្នាក់មូលដ្ឋាន
- ផលិតកម្មសត្វនៅកម្ពុជាមានបម្រែបម្រួលកំណើនយឺត ដោយមានការលំបាកកន្លងមក និងការប្រឈមដូចជា ជំងឺឆ្លងរាតត្បាត និងកង្វះមធ្យោបាយគ្រប់គ្រាន់ លើការការពារ និងកម្ចាត់ ការប្រកួតប្រជែងនៃទីផ្សារសាច់សត្វ ដោយសារថ្លៃដើមផលិតកម្មខ្ពស់ ពិសេសថ្លៃចំណីសត្វ និងថ្នាំព្យាបាលសត្វជាដើម

- ព្រៃលិចទឹក ត្រូវបានប្រឈមនឹងការកាប់បំផ្លាញ ដែលត្រូវតែមានវិធានការជាបន្តទៀតដោយម៉ឺងម៉ាត់។ ធនធានមនុស្សនិងថវិកាក្នុងការចាត់វិធានការបង្ក្រាបបទល្មើសនេសាទ ការពារកន្លែងអភិរក្ស ទាំងទឹកសាបនិងសមុទ្រ នៅមានការខ្វះខាត។ ការបោះបង្គោលព្រំប្រទល់ព្រៃលិចទឹក និងការលុបបំបាត់ បទល្មើសជលផល នៅមានកម្រិតនៅឡើយ។ សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទ ក៏នៅមានកម្រិតដែរ ដោយសហគមន៍ភាគច្រើនពុំមានការជួយឧបត្ថម្ភគាំទ្រគ្រប់គ្រាន់។ ការកំណត់ព្រំប្រទល់ដែននេសាទ និងការបោះបង្គោលព្រំតែងជួបប្រទះការលំបាក។ ការព្រួយបារម្ភមួយទៀត គឺការសាងសង់ទំនប់វារីអគ្គិសនីនៅដងទន្លេមេគង្គខាងលើ ដែលអាចប៉ះពាល់ដល់ធនធានជលផល
- នៅក្នុងផ្នែកព្រៃឈើ ការធ្វើឱ្យសម្រេចបាននូវការពង្រីកគម្របព្រៃឈើ៦០% នៅឆ្នាំ២០១៥ គឺជាភារកិច្ចមួយដ៏ធំធេង និងត្រូវមានការយកចិត្តទុកដាក់ខ្ពស់។ ការធ្លាក់ចុះនូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើក្នុងដំណាក់កាលចុងក្រោយនេះ គឺបណ្តាលមកពីកំណើននៃការប្រើប្រាស់ដីកសិកម្ម ស្របទៅនឹងកំណើនប្រជាពលរដ្ឋ និងការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកសិកម្ម។ កិច្ចសហការនិងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ជាពិសេសក្នុងការទប់ស្កាត់ការកាប់រានទន្ទ្រានយកដីព្រៃឈើ និងការកំណត់ព្រំប្រទល់ដែនព្រៃឈើ ដែលតែងជួបប្រទះការលំបាក និងមានវិវាទ ព្រមទាំងមានការលួចវាយបំផ្លាញបង្គោលព្រំដែលបានបោះរួច។ ប្រជាជនមូលដ្ឋានដែលរស់នៅក្នុងនិងក្បែរតំបន់ព្រៃឈើ នៅតែពឹងអាស្រ័យខ្លាំងលើព្រៃឈើ ហើយការគ្រប់គ្រងជនចំណាកស្រុក នៅមានភាពធូររលុង ដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ។

## ២. ការវាយតម្លៃ និង សន្និដ្ឋាន

ផ្អែកលើលទ្ធផលទទួលបានក្នុងរយៈពេល៥ឆ្នាំ (២០០៩-២០១៣) កន្លងមកនេះ យើងអាចវាយតម្លៃជារួមបានថា បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិ រួមមានគ្រោះរាំងស្ងួតដោយសារកូនរដូវប្រាំងនៅពាក់កណ្តាលរដូវវស្សា គ្រោះជំនន់ទឹកភ្លៀងចុងរដូវវស្សា តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ផងនោះ បានធ្វើឱ្យផលិតកម្មកសិកម្ម មានការរីកចម្រើនគួរឱ្យកត់សម្គាល់និងជាទីមោទនៈ។

ផលិតកម្មស្រូវរយៈពេល៥ឆ្នាំ (២០០៩-២០១៣) នេះ បានទទួលលទ្ធផលគួរជាទីពេញចិត្ត។ កម្ពុជាទទួលបានបរិមាណផលស្រូវចំនួន៩,៣៨លានតោន និងអាចសល់ស្បៀង(ជាអង្ករ) សរុបចំនួន

៣,០៩លានតោន (ឬ៤,៨២លានតោនស្រូវ) នៅឆ្នាំ២០១៣ ដែលនេះជាជោគជ័យមួយគួរជាទីមោទនៈបំផុតសម្រាប់កម្ពុជា។ ផ្អែកលើសមិទ្ធផលខាងលើនេះ យើងអាចវាយតម្លៃជារួមបានថា ផលិតកម្មកសិកម្មកម្ពុជាយើង ពិសេសផលិតកម្មស្រូវពីមួយឆ្នាំទៅមួយឆ្នាំ មានការវិវឌ្ឍឈានឡើងជាលំដាប់ ដោយសារកត្តា២យ៉ាងគឺៈ (១) ការពង្រីកដីដាំដុះ តាមរយៈវិធានការបង្កើនរដូវ និង (២) កត្តាកើនឡើងនៃទិន្នផល (ពី២,៨៣តោន/ហ.តឆ្នាំ២០០៩ដល់៣,១៦តោន/ហ.តឆ្នាំ២០១៣) ដែលជាសមិទ្ធផលនៃការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយពូជថ្មី បច្ចេកទេសដាំដុះ និងការថែទាំសមស្រប។

ចំពោះដំណាំរួមផ្សំនិងឧស្សាហកម្ម ដំណាំឈើហូបផ្លែនិងដំណាំអចិន្ត្រៃយ៍ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ជាលក្ខណៈគ្រួសារនិងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ ជាក់ស្តែងផ្ទៃដីដាំដុះកៅស៊ូមានសន្ទុះកើនឡើង ពិសេសការអភិវឌ្ឍកៅស៊ូគ្រួសារ មានការវិវឌ្ឍតាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

ដោយឡែក ផលិតកម្មសត្វនៅកម្ពុជា ជាពិសេស គោ ក្របី ជ្រូក និងបក្សី មានការវិវត្តគួរកត់សម្គាល់។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ ឃើញថាផលិតកម្មគោថយចុះប្រមាណ៤,១៦% ក្របីថយចុះ៥,៧៦%។ ការថយចុះនេះគឺបណ្តាលមកពីពលកម្មចំណាកស្រុក ការប្រើប្រាស់គ្រឿងយន្តក្នុងផលិតកម្មកសិកម្ម ជំនួសឲ្យការប្រើប្រាស់កម្លាំងអូសទាញគោក្របី (នៅឆ្នាំ២០១៣ ការភ្ជួររាស់ដោយគោក្របីមានចំនួន០,៩៦លានហាត ស្មើនឹង៣០% ខណៈដែលការភ្ជួររាស់ដោយត្រាក់ទ័រ គោយន្តមានចំនួន២,៣១លានហាត ស្មើនឹង៧០%)។ ការចិញ្ចឹមបក្សីពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់៣៥% គឺពី២០,១៩លានក្បាល ដល់២៧,៣២លានក្បាល។ តាមរយៈការវាយតម្លៃជារួម ការបង្កើនការងារស្រាវជ្រាវនិងផ្សព្វផ្សាយពូជ ការបង្ការជំងឺឆ្លងសត្វ និងការពង្រីកចំណេះដឹងផ្នែកបច្ចេកទេសនៃការចិញ្ចឹមសត្វ ដល់ប្រជាកសិករមានភាពទូលាយជាងមុន និងមានប្រសិទ្ធភាព ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ។

ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល បាននិងកំពុងស្ថិតនៅតែជាបញ្ហាប្រឈមរវាងអភិរក្សនិងអភិវឌ្ឍ ហើយដែលត្រូវតែខិតខំរកឱ្យឃើញនូវដំណោះស្រាយដ៏សមស្របមួយ ប្រកបដោយប្រសិទ្ធភាព និងចូលរួមដោយសុឆន្ទៈជាមួយនឹងការបន្តពង្រឹងការ អនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗ។

លើសពីនេះទៀត ផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល។ តែទោះយ៉ាងណាក្តី ផ្លូវនៅវែងឆ្ងាយទៀតដើម្បីសម្រេចបានគោលដៅ និងមហិច្ឆតាធំធេងដែលយើងចង់បាន សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រទំនើប និងមានប្រសិទ្ធភាពខ្ពស់។

# ផ្នែកទី ២
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨

----------✍ ✍---------

## I- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨

### ក. សេចក្តីផ្តើម

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់ការលើកកម្ពស់វិស័យកសិកម្ម សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងពន្លឿនការកាត់បន្ថយភាពក្រីក្រ។ ចតុកោណយុទ្ធសាស្ត្រទាំងបួនសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិគឺ៖ ១-ការលើកស្ទួយវិស័យកសិកម្ម ២-ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៣-ការអភិវឌ្ឍវិស័យឯកជននិងការងារ និង ៤-ការកសាងសមត្ថភាពនិងអភិវឌ្ឍន៍ធនធានមនុស្ស។

ការបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គឺជាជំហ៊ាននាំឆ្ពោះទៅមុខរបស់កម្ពុជា ដើម្បីឈានឡើងទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ពោលគឺការឆ្លងកាត់ពីឋានៈនៃប្រទេសមានចំណូលទាបទៅប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយបន្ថែមលើនេះ បន្តរៀបចំកសាងមូលដ្ឋានគ្រឹះសម្រាប់ការសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ពិសេសគឺមហិច្ឆតាក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវ «**គោលដៅជាយុទ្ធសាស្ត្រ៤**» និង «**វិស័យអាទិភាព៤**» ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្ត ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ។ គោលដៅជាយុទ្ធសាស្ត្រ៤ របស់រាជរដ្ឋាភិបាល ត្រូវបានកំណត់ដូចខាងក្រោម៖

(ទី១) ធានាឲ្យបាននូវ**កំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧%** ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និង ធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចឲ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបាន អត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ។

(ទី២) **បង្កើតការងារឲ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន** ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អ និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងការទាក់ទាញ និងជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគ ទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគមកពីក្រៅប្រទេស។

(ទី៣) **សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុងមួយឆ្នាំ** ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុង «គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា» ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

(ទី៤) **បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ** ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើង។

ក្នុងបរិបទនៃការលើកស្ទួយវិស័យកសិកម្ម រាជរដ្ឋាភិបាលបានផ្តោតលើគោលដៅជាយុទ្ធសាស្ត្រ៤ជាសំខាន់រួមមាន៖ (១) **ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម (២) ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម (៣) កំណែទម្រង់ដីធ្លី ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (៤) ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។**

គោលនយោបាយអភិវឌ្ឍន៍កសិកម្មរបស់រាជរដ្ឋាភិបាលដែលបានកំណត់នេះ គឺជាការតម្រង់ទិសច្បាស់លាស់ ក្នុងការលើកកម្ពស់វិស័យកសិកម្ម ឱ្យក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចផ្តល់ចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ ដល់ការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុក រួមជាមួយធនធានថវិកានិងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តប្រពលវប្បកម្មកសិកម្ម ដោយដោះស្រាយជាកញ្ចប់នូវបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា ផ្លូវថ្នល់ ធារាសាស្ត្រ និងអគ្គិសនី ព្រមទាំងឥណទានទីផ្សារ និងការកែច្នៃកសិផល ជាពិសេសការកែច្នៃសម្រាប់ការនាំចេញ ដើម្បីធានាបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារនិងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញផលិតផលកសិកម្ម។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់ លើវិស័យអាទិភាព៤ដែលក្នុងនោះចំណុចអាទិភាពទី៣ មានពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម៖ «**ការអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម**» តាមរយៈ (១) ការបង្កើនតម្លៃបន្ថែមនៃការផលិត និងការនាំចេញអង្ករ ជាពិសេសការផ្តោតលើអង្ករក្រអូប អង្ករសរីរាង្គ និងកសិផលមានតម្លៃខ្ពស់ផ្សេងទៀត ដូចជាកៅស៊ូ ស្វាយចន្ទី ពោត សណ្តែក ល្ង ម្រេច ស្ករត្នោត ផ្លែឈើ កាហ្វេ បន្លែបង្ការនិងផ្កាជាដើម (២) ការជំរុញការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដែលទីផ្សារត្រូវការ ដូចជាសាច់ ត្រី ផលិតផលទឹកដោះគោជាដើម (៣) ការជំរុញការលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម និង (៤) ការបង្កើនផលិតភាព ទំនើបកម្មកសិកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ត្រូវបានរៀបចំឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនូវទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលកម្ពុជា។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក៏បានរៀបចំធ្វើឱ្យមានសង្គតិភាពជាមួយ «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**» សំដៅចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ និងពន្លឿនការកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកម្ពស់ និងជំរុញការអភិវឌ្ឍវិស័យកសិកម្ម។

## ខ. ចក្ខុវិស័យ (Vision)

វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលគឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាតាមអភិក្រម និងក្នុងវិសាលភាពនិងល្បឿនថ្មី ដើម្បីប្រែក្លាយវិស័យនេះពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម (បើកទូលាយ) ពោលគឺពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់ (ធនធានដីនិងធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ឈានទៅរកដំណាក់កាលថ្មី ដែលផ្តោតលើផលិតកម្មតាមបែបប្រពលវប្បកម្ម (ស៊ីជម្រៅ) ពោលគឺពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី ការស្រាវជ្រាវ និងការអភិវឌ្ឍយន្តូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មមុខដំណាំ និងផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វនិងវារីវប្បកម្មផង ដោយគិតគូរផងដែរអំពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព និងការធានាចីរភាព បរិស្ថាននិងធនធានធម្មជាតិ។ ទន្ទឹមនេះ ការបន្តជំរុញការធ្វើពាណិជ្ជូបនីយកម្ម និងការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម នឹងជួយបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាជួយបង្កើនចំណូលជូនកសិករ។

ចក្ខុវិស័យរយៈពេលវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺដើម្បី៖ **«រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ធានាបាននូវភាពមានស្បៀងគ្រប់គ្រាន់ និងប្រកបដោយសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប តាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា តាមអភិក្រម និងក្នុងវិសាលភាព និងល្បឿនថ្មី សំដៅជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព»។**

## គ. បេសកកម្ម (Mission)

បេសកកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺដើម្បី៖ **«ចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈ ការផ្តល់សេវាកម្មមានគុណភាពខ្ពស់ ដែលនាំដល់ការផ្គត់ផ្គង់ស្បៀងប្រកបដោយសុវត្ថិភាព បង្កើនផលិតភាពកសិកម្មនិងតម្លៃបន្ថែម ដោយផ្អែកទៅលើមូលដ្ឋាននិរន្តរភាព និងប្រសិទ្ធភាពតម្លៃចំពោះវិស័យ ដែលពឹងផ្អែកលើផលិតផលកសិកម្ម នេសាទ និងរុក្ខាប្រមាញ់»** ។

## ឃ. ទិសដៅគោលនយោបាយ (Policy Goal)

### ១. ទិសដៅគោលនយោបាយរួម (Overall Policy Goal)

**«ជំរុញកំណើនក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម និងការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព»**

ដើម្បីសម្រេចបាននូវទស្សនវិស័យ និងទិសដៅគោលនយោបាយរួមនេះ សកម្មភាពគាំទ្រជាច្រើននឹងត្រូវបានផ្តល់ រួមជាមួយនូវធាតុចូលសំខាន់ៗ សំដៅជំរុញដល់ការលូតលាស់សេដ្ឋកិច្ច ដូចជាការផ្តល់នូវសេវាកម្មមានគុណភាពខ្ពស់ ហើយធានាបានការផ្គត់ផ្គង់ស្បៀងអាហារប្រកបដោយសុវត្ថិភាព ជាពិសេសបង្កើនផលិតផលកសិកម្ម និងតម្លៃបន្ថែមដោយផ្អែកលើនិរន្តរភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការចំណាយលើវិស័យកសិកម្ម។ ក្នុងលក្ខខណ្ឌធម្មតា និងមិនមានគ្រោះធម្មជាតិកើតឡើង កំណើននៃផ្នែកកសិកម្មនឹងត្រូវរក្សាក្នុងរង្វង់ពី៣ទៅ៥%ក្នុងមួយឆ្នាំៗ។

ដីកសិកម្មជាធនធានធម្មជាតិសំខាន់ ដែលទាមទារការប្រើប្រាស់ឲ្យបានសមស្រប ធានារក្សាបាននូវគុណភាពពីធម្មជាតិនិងកែលម្អគុណភាព ដើម្បីគោលដៅការអភិវឌ្ឍផលិតកម្មមួយប្រកបដោយនិរន្តរភាព។ ក្នុងន័យនេះ ការជំរុញការស្រាវជ្រាវ និងរៀបចំចំណាត់ថ្នាក់ដី ទៅតាមប្រភេទដំណាំមានសក្តានុពលអំណោយផលដល់ផលិតកម្មកសិកម្ម គឺជាការចាំបាច់និងត្រូវយកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាព ពិសេសជំរុញការកសាងច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ដើម្បីមាននីតិវិធីគ្រប់គ្រងការពារដីដែលមានគុណភាពសម្រាប់ផលិតកម្ម និងមានវិធានបច្ចេកទេសថែរក្សា និងកែលម្អឡើងវិញ។

ការប្រែប្រួលអាកាសធាតុ បាននិងកំពុងធ្វើឱ្យប៉ះពាល់ខ្លាំងដល់វិស័យកសិកម្ម និងផលិតកម្មស្បៀងអាហារ។ ផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាព ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុឆ្នាំ២០១៤-២០១៨ ត្រូវបានរៀបចំនិងបានដាក់ឲ្យអនុវត្ត។ ផែនការយុទ្ធសាស្រ្តនេះមានចក្ខុវិស័យ ធ្វើឱ្យវិស័យកសិកម្មកម្ពុជា នៅតែបន្តកែលម្អជីវភាពរស់នៅ ធានាសន្តិសុខ និងសុវត្ថិភាពស្បៀង កំណើនសេដ្ឋកិច្ចជាតិនិងនិរន្តរភាពបរិស្ថាន តាមរយៈការអនុវត្តកសិកម្មវៃឆ្លាតជាមួយអាកាសធាតុ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយចីរភាព និងកាន់តែបៃតង ជាពិសេសសំដៅជួយដល់សហគមន៍ជនបទ និងក្រុមជនងាយរងគ្រោះ។

ដើម្បីសម្រេចនូវចក្ខុវិស័យនេះ បេសកកម្មក្នុងការចូលរួមចំណែកបន្សាំ និងកាត់បន្ថយផលប៉ះពាល់ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ត្រូវបានកំណត់ និងបានផ្តោតលើការផ្តល់សេវាកម្មមានគុណភាពកាន់តែខ្ពស់ ដែលនាំដល់ការបង្កើនសមត្ថភាពបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើវិធានការសមស្រប និងមានប្រសិទ្ធភាពខ្ពស់ ក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ ជីវចម្រុះ និងជលផលប្រកបដោយចីរភាព។

ផែនការយុទ្ធសាស្រ្តនេះមានគោលបំណងសំខាន់គឺ ចូលរួមចំណែកជួយកាត់បន្ថយផលប៉ះពាល់និងឥទ្ធិពលអវិជ្ជមានទាំងឡាយលើវិស័យកសិកម្ម ផលិតកម្មសត្វ ព្រៃឈើ និងជលផល ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ សំដៅស្តារនូវការខូចខាត និងការបាត់បង់ផលប្រយោជន៍នានា តាមរយៈការបង្កើនវិធានការបន្សាំ និងវិធានការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនិងការឡើងកម្តៅនៃភពផែនដី។

គោលដៅចំនួន៥ ត្រូវបានកំណត់គឺៈ (ទី១) បង្កើនសមត្ថភាពស្ថាប័ន និងធនធានមនុស្សលើការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗនៃពូជដំណាំ កៅស៊ូ ផលិតកម្មសត្វ ព្រៃឈើ និងធនធានជលផល ដែលមានលទ្ធភាពបន្សាំទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ (ទី២) បង្កើនសមត្ថភាពដល់កសិករងាយរងគ្រោះលើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗក្នុងផលិតកម្មដំណាំនិងសត្វ ដែលអាចបន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុ (ទី៣) បង្កើនការកាត់បន្ថយនូវការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់និងរេចរឹលព្រៃឈើ និងពីផលិតកម្មសត្វ ផលិតកម្មដំណាំ និងពីការកែច្នៃបឋមនៃផលិតផលកសិកម្មពុំសមស្រប (ទី៤) ជំរុញការអភិវឌ្ឍនិងបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងវិស័យជលផល ដោយចីរភាពដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និង (ទី៥) ជំរុញការអភិវឌ្ឍធនធានមនុស្សសម្រាប់ជាមូលដ្ឋាននៃការចូលរួមចំណែកបន្សាំ និងកាត់បន្ថយផលប៉ះពាល់ ដែលបង្កដោយការប្រែប្រួលអាកាសធាតុលើផលិតកម្មដំណាំកៅស៊ូ សត្វ ព្រៃឈើ និងជលផល។

## ២. សសរស្តម្ភគ្រឹះទាំង៤ (4 Basic Pillars)

ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្ត្រចម្បងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់នូវសសរស្តម្ភគ្រឹះចំនួន៤ ដើម្បីជំរុញកំណើនកសិកម្មៈ

| | |
|---|---|
| *សសរស្តម្ភទី-១ៈ* | *"ការបង្កើនផលិតភាព ពិពិធកម្មវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម"* |
| *សសរស្តម្ភទី-២ៈ* | *"ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម"* |
| *សសរស្តម្ភទី-៣ៈ* | *"ការគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព"* |
| *សសរស្តម្ភទី-៤ៈ* | *"ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម"* |

សសរស្តម្ភទី១ ទី២ និងទី៣ គឺជាមូលដ្ឋានគ្រឹះចម្បង សម្រាប់ជំរុញកំណើនរីកលូតលាស់នៃវិស័យកសិកម្មឲ្យបានក្នុងរង្វង់៥%ក្នុងមួយឆ្នាំ។ ដោយឡែកសសរស្តម្ភទី៤ គឺជាមូលដ្ឋានគាំទ្រកំណើននេះ ដែលពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពស្ថាប័នជំនាញ ការបង្កើននូវប្រសិទ្ធភាពនៃសេវាគាំទ្រនានា ពិសេសការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម។

**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ៖ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព**

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ៖** កំណើនសេដ្ឋកិច្ច៧% និងកាត់បន្ថយភាពក្រីក្រ > ១%ក្នុង១ឆ្នាំ




## ខ. កម្មវិធីទាំង៥របស់ក្រសួង (MAFF Programmes):

ដើម្បីធ្វើឱ្យសម្រេចបានទិសដៅគោលនយោបាយ និងយុទ្ធសាស្ត្រទាំងប្រាំខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកម្មវិធីអាទិភាពសំខាន់ៗចំនួនប្រាំ ដែលជាផ្នែកមួយនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ សំដៅពង្រឹងការអនុវត្តថវិកាតាមកម្មវិធី និងកម្មវិធីវិនិយោគសាធារណៈ ដោយរួមបញ្ចូលនូវប្រភពធនធានថវិកាខាងក្រៅផងដែរ។ កម្មវិធីទាំង៥នោះរួមមាន៖

**កម្មវិធីទី-១៖ បង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម**

**កម្មវិធីទី-២៖ ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ**

**កម្មវិធីទី-៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព**

**កម្មវិធីទី-៤៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តភាព**

**កម្មវិធីទី-៥៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស**

## រចនាសម្ព័ន្ធកម្មវិធីក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨




កម្មវិធីនីមួយៗមានគោលបំណងច្បាស់លាស់ សម្រាប់តម្រង់ទិសការអនុវត្តក្នុងរយៈពេល៥ឆ្នាំ (២០១៤-២០១៨) ដែលគោលបំណងនៃកម្មវិធីទាំង៥ត្រូវបានកំណត់ដូចខាងក្រោម៖

### កម្មវិធីទី-១៖ បង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម

ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម ជាគោលដៅយុទ្ធសាស្ត្រមួយដ៏សំខាន់ ដើម្បីរួមចំណែកជំរុញកំណើនក្នុងវិស័យកសិកម្ម។ ការបង្កើនផលិតភាពគឺផ្តោតជាសំខាន់លើការបង្កើនរដូវដាំដុះដំណាំ (ឲ្យបានពីរដង ឬបីដងក្នុងមួយឆ្នាំ) និងការអនុវត្តតាមគោលការណ៍ "**ប្រពលវប្បកម្ម**" ដើម្បីបង្កើនទិន្នផល។ ពិពិធកម្មកសិកម្ម គឺត្រូវផ្តោតលើការជំរុញផលិតមុខដំណាំដែលមានផលចំណេញខ្ពស់និងមានតម្រូវការទីផ្សារ។ ពាណិជ្ជូបនីយកម្មកសិកម្ម ពិសេសការនាំចេញ គឺត្រូវបានជំរុញឲ្យអនុវត្តនិងធានាថាមិនឲ្យប៉ះពាល់ដល់សន្តិសុខស្បៀងក្នុងប្រទេស។

**គោលបំណងកម្មវិធីទី១៖** "ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំតាមរយៈការបង្កើនការស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម សំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីប្រកបដោយនិរន្តរភាព" ។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ នឹងផ្តោតសកម្មភាពជាអាទិភាពលើះ

- ការបន្តបង្កើនផលិតភាពស្រូវនិងដំណាំផ្សេងទៀតតាមរយៈការពង្រឹង ការពង្រីក និងការធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេស និងព័ត៌មានទីផ្សារកសិកម្ម ដោយជំរុញសេវាទាំងនោះឲ្យមានរចនាសម្ព័ន្ធទៅដល់មូលដ្ឋាន ហើយផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្ត និងដៃគូដែលមានការពាក់ព័ន្ធ ការលើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍ ដើម្បីបង្កើនផលិតភាព និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការផលិតនិងប្រើប្រាស់ពូជដែលមានគុណភាព និងឆ្លើយតបនឹងតម្រូវការទីផ្សារ ការកែលម្អប្រព័ន្ធប្រមូល និងទុកដាក់កសិផល ការរៀបចំនិងកែសម្រួលក្របខណ្ឌគតិយុត្ត សម្រាប់ការគ្រប់គ្រង ការផលិតពូជ ការនាំចូលធាតុចូលកសិកម្ម ប្រព័ន្ធកសិកម្មតាមកិច្ចសន្យា ការគ្រប់គ្រងដីកសិកម្ម និងការអភិវឌ្ឍធនធានមនុស្សសម្រាប់ផ្នែកផលិតកម្មដំណាំកសិកម្ម។ ដើម្បីបំពេញសេចក្តីត្រូវការរបស់កសិករ ការផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្មរបស់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល ត្រូវបានជំរុញឲ្យមានការចូលរួមកាន់តែច្រើនថែមទៀត។
- ការបន្តជំរុញពិពិធកម្ម តាមរយៈការលើកកម្ពស់ការស្រាវជ្រាវនិងអភិវឌ្ឍ ការផ្សព្វផ្សាយមុខដំណាំថ្មីៗ ដែលមានសក្តានុពលសម្រាប់ការដាំដុះនិងការនាំចេញ ការពង្រឹងបរិស្ថានអនុគ្រោះ សម្រាប់ទាក់ទាញការវិនិយោគឯកជន ពិសេសក្នុងការស្រាវជ្រាវ ការផលិត ការចែកចាយ និងការកែច្នៃកសិផល ការបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធទាំងអស់ ក្នុងការផ្ទេរចំណេះដឹង ចំណេះធ្វើ និងបច្ចេកវិទ្យាថ្មីៗដល់កសិករ ពិសេសការអនុវត្តផលិតកម្មល្អប្រសើរ (Good Agricultural Practices-GAP) និងការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម។
- ការបន្តលើកកម្ពស់ពាណិជ្ជូបនីយកម្ម តាមរយៈការជំរុញការអនុវត្តច្បាប់ និងគោលនយោបាយ ព្រមទាំងការពង្រឹងយន្តការស្ថាប័ន ដើម្បីជំរុញការធ្វើពាណិជ្ជកម្ម និងការនាំចេញកសិផល រួមមានការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវច្បាប់ស្តីពីសហគមន៍កសិកម្ម ការលើកកម្ពស់សមត្ថភាពកែច្នៃ ការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម រួមបញ្ចូលនូវយន្តការ «ច្រកចេញចូលតែមួយ» ការលើកស្ទួយគុណភាពកសិផលឲ្យស្របតាមស្តង់ដារអន្តរជាតិ ការបង្កើនសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទានតាមថ្លៃសមស្រប ការលើកស្ទួយភាពជាដៃគូរវាងសហគមន៍កសិករនិងពាណិជ្ជករ ក៏ដូចជារវាងកសិ-ឧស្សាហកម្មខ្នាតធំ និងកសិកម្មលក្ខណៈគ្រួសារ តាមរយៈការដាក់ឲ្យអនុវត្តប្រព័ន្ធ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Farming System)"។ ភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជននឹងត្រូវបានជំរុញ ក្នុងគោលដៅបង្កើនផលិតភាពកសិកម្មផងដែរ។

- បន្តពង្រឹងនិងពង្រីកសមត្ថភាពពិសោធន៍ វិភាគក្នុងមន្ទីរពិសោធន៍កសិកម្មជាតិ តាមរយៈការពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីជាប្រចាំ និងស្វែងរកថវិកាដើម្បីបំពាក់នូវសម្ភារបរិក្ខារទំនើបទាន់សម័យគ្រប់គ្រាន់ សម្រាប់ដំណើរការពិសោធន៍វិភាគ និងជំរុញការអនុវត្តការងារធូបទកម្មលើផលិតផលនិងសម្ភារវេចខ្ចប់ ចូលរួមចំណែកលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម សម្រាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ និងធានាសុខភាពសាធារណៈ។
- បន្តជំរុញការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឲ្យការងារពិសោធន៍ស្រាវជ្រាវអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្រប លើគ្រប់មុខជំនាញពាក់ព័ន្ធនឹងផលិតកម្មដំណាំ ពិសេសដំណាំស្រូវ ដើម្បីឈានឆ្ពោះទៅសម្រេចបានជាបណ្តើរៗ នូវគោលដៅនៃគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។
- អនុវត្តវិធានការជាយុទ្ធសាស្ត្រនិងផែនការសកម្មភាព ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ លើវិស័យកសិកម្មនិងកសិ-ឧស្សាហកម្ម ដែលរួមមានៈ ការជំរុញការធ្វើប្រពលវប្បកម្ម និងពិពិធកម្មដំណាំសមស្រប ការពង្រឹងសមត្ថភាពសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីអភិវឌ្ឍន៍បច្ចេកទេសថ្មីៗ ការជំរុញការអភិវឌ្ឍកសិកម្ម កសិ-ឧស្សាហកម្ម ដោយបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ការពង្រឹងសមត្ថភាពស្ថាប័នជំនាញ ក្នុងការធ្វើអន្តរាគមន៍ចំពោះគ្រោះមហន្តរាយធម្មជាតិ ការអភិវឌ្ឍធនធានមនុស្ស និងការឆ្លើយតបចំពោះយេនឌ័រនិងកុមារ។
- ជំរុញការដាំដុះដំណាំកៅស៊ូតាមគ្រប់រូបភាព ទាំងការពង្រីកចម្ការកៅស៊ូមានស្រាប់ ចម្ការកៅស៊ូវិនិយោគឯកជន ពិសេសបង្កើនផ្ទៃដីដាំដុះកៅស៊ូគ្រួសារ។ ជំរុញនិងបង្កើនការធ្វើសហប្រតិបត្តិការ និងចូលរួមជាមួយបណ្ដាវិទ្យាស្ថាន និងអង្គការកៅស៊ូអន្តរជាតិនានា ដើម្បីផ្លាស់ប្ដូរបទពិសោធន៍បច្ចេកវិទ្យា និងចំណេះដឹងទូទៅលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូ និងខិតខំកៀរគររកប្រភពទុនពីស្ថាប័នភ្នាក់ងារហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារនៅទូទាំងប្រទេស។
- អនុវត្តវិធានការជាយុទ្ធសាស្ត្រ ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យកៅស៊ូ ដោយត្រូវផ្តោតជាសំខាន់ លើការជំរុញការប្រើប្រាស់ក្លូនកៅស៊ូដែលអាចបន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុ ការបង្កើតក្លូនកៅស៊ូថ្មី ការជំរុញការសិក្សាស្រាវជ្រាវពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើដំណាំកៅស៊ូ ការកសាងសមត្ថភាពមន្ត្រីជំនាញ ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុលើដំណាំកៅស៊ូ ការបង្កើនសមត្ថភាពបច្ចេកទេសដំណាំកៅស៊ូ ជំរុញការអនុវត្តកសិកម្មល្អប្រសើរ (GAP) និងការបង្កើនប្រសិទ្ធភាពប្រើប្រាស់ធាតុចូល ក្នុងផលិតកម្មកែច្នៃជ័រនិងឈើកៅស៊ូ។

- បន្តជំរុញការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជាឧបករណ៍អនុវត្តការងារ និងឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្ម រួមមាន៖ ច្បាប់ស្តីពីការការពារដំណាំនិងភូតគាមអនាម័យ ច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ច្បាប់ស្តីពីកៅស៊ូ លិខិតបទដ្ឋានក្រោមច្បាប់សម្រាប់គាំទ្រការអនុវត្តច្បាប់ស្តីពីសហគមន៍កសិកម្ម ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម រៀបចំគោលនយោបាយសម្រាប់អភិវឌ្ឍសហគមន៍កសិកម្ម អនុក្រឹត្យនិងប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជ ប្រកាសរួមស្តីពីសោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងការកម្ចាត់សមាសភាពចង្រៃ ប្រកាសស្តីពីការតែងតាំងនគរបាលយុត្តិធម៌សម្រាប់សមត្ថកិច្ចមន្ត្រីភូតគាមអនាម័យ វិសោធនកម្មលើប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងត្រារបស់មន្ត្រីភូតគាមអនាម័យ។ល។
- ជំរុញឱ្យមានការវិនិយោគផ្នែកកសិកម្មពិតប្រាកដ លើកកម្ពស់ការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព ក្នុងគោលដៅពន្លឿនការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបន្តត្រួតពិនិត្យការអនុវត្តកិច្ចសន្យាវិនិយោគ និងឈានដល់ការស្នើឲ្យដកហូតមកវិញនូវដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនដែលបានបំពាននីតិវិធីនិងលក្ខខណ្ឌនៃកិច្ចសន្យា។

### សូចនាកររបស់កម្មវិធីទី១៖

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ផ្ទៃដីដំណាំគ្រប់ប្រភេទ | លានហ.ត | ៤,៥០ | ៤,៨១ | ៥,០២ | ៥,២៣ | ៥,៤៤ | ៥,៦៥ |
| ២. ទិន្នផលស្រូវ | តោន/ហ.ត | ៣,១៦ | ៣,១៧ | ៣,១៨ | ៣,២១ | ៣,២៣ | ៣,២៥ |
| ៣. ផលិតផលស្រូវផលិតលើស | លានតោន | ៤,៨២ | ៥,២៤ | ៥,៤១ | ៥,៦០ | ៥,៧៩ | ៦,០០ |

## *កម្មវិធីទី-២៖ ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ*

រាជរដ្ឋាភិបាលនីតិកាលទី៥ មានគោលដៅជំរុញលើកកម្ពស់ចលនាចិញ្ចឹមសត្វ និងវារីវប្បកម្មឲ្យកាន់តែទូលាយថែមទៀត តាមរយៈការបង្កើតក្របខណ្ឌគោលនយោបាយ ដោយផ្អែកលើគោលការណ៍ខ្សែសង្វាក់តម្លៃ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គ ដល់ការអភិវឌ្ឍវិស័យនេះ ដោយគិតគូរយ៉ាងខ្លាំងដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេសអនាម័យ និងភូតគាមអនាម័យ។

**គោលបំណងកម្មវិធីទី-២៖** "ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣ភាគរយក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវនិងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺ

ឆ្លងសត្វ និងជំងឺស្វូណូស៊ីស ធានាការផ្គត់ផ្គង់សត្វ សាច់សត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និង បង្កើនសក្តានុភាពនៃការនាំចេញ" ។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តោត សកម្មភាពជាអាទិភាពលើ៖

- ការជំរុញរៀបចំ និងដាក់ឲ្យអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការលើក កម្ពស់ការចិញ្ចឹមសត្វ
- ការជំរុញការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍលើការបង្កាត់ពូជ ការគ្រប់គ្រង សុខភាពសត្វ ការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋានក្នុងវិស័យផលិតកម្មសត្វ
- អនុវត្តវិធានការជាយុទ្ធសាស្ត្រក្នុងផែនការសកម្មភាពដើម្បីឆ្លើយតបនឹងផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ លើវិស័យផលិតកម្មសត្វនិងសុខភាពសត្វ ដោយត្រូវ ផ្តោតលើការសម្របសម្រួលផលិតកម្មសត្វ ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការពង្រឹងសមត្ថភាពនិងការផ្សព្វផ្សាយ ការធ្វើអន្តរាគមន៍និងការជួយសង្គ្រោះ ការ គ្រប់គ្រងកាកសំណល់សត្វ និងការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានា
- ការជំរុញអនុម័តនិងអនុវត្តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋាន សម្រាប់រៀបចំស្ថាប័ន និងគ្រប់គ្រងវិស័យនេះ ក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដារ អនាម័យលើផលិតផលពីសត្វ ការពង្រឹងនិងជំរុញអនុវត្តវិធានការអនាម័យសត្វភូតគាម អនាម័យ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ ក៏ដូចជាដើម្បី ការពារសុខភាពសាធារណៈ
- ការជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វ ក្នុងទ្រង់ទ្រាយមធ្យមនិងធំ ដើម្បី គាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន និងការរកទីផ្សារជូនកសិករ ការលើកទឹកចិត្តការវិនិយោគឯកជនក្នុងការកែច្នៃ ផលិតផលសត្វ ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្រួលពាណិជ្ជកម្មលើ បសុសត្វ និងផលិតផលមានដើមកំណើតពីសត្វ។

**សូចនាកររបស់កម្មវិធីទី២៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ផលិតកម្មសត្វគ្រប់ប្រភេទ | លានក្បាល | ៣៤,៨១ | ៣៥,៨៦ | ៣៦,៩៣ | ៣៨,០៣ | ៣៩,១៧ | ៤០,៣៤ |
| ២. អត្រា (%) នៃចំនួនសត្វចាក់វ៉ាក់សាំង | ភាគរយ | - | ១០ | ១២ | ១៥ | ១៧ | ២០ |
| ៣. សត្តឃាតដ្ឋានអនុវត្តល្អប្រសើរលើអនាម័យ | ចំនួនសត្តឃាតដ្ឋាន | - | ២៥ | ៥០ | ៧៥ | ១០០ | ១២៥ |

## កម្មវិធីទី-៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទម្រង់ជលផល ក្នុងគោលដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ធានាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងថែរក្សាធនធានមច្ឆជាតិឲ្យគង់វង្ស តាមរយៈការរៀបចំសហគមន៍នេសាទ អភិរក្សព្រៃលិចទឹក ប្រយុទ្ធនឹងការនេសាទខុសច្បាប់ និងអភិវឌ្ឍន៍វារីវប្បកម្ម ដើម្បីចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។

កំណែទម្រង់ស៊ីជម្រៅវិស័យជលផល រាជរដ្ឋាភិបាលបានលុបឡូត៍នេសាទទាំងអស់ ដោយបានផ្តល់ជូនប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ទន្ទឹមនឹងការពង្រឹងនិងពង្រីកសហគមន៍នេសាទ និងកន្លែងអភិរក្សធនធានជលផល ព្រមទាំងអនុវត្តយ៉ាងសកម្មនូវវិធានការការពារព្រៃលិចទឹក ជាពិសេសព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ដែលជាជម្រកដ៏សំខាន់សម្រាប់ការរស់នៅនិងជាកន្លែងបន្តពូជរបស់មច្ឆជាតិ។

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវចំណុចដៅ៣សំខាន់ៗដូចខាងក្រោម៖

- ត្រូវសម្រេចឲ្យបានតាមទិសដៅ៥ឆ្នាំ (២០១៤-២០១៨) ដូចមាននៅក្នុងក្របខណ្ឌផែនការយុទ្ធសាស្រ្តវិស័យជលផលឆ្នាំ២០១០-២០១៩
- ជំរុញបន្តរៀបចំនិងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្រ្តគ្រប់ជ្រុងជ្រោយមួយ សម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ ក្នុងការកំណត់បញ្ហាប្រឈមជាលក្ខណៈអន្តរជាតិ ចំពោះវិស័យជលផលកម្ពុជា រួមមានបម្រែបម្រួលអាកាសធាតុ ការសាងសង់ទំនប់វារីអគ្គិសនី និងភាពរេចរិលនៃបរិស្ថាន
- ធានានូវការទទួលទានផលត្រីរបស់ប្រជាជនតាមកម្រិត ៥២,៤ គ.ក្រ សម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ។

**គោលបំណងកម្មវិធីទី៣៖** "បង្កើនការការពារនិងអភិរក្សធនធានជលផល តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ពង្រឹងសមត្ថភាពគ្រប់គ្រង ១០០សហគមន៍នេសាទជារៀងរាល់ឆ្នាំ និងជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងរង្វង់១៥%ក្នុងមួយឆ្នាំ ដើម្បីធានាឱ្យបាននូវនិរន្តរភាពធនធានជលផល ព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពផលផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ"។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ នឹងផ្តោតសកម្មភាពជាអាទិភាពលើះ

- ការបន្តជំរុញអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល២០១០-២០១៩ សំដៅបង្កើនផលិតផលត្រី ដើម្បីធានាសេចក្តីត្រូវការរបស់ប្រជាជន និងទីផ្សារនាំចេញ ដោយផ្តោតជាសំខាន់លើសសរស្តម្ភបីគឺះ (១)គ្រប់គ្រងប្រកបដោយនិរន្តរភាពនូវការធ្វើនេសាទទឹកសាបនិងសមុទ្រ (២)ជំរុញនិងអភិវឌ្ឍវារីវប្បកម្មទឹកសាប និងទឹកប្រៃ (៣)កែលម្អគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។
- ការបន្តពង្រឹងការគ្រប់គ្រងនិងអភិរក្សធនធានជលផលប្រកបដោយចីរភាពស្របតាម «ក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផលឆ្នាំ២០១០-២០១៩» និង «សេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយវិស័យជលផលជាតិ» ពិសេសតាមរយៈ ការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទគ្រប់ប្រភេទ ជាអាទិ៍ ការពង្រឹងការគ្រប់គ្រងឧបករណ៍នេសាទ ការលុបបំបាត់ការនេសាទហួសកម្រិត ការពង្រឹងសមត្ថភាពសហគមន៍នេសាទ ក្នុងការគ្រប់គ្រង ប្រើប្រាស់ និងអភិរក្សធនធានជលផល ការការពារជីវចម្រុះនិងជម្រកវារីសត្វ ការគ្រប់គ្រងគុណភាពទឹកសាបនិងសមុទ្រ ដោយកាត់បន្ថយសារជាតិពុលជាអតិបរមា ការថែទាំនិងជំរុញការដាំព្រៃលិចទឹក និងព្រៃកោងកាង ការកំណត់ព្រំប្រទល់ព្រៃលិចទឹក និងតំបន់អភិរក្សជលផល ព្រមទាំងការកសាងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ។
- ការបង្កើនវារីវប្បកម្ម គឺជាភាពចាំបាច់ ដើម្បីការពារធនធានមច្ឆជាតិ ដែលនឹងត្រូវផ្តល់នូវការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី រួមទាំងបច្ចេកទេស ពូជត្រី ឥណទាន និងទីផ្សារ។ ការធ្វើឲ្យប្រសើរឡើងនូវការអនុវត្តច្បាប់ តាមរយៈការប្រើប្រាស់បន្តនូវយន្តការដែលមានស្រាប់ គឺជាអាទិភាពក្នុងការការពារធនធានជលផល។

## សូចនាកររបស់កម្មវិធីទី៣ះ

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ផលិតផលវារីវប្បកម្ម | ពាន់តោន | ៩០ | ១២០ | ១៤៤ | ១៧២ | ២០៧ | ២៥០ |
| ២. បរិមាណផលចាប់ផលផល (ទឹកសាប និងសមុទ្រ) | ពាន់តោន | ៦០០ | ៦០០ | ៦០០ | ៦០០ | ៦០០ | ៦០០ |
| ៣. អត្រា%នៃអ្នកកែច្នៃបានកែលម្អគុណភាព និងសុវត្ថិភាពផលិតផលជលផល | % | ២ | ៥ | ១០ | ១៥ | ២០ | ២៥ |

## *កម្មវិធីទី-៤៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព*

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល បានផ្តោតលើការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ដើម្បីធានាកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ តាមរយៈការជំរុញអនុវត្ត «**កម្មវិធីព្រៃឈើជាតិ**» ការត្រួតពិនិត្យតាមដានការធ្វើអាជីវកម្មព្រៃឈើ ការពង្រឹងការអនុវត្ត «**ច្បាប់ស្តីពីព្រៃឈើ**» និងការអនុវត្តវិធានការម៉ឺងម៉ាត់ចំពោះបទល្មើសព្រៃឈើ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃការពារ ការអនុវត្តស៊ីជម្រៅនូវកំណែទម្រង់ក្នុងវិស័យព្រៃឈើ។

ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងនិងពង្រីកថែមទៀត នូវការគ្រប់គ្រងធនធានធម្មជាតិសំដៅរក្សា «**តុល្យភាពរវាងការអភិវឌ្ឍនិងការអភិរក្ស**» ពិសេសលើកកម្ពស់វិភាគទាននៃធនធានធម្មជាតិ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈ (១)ការធានាគម្របបៃតង ការអភិរក្សព្រៃឈើនិងសត្វព្រៃ (២)ការធានាចីរភាពប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាគុណភាពដី និងចីរភាពនៃប្រភពទឹក ដោយផ្តោតទៅលើការការពារជីវចម្រុះ តំបន់ដីសើម និងតំបន់ឆ្នេរ។

**គោលបំណងកម្មវិធីទី៤៖** "បង្កើនការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំឈើឱ្យបានយ៉ាងតិច២៥.០០០ហ.តក្នុង១ឆ្នាំ បង្កើតព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃឱ្យបាន៥០.០០០ហ.តក្នុង១ឆ្នាំ និងបង្កើតសហគមន៍ព្រៃឈើឱ្យបាន៣២សហគមន៍ក្នុងមួយឆ្នាំ"។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តោតសកម្មភាពជាអាទិភាពលើ៖

- ការបន្តគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃ ប្រកបដោយចីរភាព និងសមធម៌ស្របតាម «**កម្មវិធីព្រៃឈើជាតិ**» ពិសេសតាមរយៈការពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ការកំណត់ព្រំប្រទល់ ចំណាត់ថ្នាក់និងការចុះបញ្ជីដែនព្រៃឈើ ការគ្រប់គ្រងនិងប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនូវព្រៃឈើរដ្ឋនិងឯកជន។
- ការអនុវត្តវិធានការលើកកម្ពស់ជីវភាព និងការចូលរួមរបស់សហគមន៍ដែលរស់នៅអាស្រ័យព្រៃឈើ ការលើកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងនិងអភិរក្ស ការកាត់បន្ថយនូវការបាត់បង់និងរេចរិលព្រៃឈើ។
- ការបង្កើនការដាំនិងស្តារព្រៃឈើឡើងវិញ ការពង្រឹងកិច្ចអភិរក្សសត្វព្រៃ និងជម្រកសត្វព្រៃ ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការជំរុញការងារស្រាវជ្រាវនិងផ្សព្វផ្សាយក្នុងវិស័យព្រៃឈើ។
- ការបន្តជំរុញអនុវត្តវិធានការនានា ដើម្បីរក្សាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី សំដៅធានាគុណភាពដីនិងទឹក រួមទាំងទឹកក្រោមដីផង សម្រាប់បម្រើឲ្យវិស័យកសិកម្ម និង

ជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការជំរុញការរៀបចំ និងអនុវត្តគោលនយោបាយនិងបទដ្ឋានគតិយុត្ត ព្រមទាំងផែនការសកម្មភាព និងកម្មវិធីនានាឲ្យមានប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចជា ជម្រកសត្វព្រៃ តំបន់ព្រៃការពារ តំបន់អភិរក្សធម្មជាតិ។

- ការបន្តជំរុញអនុវត្តកិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងក្របខណ្ឌគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ តាមរយៈការអនុវត្តក្របខណ្ឌគតិយុត្ត និងយន្តការសម្រាប់ការធ្វើពាណិជ្ជកម្មកាបូន ការពង្រឹងសមត្ថភាព ការរៀបចំនិងអនុវត្តវិធានការសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

**សូចនាកររបស់កម្មវិធីទី៤៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១.ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃ | លានហ.ត | ១,៥០ | ១,៥៥ | ១,៦០ | ១,៦៥ | ១,៧០ | ១,៧៥ |
| ២. ផ្ទៃដីដាំព្រៃឡើងវិញ | ហិកតា | ១៧.៩៥០ | ២០.២៨០ | ២២.៣០០ | ២៤.៥០០ | ២៧.០០០ | ២៩.៧០០ |
| ៣. ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើត និងពង្រឹងសមត្ថភាព | ចំនួនសហគមន៍ | ៤៥៧ | ៤៨៩ | ៥២០ | ៥៥០ | ៥៧០ | ៦០០ |

## *កម្មវិធីទី-៥៖ "ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម"*

ដើម្បីរួមចំណែកជំរុញវិស័យកសិកម្ម ការពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស គឺជាចំណុចអាទិភាពមួយដ៏សំខាន់ ដែលត្រូវយកចិត្តទុកដាក់អនុវត្ត។

**គោលបំណងកម្មវិធីទី-៥៖** "បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំនិងបណ្តុះបណ្តាល សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព"។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវផ្តោតសកម្មភាពជាអាទិភាពលើ៖

- **ការពង្រឹងស្ថាប័ន៖** ជំរុញការគ្រប់គ្រងអង្គភាពជំនាញក្រោមឱវាទក្រសួង ឲ្យមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តគោលនយោបាយ សម្រាប់អភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព

- **ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ៖** បង្កើនសមត្ថភាពកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រ ពង្រឹងប្រព័ន្ធព័ត៌មាននិងទីផ្សារកសិកម្ម ការគ្រប់គ្រងគម្រោងវិនិយោគ សាធារណៈនិងឯកជន ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព ភាពស័ក្តិសិទ្ធក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ ការធ្វើអធិការកិច្ច សវនកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ និងសេវាគាំទ្រពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។
- **ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម៖** បង្កើនចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញកសិកម្មពាក់ព័ន្ធនានា ស្រាវជ្រាវបន្ថែមនូវបច្ចេកវិទ្យានិងរបកគំហើញថ្មីៗ សំដៅពង្រឹងនិងពង្រីកធនធានមនុស្សក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម។

សូចនាកររបស់កម្មវិធីទី៥៖

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១.អនុបាតនៃការអនុវត្ត សកម្មភាពសម្រាប់ ថវិកាកម្មវិធី | % | ៩១ | ៩៣ | ៩៤ | ៩៥ | ៩៥ | ៩៥ |
| ២.និស្សិតបានបញ្ចប់ការសិក្សា | នាក់ | ១.៩២០ | ១.៩៥០ | ១.៩៥០ | ២.០០០ | ២.០០០ | ២.០០០ |
| ៣.មន្ត្រីទទួលបានការបណ្តុះ បណ្តាលក្នុងនិងក្រៅ ប្រទេស | នាក់ | ២៨០ | ២៩០ | ៣០០ | ៣១០ | ៣២០ | ៣៥០ |

## ច. អនុកម្មវិធីនិងគម្រោងសកម្មភាព តាមបណ្តាអនុវិស័យជំនាញ

ដើម្បីសម្រេចគោលដៅចម្បងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់យ៉ាងច្បាស់នូវ «**កម្មវិធី**» ចំនួន៥ និងបានកំណត់នូវ «**អនុកម្មវិធី**» មួយចំនួន ដោយបានបង្ហាញជាក់លាក់ទៅតាមអនុវិស័យនីមួយៗ នៅក្នុងការអភិវឌ្ឍវិស័យកសិកម្មមានដូចខាងក្រោម៖

## ១. កម្មវិធីទី១៖ បង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម

### ១.១ អនុកម្មវិធីទី១.១ ៖ សម្របសម្រួលបច្ចេកទេស និងបង្កើនសមត្ថភាពអង្គភាព

**គោលបំណង** ៖ "បង្កើនសមត្ថភាពក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍផលិតកម្មកសិកម្ម និងសេវាកម្មគាំទ្រប្រកបដោយប្រសិទ្ធភាព"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ភាគរយនៃប្រសិទ្ធភាពនៃការអនុវត្តថវិកា | % | ៩៥ | ៩៦ | ៩៦,៥ | ៩៧ | ៩៧,៥ | ៩៨ |
| ២. ចំនួនស្ថានីយ៍ មណ្ឌលអភិវឌ្ឍន៍កសិកម្ម និងកសិដ្ឋានត្រូវបានស្តារ | ចំនួន | ១ | ២ | ៤ | ៦ | ៨ | ១០ |

**គម្រោងសកម្មភាព៖**

១. លើកកម្ពស់ប្រសិទ្ធភាពការងាររបស់ស្ថាប័នទាំងមូល តាមរយៈការពង្រឹងសមត្ថភាពកសាងផែនការការងារនិងថវិកា ការអនុវត្តថវិកា ការតាមដាននិងវាយតម្លៃ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

២. ជំរុញការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតាមបណ្តាកសិដ្ឋាន ស្ថានីយ និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឱ្យការងារផលិតកម្មពូជ ពិសោធន៍ស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាលើគ្រប់មុខជំនាញពាក់ព័ន្ធនឹងការអភិវឌ្ឍផលិតកម្មដំណាំ ទៅដល់ស្រទាប់ប្រជាកសិករ និងផលិតករគ្រប់កម្រិត។

៣. ចូលរួមអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់យេនឌ័រក្នុងវិស័យកសិកម្ម តាមរយៈការបញ្ជ្រាបការយល់ដឹងអំពីយេនឌ័រនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម និងការលើកទឹកចិត្តការចូលរួមរបស់ស្ត្រីនៅក្នុងការដឹកនាំនិងគ្រប់គ្រងសហគមន៍កសិកម្ម។

៤. លើកកម្ពស់ស្មារតីប្រកួតប្រជែង ការទទួលស្គាល់ ការផ្លាស់ប្តូរនូវស្នាដៃ គំនិតច្នៃប្រឌិត និងបទពិសោធន៍ល្អផ្សេងៗរបស់កសិករ នៅក្នុងកិច្ចដំណើរការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈការរៀបចំឱ្យមានជាវេទិកាសន្និបាតកសិករទូទាំងប្រទេសប្រចាំឆ្នាំ។

### ១.២ អនុកម្មវិធីទី១.២ ៖ ជំរុញការគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយចីរភាព

**គោលបំណង** ៖ "ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងជីជាតិដី កំណត់តំបន់ដាំដុះសម្រាប់ការប្រើប្រាស់ដីកសិកម្មប្រកបដោយប្រសិទ្ធភាព និងទប់ស្កាត់បញ្ហាឱនភាពដី និងបន្សាំជាមួយការប្រែប្រួលអាកាសធាតុ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ផែនទីវាយតម្លៃចំណាត់ថ្នាក់ដីនិងការប្រើប្រាស់ដីកសិកម្មនឹងត្រូវបានកំណត់ | ចំនួនផែនទីប្រចាំស្រុក | ១៨ | ២៧ | ៣៨ | ៥១ | ៦៦ | ៨៣ |
| ២. ទំហំផ្ទៃដីដាំដុះដំណាំត្រូវបានកែលម្អ | ហិកតា | ៤២០ | ៦៣០ | ៨៥៥ | ១.០៩០ | ១.៣៤០ | ១.៦១៥ |

**គម្រោងសកម្មភាព៖**

១. លើកកម្ពស់ការថែរក្សានិងកែលម្អដីជាតិដី ដែលជាមូលដ្ឋាននៃការធ្វើប្រពលវប្បកម្មដំណាំប្រកបដោយនិរន្តរភាព តាមរយៈការបង្កើនចំណេះដឹង ស្តីពីបច្ចេកទេសគ្រប់គ្រងដីជាតិដី ពិសេសជំរុញការប្រើប្រាស់ជីធម្មជាតិនិងជីគីមី សមស្របតាមបទដ្ឋានបច្ចេកទេស។

២. ជំរុញការសិក្សាចងក្រងព័ត៌មាននិងទិន្នន័យមូលដ្ឋានសម្រាប់ការវាយតម្លៃអំពីឱនភាពដីកសិកម្ម ការកំណត់តំបន់ដាំដុះ ចំណាត់ថ្នាក់ដីដំណាំស្រូវ សំដៅតម្រង់ទិសការកសាងផែនការប្រើប្រាស់ធនធានដីកសិកម្ម សម្រាប់ការលើកកម្ពស់ប្រពលវប្បកម្ម និងពិពិធ-ភាវូបនីយកម្មកសិកម្មប្រកបដោយនិរន្តរភាព។

៣. ពង្រឹងសមត្ថភាពធន់ទ្រាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម តាមរយៈការលើកកម្ពស់ការសិក្សាស្រាវជ្រាវពីវិធានការបន្សាំនានា សម្រាប់ធានានិរន្តរភាពនៃប្រព័ន្ធផលិតកម្មកសិកម្ម ការកំណត់តំបន់ងាយរងគ្រោះដោយកត្តាធម្មជាតិនានាមានជាអាទិ៍ទឹកជំនន់ គ្រោះរាំងស្ងួត និងការជ្រៀតចូលនៃទឹកប្រៃ ដើម្បីជាមូលដ្ឋាននៃការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម។

៤. បន្តជំរុញការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម និងលិខិតបទដ្ឋានគតិយុត្តនិងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាឧបករណ៍ចង្អុលបង្ហាញផ្លូវនៃការអនុវត្តការងារ ចូលរួមធានានិរន្តរភាពនៃការប្រើប្រាស់ដីកសិកម្ម។

## ១.៣ អនុកម្មវិធីទី១.៣ ៖ ជំរុញការអភិវឌ្ឍដំណាំស្រូវ

**គោលបំណង ៖** "បង្កើនផលិតភាពដំណាំស្រូវ ដើម្បីធានាសន្តិសុខស្បៀង និងការនាំចេញអង្ករ តាមរយៈការអភិវឌ្ឍ និងការប្រើប្រាស់ពូជស្រូវមានគុណភាពល្អ និងបច្ចេកទេសសមស្របប្រកបដោយប្រសិទ្ធភាព"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. អត្រាគ្រួសារកសិករប្រើប្រាស់ពូជស្រូវសុទ្ធ | % | ២០ | ២៥ | ៣០ | ៣៥ | ៣៨ | ៤០ |
| ២. ទិន្នផលស្រូវកើនឡើង | តោន/ហត | ៣,១៦ | ៣,១៧ | ៣,១៨ | ៣,២១ | ៣,២៣ | ៣,២៥ |

**គម្រោងសកម្មភាព៖**

១. សិក្សាស្រាវជ្រាវ អភិវឌ្ឍ ផលិត និងផ្សព្វផ្សាយពូជស្រូវ ដែលមានសក្តានុពល និងទិន្នផលខ្ពស់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនិងតម្រូវការទីផ្សារ។

២. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកទេសផលិតកម្មដំណាំស្រូវ ស្របតាមប្រព័ន្ធកេរ្យត្របរិស្ថាននីមួយៗ សំដៅជំរុញផលិតកម្ម លើកកម្ពស់គុណភាពផលិតផល និងប្រសិទ្ធភាពសេដ្ឋកិច្ច។

៣. រៀបចំចងក្រងឯកសារបច្ចេកទេស និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករអំពីបច្ចេកទេសផលិតកម្មដំណាំស្រូវ និងបច្ចេកទេសក្រោយពេលប្រមូលផល សំដៅពង្រឹងសមត្ថភាពអនុវត្តការដាំដុះ ឱ្យទទួលបានទិន្នផលខ្ពស់ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងរក្សាគុណភាពផលិតផល សំដៅងាយស្រួលរកទីផ្សារ និងទទួលបានតម្លៃខ្ពស់។

៤. កសាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីជំរុញផលិតកម្មស្រូវ និងការត្រួតពិនិត្យគុណភាព ស្របតាមស្តង់ដារជាតិនិងអន្តរជាតិ។

៥. អង្កេត វិភាគទិន្នន័យ និងរៀបចំវេទិកាផ្លាស់ប្តូរបទពិសោធន៍ ស្តីពីបច្ចេកទេស បញ្ហាប្រឈម និងដំណោះស្រាយក្នុងផលិតកម្ម និងវាយតម្លៃលទ្ធផលសម្រេចបាន។

## ១.៤ អនុកម្មវិធីទី១.៤ ៖ ជំរុញការអភិវឌ្ឍដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ

**គោលបំណង ៖** "បង្កើនផលិតភាពនិងផលិតកម្មដំណាំសាកវប្បកម្ម សម្រាប់តម្រូវការក្នុងស្រុកនិងការនាំចេញ តាមរយៈការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាដំណាំសាកវប្បកម្ម ទទួលបានទិន្នផលខ្ពស់ ធន់ទ្រាំនឹងសមាសភាពចង្រៃ និងបន្សុាំការប្រែប្រួលអាកាសធាតុ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ផ្ទៃដីផលិតកម្មដំណាំបន្លែ | ពាន់ហ.ត | ៥២ | ៥៥ | ៥៨ | ៦១ | ៦៤ | ៦៧ |
| ២. បរិមាណផលបន្លែ | ពាន់តោន | ៤២៣ | ៤៤៤ | ៤៦៦ | ៤៨៩ | ៥១៣ | ៥៣៩ |
| ៣. ផ្ទៃដីផលិតកម្មដំណាំឈើហូបផ្លែ | ពាន់ហ.ត | ៧៩ | ៨៣ | ៨៧ | ៩១ | ៩៦ | ១០១ |

**គម្រោងសកម្មភាព៖**

១. សិក្សាស្រាវជ្រាវ អភិវឌ្ឍ ផលិត និងផ្សព្វផ្សាយពូជដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ ដែលមានសក្ដានុពល និងទិន្នផលខ្ពស់ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងតម្រូវការទីផ្សារ។

២. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកទេសផលិតកម្មសាកវប្បកម្ម និងដំណាំរួមផ្សំ សមស្របតាមប្រព័ន្ធកេ្សត្របរិស្ថាននីមួយៗ សំដៅជំរុញផលិតភាព ពិពិធភាវូបនីយកម្ម លើកកម្ពស់គុណភាពផលិតផល និងប្រសិទ្ធភាពសេដ្ឋកិច្ច។

៣. រៀបចំឯកសារបច្ចេកទេស និងបណ្តុះបណ្តាលបច្ចេកទេសដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករ អំពីបច្ចេកទេសផលិតកម្ម ផលិតកម្មពូជដំណាំរួមផ្សំ ការអនុវត្តកសិកម្មល្អ ការគ្រប់គ្រងក្រោយពេលប្រមូលផល សំដៅជំរុញទំនើបកម្មនៃផលិតកម្មសាកវប្បកម្ម និងដំណាំរួមផ្សំ ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងផលិតភាពស្របតាមស្តង់ដារគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម។

៤. កសាងនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាឧបករណ៍ចង្អុលបង្ហាញផ្លូវនៃការអភិវឌ្ឍសាកវប្បកម្មនិងដំណាំរួមផ្សំ។

## ១.៥ អនុកម្មវិធីទី១.៥ ៖ ជំរុញការអភិវឌ្ឍដំណាំឧស្សាហកម្ម

**គោលបំណង ៖** "បង្កើនផលិតភាពដំណាំឧស្សាហកម្ម ដើម្បីគាំទ្រដល់ការកែច្នៃក្នុងស្រុក និងការនាំចេញ តាមរយៈ ការស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្សព្វផ្សាយបច្ចេកទេស"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ផលិតកម្មដំណាំឧស្សាហកម្ម | ពាន់ហ.ត | ៨៣២ | ៨៥៧ | ៨៨១ | ៩០៥ | ៩២៩ | ៩៥៤ |
| ២. បរិមាណផលដំណាំឧស្សាហកម្ម | លានតោន | ៩,៨ | ១០,២ | ១០,៥ | ១០,៩ | ១១,៣ | ១១,៧ |

**គម្រោងសកម្មភាព៖**

១. សិក្សាស្រាវជ្រាវ អភិវឌ្ឍ ផលិត និងផ្សព្វផ្សាយពូជដំណាំឧស្សាហកម្ម ដែលមានសក្តានុពល និងទិន្នផលខ្ពស់ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងតម្រូវការទីផ្សារ។

២. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកទេសផលិតកម្មដំណាំឧស្សាហកម្ម សមស្របតាមប្រព័ន្ធកសិកម្ម (ស្រែ ចម្ការ ទីទួល ...) ភាពសុខកម្ម ពិពិធភាវូបនីយកម្ម គុណភាពផលិតផល និងប្រសិទ្ធភាពសេដ្ឋកិច្ច។

៣. រៀបចំឯកសារបច្ចេកទេស និងបណ្តុះបណ្តាលបច្ចេកទេសដំណាំឧស្សាហកម្ម ដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករ អំពីបច្ចេកទេសផលិតកម្ម និងការគ្រប់គ្រងក្រោយពេលប្រមូលផលដំណាំឧស្សាហកម្ម ផលិតកម្មពូជដំណាំឧស្សាហកម្ម ការគ្រប់គ្រងក្រោយពេលប្រមូលផល ការអនុវត្តកសិកម្មល្អ សំដៅជំរុញទំនើបកម្មនៃផលិតកម្មដំណាំឧស្សាហកម្មប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងផលិតភាពស្របតាមស្តង់ដារគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម។

៤. កសាងនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនិងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាឧបករណ៍ចង្អុលបង្ហាញផ្លូវនៃការអភិវឌ្ឍ និងគ្រប់គ្រងផលិតកម្មដំណាំឧស្សាហកម្ម។

## ១.៦ អនុកម្មវិធីទី១.៦ ៖ ជំរុញការអភិវឌ្ឍគ្រឿងយន្តកសិកម្ម

**គោលបំណង** ៖ "បង្កើនការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម ប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ធានាសុវត្ថិភាពស្បៀង និងបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ការរៀបចំដីដោយគ្រឿងយន្តកសិកម្ម | ភាគរយ | ៦០ | ៦៥ | ៧០ | ៧៥ | ៨០ | ៨៥ |
| ២. ការប្រមូលផលស្រូវដោយគ្រឿងយន្តកសិកម្ម | ភាគរយ | ៧ | ១០ | ១៥ | ២០ | ២៥ | ៣០ |

**គម្រោងសកម្មភាព៖**

១. សិក្សាស្រាវជ្រាវ កែច្នៃ ផលិតសាកពិសោធន៍ និងកែលម្អគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម ទ្រទ្រង់ខ្សែសង្វាក់ផលិតកម្ម និងកែច្នៃផលិតផលឱ្យសមស្របទៅតាមប្រភេទមុខដំណាំ លក្ខខណ្ឌដី ស្ថានភាពភូមិសាស្ត្រ និងលទ្ធភាពទទួលយកបានរបស់អ្នកប្រើប្រាស់។

២. អប់រំនិងផ្សព្វផ្សាយស្តីពីបច្ចេកទេសប្រើប្រាស់ និងថែទាំគ្រឿងយន្តនិងឧបករណ៍កសិកម្ម ដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករ តាមរយៈសកម្មភាពបណ្តុះបណ្តាល ធ្វើបង្ហាញ និងកិច្ចអន្តរាគមន៍ផ្នែកគ្រឿងយន្តកសិកម្មនានា។

៣. កែលម្អប្រព័ន្ធដីស្រែចំការ និងប្រព័ន្ធគ្រប់គ្រងបញ្ចេញបញ្ចូលទឹកក្នុងស្រែ ឱ្យស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីបង្កើនផលិតភាព និងផលចំណេញនៅក្នុងផលិតកម្ម និងភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

៤. កសាងនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាមូលដ្ឋានសម្រាប់តម្រង់ទិសការអភិវឌ្ឍ និងគ្រប់គ្រងយន្តូបនីយកម្មកសិកម្ម។

## ១.៧ អនុកម្មវិធីទី១.៧៖ ជំរុញការអភិវឌ្ឍការងារការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

**គោលបំណង ៖** "កាត់បន្ថយការបាត់បង់ទិន្នផលដំណាំ ធានាគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងសម្រួលការនាំចេញ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. អត្រាសង្គ្រោះពីការរាតត្បាត | % | ៥០ | ៧០ | ៧៥ | ៨០ | ៨៥ | ៩០ |
| ២. បរិមាណនៃការទទួលយកកសិផលលើទីផ្សារអន្តរជាតិ | ពាន់តោន | ២.៩០០ | ៣.១៩០ | ៣.៤៨០ | ៣.៧៧០ | ៤.០៦០ | ៤.៣៥០ |

**គម្រោងសកម្មភាព៖**

១. សិក្សាស្រាវជ្រាវ ចងក្រងបញ្ជីឈ្មោះសមាសភាពចង្រៃ និងអភិវឌ្ឍន៍វិធានការគ្រប់គ្រង និងកម្ចាត់សមាសភាពចង្រៃលើដំណាំនិងផលិតផលស្តុក។

២. លើកកម្ពស់ចំណេះដឹងស្តីពីបច្ចេកទេសការពារដំណាំនិងភូតគាមអនាម័យដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករ តាមរយៈសកម្មភាពបណ្តុះបណ្តាល ការធ្វើបង្ហាញ និងកិច្ចអន្តរាគមន៍នានា។

៣. លើកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម តាមរយៈការកសាងសមត្ថភាពស្តីពីការអនុវត្តកសិកម្មល្អ និងការតាមដាននិងវាយតម្លៃ សក្តានុពលហានិភ័យ។

៤. ទប់ស្កាត់ហានិភ័យនានា ពាក់ព័ន្ធនឹងការរាតត្បាតសមាសភាពចង្រៃផ្សេងៗ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយជំរុញការវិភាគតាមដាននិងវាយតម្លៃលើទំនិញ និង

ផលិតផលកសិកម្មនាំចូល ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដោយអនុលោមតាមបទដ្ឋាននៃវិធានភូតគាមអនាម័យជាធរមាន។

៥. កសាងនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាមូលដ្ឋានសម្រាប់តម្រង់ទិសការអភិវឌ្ឍ និងគ្រប់គ្រងការការពាររុក្ខជាតិនិងភូតគាមអនាម័យ។

## ១.៨ អនុកម្មវិធីទី១.៨ ៖ ពង្រឹងនិងកែលម្អប្រព័ន្ធនិងសេវាផ្សព្វផ្សាយកសិកម្ម

**គោលបំណង ៖** "ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធ និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងជំរុញកំណើននៃការទទួលយកទៅអនុវត្តរបស់កសិករប្រកបដោយប្រសិទ្ធភាព"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. អត្រានៃគ្រួសារកសិករដែលទទួលបានសេវាផ្សព្វផ្សាយកសិកម្ម | % | ២៥ | ២៨ | ៣០ | ៣៥ | ៣៨ | ៤០ |
| ២. ចំនួននៃភ្នាក់ងារផ្សព្វផ្សាយកសិកម្មត្រូវបានពង្រឹងសមត្ថភាព | នាក់ | ១០.៥០០ | ១១.១០០ | ១១.៧០០ | ១២.៣០០ | ១២.៩០០ | ១៣.៥០០ |

**គម្រោងសកម្មភាព៖**

១. ពង្រឹងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម ដោយធ្វើការរៀបចំពង្រឹងស្ថាប័នផ្សព្វផ្សាយកសិកម្ម និងក្របខណ្ឌច្បាប់ ធ្វើការត្រួតពិនិត្យនិងវាយតម្លៃសេវាកម្មផ្សព្វផ្សាយកសិកម្ម និងប្រសិទ្ធភាពនៃការទទួលយកសេវាផ្សព្វផ្សាយកសិកម្ម និងកសាងមូលដ្ឋានទិន្នន័យវិភាគប្រព័ន្ធកេ្សត្របរិស្ថាន និងស្ថានភាពសេដ្ឋកិច្ចគ្រួសារកសិករ។

២. ពង្រឹងនិងពង្រីកមូលដ្ឋានធនធានមនុស្ស ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សំដៅពង្រីកសេវាផ្សព្វផ្សាយកសិកម្ម ឱ្យដល់សហគមន៍ផលិតកម្មនៅទូទាំងប្រទេស តាមរយៈការបង្កើតគោលការណ៍ និងសៀវភៅណែនាំអំពីការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម សកម្មភាពបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ជាពិសេសភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ឃុំ-សង្កាត់។

៣. ពង្រីកវិសាលភាពនៃការទទួលបានព័ត៌មានបច្ចេកទេសកសិកម្មនិងសេវាពាក់ព័ន្ធផ្សេងៗ តាមរយៈការបង្កើត និងចងក្រងបង្គុំបច្ចេកវិទ្យាកសិកម្ម ផលិតផ្សព្វផ្សាយឯកសារបច្ចេកទេសកសិកម្ម សកម្មភាពបណ្តុះបណ្តាល ធ្វើបង្ហាញ និងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈផ្សេងៗ។

## ១.៩ អនុកម្មវិធីទី១.៩ ៖ លើកកម្ពស់ការអភិវឌ្ឍសហគមន៍កសិកម្ម

**គោលបំណង** ៖ "បង្កើតនិងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ឲ្យមានប្រសិទ្ធភាពក្នុងប្រព័ន្ធខ្សែសង្វាក់ផលិតកម្មកសិកម្មនិងទីផ្សារ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនសហគមន៍កសិកម្មត្រូវបានបង្កើតនិងចុះបញ្ជី | សហគមន៍ | ៤៨០ | ៥៥០ | ៥៨០ | ៦០០ | ៦២០ | ៦៤០ |
| ២. ថ្នាក់ដឹកនាំ និងសមាជិកសហគមន៍កសិកម្ម ត្រូវបានពង្រឹងសមត្ថភាព | នាក់ | ១.៧៥៦ | ៣.៨៤៧ | ៥.៥៩៧ | ៧.៤៧២ | ៩.៦៧២ | ១២.០៧២ |
| ៣. ចំនួនសហគមន៍កសិកម្មត្រូវបានក្លាយជាសហគ្រាសសេដ្ឋកិច្ចកសិកម្មមានការដំណើរការល្អនិងរីកចម្រើន | សហគមន៍ | ២ | ៤ | ៦ | ៨ | ១០ | ១២ |

**គម្រោងសកម្មភាព៖**

១. ជំរុញការបង្កើតនិងចុះបញ្ជីសហគមន៍កសិកម្ម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្តុំ ក្នុងភាពជាដៃគូជាមួយផ្នែកឯកជននានា ដើម្បីទទួលបានទាំងបច្ចេកវិទ្យាថ្មីនិងឥណទាន និងធានាស្ថេរភាពនៃការផ្គត់ផ្គង់ផលិតផលទៅកាន់ទីផ្សារក្នុងស្រុកនិងក្រៅស្រុក។

២. អភិវឌ្ឍន៍សហគមន៍កសិកម្មឱ្យក្លាយជាសហគ្រាសសេដ្ឋកិច្ចកសិកម្មជនបទ ដោយបង្កលក្ខណៈងាយស្រួលជូនសមាជិកសហគមន៍ ក្នុងការទទួលបាននូវឱកាសពង្រឹងសមត្ថភាពលើការងារដឹកនាំនិងគ្រប់គ្រងសហគមន៍ ការរៀបចំផែនការធុរកិច្ច ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ការចុះបញ្ជីគណនេយ្យ ការផ្គត់ផ្គង់ធាតុចូលកសិកម្ម ទីផ្សារកសិកម្ម តាមរយៈការចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកាជាតិនិងអន្តរជាតិផ្សេងៗ។

៣. ជំរុញការអភិវឌ្ឍន៍ការងារជំនួញរបស់សហគមន៍កសិកម្ម តាមរយៈការរៀបចំវេទិកាធុរកិច្ច ការរៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ និងការធ្វើទស្សនកិច្ចសិក្សា។ល។ ដើម្បីធ្វើឱ្យសហគមន៍កសិកម្មអាចបង្កើតដៃគូជំនួញ និងបង្កើនអំណាចចរចាថ្លៃទីផ្សារ ដែលនាំទៅដល់ការបង្កើនប្រាក់ចំណូលគ្រួសារកសិករ។

៤. ផ្សព្វផ្សាយច្បាប់ស្តីពីសហគមន៍កសិកម្មឱ្យបានទូលំទូលាយ និងកសាងគោលនយោបាយលិខិតបទដ្ឋានគតិយុត្ត និងយន្តការពាក់ព័ន្ធ ដើម្បីជំរុញអនុវត្តច្បាប់ស្តីពីសហគមន៍កសិកម្មឱ្យបានពេញលេញ។

## ១.១០ អនុកម្មវិធីទី១.១០ ៖ ពង្រឹងនិងអភិវឌ្ឍសមត្ថភាពមន្ទីរពិសោធន៍ជាតិកសិកម្ម

**គោលបំណង** ៖ "លើកកម្ពស់សមត្ថភាពការផ្តល់សេវាកម្មវិភាគ និងត្រួតពិនិត្យគុណភាពដី ជី ទឹក ថ្នាំកសិកម្ម សំណល់គីមីកសិកម្ម និងជីវបច្ចេកវិទ្យា ដើម្បីរួមចំណែកបង្កើនផលិតភាពកសិកម្ម គុណភាព និងសុវត្ថិភាពកសិផល សម្រាប់ប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនសំណាកដែលត្រូវវិភាគ | សំណាក | ៥៥០ | ៦០៥ | ៦៦៥ | ៧៣១ | ៨០៤ | ៨៨៤ |
| ២. ចំនួនវិធីសាស្ត្រ/នីតិវិធីវិភាគត្រូវផលិត | ចំនួនឯកសារ | ៣៤ | ៣៧ | ៤០ | ៤៣ | ៤៦ | ៤៩ |

**គម្រោងសកម្មភាព៖**

១. ពង្រឹងនិងពង្រីកសមត្ថភាពសេវាពិសោធន៍វិភាគគ្រប់ផ្នែកជំនាញ ដោយចងក្រងឯកសារពិធីសារវិភាគពាក់ព័ន្ធស្របតាមបទដ្ឋានស្តង់ដារអន្តរជាតិ សម្រាប់ជាមូលដ្ឋានវិទ្យាសាស្ត្រនៃដំណើរការពិសោធន៍វិភាគ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី។

២. ផ្តល់ការគាំទ្រសេវាសាធារណៈសម្រាប់ការពិសោធន៍ វិភាគគុណភាពលើធាតុចូលកសិកម្មផ្សេងៗ ដើម្បីជាមូលដ្ឋាននៃការសម្រេចចិត្តត្រឹមត្រូវ ក្នុងការប្រើប្រាស់ធាតុចូលសម្រាប់ការអភិវឌ្ឍផលិតកម្មកសិកម្ម។

៣. សិក្សាអង្កេត និងវិភាគគុណភាពថ្នាំនិងជីកសិកម្ម និងហានិភ័យនៃថ្នាំកសិកម្ម នៅលើបន្លែនិងផ្លែឈើ។

៤. រៀបចំនិងកសាងលិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ទីរពិសោធន៍ជាតិកសិកម្ម។

## ១.១១ អនុកម្មវិធីទី១.១១ ៖ ជំរុញការវិនិយោគនិងអភិវឌ្ឍន៍ដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់និងចីរភាព

**គោលបំណង** ៖ "បង្កើនសមត្ថភាពបច្ចេកទេសក្នុងការអភិវឌ្ឍដំណាំកៅស៊ូ សំដៅបង្កើនបរិមាណនិងគុណភាពកៅស៊ូ ពង្រឹងសមត្ថភាពសហគមន៍កសិករកៅស៊ូ និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ដីកៅស៊ូប្រកបដោយនិរន្តរភាព"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ផ្ទៃដីកៅស៊ូ | ពាន់ហិកតា | ៣២៨,៧៧ | ៣៣៤,៣៥ | ៣៦២,៣៥ | ៣៨៤,៣៥ | ៤០៤,៣៥ | ៤២២,៣៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២. ផ្ទៃដីកៅស៊ូចៀរជ័រ | ពាន់ហិកតា | ៧៨,៤៩ | ១១០,០៥ | ១៤១,៦០ | ១៨៣,៦០ | ២២០,៥០ | ២៨០,៥០ |
| ៣. ផលិតផលកៅស៊ូ | ពាន់តោន | ៨៥,២៤ | ១២១,៥៣ | ១៥៧,១០ | ២០៦,៥០ | ២៦២,៥០ | ៣៣៣,០៧ |

**គម្រោងសកម្មភាព៖**

១. បណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ។

២. ផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ។

៣. ស្រង់ស្ថិតិនិងកំណត់ទីតាំងចម្ការកៅស៊ូគ្រួសារ។

៤. បណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់មន្ត្រីបង្គោល។

៥. ពង្រឹងនិងចងក្រងសមាគមឬសហគមន៍កសិករកៅស៊ូគ្រួសារ។

៦. ផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូតាមទូរទស្សន៍។

៧. សិក្សានិងកំណត់ទីតាំងដីកបនឹងដំណាំកៅស៊ូ។

៨- សិក្សាវាយតម្លៃលើលទ្ធផលនិងប្រសិទ្ធភាពនៃវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាល។

៩- សិក្សាអង្កេតលក្ខណៈសម្បត្តិ (Profile) របស់ចម្ការកៅស៊ូគ្រួសារ។

១០- ផលិតនិងបោះពុម្ពផ្សាយឯកសារបច្ចេកទេសកៅស៊ូ។

## ១.១២ អនុកម្មវិធីទី១.១២ ៖ ជំរុញខ្សែចង្វាក់តម្លៃកៅស៊ូឱ្យបានល្អ

**គោលបំណង ៖** "ពង្រឹងនិងជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ស្តីពីទីផ្សារកៅស៊ូ ដើម្បីបង្កើនប្រាក់ចំណូលដល់កសិករកៅស៊ូគ្រួសារ សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១-អត្រានៃប្រាក់ចំណូលកសិករកៅស៊ូគ្រួសារទទួលបាន | (%) | ៧០ | ៧២ | ៧៤ | ៧៦ | ៨០ | ៨០ |
| ២-ចំនួនកសិករកៅស៊ូគ្រួសារត្រូវបានបណ្តុះបណ្តាលទីផ្សារកៅស៊ូ | នាក់ | ៩០ | ១៨០ | ២០០ | ២៥០ | ៣០០ | ៣៥០ |

**គម្រោងសកម្មភាព៖**

១- បណ្តុះបណ្តាលនិងផ្សព្វផ្សាយ អំពីទីផ្សារកៅស៊ូដល់សហគមន៍កៅស៊ូគ្រួសារ ឱ្យបង្កើតមជ្ឈមណ្ឌលលក់ដូរកៅស៊ូរួម។

២- ផ្តល់ព័ត៌មានពីការផ្គត់ផ្គង់ តម្រូវការ និងតម្លៃកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ។

៣- បង្កើតនិងគ្រប់គ្រងគេហទំព័រព័ត៌មានកៅស៊ូ។

### ១.១៣ អនុកម្មវិធីទី១.១៣ ៖ លើកកម្ពស់គុណភាពផលិតផលកៅស៊ូ

**គោលបំណង៖** "ពង្រឹងសមត្ថភាពកែច្នៃសំដៅបង្កើនទាំងបរិមាណនិងគុណភាពផលិតផលកៅស៊ូស្របតាមបទដ្ឋានបច្ចេកទេសកែច្នៃ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១-ប្រតិបត្តិករកៅស៊ូទទួលបានការបណ្តុះបណ្តាលពីបច្ចេកទេសកែច្នៃ | នាក់ | - | ៤០ | ២៤០ | ៣៧០ | ៤២០ | ៤៧០ |
| ២-អត្រាគុណភាពផលិតផលកៅស៊ូកើនឡើង | (%) | ៧១ | ៧៣ | ៧៥ | ៧៦ | ៧៨ | ៨០ |

**គម្រោងសកម្មភាព៖**

១- ស្រង់ស្ថិតិរោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូ។

២- ផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ។

៣- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក (USS) ដល់សហគមន៍កៅស៊ូគ្រួសារ។

៤- បង្កើតមណ្ឌលបង្ហាញការកែច្នៃកៅស៊ូសន្លឹក (USS) រួម។

### ១.១៤ អនុកម្មវិធីទី១.១៤៖ លើកកម្ពស់ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្សក្នុងផ្នែកកៅស៊ូ

**គោលបំណង ៖** "បង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពាក់ព័ន្ធនឹងផ្នែកកៅស៊ូ និងបង្កើនសមត្ថភាពជំនាញរបស់ប្រតិបត្តិករកៅស៊ូ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ប្រតិបត្តិករកៅស៊ូទទួលបានការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តអំពីកៅស៊ូ | នាក់ | ២០០ | ៣០០ | ៣៥០ | ៤០០ | ៤៥០ | ៥០០ |
| ២. ប្រតិបត្តិករកៅស៊ូទទួលបានការបណ្តុះបណ្តាល និងបង្កើនសមត្ថភាពជំនាញ | នាក់ | - | - | ២០ | ២០ | ២០ | ២០ |

**គម្រោងសកម្មភាព៖**

១-សម្របសម្រួលរវាងម្ចាស់ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម និងម្ចាស់ចម្ការកៅស៊ូគ្រួសារ។

២-រៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងលិខិតបទដ្ឋានក្រោមច្បាប់។

៣-ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់ផ្នែកកៅស៊ូ។

៤-បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ។

៥- សិក្សាពីតម្រូវការធនធានមនុស្សនិងកម្លាំងពលកម្មក្នុងផ្នែកកៅស៊ូ។

៦- ពិនិត្យ វាយតម្លៃលើលទ្ធផលនិងប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធដល់ផ្នែកកៅស៊ូ។

## ១.១៥ អនុកម្មវិធីទី១.១៥ ៖ ពង្រឹងការងាររដ្ឋបាល និងអភិបាលកិច្ចក្នុងផ្នែកកៅស៊ូ

**គោលបំណង ៖** "បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងអភិបាលកិច្ចល្អក្នុងផ្នែកកៅស៊ូ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១-ប្រសិទ្ធភាពនៃការអនុវត្តថវិកា | (%) | ៨៩ | ៩០ | ៩២ | ៩៣ | ៩៤ | ៩៥ |
| ២-បណ្តុះបណ្តាលមន្ត្រីពីការងារគ្រប់គ្រង និងអភិបាលកិច្ច | វគ្គ | - | ០១ | ០២ | ០២ | ០២ | ០២ |

**គម្រោងសកម្មភាព៖**

១- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកា។

២- បណ្តុះបណ្តាលការរៀបចំនិងគ្រប់គ្រងអនុកម្មវិធី។

៣- រៀបចំសន្និបាត/ប្រជុំបូកសរុបប្រចាំឆ្នាំ។

៤- តាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូ និងវាយតម្លៃលទ្ធផលដែលសម្រេចបាន។

៥- គាំទ្រការសម្របសម្រួលការងារកិច្ចការរដ្ឋបាល។

៦- តាមដានត្រួតពិនិត្យដំណើរការរបស់ស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ។

៧- សិក្សាអង្កេតលក្ខណ:សម្បត្តិ (Profile) របស់ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម។

## ១.១៦ អនុកម្មវិធីទី១.១៦៖ លើកកម្ពស់គុណភាពពូជកៅស៊ូថ្មី និងប្រសិទ្ធភាពគុណភាព ផលិតផលកៅស៊ូកម្ពុជា

**គោលបំណង ៖** "ធ្វើឲ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការប្រើប្រាស់ពូជកៅស៊ូថ្មី បន្សាំបាននឹងការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យផលិតផលកៅស៊ូកម្ពុជាមានគុណភាព ប្រកួតប្រជែង និងមានតម្លៃខ្ពស់លើទីផ្សារអន្តរជាតិ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១. អត្រា (%) នៃការត្រួតពិនិត្យនិងផ្តល់វិញ្ញាបនបត្រច្បារពូជ | % | ១០ | ២០ | ៣០ | ៤០ | ៥០ |
| ២. អត្រា (%) នៃការចុះបញ្ជិការោងចក្រយថាប្រភេទកៅស៊ូកម្ពុជា (CSR) | % | ១០ | ១៥ | ២០ | ២៥ | ៣០ |
| ៣. ចំនួនកសិករទទួលបាននូវការបណ្តុះបណ្តាល | នាក់ | ២០០ | ៤០០ | ៦០០ | ៨០០ | ១.០០០ |

**គម្រោងសកម្មភាព៖**

១. រៀបចំច្បារបង្កាត់ពូជថ្មី ថែទាំ និងបង្កាត់ពូជ។
២. បង្កើតចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំចំនួនពីរកន្លែង។
៣. តាមដានការលូតលាស់និងស្រង់ទិន្នន័យចម្ការពិសោធន៍ប្រាំតំបន់។
៤. គ្រប់គ្រងថែទាំច្បារពូជក្នុងស្ថានីយអនុវត្ត។
៥. គ្រប់គ្រង ថែទាំកៅស៊ូមិនទាន់ឲ្យផល និងថ្នាលបណ្តុះកូនកៅស៊ូក្នុងស្ថានីយអនុវត្ត។
៦. ស្រាវជ្រាវការប្រើប្រាស់ជីលើកៅស៊ូមិនទាន់ឲ្យផល និងកៅស៊ូឲ្យផល។
៧. បន្តការតាមដានលទ្ធផលចម្ការពិសោធន៍។
៨. ផ្សព្វផ្សាយបច្ចេកទេសដាំដុះថ្មី ថែទាំកៅស៊ូ និងព្យាបាល ជំងឺកៅស៊ូគ្រប់ប្រភេទដល់កសិករ។
៩. ពិសោធន៍ស្រាវជ្រាវលើគុណភាពដីសម្រាប់ដំណាំកៅស៊ូ។
១០. តាមដានលើប្រព័ន្ធចង្វាក់ចៀរជ័ររង្វើល លក្ខខណ្ឌក្នុងស្ថានីយអនុវត្ត។
១១.វិភាគសរីរៈទឹកជ័រកៅស៊ូចំការពិសោធន៍នានាក្នុងស្ថានីយអនុវត្ត លើការវិភាគអំពីអញ្ញត្តិ។
១២. បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសប្រមូលផលទឹកជ័រ។
១៣. ធ្វើតេស្តបញ្ជាក់គុណភាពកៅស៊ូអន្តរមន្ទីរពិសោធន៍ជាមួយសមាគមកៅស៊ូអន្តរជាតិ។
១៤. រៀបចំនិងធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក។
១៥. ចុះត្រួតពិនិត្យរោងចក្រ CSR និង Lab CSR។
១៦. ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យទទួលស្គាល់តាមស្តង់ដារអន្តរជាតិ ISO/IEC17025។
១៧. ចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។
១៨. វិភាគទាន IRRDB និងធ្វើសំណាកជ័រ។

## ១.១៧ អនុកម្មវិធីទី១.១៧ ៖ ជំរុញនិងលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម

**គោលបំណង ៖** "បង្កើតការងារ បង្កើនតម្លៃបន្ថែម និងជំរុញការឈានចូលទីផ្សារនៃផលិតផលកសិកម្មតាមរយៈការបង្កើនសមត្ថភាពជំនាញកសិឧស្សាហកម្ម ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការលើកកម្ពស់គុណភាព សុវត្ថិភាពនៃផលិតផលកសិកម្ម"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១.កសិករ និងអ្នកពាក់ព័ន្ធត្រូវបានបណ្តុះបណ្តាលបច្ចេកទេសកសិ-ឧស្សាហកម្ម | នាក់ | ១.១១០ | ១.១១០ | ១.៥០០ | ១.៧៥០ | ២.០០០ | ២.២៥០ |
| ២.ចំនួនសហគ្រាសកែច្នៃផលិតផលកសិកម្មបានកើនឡើង | % | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| ៣.បរិមាណនៃផលិតផលកសិកម្មចូលទៅកាន់ទីផ្សារមានការកើនឡើង | % | ៥ | ១០ | ១០ | ១០ | ១០ | ១០ |

**គម្រោងសកម្មភាព៖**

១. ការបណ្តុះបណ្តាលអំពីបច្ចេកទេសកែច្នៃផលិតផលកសិកម្ម។
២. ការបណ្តុះបណ្តាលអំពីស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម។
៣. ការបណ្តុះបណ្តាលអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យានិងក្របខណ្ឌគតិយុត្ត។
៤. ការបណ្តុះបណ្តាលអំពីបច្ចេកទេសក្រោយពេលប្រមូលផលនៃផលិតផលកសិកម្ម។
៥. ការសម្របសម្រួលការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា រវាងភាគីអ្នកផលិត (ក្រុមកសិករ) និងភាគីអ្នកទិញ (ក្រុមហ៊ុន)។
៦. ពង្រឹងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។
៧. កសាងមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសកសិ-ឧស្សាហកម្ម។
៨. ធ្វើបច្ចុប្បន្នភាពទិន្នន័យសហគ្រាសកសិ-ឧស្សាហកម្ម។
៩. ការចងក្រងសហគមន៍កសិ-ឧស្សាហកម្ម។
១០. កសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងការផ្សព្វផ្សាយ។
១១. អនុវត្តល្អលើបច្ចេកទេសប្រមូលផល ការដឹកជញ្ជូន ការសម្ងួត ការរក្សាទុកផលិតផលកែច្នៃ និងវេចខ្ចប់ ក្នុងការចូលរួមកាត់បន្ថយការប្រែប្រួលអាកាសធាតុ។
១២. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាសមស្រប ផ្នែកក្រោយពេលប្រមូលផល ផ្នែកកែច្នៃ និងវេចខ្ចប់ផលិតផលកសិកម្ម ក្នុងការចូលរួមកាត់បន្ថយការបាត់បង់ ទាំងបរិមាណ និងគុណភាព និងការបំភាយឧស្ម័នផ្ទះកញ្ចក់តិច។
១៣. គ្រប់គ្រង និងប្រើប្រាស់សំណល់កសិកម្ម និងកសិ-ឧស្សាហកម្មគ្រប់ប្រភេទ និងកែច្នៃសំណល់កសិកម្ម ជាប្រភពថាមពលជីធម្មជាតិនិងចំណីសត្វ ដើម្បីចូលរួមកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់តិច។
១៤. បណ្តុះបណ្តាលបច្ចេកវិទ្យាសមស្រប ដែលមានការបំភាយឧស្ម័នផ្ទះកញ្ចក់តិច ដល់សហគ្រាសវិនិយោគកសិ-ឧស្សាហកម្ម។
១៥. បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីមន្ទីរពិសោធន៍ លើការធ្វើវិភាគគុណភាព ផលិតផលកសិកម្ម។
១៦. ផ្គត់ផ្គង់ឧបករណ៍សម្ភារបរិក្ខា សម្រាប់កិច្ចដំណើរការមន្ទីរពិសោធន៍ វិភាគគុណភាព ផលិតផលកសិកម្ម។
១៧. ការគាំទ្រធានារ៉ាប់រងសុខភាពដល់មន្ត្រីមន្ទីរពិសោធន៍វិភាគគុណភាពផលិតផលកសិកម្ម។

## ១.១៨ អនុកម្មវិធីទី១.១៨៖ ការស្រាវជ្រាវដើម្បីលើកកម្ពស់ផលិតភាពដំណាំកសិកម្ម

**គោលបំណង៖** "ជំរុញការអភិរក្ស និងប្រើប្រាស់ពន្ធុរុក្ខជាតិ ការបង្កើតពូជដំណាំដែលបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មានគុណភាពល្អ និងឆ្លើយតបទៅនឹងទីផ្សារ និងការស្រាវជ្រាវរកបច្ចេកវិទ្យាថ្មីៗ ក្នុងការប្រើប្រាស់ធាតុចូលកសិកម្ម ដើម្បីលើកកម្ពស់ផលិតភាពដំណាំកសិកម្ម" ។

**សូចនាករ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១២ ជាក់ស្តែង | ២០១៣ | ព្យាករណ៍តាមឆ្នាំ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
| ១. ចំនួនពូជដំណាំដែលត្រូវបានប្រមូលបន្ថែម | ចំនួនសំណាក | ៦.១៧១ | ២០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ២. ប្រភេទពូជដំណាំថ្មីៗដែលត្រូវបានបញ្ចេញ | ចំនួនពូជ | ៥០ | ១ | ២ | ១ | ២ | ១ | ៣ |
| ៣. បច្ចេកទេសថ្មីៗដែលត្រូវបានបង្កើត | ចំនួន | ៣២ | ៩ | ៧ | ៦ | ៧ | ១០ | ៩ |

**គម្រោងសកម្មភាព៖**

១. សមូហកម្ម អភិរក្សកម្ម (Genebank) វាយតម្លៃ និងប្រើប្រាស់ធនធានពន្ធុរុក្ខជាតិទាំងអស់ដែលមានគុណប្រយោជន៍ សម្រាប់ដំណាំស្បៀងនិងកសិកម្ម។

២. អភិវឌ្ឍពូជស្រូវទំនាបរំពឹងទឹកភ្លៀងដែលធន់នឹងកត្តាមិនអំណោយផលផ្នែកជីវៈ (Biotic stresses) និង អជីវៈ (Abiotic stresses) ព្រមទាំងមានទិន្នផលខ្ពស់ និងគុណភាពល្អ។

៣. អភិវឌ្ឍពូជស្រូវស្រាលមានទិន្នផលខ្ពស់ គុណភាពអង្ករល្អ ហើយធន់នឹងមមាចត្នោត (BPH) និង កម្តៅ។

៤. អភិវឌ្ឍពូជដំណាំពពួកសណ្តែក ល្ង ពោត ស្វាយ និង បន្លែដែលមានទិន្នផលខ្ពស់ និង គុណភាពល្អ។

៥. សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រ អំពីបច្ចេកទេសគ្រប់គ្រងដីប្រកបដោយនិរន្តរភាព និងកំណត់តម្រូវការសារធាតុចិញ្ចឹមរបស់ដំណាំសម្រាប់ប្រព័ន្ធផលិតកម្មដំណាំស្រូវ និងដំណាំដំឡូងមី។

៦. សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេកទេសប្រើប្រាស់ និងគ្រប់គ្រងទឹកស្រោចស្រពដំណាំ ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាន។

៧. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេកទេសគ្រប់គ្រងសមាសភាពចង្រៃ៖ ខ្យងពណ៌មាស ពពួកមមាច ជំងឺ និង ស្មៅលើដំណាំស្រូវតាមក្បែគ្របរិស្ថាន និងសត្វល្អិតលើដំណាំសណ្តែកសៀង។

៨. សិក្សាស្រាវជ្រាវ អភិវឌ្ឍបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេកទេសមុនប្រមូលផលដំណាំ ដែលឆ្លើយតបទៅនឹងបរិបទនៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម តាមរយៈការអភិវឌ្ឍឧបករណ៍ដាំគ្រាប់ស្ងួតសម្រាប់ដំណាំស្រូវ។
៩. សិក្សាស្រាវជ្រាវអំពីពេលវេលា និងវិធីសាស្ត្រប្រមូលផលដំណាំស្រូវ និង ពោតដោយកំបៃ (Combined harvester)។
១០.សិក្សាស្រាវជ្រាវពីកត្តាជះឥទ្ធិពលលើការវេចខ្ចប់បឋម និងដឹកជញ្ជូនសម្រាប់ដំណាំខាត់ណា ស្ពៃ និងចេក ប្រកបដោយគុណភាព និងសុវត្ថិភាព។
១១.សិក្សាស្រាវជ្រាវ និងអភិវឌ្ឍឧបករណ៍ប្រើប្រាស់ សម្រាប់ញែកគ្រាប់ស្រូវ និងសណ្តែកបាយ។
១២.សិក្សាវាយតម្លៃសមត្ថភាពសហគមន៍ជនបទ ក្នុងការទទួលយកនិងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ បញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។
១៣.សិក្សាវាយតម្លៃអំពីឥទ្ធិពលនៃការទទួលយក និងការប្រើប្រាស់បច្ចេកទេសថ្មីៗបញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ទៅលើសង្គមសេដ្ឋកិច្ចជនបទ។

## ១.១៩ អនុកម្មវិធីទី១.១៩៖ ការស្រាវជ្រាវដើម្បីលើកកម្ពស់ពិពិធកម្មដំណាំកសិកម្ម និងការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម

**គោលបំណង៖** "លើកកម្ពស់ការអភិវឌ្ឍបង្កុំបច្ចេកវិទ្យាពិពិធកម្មដំណាំស្រូវ ជាមូលដ្ឋានស្របតាមលក្ខខណ្ឌដាំដុះ និងសង្គមសេដ្ឋកិច្ចរបស់កសិករ និងជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម និងគ្រាប់ពូជដំណាំថ្មីៗ ដែលមានសក្តានុពលសម្រាប់ការដាំដុះនិងការនាំចេញ"។

**សូចនាករ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១២ ជាក់ស្តែង | ២០១៣ | ព្យាករណ៍តាមឆ្នាំ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
| ១. បង្កុំបច្ចេកវិទ្យាពិពិធកម្មដំណាំស្រូវជាមូលដ្ឋានត្រូវបានបញ្ចេញ | ចំនួន | ៣ | - | ២ | ១ | ១ | ១ | ១ |
| ២. កំណើនផ្ទៃដីដាំដុះដោយពូជស្រូវ និងបច្ចេកទេសថ្មីៗដែលបញ្ចេញដោយកាឌី | % | ៣០ | ២ | ២ | ២ | ២ | ២ | ២ |
| ៣. បរិមាណគ្រាប់ពូជដំណាំដែលមាន ភាពសុទ្ធខ្ពស់ និងគុណភាពល្អ | តោន | ៤៦ | ៥០ | ៥០ | ៥៥ | ៥៥ | ៦០ | ៦០ |

**គម្រោងសកម្មភាព៖**

១. អភិវឌ្ឍបង្កុំបច្ចេកវិទ្យាប្រព័ន្ធផលិតកម្មដំណាំស្រូវជាមូលដ្ឋាន ដែលមានលក្ខណៈសេដ្ឋកិច្ចនិងបរិស្ថាន សម្រាប់តំបន់ទំនាបរំពឹងទឹកភ្លៀង តំបន់ស្រោចស្រពពេញលេញ និងតំបន់ឆ្នេរ។

២. សិក្សាស្រាវជ្រាវអំពីកសិកម្មអភិរក្ស (Conservation Agriculture) សម្រាប់លក្ខខណ្ឌក្នុងប្រទេសកម្ពុជា។

៣. ជំរុញការចូលទីផ្សារនៃបច្ចេកវិទ្យាបញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាពិសេសពូជស្រូវ តាមរយៈការធ្វើកសិកម្មតាមកិច្ចសន្យាផលិតស្រូវ ក្រអូបផ្ការំដួល ផ្ការមៀត និង សែនពិដោរ។

៤. ជំរុញប្រព័ន្ធផលិតកម្ម និងការប្រើប្រាស់គ្រាប់ពូជដំណាំ ដែលបានបញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា។

៥. ធ្វើឲ្យកាន់តែប្រសើរឡើងនូវទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីបង្កើនការយល់ដឹងជាសាធារណៈ តាមរយៈការបោះពុម្ពផ្សាយ គេហទំព័រ និងមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត។

## ១.២០ អនុកម្មវិធីទី១.២០៖ បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍធនធានមនុស្ស ផ្នែកពិសោធន៍ស្រាវជ្រាវ

**គោលបំណង៖** "លើកកម្ពស់សមត្ថភាព និងទេពកោសល្យរបស់អ្នកគ្រប់គ្រង អ្នកស្រាវជ្រាវសេវាទ្រទ្រង់ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យា" ។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១២ ជាក់ស្តែង | ២០១៣ | ព្យាករណ៍តាមឆ្នាំ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
| ១. មន្ត្រីបញ្ចប់ការសិក្សាថ្នាក់ក្រោយឧត្តម និងនិកាសសិក្ខាកាមទទួលបានការបណ្តុះបណ្តាល | ចំនួន | ១២៨ | ១៣២ | ១០៥ | ១០៥ | ១០៥ | ១០៥ | ១០៥ |
| ២. ឯកសារវិទ្យាសាស្ត្របោះពុម្ពផ្សាយ (Internationally published scientific papers) | ប្រភេទ | ១៥០ | ១ | ២ | ៣ | ៥ | ៦ | ៧ |
| ៣. កំណើនប្រសិទ្ធភាពនៃប្រព័ន្ធទ្រទ្រង់ក្នុងការផ្តល់សេវាស្រាវជ្រាវដល់សេដ្ឋកិច្ច | % | ១០០ | ២ | ២ | ២ | ២ | ២ | ២ |

**គម្រោងសកម្មភាព៖**

១. បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង អភិបាលកិច្ច អភិវឌ្ឍន៍ធនធានមនុស្ស សេវាកម្មស្រាវជ្រាវ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីគាំទ្រដល់ការអភិវឌ្ឍរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ប្រកបដោយនិរន្តរភាព។

២. បង្កើនសមត្ថភាព និងទេពកោសល្យរបស់អ្នកស្រាវជ្រាវ និងអ្នកផ្សព្វផ្សាយ តាមរយៈការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស។

### ១.២១ អនុកម្មវិធីទី១.២១៖ ការបង្កើនផលិតភាពកសិកម្មរបស់មន្ទីរកសិកម្មរាជធានី ខេត្ត

អនុកម្មវិធីនេះ គឺជាការប្រមូលផ្តុំនូវចង្កោមសកម្មភាពទាំងអស់ របស់មន្ទីរកសិកម្មរាជធានី ខេត្តទាំង២៥សម្រាប់អនុវត្ត សំដៅចូលរួមចំណែកសម្រេចបាននូវគោលបំណង និងសូចនាករនៃកម្មវិធីទី-១ *"បង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម"*។

## ២. កម្មវិធីទី២ ៖ ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ

### ២.១ អនុកម្មវិធីទី២.១ ៖ អភិវឌ្ឍន៍ការចិញ្ចឹមសត្វនិងបង្កើនផលិតភាពសត្វ

**គោលបំណង** ៖ "អនុវត្តឲ្យល្អប្រសើរឡើងការចិញ្ចឹមសត្វនិងបង្កើនផលិតផលសត្វ"។

**សូចនាករ** ៖

| សូចនាករលទ្ធផល | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១.ចំនួនកសិដ្ឋានចិញ្ចឹមសត្វស្របតាមបទដ្ឋានបច្ចេកទេស | កន្លែង | - | - | ៣០ | ៦០ | ១០០ | ២០០ |
| ២.ចំនួនជ្រូកកើនឡើង២%ក្នុងមួយឆ្នាំ | លានក្បាល | ២,៤០ | ២,៤៥ | ២,៥០ | ២,៥៤ | ២,៦០ | ២,៦៥ |
| ៣.ចំនួនបក្សីកើនឡើង៤%ក្នុងមួយឆ្នាំ | លានក្បាល | ២៧,៣១ | ២៨,៣៩ | ២៩,៥២ | ៣០,៧០ | ៣១,៩០ | ៣៣,២០ |

**គម្រោងសកម្មភាព៖**

១. រៀបចំកែសម្រួល និងបោះពុម្ពឯកសារបទដ្ឋានបច្ចេកទេសចិញ្ចឹមសត្វតាមបច្ចេកទេសជីវសុវត្ថិភាពនៅតាមគ្រួសារ និងតាមគោលការណ៍ GAHP នៅកសិដ្ឋាន។

២. ផ្សព្វផ្សាយដល់មន្ត្រី អ្នកពាក់ព័ន្ធ លើឯកសារបទដ្ឋានបច្ចេកទេសចិញ្ចឹមសត្វ តាមបច្ចេកទេសជីវសុវត្ថិភាពនៅតាមគ្រួសារ និងតាមគោលការណ៍ GAHP នៅកសិដ្ឋាន។

៣. ការចិញ្ចឹមសត្វបង្ហាញជាលក្ខណៈគ្រួសារ ដោយអនុវត្តតាមបច្ចេកទេសជីវសុវត្ថិភាព។

៤. ការចិញ្ចឹមសត្វបង្ហាញដោយអនុវត្តតាមបទដ្ឋានបច្ចេកទេសចិញ្ចឹមសត្វ GAHP នៅកសិដ្ឋាន។

៥. ពង្រឹងសមត្ថភាពមន្ត្រី អ្នកពាក់ព័ន្ធលើការចិញ្ចឹមសត្វ តាមបទដ្ឋានលក្ខណៈបច្ចេកទេស។

៦. តាមដាន និងវាយតម្លៃលើប្រសិទ្ធភាព នៃគោលការណ៍អនុវត្តល្អប្រសើរ GAHP នៃការចិញ្ចឹមសត្វ។

៧. ជំរុញការគ្រប់គ្រង និងកែច្នៃកាកសំណល់សត្វ តាមរយៈការបង្កើតឡជីវឧស្ម័ន។

៨. រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យសត្វ ភិនសត្វ និងអត្តសញ្ញាណសត្វ។

៩. តាមដានត្រួតពិនិត្យលើការគ្រប់គ្រងការងារផលិតកម្មសត្វនៅតាមរាជធានី ខេត្ត។

## ២.២ អនុកម្មវិធីទី២.២៖ ពង្រឹងសេវាកម្មសុខភាពសត្វ ការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វ

**គោលបំណង៖** "បង្កើនការត្រួតពិនិត្យជំងឺសត្វ ដើម្បីកាត់បន្ថយការរាលដាលជំងឺឆ្លងសត្វ បង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងធ្វើឲ្យប្រសើរឡើងសុខភាពសត្វ"។

**សូចនាករ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចាក់វ៉ាក់សាំងការពារជំងឺអុតក្តាមគោក្របី | (%) | ២ | ២ | ៤ | ៦ | ៨ | ១០ |
| ២. ចាក់វ៉ាក់សាំងការពារជំងឺសារទឹកគោក្របី | (%) | ៤០ | ៤៥ | ៥០ | ៥៥ | ៦០ | ៦៥ |
| ៣. ចំនួនមន្ត្រីនិងអ្នកពាក់ព័ន្ធត្រូវបានបណ្តុះបណ្តាល | នាក់ | - | ២៥០ | ៣៥០ | ៤៥០ | ៥៥០ | ៦៥០ |

**គម្រោងសកម្មភាព៖**

១. សិក្សាស្រាវជ្រាវកំណត់តំបន់ដែលមានហានិភ័យនៃជំងឺឆ្លងសត្វ។

២. ពង្រឹងសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធលើបច្ចេកទេស វិធានបសុពេទ្យ និងការគ្រប់គ្រងសុខភាពសត្វ។

៣. កម្មវិធីយុទ្ធនាការចាក់ថ្នាំបង្ការ ការពារជំងឺឆ្លងសត្វនៅតាមមូលដ្ឋាននៃរាជធានី ខេត្ត។

៤. តាមដាននិងវាយតម្លៃលើការចាក់វ៉ាក់សាំងសត្វនៅរាជធានី ខេត្ត។

៥. គ្រប់គ្រងស្ថានភាពសុខភាពសត្វ ទប់ស្កាត់ការរាលដាលជំងឺឆ្លងសត្វ និងអនុវត្តវិធានបសុពេទ្យ។

៦. គាំទ្រកិច្ចសហការលើការផ្តល់សេវាកម្មសុខភាពសត្វ ដល់ភ្នាក់ងារសុខភាពសត្វភូមិនៅតាមមូលដ្ឋាន។

៧. តាមដាននិងវាយតម្លៃលើការងារទាក់ទងនឹងសុខភាពសត្វ គ្រប់គ្រង និងប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វ។

## ២.៣ អនុកម្មវិធីទី២.៣៖ ពង្រឹងការងារអធិការកិច្ចនិងចត្តាឡីស័ក

**គោលបំណង៖** "ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ចំណីសត្វ និងបសុឱសថ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១. ចំនួនស្ថានីយ៍ចត្តាឡីស័កត្រូវបង្កើត | ចំនួនស្ថានីយ៍ | - | - | ១ | ១ | ១ |
| ២. ចំនួនការត្រួតពិនិត្យចលនាសត្វ | លើក | ៥០ | ១០០ | ២០០ | ៣០០ | ៤០០ |
| ៣. ចំនួនកន្លែងលក់បសុឱសថ ចំណីសត្វ និងបរិក្ខារបសុពេទ្យត្រូវត្រួតពិនិត្យ | កន្លែង | - | ៥០ | ១០០ | ១៥០ | ២០០ |

**គម្រោងសកម្មភាព៖**

១. សិក្សាស្រាវជ្រាវកំណត់តំបន់សម្រាប់បង្កើតស្ថានីយចត្តាឡីស័កនៅតាមរាជធានី ខេត្ត។

២. រៀបចំបង្កើតស្ថានីយចត្តាឡីស័ក និងចំណាយលើកិច្ចដំណើការ។

៣. តាមដានត្រួតពិនិត្យ និងគ្រប់គ្រងចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ។

៤. តាមដានត្រួតពិនិត្យនិងគ្រប់គ្រងកន្លែងលក់បសុឱសថ ចំណីសត្វ និងបរិក្ខាបសុពេទ្យ។

៥. បំពាក់បំប៉នពង្រឹងសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធលើបច្ចេកទេសត្រួតពិនិត្យ វិធានបសុពេទ្យ និងការគ្រប់គ្រងចលនាសត្វ។

៦. ផ្សព្វផ្សាយ និងណែនាំដល់អ្នកពាក់ព័ន្ធលើបទដ្ឋានបច្ចេទេស ទាក់ទងនឹងផ្នែកផលិតកម្ម និងបសុព្យាបាល។

## ២.៤ អនុកម្មវិធីទី២.៤÷ ធ្វើឲ្យប្រសើរឡើងសុខភាពសាធារណៈ ពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺសូណូស៊ីស

**គោលបំណង÷** "បង្ការ ទប់ស្កាត់ ជំងឺឆ្លងរាលដាលពីសត្វទៅមនុស្ស និងពីមនុស្សមកសត្វ ធានាសុវត្ថិភាពសាច់និងផលិតផលសាច់"។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១.ចំនួនសត្តឃាតដ្ឋានត្រូវកែលម្អអនាម័យល្អប្រសើរតាមលក្ខណៈបច្ចេកទេស | កន្លែង | - | - | ២៥ | ៥០ | ៧៥ | ១០០ |
| ២.ចំនួនមន្ត្រីនិងអ្នកពាក់ព័ន្ធត្រូវបណ្តុះបណ្តាល | នាក់ | - | ៤៥០ | ៥០០ | ៦០០ | ៧០០ | ៨០០ |
| ៣.តាមដាននិងវាយតម្លៃលើការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ | លើក | ១៨ | ២០ | ២២ | ២៥ | ២៨ | ៣០ |

**គម្រោងសកម្មភាព៖**

១. ការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ និងសុខភាពសាធារណៈ។

២. ការជំរុញការអនុវត្តតាមដាន វាយតម្លៃការងារសត្តឃាតដ្ឋាន អនាម័យសាច់ និងកន្លែងតាំងលក់ (ការរៀបចំសត្តឃាតដ្ឋានតាមបទដ្ឋានបច្ចេកទេស និងការរៀបចំកន្លែងតាំងលក់តាមបទដ្ឋានបច្ចេកទេស)។

៣. បណ្តុះបណ្តាល និងវិក្រឹត្យការបច្ចេកទេស ត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន និងសាច់សត្វ។

៤. ផ្សព្វផ្សាយអនុក្រឹត្យ លិខិតបទដ្ឋាន នីតិវិធីទាក់ទងការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យអនាម័យសាច់ សត្វ និងផលិតផលសត្វ។

## ២.៥ អនុកម្មវិធីទី២.៥៖ ការអង្កេតឃ្លាំមើលស្រាវជ្រាវជំងឺសត្វនិងធ្វើរោគវិនិច្ឆ័យសត្វ

**គោលបំណង៖** "កំណត់រកប្រភពជំងឺសត្វ រាយការណ៍ និងធ្វើការឆ្លើយតបបន្ទាន់ជំងឺសត្វទាន់ពេលវេលា"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១.ចំនួនមន្ត្រីនិងអ្នកពាក់ព័ន្ធទទួលបានបណ្តុះបណ្តាល | នាក់ | ២០០ | ២៥០ | ៣០០ | ៣៥០ | ៤០០ |
| ២.តាមដាន ឃ្លាំមើល និងស្រាវជ្រាវជំងឺសត្វ៖ AI, FMD, CSF, PRRS, និង HS | លើក | ១៥ | ២០ | ២៥ | ៣០ | ៣៥ |
| ៣.ចំនួនវត្ថុវិភាគ និងការធ្វើរោគវិនិច្ឆ័យ | ចំនួនវត្ថុវិភាគ | ៩.២២២ | ៩.៦៨៣ | ១០.១៦៧ | ១០.៦៧៥ | ១១.២០៨ |

**គម្រោងសកម្មភាព៖**

១. អង្កេតតាមដាន ឃ្លាំមើល និងស្រាវជ្រាវជំងឺសត្វ។

២. បំប៉ននិងពង្រឹងសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធលើការតាមដាន ឃ្លាំមើល និងស្រាវជ្រាវជំងឺសត្វ។

៣. បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពមន្ត្រីមន្ទីរពិសោធន៍លើការធ្វើរោគវិនិច្ឆ័យជំងឺសត្វ។

៤. ស្រាវជ្រាវជំងឺសត្វ ករណីសង្ស័យពេលផ្ទុះ និងក្រោយពេលផ្ទុះជំងឺឆ្លងសត្វ។

៥. ផ្តល់ឧបករណ៍ សម្ភារបរិក្ខារសម្រាប់កិច្ចដំណើរការមន្ទីរពិសោធន៍ រោគវិនិច្ឆ័យជំងឺសត្វ។

៦. ការគ្រប់គ្រង ត្រៀមរៀបចំបង្ការទប់ស្កាត់ជាបន្ទាន់ជំងឺផ្តាសាយបក្សី។

៧. គាំទ្រដល់ការធានារ៉ាប់រងសុខភាពមន្ត្រីមន្ទីរពិសោធន៍ និងជីវសុវត្ថិភាពមន្ទីរពិសោធន៍។

៨. សិក្សាស្រាវជ្រាវលើជំងឺឆ្លងសត្វនៅកម្ពុជា។

៩. គាំទ្រយន្តការនៃប្រព័ន្ធរាយការណ៍ពីស្ថានភាពជំងឺសត្វ។

១០. តាមដាន និងវាយតម្លៃលើការអនុវត្តការអង្កេតឃ្លាំមើល ស្រាវជ្រាវជំងឺសត្វ និងធ្វើរោគវិនិច្ឆ័យជំងឺសត្វ។

## ២.៦ អនុកម្មវិធីទី២.៦៖ ការស្រាវជ្រាវផលិតកម្មសត្វ សេនេទិចសត្វ ចំណីសត្វ និងការបង្កាត់ពូជសត្វ

**គោលបំណង៖** "ធ្វើឱ្យប្រសើរឡើងនូវពូជសត្វ និងគុណភាពចំណីសត្វ ការកែលម្អការបង្កាត់ពូជសត្វ ក្នុងគោលបំណងបង្កើនផលិតកម្មសត្វ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១.ចំនួនកូនពូជជ្រូកផលិត | ក្បាល | ៥០០ | ៧៥០ | ៨៣០ | ៩១០ | ១.០០០ |

| | | | | | | |
|---|---|---|---|---|---|---|
| ២.ចំនួនទឹកមេជីវិតបង្កា (Semen) ត្រូវផលិត | កម្រិត | ២០០ | ២០០ | ២២០ | ២៤០ | ២៦០ |
| ៣.ចំនួនវត្ថុវិភាគនិងវិភាគចំណីសត្វ | ចំនួនវត្ថុវិភាគ | - | - | ៥០ | ៥៥ | ៦០ |

**គម្រោងសកម្មភាព៖**

១. រៀបចំ កែសម្រួល បោះពុម្ពឯកសារបទដ្ឋានគតិយុត្តគាំទ្របច្ចេកទេស និងផ្សព្វផ្សាយការស្រាវជ្រាវ។

២. ពិសោធន៍ និងស្រាវជ្រាវវត្ថុធាតុដើម ចំណីសត្វ និងសមាសធាតុផ្សំ និងសារធាតុបន្ថែមផ្សេងៗទៀត។

៣. ការស្រាវជ្រាវពូជសត្វ សេនេទិច និងការបង្កាត់ពូជ។

៤. ពិសោធន៍ និងស្រាវជ្រាវពូជជ្រូកនៅស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន។

៥. ពិសោធន៍ និងស្រាវជ្រាវពូជគោនៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ។

៦. ពិសោធន៍ និងស្រាវជ្រាវពូជបក្សីសម្រាប់ការផ្សព្វផ្សាយដល់កសិករ។

៧. តាមដាន និងវាយតម្លៃលើការអនុវត្តការផលិតកម្មសត្វ ចំណីសត្វ និងការបង្កាត់ពូជសត្វ។

## ២.៧ អនុកម្មវិធីទី២.៧÷ ពង្រឹងសមត្ថភាពអង្គភាព ការអនុវត្តច្បាប់ និងការអភិវឌ្ឍធនធានមនុស្សផ្នែកផលិតកម្មសត្វ

**គោលបំណង**÷ "បង្កើនការគ្រប់គ្រងអង្គភាព តាមរយៈពង្រឹងសមត្ថភាពមន្ត្រី ការរៀបចំនិងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត"។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១.ចំនួនមន្ត្រីនិងអ្នកពាក់ព័ន្ធត្រូវបណ្តុះបណ្តាល | នាក់ | - | ១២០ | ១២០ | ១២០ | ១៤០ |
| ២.ចំនួនអ្នកពាក់ព័ន្ធទទួលការផ្សព្វផ្សាយលើការអនុវត្តច្បាប់ និងលិខិតបដ្ឋានគតិយុត្ត | នាក់ | ៥០ | ១២០ | ១២០ | ១២០ | ១៤០ |
| ៣.តាមដានត្រួតពិនិត្យ និងដោះស្រាយវិវាទ | លើក | - | ១៥ | ២០ | ៣០ | ៤០ |

**គម្រោងសកម្មភាព៖**

១. រៀបចំ កែសម្រួល បោះពុម្ព និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

២. ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

៣. ពង្រឹងយន្តការនៃការតាមដានត្រួតពិនិត្យ និងដោះស្រាយវិវាទទាក់ទងនឹងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

៤. ពង្រឹងសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធលើការងារគ្រប់គ្រងរដ្ឋបាល ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ។
៥. គាំទ្រការសម្របសម្រួលការងារកិច្ចការរដ្ឋបាល។
៦. ជំរុញការតាមដាន និងវាយតម្លៃលើការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ផ្នែកសុខភាពសត្វនិងផលិតកម្មសត្វ។

## ២.៨ អនុកម្មវិធីទី២.៨÷ ពង្រឹងការអនុវត្តគោលនយោបាយ កម្មវិធី/ផែនការយុទ្ធសាស្ត្រនិងថវិកា និងបង្កើនប្រសិទ្ធភាពសេវាគាំទ្រផលិតកម្មសត្វ

**គោលបំណង**÷ "ពង្រឹងសមត្ថភាពលើការកសាង និងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ថវិកា ផែនការអភិវឌ្ឍន៍វិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងសម្របសម្រួលការងារ ដើម្បីបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងតាមដានវាយតម្លៃ"។

**សូចនាករ** ÷

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១.ចំនួនមន្ត្រី និងអ្នកពាក់ព័ន្ធត្រូវបណ្តុះបណ្តាល | នាក់ | - | ១២០ | ១៥០ | ១៥០ | ១៥០ |
| ២.ចំនួនការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ | លើក | - | ៣០ | ៣៥ | ៣៥ | ៤០ |
| ៣.ចំនួនអ្នកពាក់ព័ន្ធទទួលការផ្សព្វផ្សាយ | នាក់ | - | ២០០ | ២៥០ | ៣០០ | ៣៥០ |

**គម្រោងសកម្មភាព**៖

១. រៀបចំប្រជុំ និងសិក្ខាសាលាពាក់ព័ន្ធនឹងការងារផលិតកម្ម និងបសុព្យាបាលជាមួយមន្ត្រីថ្នាក់កណ្តាល រាជធានី ខេត្ត និងអ្នកពាក់ព័ន្ធ។
២. ប្រជុំទ្វេភាគីការងារផលិតកម្ម និងបសុព្យាបាល។
៣. អង្កេតតាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសុខភាពសត្វ និងផលិតកម្មសត្វ គម្រោងដៃគូអភិវឌ្ឍន៍ គម្រោងថវិកាតាមកម្មវិធី និងការអនុវត្តឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធថវិកា។
៤. អនុវត្តការងារសុខភាពសត្វជាអន្តរជាតិរួមទាំងការបង់វិភាគទានអង្គការអន្តរជាតិ OIE។
៥. គាំទ្រកិច្ចដំណើរការប្រតិបត្តិអង្គភាព ផ្គត់ផ្គង់ម៉ាស៊ីន ឧបករណ៍សម្ភារបរិក្ខារ ផ្គត់ផ្គង់បៀវត្សមន្ត្រីរាជការ និងជួលបុគ្គលិក។

## ២.៩ អនុកម្មវិធីទី២.៩÷ ជំរុញការផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វ និងសុខភាពសត្វ

**គោលបំណង**÷ "បង្កើនការផ្សព្វផ្សាយពីបច្ចេកទេសចិញ្ចឹមសត្វ ជំងឺសត្វ និងព័ត៌មានស្តីពីការងារសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីបញ្ជ្រាបការយល់ដឹងដល់កសិករនិងអ្នកចិញ្ចឹមសត្វ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១. ចំនួនមន្ត្រីនិងអ្នកពាក់ព័ន្ធត្រូវបណ្តុះបណ្តាល | នាក់ | ១០០ | ២០០ | ៤០០ | ៦០០ | ៨០០ |
| ២.ចំនួនសហគមន៍ត្រូវបានបង្កើត | សហគមន៍ | - | ១ | ៣ | ៣ | ២ |
| ៣.កសិករទទួលបានសេវាផ្សព្វផ្សាយចិញ្ចឹមសត្វ | នាក់ | ៥០០ | ១.២០០ | ១.២០០ | ១.២០០ | ១.២០០ |

**គម្រោងសកម្មភាព៖**

១. រៀបចំចងក្រង កែសម្រួល និងបោះពុម្ពឯកសារផ្សព្វផ្សាយលើបច្ចេកទេសចិញ្ចឹមសត្វ ជំងឺសត្វ និងព័ត៌មានស្តីពីការងារសុខភាពសត្វនិងផលិតកម្មសត្វ។

២. ឃោសនាផ្សព្វផ្សាយស្តីពីបច្ចេកទេសចិញ្ចឹមសត្វ ជំងឺសត្វ និងព័ត៌មានទាក់ទងនឹងផលិតកម្មសត្វ។

៣. ពង្រឹងសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធលើបច្ចេកទេសចិញ្ចឹមសត្វ ជំងឺសត្វ និងព័ត៌មានទាក់ទងនឹងការងារសុខភាពសត្វ និងផលិតកម្មសត្វ។

៤. គាំទ្រការផ្គត់ផ្គង់បោះពុម្ពឯកសារបច្ចេកទេសចិញ្ចឹមសត្វ ជំងឺសត្វ និងព័ត៌មានទាក់ទងនឹងការងារសុខភាពសត្វ និងផលិតកម្មសត្វ។

៥. គាំទ្រការផ្គត់ផ្គង់មធ្យោបាយធ្វើដំណើរ ម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារផ្សព្វផ្សាយសម្រាប់ការយកព័ត៌មាន អប់រំ និងការប្រាស្រ័យទាក់ទង (IEC)។

៦. រៀបចំចងក្រងសហគមន៍អ្នកចិញ្ចឹមសត្វ និងភ្នាក់ងារសុខភាពសត្វភូមិនៅតាមមូលដ្ឋាន។

៧. រៀបចំយុទ្ធនាការឃោសនាផ្សព្វផ្សាយនៅតាមរាជធានី ខេត្ត។

៨. រៀបចំកសាងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្សព្វផ្សាយការងារសុខភាពសត្វ និងផលិតកម្មសត្វ។

## ២.១០ អនុកម្មវិធីទី ២.១០៖ ជំរុញផលិតកម្មសត្វនិងសុខភាពសត្វរបស់មន្ទីរកសិកម្មរាជធានី ខេត្ត

អនុកម្មវិធីនេះ គឺជាការប្រមូលផ្តុំនូវចង្កោមសកម្មភាពទាំងអស់ របស់មន្ទីរកសិកម្មរាជធានីខេត្តទាំង២៥សម្រាប់អនុវត្ត សំដៅចូលរួមចំណែកសម្រេចបាននូវគោលបំណង និងសូចនាករនៃកម្មវិធីទី-២ "*ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ*"។

## ៣. កម្មវិធីទី-៣ ៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

### ៣.១ អនុកម្មវិធីទី៣.១ ៖ ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍នេសាទ

**គោលបំណង ៖** "ពង្រឹងការចូលរួមនិងបង្កើនសមត្ថភាពរបស់សហគមន៍នេសាទ ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព"។

**សូចនាករ**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១.ចំនួនសហគមន៍នេសាទត្រូវបានចុះបញ្ជី | ចំនួនសហគមន៍នេសាទ | ៣៦០ (បូកយោង៣៦០) | ៣៧៧ | ៤២៧ | ៤៧៧ | ៥១៦ | ៥១៦ |
| ២.សហគមន៍នេសាទចុះបញ្ជីរួច ត្រូវបានពង្រឹងប្រកបដោយប្រសិទ្ធភាព | ចំនួនសហគមន៍នេសាទ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ៣.សហគមន៍ត្រូវបានពង្រីកមុខរបរ និងបង្កើនប្រាក់ចំណូល | ចំនួនសហគមន៍នេសាទ | ១០ | ២០ | ៣០ | ៤០ | ៥០ | ៦០ |

**គម្រោងសកម្មភាព**

១. ការកំណត់ព្រំប្រទល់ ការរៀបចំផែនទី និងឯកសារពាក់ព័ន្ធ សម្រាប់ការចុះបញ្ជីសហគមន៍នេសាទ។

២. ការរៀបចំកិច្ចព្រមព្រៀងសហគមន៍នេសាទ។

៣. រៀបចំផែនការគ្រប់គ្រង (រួមទាំងផែនការវិនិយោគ) និងអនុវត្តផែនការ ដើម្បីជាសហគមន៍នេសាទគំរូគ្មានបទល្មើសជលផល (រួមទាំងលុបបំបាត់ពលកម្មកុមារ លើកស្ទួយស្ត្រី និងទប់ទល់នឹងបម្រែបម្រួលធាតុអាកាស)។

៤. ការរៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទដែលផុតអាណត្តិ។

៥. កែសម្រួលក្របខណ្ឌច្បាប់ស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍នេសាទ។

៦. បង្កើតនិងកែលម្អកន្លែងអភិរក្សសហគមន៍នេសាទ។

៧. ជំរុញនិងពង្រឹងជីវភាពរស់នៅរបស់សហគមន៍នេសាទ។

៨. បង្កើត និងពង្រឹងក្រុមល្បាតសហគមន៍នេសាទ។

៩. រៀបចំសិក្ខាសាលាស្តីពីការរីកចម្រើននៃការអនុវត្តការគ្រប់គ្រងសហគមន៍នេសាទ។

១០. ពង្រឹងសមត្ថភាពនិងផ្សព្វផ្សាយអំពីច្បាប់ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

១១. សម្របសម្រួល និងជំរុញការបង្កើតអេកូទេសចរណ៍នៅតាមសហគមន៍នេសាទ។

១២. សម្របសម្រួល និងជំរុញការផ្លាស់ប្តូរបទពិសោធន៍ ស្តីពីការគ្រប់គ្រងសហគមន៍

នេសាទ និងផ្តល់ការបណ្តុះបណ្តាល។

១៣. ចុះតាមដាននិងវាយតម្លៃពីប្រសិទ្ធភាពនៃការគ្រប់គ្រងសហគមន៍នេសាទ។

១៤. អនុវត្តសកម្មភាពសម្រាប់កាត់បន្ថយភាពងាយរងគ្រោះ ដោយការប្រែប្រួលអាកាសធាតុដល់សហគមន៍នេសាទ។

## ៣.២ អនុកម្មវិធីទី ៣.២÷ ការគ្រប់គ្រងដែននេសាទ

**គោលបំណង** ÷ "ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងកែលម្អដែននេសាទ និងការធ្វើអាជីវកម្មនេសាទ ដើម្បីធានានិរន្តរភាពធនធានជលផល"។

**សូចនាករ**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ព្រៃលិចទឹកនិងព្រៃកោងកាងត្រូវបានការពារនិងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព | ហិកតា | ២០០ | ៤៥០ | ៣.៥០០ | ៧.៥០០ | ១២.០០០ | ១៥.០០០ |
| ២. ដែននេសាទត្រូវបានកែលម្អប្រកបដោយប្រសិទ្ធភាព | គីឡូម៉ែត្រ | - | - | ៥ | ១០ | ១៥ | ២០ |
| ៣. អ្នកនេសាទអនុវត្តតាមបទបញ្ញត្តិនៃការធ្វើអាជីវកម្មនេសាទនិងការប្រើប្រាស់ឧបករណ៍នេសាទប្រកបដោយប្រសិទ្ធភាព | ចំនួនអ្នកនេសាទ | ២.៧៥០ | ៥.៧៥០ | ១០.៧៥០ | ១៥.៧៥០ | ២០.៧៥០ | ២៥.៧៥០ |

**គម្រោងសកម្មភាព ÷**

១. ការចុះកំណត់ព្រំប្រទល់នាទីព្រៃលិចទឹកនិងព្រៃកោងកាង។

២. ការរៀបចំផែនទីព្រៃលិចទឹកនិងព្រៃកោងកាង។

៣. ការបោះបង្គោលព្រំប្រទល់នាទីព្រៃលិចទឹកនិងព្រៃកោងកាង។

៤. សិក្សានិងកែលម្អដែននេសាទឡើងវិញ រួមទាំងលើកកម្ពស់ភាពបន្សុាំនៃការប្រែប្រួលអាកាសធាតុ។

៥. សិក្សានិងវាយតម្លៃតំបន់ដែលអនុញ្ញាតឲ្យធ្វើការអភិវឌ្ឍន៍នានាក្នុងដែននេសាទ។

៦. ផ្សព្វផ្សាយពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារសំខាន់នាទីព្រៃលិចទឹក។

៧. រៀបចំផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់បទល្មើសនេសាទ ការនេសាទគ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

៨. តាមដាននិងត្រួតពិនិត្យការចុះបញ្ជីនាវានេសាទ។

៩. ធ្វើជំរឿនទូកនេសាទ ផ្សព្វផ្សាយប្រកាសស្តីពីបទបញ្ញាបច្ចេកទេស នៃការគ្រប់គ្រងទូកនេសាទ និងប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់គម្រូសៀវភៅនាវានេសាទ។

១០. តាមដាននិងវាយតម្លៃសភាពការណ៍អាជីវកម្មនេសាទ និងស្ថានភាពដែននេសាទ។
១១. រៀបចំផែនការសកម្មភាពសម្រាប់គ្រប់គ្រងនិងកែលម្អដែននេសាទ និងការធ្វើអាជីវកម្មនេសាទ។
១២. លើកកម្ពស់ភាពធន់ទ្រាំនឹងការប្រែប្រួលអាកាស នៃធនធានជលផលធម្មជាតិ។
១៣. លើកកម្ពស់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសក្នុងវិស័យជលផល។
១៤. បង្កើតប្រព័ន្ធសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ និងគណនេយ្យភាពក្នុងវិស័យជលផល។

## ៣.៣ អនុកម្មវិធីទី ៣.៣÷ ជំរុញការអភិវឌ្ឍវារីវប្បកម្ម

**គោលបំណង** ÷ "ផ្គត់ផ្គង់ការប្រើប្រាស់សាច់ត្រី និងបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋនិងសន្តិសុខស្បៀង"។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. អត្រាកសិករចិញ្ចឹមត្រីកើនឡើង | % | ៥ | ១០ | ១៥ | ២០ | ២៥ | ៣០ |
| ២. កូនត្រីពូជមានគុណភាព កើនឡើង | លានក្បាល | ១៥០ | ១៧០ | ២០០ | ២២០ | ២៤០ | ២៦០ |
| ៣. ស្រះជម្រកត្រីសហគមន៍កើនឡើង | ចំនួន | ៧៧៩ | ៨៩៦ | ៩៦២ | ១.០២៨ | ១.០៩៤ | ១.១៦០ |

**គម្រោងសកម្មភាព ÷**

១. ផ្សព្វផ្សាយនិងតាមដានបច្ចេកទេសចិញ្ចឹមត្រី រួមទាំងការយល់ដឹងពីការបន្សាំការប្រែប្រួលអាកាសធាតុ។
២. ផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែជាលក្ខណៈគ្រួសារ។
៣. អនុវត្តការផ្សព្វផ្សាយបច្ចេកទេសការអនុវត្តវារីវប្បកម្មល្អ ។
៤. ផ្សព្វផ្សាយនិងតាមដានបច្ចេកទេសផលិតចំណីត្រី។
៥. ពង្រឹងសមត្ថភាពបណ្តាញកសិករផលិតកូនត្រីពូជ។
៦. ជំរឿនស្ថិតិកសិករចិញ្ចឹមត្រី ដើម្បីរៀបចំផែនការសកម្មភាពអភិវឌ្ឍន៍វារីវប្បកម្ម។
៧. រៀបចំបង្កើតសហគមន៍ស្រះជម្រកត្រី។
៨. ពង្រឹងសមត្ថភាពសហគមន៍ស្រះជម្រកត្រី។
៩. ផ្សព្វផ្សាយពីបេច្ចកទេសចិញ្ចឹមត្រីដល់សិស្សនិងគ្រូបង្រៀននៅតាមសាលានានា។
១០. បង្កើតសារពើភ័ណ្ឌធនធានវារីវប្បកម្មជាតិ។
១១. បង្កើតបណ្តាញផ្លាស់ប្តូរពត៌មានទីផ្សារតាមរយៈទូរស័ព្ទ/internet។
១២. ចុះបញ្ជីកសិករចិញ្ចឹមត្រី។

១៣. បង្កើតបណ្តាញកសិករវារីវប្បកម្មសម្រាប់ការលើកបញ្ហាវារីវប្បកម្ម។
១៤. ផលិតកម្មចំណីវារីវប្បកម្ម (Artemia Cyst) នៅខេត្តកំពតនិងកែប។
១៥. ការពង្រឹងសមត្ថភាពលើបច្ចេកទេសវារីវប្បកម្ម។
១៦. ផលិតសម្ភារផ្សព្វផ្សាយវារីវប្បកម្ម។
១៧. បង្កើតបណ្តាញអប់រំវារីវប្បកម្មកម្ពុជា។
១៨. ជំរុញការបង្កើតប្រព័ន្ធផលិតកម្មវារីវប្បកម្ម និងការអនុវត្តដែលមានការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុបានច្រើន។

## ៣.៤ អនុកម្មវិធីទី ៣.៤÷ ការអភិវឌ្ឍធនធានមនុស្ស និងការពារធនធានជលផល

**គោលបំណង÷** "បង្កើនសមត្ថភាពគ្រប់គ្រងនិងពង្រឹងការអនុវត្តច្បាប់ ដោយបង្ក្រាបនិងទប់ស្កាត់បទល្មើស ដើម្បីថែរក្សាការពារប្រភពធនធានជលផលប្រកបដោយនិរន្តរភាព"។

**សូចនាករ**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| 1. អត្រាសកម្មភាពបទបទល្មើសនេសាទថយចុះ | % | ៥៦ | ៤០ | ៣០ | ២៥ | ២០ | ១០ |
| 2. អត្រានៃអ្នកទទួលចំណេះដឹងពីច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកើនឡើង | % | ១០ | ៨ | ១០ | ១៥ | ២០ | ២៥ |
| ៣. អត្រាមន្ត្រីជលផលត្រូវបានពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពការងារ | % | - | - | ៥ | ១០ | ១៥ | ២០ |

**គម្រោងសកម្មភាព**

១. ការផ្សព្វផ្សាយច្បាប់ស្តីពីជលផលនិងលិខិតបទដ្ឋានគតិយុត្ត និងតាមដាននិងវាយតម្លៃពីការយល់ដឹង និងអនុវត្តច្បាប់ដោយអ្នកពាក់ព័ន្ធ។
២. ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល។
៣. វាយតម្លៃពីប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងលុបបំបាត់បទល្មើសជលផល។
៤. រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សវិស័យជលផលឆ្នាំ ២០១៥-២០២០ និងវាយតម្លៃពីសមត្ថភាពមន្ត្រី និងការអនុវត្តការងារ។
៥. រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ និងលប់បំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងវិស័យជលផលឆ្នាំ២០១៥-២០២០។
៦. រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុក្នុងវិស័យជលផលឆ្នាំ២០១៥-២០២០។
៧. ការដាក់បញ្ចូលនិងការអនុវត្តការប្រើប្រាស់ប្រព័ន្ធព័ត៌មានបច្ចេកវិទ្យា និងការ

ទំនាក់ទំនងទំនើប ចូលរួមទៅក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផល។

## ៣.៥ អនុកម្មវិធីទី ៣.៥ ÷ ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

**គោលបំណង** ÷ "លើកកម្ពស់ការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដើម្បីជំរុញការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផលទឹកសាបប្រកបដោយនិរន្តរភាព"។

**សូចនាករ**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនឯកសារស្រាវជ្រាវដែលបានចងក្រងនិងបោះពុម្ពជារៀងរាល់ឆ្នាំ | ចំនួនឯកសារ | ១២ | ១២ | ១៣ | ១៥ | ១៧ | ១៩ |
| ២. អ្នកពាក់ព័ន្ធអនុវត្តប្រព័ន្ធត្រួតពិនិត្យអេកូឡូស៊ី-ជីវសាស្ត្រប្រកបដោយប្រសិទ្ធភាព | នាក់ | ៥០០ | ៥០០ | ៥០០ | ៥០០ | ៥០០ | ៥០០ |
| ៣. ទិន្នន័យនិងព័ត៌មានជលផលទឹកសាបត្រូវបានប្រើប្រាស់ | ចំនួនទិន្នន័យ | ១០០ | ១១០ | ១២០ | ១៣០ | ១៤០ | ១៥០ |

**គម្រោងសកម្មភាព**

១. វិភាគខ្សែសង្វាក់ផលិតកម្មត្រីឆ្អិតទឹកសាបរួមទាំងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

២. សិក្សាស្រាវជ្រាវប្រភេទកូនត្រី។

៣ សិក្សាស្រាវជ្រាវផលិតកម្មជលផលដាយ។

៤. សិក្សាស្រាវជ្រាវផលិតកម្មជលផលលក្ខណៈគ្រួសារ។

៥. សិក្សាវាយតម្លៃផលិតកម្មជលផលទឹកសាប និងគ្រួសារប្រកបមុខរបរនេសាទអាជីព។

៦. សិក្សាស្រាវជ្រាវពូជត្រីទឹកសាប។

៧. សិក្សាប្រភេទឧបករណ៍នេសាទទឹកសាប។

៨. ការផ្តល់ចំណេះដឹងលើការអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃទៅលើអេកូឡូស៊ីជីវសាស្ត្រទឹកសាបដើម្បីធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានធម្មជាតិ។

៩. សិក្សាស្រាវជ្រាវអំពីឥទ្ធិពលនៃការសាងសង់ទំនប់វារីអគ្គិសនីនៅតំបន់ទន្លេមេគង្គទៅលើវិស័យជលផល។

១០. សិក្សាស្រាវជ្រាវការគ្រប់គ្រងជលផលនេសាទទឹកសាបកម្ពុជារួមទាំងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

១១.	សិក្សាលើតំបន់ការពារនេសាទទឹកសាប និងបង្កើតបណ្តាញតំបន់ការពារនេសាទទឹកសាប។

១២.	ពង្រឹងសមត្ថភាពនិងការគ្រប់គ្រងបណ្ណាល័យសាស្ត្រ។

## ៣.៦ អនុកម្មវិធីទី ៣.៦ ÷ ការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ

**គោលបំណង** ÷ "រួមចំណែកធ្វើឲ្យប្រសើរឡើងការគ្រប់គ្រង និងអភិវឌ្ឍធនធានជលផលសមុទ្រប្រកបដោយនិរន្តរភាព"។

**សូចនាករ**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១. ប្រសិទ្ធភាពនៃការស្រាវជ្រាវនិងឯកសារស្តីពីធនធានជលផលសមុទ្រកើនឡើង | ចំនួនឯកសារ | ២ | ១០ | ៣០ | ៤០ | ៥០ |
| ២. ប្រសិទ្ធភាពនៃការរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រ ការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍នៃការគ្រប់គ្រងធនធានជលផលសមុទ្រកើនឡើង | % | - | ១០ | ២០ | ៣០ | ៤០ |
| ៣. ការកសាងសមត្ថភាពនិងផ្សព្វផ្សាយដល់មន្ត្រីជលផលនិងអ្នកពាក់ព័ន្ធកើនឡើង | នាក់ | ៥០ | ៥០០ | ១.០០០ | ២.០០០ | ៣.០០០ |

**គម្រោងសកម្មភាព**

១.	សិក្សាតាមដានស្ថានភាពនេសាទសមុទ្រ។

២.	ពិនិត្យឡើងវិញ និងកំណត់អត្តសញ្ញាណប្រទេភេទវារីសត្វសមុទ្រ។

៣.	សិក្សាលក្ខណៈជីវសាស្ត្រកូនវារីសត្វសមុទ្រ។

៤.	វាយតម្លៃផលប៉ះពាល់ធនាគារក្តាម។

៥.	សិក្សា ស្រាវជ្រាវ តាមដានស្ថានភាពផលិតកម្មជលផលសមុទ្រ និងសេដ្ឋកិច្ចសង្គម។

៦.	សិក្សាលក្ខណៈជីវសាស្ត្រកូនវារីសត្វសមុទ្រ។

៧.	ស្រាវជ្រាវបច្ចេកទេសនិងកំណត់ប្រភេទ និងប្រសិទ្ធភាពនៃឧបករណ៍នេសាទសមុទ្រ។

៨.	ស្រាវជ្រាវពីផលប៉ះពាល់លើធនធានជលផលសមុទ្រ ដែលបង្កដោយសកម្មភាពផ្សេងៗ។

៩.	សិក្សាពីទំនាក់ទំនងនិងផលប៉ះពាល់រវាងការនេសាទ និងសកម្មភាពវារីវប្បកម្ម។

១០.	ស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មសមុទ្រ។

១១.	សិក្សានិងលើកកម្ពស់ផលិតកម្ម និងការផ្សព្វផ្សាយប្រភេទពូជត្រីសមុទ្រជិតផុតពូជ។

១២.	សិក្សាស្រាវជ្រាវលើកកម្ពស់សមត្ថភាពមន្ទីរពិសោធន៍លើចំណីត្រី ជំងឺត្រី និងពូជត្រី។

១៣. លើកកម្ពស់សមត្ថភាពមន្ត្រីជលផល និងភាគីពាក់ព័ន្ធលើវិធីសាស្ត្រស្រាវជ្រាវការតាមដាន និងវាយតម្លៃ ការគ្រប់គ្រង និងបច្ចេកទេសវារីវប្បកម្ម ការផ្សព្វផ្សាយ និងបច្ចេកទេសពាក់ព័ន្ធផ្សេងទៀតលើធនធានជលផលសមុទ្រ។

១៤. បង្កើតផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ។

១៥. កសាងហេដ្ឋារចនាសម្ព័ន្ធ និងដំណើរការវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ។

១៦. បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ ព័ត៌មានវិទ្យាសាស្ត្រ បច្ចេកទេស និងការផ្សព្វផ្សាយ។

១៧. សិក្សាពីខ្សែសង្វាក់តម្លៃផលិតកម្មជលផលសមុទ្រនិងតម្លៃទីផ្សារ។

១៨. សិក្សាពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ប្រព័ន្ធអេកូឡូស៊ីជីវសាស្ត្រសមុទ្រ។

## ៣.៧ អនុកម្មវិធីទី ៣.៧÷ សិក្សាស្រាវជ្រាវបច្ចេកទេសវារីវប្បកម្ម

**គោលបំណង** ÷ "សិក្សាស្រាវជ្រាវបច្ចេកទេសចិញ្ចឹម និងផលិតពូជវារិជាតិ ដើម្បីផ្គត់ផ្គង់ និងអភិវឌ្ឍន៍បច្ចេកទេសវារីវប្បកម្ម"។

**សូចនាករ**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ប្រភេទពូជត្រីថ្មីៗនិងបង្កងត្រូវបានស្រាវជ្រាវ ដើម្បីផលិតពូជមានគុណភាពសម្រាប់ចិញ្ចឹម | ចំនួនប្រភេទ | ២ | ២ | ៨ | ៨ | ៨ | ៨ |
| ២. មេពូជវារីជាតិមានគុណភាពត្រូវបានផលិត | គ.ក្រ | ៤៨០ | ១.០០០ | ៣.៥០០ | ៣.៥០០ | ៣.៥០០ | ៣.៥០០ |
| ៣. កូនត្រីនិងបង្កងពូជដែលមានគុណភាពត្រូវបានផលិត | លានក្បាល | - | ១០ | ២០ | ៣០ | ៤០ | ៥០ |

**គម្រោងសកម្មភាព ÷**

១. សិក្សាស្រាវជ្រាវបំប៉នប្រភេទមេពូជត្រីឆ្តោកនិងត្រីខ្សា។

២. សិក្សាស្រាវជ្រាវបំប៉នប្រភេទមេពូជនិងផលិតកូនត្រីឆ្លង់ និងត្រីតុកកែ។

៣. ស្រាវជ្រាវការរីកលូតលាស់ឧបករណ៍នេសាទរបស់ភាគីពាក់ព័ន្ធ។

៤. ផលិតកូនត្រីនិងបង្កងពូជ ដែលធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ។

៥. ការស្រាវជ្រាវចំណីត្រីដើម្បីផលិតមេពូជ និងកូនត្រីពូជមានគុណភាព។

៦. ផ្ទេរបច្ចេកទេសថ្មីៗ និងចែកចាយកូនត្រីពូជ បង្កង និងត្រីមេពូជដល់កសិករចិញ្ចឹម

និងកសិករផលិតពូជ។

៧. លែងកូនត្រីពូជ បង្កង និងត្រីមេពូជចូលទៅក្នុងបឹងធម្មជាតិ ឬតាមស្រះសហគមន៍។

៨. បង្កើនសត្ថភាពមន្ត្រីរបស់វិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្ម តាមរយៈការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស។

## ៣.៨ អនុកម្មវិធីទី ៣.៨ ÷ ការធ្វើឲ្យប្រសើរឡើងផ្នែកកែច្នៃផលផល

**គោលបំណង ÷** "បង្កើនគុណភាព និងសុវត្ថិភាព នៃផលផលិតផលជលផល ដើម្បីការពារសុខភាពសាធារណៈ និងជំរុញការនាំចេញ"។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. អ្នកកែច្នៃនិងអ្នកពាក់ព័ន្ធអនុវត្តអនាម័យល្អ និងការផលិតល្អប្រកបដោយប្រសិទ្ធភាព | នាក់ | ២១០ | ២៥០ | ២៥០ | ២៥០ | ២៥០ | ២៥០ |
| ២. អ្នកពាក់ព័ន្ធទទួលបានព័ត៌មាននៃបច្ចេកវិទ្យាកែច្នៃជលផលពេញលេញ | នាក់ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ |
| ៣. កន្លែងកែច្នៃត្រូវបានចុះបញ្ជីបញ្ជាក់គុណភាពនិងត្រួតពិនិត្យលើការអនុវត្តអនាម័យល្អនិងផលិតល្អ | ចំនួនកន្លែងកែច្នៃ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |

**គម្រោងសកម្មភាព**

១. រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ការកែច្នៃផលផលិតផលជលផល។

២. ពង្រឹងសមត្ថភាពរបស់អង្គភាពមានសមត្ថកិច្ចជលផលលើការផ្តល់សេវាកម្មសាធារណៈពាក់ព័ន្ធសុវត្ថិភាព គុណភាពផល ផលិតផលជលផល។

៣. សាងសង់មន្ទីរពិសោធន៍និងបំពាក់សម្ភារបរិក្ខារសម្រាប់វិភាគសុវត្ថិភាពលើផលិតផល។

៤. រៀបចំបទដ្ឋានគតិយុត្តនិងពង្រឹងការអនុវត្តក្នុងការគ្រប់គ្រង និងត្រួតពិនិត្យសុវត្ថិភាពគុណភាពលើផល ផលិតផលជលផល។

៥. បណ្តុះបណ្តាលស្តីពីការអនុវត្តអនាម័យល្អ និងអនុវត្តផលិតល្អក្នុងខ្សែសង្វាក់ផលិតកម្មរួមទាំងការបម្រែបម្រួលធាតុអាកាស។

៦. ផ្សព្វផ្សាយអំពីសុវត្ថិភាព គុណភាព អនាម័យ បច្ចេកទេសកែច្នៃ ការដឹកជញ្ជូន ការលើកដាក់ វេចខ្ចប់និងការថែរក្សាផល ផលិតផលជលផល។

៧. ចុះបញ្ជីកន្លែងកែច្នៃផលផលិតផលជលផល ដែលបានអនុវត្តអនាម័យល្អ និងផលិតល្អ។

៨. ត្រួតពិនិត្យនិងអធិការកិច្ចសុវត្ថិភាព គុណភាពលើផល ផលិតផលជលផលនាំចេញនាំចូល។

៩. ពង្រីកទីផ្សារសម្រាប់ផលផលិតផលជលផលដើម្បីលើកស្ទួយការនាំចេញ។

១០. ផ្សព្វផ្សាយនិងអនុវត្តស្តង់ដារជាតិស្តីពីផលិតផលប្រហុក ត្រីងៀត បង្គាក្លាស្សេ និងស្តង់ដារសំខាន់ៗ ដែលចាំបាច់ដោយអ្នកកែច្នៃ។

១១. លើកកម្ពស់ខ្សែសង្វាក់ផលិតកម្មកែច្នៃ គុណភាព សុវត្ថិភាព នៃផលផលិតផល ជលផលដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

## ៣.៩ អនុកម្មវិធីទី ៣.៩ ÷ ការពារ និងអភិរក្សធនធានជលផល

**គោលបំណង÷** "រក្សាបានធនធានជលផល តាមរយៈការការពារនិងអភិរក្ស ដើម្បីរួមចំណែកធានាបានការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព"។

**សូចនាករ**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. បរិមាណនៃប្រភេទកំពុងរងគ្រោះថ្នាក់នីមួយៗ ត្រូវបានកើនឡើងនៅក្នុងបឹងធម្មជាតិ | % | ៣ | ៥ | ៨ | ១០ | ១៥ | ២០ |
| ២. កន្លែងការពារនិងអភិរក្សធនធានជលផល ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព | ចំនួន | ៣១ | ៤០ | ៥០ | ៦៥ | ៧០ | ៧៥ |
| ៣. បរិមាណជីវចម្រុះធនធានជលផលក្នុងដែននេសាទដែលបានដាំព្រៃលិចទឹកនិងព្រៃកោងកាងឡើងវិញកើនឡើង | % | ៣ | ៥ | ៨ | ១០ | ១៣ | ១៥ |

**គម្រោងសកម្មភាព**

១. ដាំព្រៃលិចទឹកនិងព្រៃកោងកាងសម្រាប់បង្កើនធនធានជលផល។

២. ផ្សព្វផ្សាយពីសារសំខាន់នៃទីជម្រកជលផល និងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់។

៣. បង្កើតនិងកែលម្អកន្លែងអភិរក្សជលផលសមុទ្រតំបន់ឆ្នេរ។

៤. បង្កើតនិងកែលម្អកន្លែងអភិរក្សជលផលក្នុងតំបន់ទឹកសាប។

៥. ការពារនិងអភិរក្សសត្វផ្សោតទន្លេមេគង្គ និងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់។

៦. សិក្សាស្រាវជ្រាវប្រភេទជីវចម្រុះមាននៅក្នុងតំបន់អភិរក្សជលផលសមុទ្រ និងតំបន់

ដែលបានដាំព្រៃលិចទឹកនិងព្រៃកោងកាងឡើងវិញ។

៧. ពង្រឹងការអភិរក្សក្រពើព្រៃនិងការលើកកម្ពស់កសិដ្ឋានចិញ្ចឹមក្រពើយកស្បែកដែលមានគុណភាពសម្រាប់ទីផ្សារអន្តរជាតិ។

៨. លើកកម្ពស់ការអភិវឌ្ឍនិងការគ្រប់គ្រងកាបូនពីវិស័យជលផល។

## ៣.១០ អនុកម្មវិធីទី ៣.១០÷ ការអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល

**គោលបំណង** ÷ "ដើម្បីគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍វិស័យជលផល តាមរយៈការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រឲ្យមានប្រសិទ្ធភាព"។

**សូចនាករ**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. អត្រានៃសកម្មភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ សម្រាប់វិស័យជលផលត្រូវបានអនុវត្តដោយជោគជ័យ | % | ៨០ | ៩០ | ៩០ | ៩០ | ៩០ | ៩០ |
| ២. អត្រានៃសកម្មភាពដែលបានអនុវត្តត្រូវបានតាមដាន និងវាយតម្លៃ | % | ៥ | ១០ | ២០ | ៣០ | ៤០ | ៥០ |

**គម្រោងសកម្មភាព**

១. រៀបចំរបាយការណ៍វឌ្ឍនភាពនិងសម្រេចបានរយៈពេល០៣ឆ្នាំនៃការអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១១-២០១៣។

២. រៀបចំធ្វើបច្ចុប្បន្នភាពក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល។

៣. ការរៀបចំផែនការសកម្មភាពវិស័យជលផលប្រចាំឆ្នាំ។

៤. ប្រមូលស្ថិតិនិងព័ត៌មានជលផល តាមរយៈការកសាងសមត្ថភាពមន្ត្រី និងអនុវត្តផ្ទាល់។

៥. តាមដាននិងវាយតម្លៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ។

៦. រៀបចំឯកសារគតិយុត្តពាក់ព័ន្ធនឹងការនាំចេញនិងនាំចូលផល ផលិតផលជលផល។

៧. ក្រុមការងារបច្ចេកទេសជលផលដំណើរការ និងសម្របសម្រួលការងាររវាងរដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលមានភាពល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាព។

៨. រៀបចំនិងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រ សម្រាប់ការជំរុញទីផ្សារនៃផល និងផលិតផលជលផល។

៩. រៀបចំនិងអនុវត្តផែនការ យុទ្ធសាស្ត្រសម្រាប់ជំរុញចលនាភូមិ១ ផលិតផលជលផល១ ឬ សេវាកម្មមួយក្នុងវិស័យជលផល។

## ៣.១១ អនុកម្មវិធីទី ៣.១១÷ អភិបាលកិច្ច និងប្រតិបត្តិការទូទៅរបស់រដ្ឋបាលជលផល

**គោលបំណង** ÷ "ដើម្បីបង្កភាពងាយស្រួលក្នុងការប្រើប្រាស់ថវិកា និងធ្វើឱ្យកាន់តែប្រសើរឡើងទៅលើមុខចំណាយនីមួយៗ ជាពិសេសលើការផ្គត់ផ្គង់ដែលត្រូវការចាំបាច់ប្រកបដោយប្រសិទ្ធភាព"។

### សូចនាករ

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| អត្រានៃការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព | % | ៩៥ | ៩៨ | ៩៨ | ៩៨ | ៩៨ | ៩៩ |

### គម្រោងសកម្មភាព

១. ផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រេងរំអិល សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល ការចំណាយសំលៀកបំពាក់។

២. ផ្គត់ផ្គង់ការចំណាយស្បៀងអាហារ និងផលិតផលកសិកម្ម (ចំណីត្រី)។

៣. សម្របសម្រួលការចំណាយសម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ ការទូទាត់ចំណាយថាមពល និងទឹក ការចំណាយការថែទាំ និងជួសជុល។

៤. សម្របសម្រួលផ្តល់សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ។

៥. ចំណាយទំនាក់ទំនងសាធារណៈ ផ្សព្វផ្សាយ និងសោហ៊ុយជាវសារព័ត៌មាន។ ឯកសារចំណាយទូទាត់សោហ៊ុយក្នុងប្រទេស។

៦. សោហ៊ុយទូរគមនាគមន៍ ទូរស័ព្ទតេឡិច ទូរសារប្រៃសណីយ៍។

## ៤.កម្មវិធីទី-៤÷ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព

### ៤.១ អនុកម្មវិធីទី៤.១៖ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ព្រៃឈើ និងសហគមន៍ព្រៃឈើ

**គោលបំណង៖** "រៀបចំគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ តាមរយៈការកំណត់ព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ បង្កើតនូវសុវត្ថិភាពកម្មសិទ្ធិដោយចុះបញ្ជីជាដីរដ្ឋ បង្កើនចំនួនសហគមន៍ព្រៃឈើ និងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន"។

**សូចនាករ ៖**

| សូចនាករនៃលទ្ធផល | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១.ប្រវែងព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ត្រូវបានបោះបង្គោល (គ.ម) | គ.ម | ៩៧ | ៣៥០ | ៤៥៥ | ៥៩២ | ៧៦៩ | ១.០០០ |
| ២.ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើន និងពង្រឹង | ចំនួន | ៥៤ | ៣២ | ៣២ | ៣២ | ៣២ | ៣២ |

**គម្រោងសកម្មភាព៖**

១. កំណត់ព្រំប្រទល់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ រៀបចំព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលបានចាត់ថ្នាក់ហើយសម្រាប់ចុះបញ្ជីដីរដ្ឋ ចាត់ថ្នាក់ព្រៃឈើតាមមុខងារ។

២. បណ្តុះបណ្តាលការអានផែនទី និងប្រើប្រាស់ឧបករណ៍ GPS ដល់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន។

៣. បណ្តុះបណ្តាលអំពីបច្ចេកទេសធ្វើសារពើភ័ណ្ឌព្រៃឈើសម្រាប់វាយតម្លៃបរិមាណកាបូនស្តុក គាំទ្រដល់កម្មវិធីរ៉េដបូកកម្ពុជា។

៤. ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអន្ត្រៃយ៍ ផ្សព្វផ្សាយស្តីពីសារសំខាន់នៃការគ្រប់គ្រងទីជម្រាល។

៥. ធ្វើនិយ័តកម្មនិងរៀបចំបង្កើតសហគមន៍ព្រៃឈើ ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ រៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ និងសុំការអនុម័ត ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សមាជិកសហគមន៍ព្រៃឈើ។

៦. លើកកម្ពស់ការយល់ដឹងលើការពង្រឹងអនុវត្តច្បាប់ និងអភិបាលកិច្ចព្រៃសហគមន៍ ពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើក្នុងការគ្រប់គ្រងព្រៃសហគមន៍។

៧. បណ្តុះបណ្តាលស្តីពីបច្ចេកទេសសារពើភ័ណ្ឌប៉ាន់ស្មានធនធានព្រៃឈើ វាយតម្លៃធនធានព្រៃឈើនិងស្ថានភាពព្រៃដើម្បីកំណត់ជាតំបន់ទេសភាព។

៨. កំណត់តំបន់សក្តានុពលប្រភពធនធានឈើសម្រាប់ដកហូតមកប្រើប្រាស់ក្នុងស្រុក។

៩. បណ្តុះបណ្តាលស្តីពីការបំពេញទិន្នន័យក្នុងទម្រង់តាមដានត្រួតពិនិត្យ វាយតម្លៃ និងរបាយការណ៍ស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព (MAR-SFM)។

១០.ពង្រឹងសមត្ថភាពផ្នែករដ្ឋបាលព្រៃឈើក្នុងការរៀបចំផែនការគ្រប់គ្រងព្រៃឈើ សម្របសម្រួលរៀបចំផែនការសកម្មភាពគ្រប់គ្រងព្រៃឈើជាតិ ចុះសម្របសម្រួលវាយតម្លៃការងារនិងរៀបចំផែនការគ្រប់គ្រងព្រៃឈើ (MAR) កម្រិតផ្នែករដ្ឋបាលព្រៃឈើទាំងអស់។

១១. រៀបចំបច្ចេកទេស និងចុះផ្សព្វផ្សាយស្តីពីការការពារទប់ស្កាត់ភ្លើងឆេះព្រៃ រៀបចំបោះពុម្ពស្លាកសម្គាល់ និងលិខិតអនុញ្ញាតចរាចរក្នុងវិស័យព្រៃឈើ។

## ៤.២ អនុកម្មវិធីទី៤.២៖ ការអភិវឌ្ឍចម្ការឈើដាំ និងរុក្ខវប្បកម្ម

**គោលបំណង** ÷ "បង្កើនការដាំឈើនិងស្តារព្រៃឈើឡើងវិញលើដីព្រៃរេចរឹល ដើម្បីចូលរួមចំណែកបម្រើផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន"។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ផ្ទៃដីអភិវឌ្ឍចំការឈើដាំ (រដ្ឋនិងដៃគូឯកជន) | ហ.ត | ១៧.៩៥០ | ២០.២៨០ | ២២.៣០០ | ២៤.៥០០ | ២៧.០០០ | ២៩.៧០០ |
| ២. កូនឈើត្រូវបានបណ្តុះ | ពាន់ដើម | ៨.១០០ | ១០.០០០ | ១០.០០០ | ១០.០០០ | ១០.០០០ | ១០.០០០ |

**គម្រោងសកម្មភាព៖**

១. ដាំឈើជាចំការថ្មី និងការថែទាំចំការឈើចាស់ឆ្នាំទី១ដល់ឆ្នាំទី៥។

២. បណ្តុះកូនឈើសម្រាប់ចែកចាយដល់ប្រជាពលរដ្ឋដាំអាស្រ័យផល។

៣. រៀបចំប្រារព្ធពិធីបុណ្យរុក្ខទិវាទូទាំងប្រទេស។

៤. រៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធថ្នាលបណ្តុះកូនឈើ។

៥. រៀបចំអនុវត្តការអភិវឌ្ឍធនធានសេនេទិច។

៦. អនុវត្តប្រព័ន្ធកសិ-រុក្ខកម្ម និងថែទាំឡូត៍បង្ហាញចាស់។

៧. រៀបចំសារពើភ័ណ្ឌចម្ការព្រៃដាំ និងរៀបចំផែនទីចម្ការព្រៃដាំ។

## ៤.៣ អនុកម្មវិធីទី៤.៣៖ ការអភិរក្សសត្វព្រៃ និងជីវចម្រុះ

**គោលបំណង** ៖ "បង្កើនការអភិរក្សសត្វព្រៃ ការគ្រប់គ្រងតំបន់ព្រៃការពារ និងជំរុញការផ្តល់សេវាសាធារណៈ តាមរយៈការរៀបចំទេសចរណ៍ធម្មជាតិ"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១.ផ្ទៃដីព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃត្រូវបានពង្រឹងការគ្រប់គ្រងនិងពង្រីកបន្ថែម (ឆ្នាំ២០១២ សម្រេចបាន១,៥លានហិកតា) | ហិកតា | ៥០.០០០ | ៥០.០០០ | ៥០.០០០ | ៥០.០០០ | ៥០.០០០ |
| ២.តំបន់ទេសចរណ៍ធម្មជាតិត្រូវបានកំណត់ | តំបន់ | ១ | ១ | ១ | ១ | ១ |

**គម្រោងសកម្មភាព៖**

១. ពង្រឹងការគ្រប់គ្រងតំបន់ព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃ។

២. រៀបចំបង្កើតតំបន់ព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃ (តំបន់ព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃបានពង្រីកបន្ថែម៥០.០០០ហិកតា/ឆ្នាំ)។

៣. សិក្សាស្រាវជ្រាវ និងកំណត់តំបន់ព្រៃឈើដែលមានសក្តានុពលសម្រាប់ទេសចរណ៍ធម្មជាតិ។

៤. ស្រាវជ្រាវតាមដានស្ថានភាពសត្វព្រៃសំខាន់ៗ។

៥. ផ្សព្វផ្សាយអំពីការទប់ស្កាត់ការជួញដូរសត្វព្រៃ។

៦. ចុះសិក្សានិងចុះបញ្ជិកាចិញ្ចឹមសត្វព្រៃ។

៧. ចុះត្រួតពិនិត្យកសិដ្ឋានចិញ្ចឹមសត្វព្រៃ និងសួនសត្វ។

៨. ថែរក្សាព្រៃឈើក្នុងតំបន់អភិរក្សជីវចម្រុះនិងសត្វព្រៃ។

៩. រៀបចំវគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយស្តីពីជីវចម្រុះ។

១០. រៀបចំនិងចូលរួមកិច្ចប្រជុំផ្សេងៗ (ក្នុងនិងក្រៅប្រទេស) ដើម្បីពង្រឹងការអភិរក្សសត្វព្រៃ និងជីវចម្រុះ។

### ៤.៤ អនុកម្មវិធីទី៤.៤៖ ការសង្គ្រោះ ស្តារលទ្ធភាពជីវសាស្ត្រ បង្កាត់ពូជ និងដោះលែងសត្វព្រៃចូលក្នុងដែនព្រៃធម្មជាតិ

**គោលបំណង ៖** "ទប់ស្កាត់ការផុតពូជធនធានសត្វព្រៃ ព្រៃឈើ និង ជីវចម្រុះ តាមរយៈការសង្គ្រោះ បង្កាត់ពូជ អប់រំផ្សព្វផ្សាយ និងសេវាកម្មទេសចរណ៍ ដើម្បីធានាបាននិរន្តរភាពរវាងតម្រូវការសេដ្ឋកិច្ច សង្គម និង បរិស្ថាន"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនសត្វព្រៃត្រូវបានសង្គ្រោះនិងថែរក្សា | ក្បាល | ១.០០០ | ១.០០០ | ១.០០០ | ១.០០០ | ១.០០០ | ១.០០០ |
| ២. អត្រាសត្វព្រៃសង្គ្រោះត្រូវបានដោះលែង | % | ៥០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ |

**គម្រោងសកម្មភាព៖**

១. អភិវឌ្ឍន៍របងសុវត្ថិភាពឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ។

២. ផ្គត់ផ្គង់ទឹក និងដឹកជញ្ជូន។

៣. ការផ្គត់ផ្គង់ចំណីសត្វ។

៤. សង្គ្រោះនិងព្យាបាលសត្វព្រៃ។

៥. សាងសង់ទ្រុងសត្វស្លាបឲ្យសមស្របតាមលក្ខណៈជីវសាស្ត្រ។

៦. គាំទ្រប្រតិបត្តការ ផ្គត់ផ្គង់សម្ភារផ្នែករដ្ឋបាល ផ្គត់ផ្គង់ថាមពល ការជួសជុល និងថែទាំ។

៧. ស្តារជីវសាស្ត្រសត្វព្រៃនិងដោះលែង។

៨. អប់រំផ្សព្វផ្សាយបរិស្ថានព្រៃឈើ និងសត្វព្រៃ។
៩. ការការពារភ្លើងព្រៃ។

## ៤.៥ អនុកម្មវិធីទី៤.៥៖ ការគ្រប់គ្រង និងអភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ ពាណិជ្ជកម្ម និង សហប្រតិបត្តិការអន្តរជាតិ

**គោលបំណង ៖** "ដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ ពាណិជ្ជកម្មពីប្រភពឈើក្នុងនិងក្រៅស្រុក សំដៅបង្កើនគុណភាពផលិតផល ឆ្លើយតបតាមលក្ខខណ្ឌនៃតម្រូវការរបស់ទីផ្សារ និងកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ ព្រមទាំងបង្កើនចំណេះដឹងស្តីពីការអនុវត្តគម្រោងរេដបូក"។

**សូចនាករ**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១.ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃផល អនុផលព្រៃឈើ និងពាណិជ្ជកម្ម | ពាន់ម៉ែត្រគូប | ១៦,៥ | ១៨ | ២០ | ២២ | ២៤ | ២៦,៥ |
| ២.ប្រជុំផ្សព្វផ្សាយ បណ្តុះបណ្តាលយន្តការរ៉េតបូកនិងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ | ដង/ឆ្នាំ | - | - | ២៧ | ២៧ | ២៧ | ២៧ |

**គម្រោងសកម្មភាព៖**

១. រៀបចំផែនការសកម្មភាព ផែនការថវិកា ផែនការយុទ្ធសាស្ត្រ សម្រាប់គ្រប់គ្រងការអភិវឌ្ឍឧស្សាហកម្មព្រៃឈើ ពាណិជ្ជកម្ម និងសហប្រតិបត្តិការអន្តរជាតិ។
២. បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងធ្វើបច្ចុប្បន្នភាពឧស្សាហកម្មព្រៃឈើ។
៣. សិក្សាស្រាវជ្រាវពីបច្ចេកទេសកែច្នៃផល អនុផលព្រៃឈើ និងធ្វើបច្ចុប្បន្នភាព។
៤. បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងធ្វើបច្ចុប្បន្នភាពពាណិជ្ជកម្មឈើ។
៥. សិក្សាស្រាវជ្រាវកំណត់ និងចងក្រងសៀវភៅបញ្ជីឈ្មោះពាណិជ្ជកម្មផលអនុផលព្រៃឈើប្រើប្រាស់ក្នុងស្រុក នាំចេញ នាំចូល និងឆ្លងកាត់។
៦. សិក្សានិងធ្វើបច្ចុប្បន្នភាពតម្លៃឈើលើទីផ្សារក្នុងស្រុកនិងអន្តរជាតិ។
៧. ផ្សព្វផ្សាយព័ត៌មានទីផ្សារដល់សហគមន៍មូលដ្ឋាន ផ្នែកឯកជន និងផលិតករដែលពាក់ព័ន្ធ។
៨. សម្របសម្រួលនិងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយដៃគូនិងអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក តាមដានការអនុវត្តកិច្ចព្រមព្រៀងអនុស្សរណៈ អនុសញ្ញាជាតិដែលពាក់ព័ន្ធវិស័យព្រៃឈើ។
៩. រៀបចំសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិនិងថ្នាក់ខេត្ត ស្តីពីការប្រែប្រួលអាកាសធាតុ និងយន្តការរេដ។

១០. រៀបចំផលិតសម្ភារផ្សព្វផ្សាយ (ផ្ទាំងរូបភាព និងសៀវភៅណែនាំ ដល់សាធារណជនទូទៅ ស្តីពីរ៉េដបូក និងការប្រែប្រួលអាកាសធាតុ)។
១១. សិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា ក្នុងការរៀបចំយុទ្ធសាស្ត្ររ៉េដបូក ថ្នាក់ជាតិ និងគោលនយោបាយពាក់ព័ន្ធ។
១២. ចុះសម្របសម្រួល តាមដាន និងវាយតម្លៃ ការអនុវត្តគម្រោងរ៉េដបូកថ្នាក់ក្រោមជាតិ ជាមួយ អង្គការដៃគូ។

## ៤.៦ អនុកម្មវិធីទី៤.៦ ÷ ការងារស្រាវជ្រាវ និងពង្រឹងសមត្ថភាពក្នុងវិស័យព្រៃឈើ

**គោលបំណង ÷**

- ពង្រឹងសមត្ថភាពសិក្សាស្រាវជ្រាវក្នុងការគ្រប់គ្រង ស្តារ និងអភិរក្សព្រៃឈើ
- បង្កើនសមត្ថភាព និងបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យព្រៃឈើ
- ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីប្រយោជន៍នៃធនធានឈើ។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនមនុស្សត្រូវបានបណ្តុះបណ្តាល | នាក់/ឆ្នាំ | ១២០ | ២០០ | ២២០ | ២៤០ | ២៦០ | ២៨០ |
| ២. ការផ្សព្វផ្សាយអំពីលិខិតបទដ្ឋានច្បាប់និងផលប្រយោជន៍នៃធនធានព្រៃឈើដល់អ្នកពាក់ព័ន្ធ | វគ្គ | - | ១ | ១០ | ១៥ | ២០ | ២៥ |
| ៣. គម្រោងស្រាវជ្រាវអំពីព្រៃឈើ និងជីវចម្រុះត្រូវបានរៀបចំ និងអនុវត្ត | គម្រោង | - | ១ | ២ | ៤ | ៦ | ៨ |

**គម្រោងសកម្មភាព៖**

១. រៀបចំផ្សព្វផ្សាយនិងបណ្តុះបណ្តាលសម្រាប់ការងារគ្រប់គ្រង និងអភិរក្សព្រៃឈើ។
២. ការដាំដូសនិងថៃទាំចម្ការកូនឈើស្រាវជ្រាវ។
៣.បង្កើតឡូត៍ពិសោធន៍ស្រាវជ្រាវប្រភេទរុក្ខជាតិដែលធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងសាកល្បងដាំបញ្ចូលនូវប្រភេទឈើក្នុងស្រុកដែលមានលក្ខណៈបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។
៤. រៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសជំនាញដល់មន្ត្រីរដ្ឋបាលព្រៃឈើប្រចាំឆ្នាំ។
៥. បង្កើតស្ថានីយស្រាវជ្រាវនិងស្តារព្រៃឈើឡើងវិញ នៅតាមបណ្តាខណ្ឌរដ្ឋបាលព្រៃ ឈើ។
៦.រៀបចំគម្រោង និងកម្មវិធីសិក្សាស្រាវជ្រាវបច្ចេកទេសថ្មីៗ ពិសេសពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ។
៧.ប្រមូលនិងអភិរក្ស គ្រាប់ពូជឈើ ពិសេសគ្រាប់ពូជឈើដែលជិតផុតពូជ។

## ៤.៧-អនុកម្មវិធីទី៤.៧៖ ពង្រឹងការអនុវត្តច្បាប់ ដើម្បីចូលរួមចំណែកថែរក្សាការពារ ព្រៃឈើប្រកបដោយនិរន្តរភាព

**គោលបំណង ៖**

- បង្កើនការយល់ដឹងអំពីច្បាប់ស្តីពីព្រៃឈើ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃឈើ ដើម្បីចូលរួមចំណែកថែរក្សាការពារធនធានព្រៃឈើប្រកបដោយនិរន្តរភាព
- គ្រប់គ្រងទិន្នន័យសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃឈើ ឲ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាព។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១. បង្កើនការពង្រឹងការអនុវត្តច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងបទល្មើសព្រៃឈើ | ចំនួនលើកចុះបង្ក្រាប | - | ១៧៥ | ២០០ | ២២៥ | ២៥០ |
| ២. ពិនិត្យ និងផ្ទៀងផ្ទាត់វត្ថុតាងបទល្មើសព្រៃឈើដែលបានចងក្រងក្នុងសំណុំរឿងបទល្មើសព្រៃឈើ | ចំនួនករណី | ២០០ | ១៥០ | ១៥០ | ១០០ | ១០០ |

**គម្រោងសកម្មភាព៖**

១. រៀបចំ ចងក្រង បោះពុម្ពផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំ។

២. រៀបចំប្រជុំនៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត។

៣. ផ្សព្វផ្សាយនិងបណ្តុះបណ្តាលច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបែបបទបច្ចេកទេសពាក់ព័ន្ធព្រៃឈើ។

៤. ចុះពង្រឹងការអនុវត្តច្បាប់នៅតាមមូលដ្ឋាន។

៥. ផលិតផែនទី និងរៀបចំស្លាកសញ្ញាសម្គាល់ និងបោះនៅលើទីតាំងដីព្រៃឈើ ដែលបានដកហូត។

៦. រៀបចំចងក្រង និងបោះពុម្ពរបាយការណ៍ និងឯកសារនានា។

៧. ចុះតាមដាន ត្រួតពិនិត្យផ្ទៀងផ្ទាត់លើការងារពាក់ព័ន្ធការកាប់រានដីព្រៃឈើ។

៨. ស្រង់ព័ត៌មានព្រៃឈើពីសារព័ត៌មាន និងស្រាវជ្រាវផ្ទៀងផ្ទាត់ព័ត៌មាន និងចាត់វិធានការតាមនីតិវិធីនៃច្បាប់។

៩. បង្កើតប្រព័ន្ធទូរស័ព្ទមិនបង់ប្រាក់ និងប្រព័ន្ធផ្ញើសារដើម្បីទទួលព័ត៌មានបទល្មើសព្រៃឈើពីសាធារណជន។

១០. ចុះពិនិត្យនិងផ្ទៀងផ្ទាត់សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ ដីព្រៃឈើ និងវត្ថុតាងនៃបទល្មើសព្រៃឈើ។

១១. រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃឈើ។

១២. តាមដាននិងជំរុញសំណុំរឿងបទល្មើសព្រៃឈើនៅតុលាការ ព្រមទាំងចូលរួមបំភ្លឺ និងសវនាការ នៅតុលាការ។

១៣. ប្រមូលចងក្រងនិងបោះពុម្ព លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យព្រៃឈើ។

១៤. ទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើសត្វព្រៃនិងកាប់រានដីព្រៃឈើដោយខណ្ឌរដ្ឋបាលព្រៃឈើមូលដ្ឋាន។

១៥. ចុះតាមដានត្រួតពិនិត្យ និងតម្រង់ទិសដល់ខណ្ឌរដ្ឋបាលព្រៃឈើមូលដ្ឋាន។

## ៤.៨ អនុកម្មវិធីទី៤.៨÷ បង្កើនប្រសិទ្ធភាពការអនុវត្តផែនការ និងការគ្រប់គ្រងថវិការដ្ឋបាលព្រៃឈើ

**គោលបំណង÷** "ពង្រឹងគណនេយ្យភាព តម្លាភាពនៃការគ្រប់គ្រងថវិកា និងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព្រៃឈើនិងសត្វព្រៃ"។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនសកម្មភាពតាមបណ្តាអនុកម្មវិធីត្រូវបានជំរុញឲ្យអនុវត្ត | ភាគរយ | ៥០ | ៦០ | ៦៥ | ៧០ | ៧៥ | ៨០ |
| ២. ប្រសិទ្ធភាពនៃការអនុវត្តថវិកា | ភាគរយ | ៩០ | ៩៤ | ៩៥ | ៩៦ | ៩៧ | ៩៨ |

**គម្រោងសកម្មភាព៖**

១. ចុះយុទ្ធនាការផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋានស្តីពីសារប្រយោជន៍ព្រៃឈើ និងគោលនយោបាយវិស័យព្រៃឈើ ចុះផ្សព្វផ្សាយដល់សហគមន៍ព្រៃឈើពីសារសំខាន់ នៃការបញ្ជ្រាបយេនឌ័រក្នុងវិស័យព្រៃឈើ។

២. រៀបចំគ្រប់គ្រង និងទុកដាក់ឯកសារបណ្ណាល័យរដ្ឋបាលព្រៃឈើ ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ធ្វើការផ្សព្វផ្សាយឯកសារបច្ចេកទេសស្រាវជ្រាវមួយចំនួន និងកិច្ចប្រជុំក្នុងវិស័យព្រៃឈើតាមប្រព័ន្ធព័ត៌មាន រៀបចំរចនាសម្ព័ន្ធ និងធ្វើបច្ចុប្បន្នភាពទិន្នន័យ គេហទំព័ររដ្ឋបាលព្រៃឈើ www.forestry.gov.kh និងសេវាប្រើប្រាស់ Internet រដ្ឋបាលព្រៃឈើ រៀបចំនិងបោះពុម្ពផ្សាយឯកសារវិស័យព្រៃឈើ និងចងក្រងសៀវភៅស្ថិតិវិស័យព្រៃឈើ។

៣. រៀបចំបូកសរុបការអនុវត្តផែនការ រៀបចំផែនការសកម្មភាព ផែនការថវិកា ផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងនិងអនុវត្តប្រចាំឆ្នាំ ចុះសម្របសម្រួលកំណត់អាទិភាព រៀបចំកម្មវិធីអនុកម្មវិធី គម្រោងអភិវឌ្ឍន៍វិស័យព្រៃឈើ ដោយសហការជាមួយបណ្តាអង្គភាពពាក់ព័ន្ធក្រោមឱវាទរដ្ឋបាលព្រៃឈើ។

៤. ចុះតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធី អនុកម្មវិធី ដែលបានអនុវត្ត ប្រមូល និង បូកសរុបរបាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃ ការអនុវត្តគម្រោងកម្មវិធី អនុកម្មវិធីពាក់ព័ន្ធ វិស័យព្រៃឈើ។

៥. ត្រួតពិនិត្យនិងវាយតម្លៃ និងធ្វើបច្ចុប្បន្នភាពទិន្នន័យ M&E ក្នុងគេហទំព័រ ប្រមូលពត៌មាន រៀបចំទិន្នន័យបច្ចុប្បន្នភាព សម្រាប់បង្ហោះក្នុងគេហទំព័រអាស៊ាន www.arkn-fpd.org។

៦. សិក្សាពីប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី អនុកម្មវិធីអភិវឌ្ឍន៍វិស័យព្រៃឈើ តាមបណ្តា អង្គភាពក្រោមឱវាទរដ្ឋបាលព្រៃឈើ បញ្ចូលទិន្នន័យកម្មវិធី អនុកម្មវិធី គម្រោងអភិវឌ្ឍន៍ពាក់ ព័ន្ធវិស័យព្រៃឈើ ទៅក្នុងប្រព័ន្ធទិន្នន័យនៃកម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យ និងធ្វើទិន្នន័យ តាមរបាយការណ៍វឌ្ឍនភាព។

## ៥. កម្មវិធីទី-៥ ÷ "ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម"

### ៥.១ អនុកម្មវិធីទី៥.១ ÷ លើកកម្ពស់ការកសាងនិងការអនុវត្តផែនការគោលនយោបាយ និងវិនិយោគកសិកម្ម

**គោលបំណង ÷** "បង្កើនសមត្ថភាពកសាងនិងអនុវត្តផែនការគោលនយោបាយ ផែនការថវិកា ពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិនិងទីផ្សារកសិកម្ម និងការគ្រប់គ្រងគម្រោងវិនិយោគ សាធារណៈ និងឯកជនប្រកបដោយប្រសិទ្ធភាព"។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. អនុបាត (%) នៃការអនុវត្ត សកម្មភាពសម្រាប់ថវិកាកម្មវិធី | ភាគរយ | ៩២ | ៩៣ | ៩៤ | ៩៥ | ៩៥ | ៩៥ |
| ២. ចំនួនសំណាកនៃការអង្កេត ស្ទង់ទិន្នផលស្រូវ | ពាន់សំណាក | ៧ | ១២,៥០ | ៣០ | ៣៥ | ៤៥ | ៦០ |
| ៣. ចំនួន SMS ត្រូវបានប្រើប្រាស់ សម្រាប់ព័ត៌មានទីផ្សារកសិកម្ម | ពាន់ SMS/ឆ្នាំ | ១៨,៥០ | ២១ | ២២ | ២៣ | ២៤ | ២៥ |

**គម្រោងសកម្មភាព៖**

១. វគ្គបណ្តុះបណ្តាលស្តីអំពីការណែនាំនិងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោង វិនិយោគសាធារណៈ (PIP)។

២. បំពាក់បំប៉នដើម្បីបង្កើនសមត្ថភាពគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទិន្នន័យ PIP និងការរក្សា និងថែទាំប្រព័ន្ធ PIP។

៣. ចុះពង្រឹងសមត្ថភាពលើការគ្រប់គ្រងទិន្នន័យដីសម្បទានសេដ្ឋកិច្ចតាមបណ្តាខេត្តគោលដៅ និងក្រុមហ៊ុនវិនិយោគ (ថ្នាក់ខេត្ត ១៨ខេត្ត)។
៤. រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបង្កើនសមត្ថភាពលើការប្រើប្រាស់ប្រព័ន្ធ GPS GIS លើដីសម្បទានសេដ្ឋកិច្ច (ថ្នាក់ខេត្ត ១៨ខេត្ត)។
៥. ចុះត្រួតពិនិត្យតាមដានការអនុវត្តរបស់មន្ទីរកសិកម្មក្នុងខេត្តគោលដៅសំដៅជំរុញតាមដានត្រួតពិនិត្យវាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនវិនិយោគដីសម្បទាន។
៦. រៀបចំកសាងផែនទី (Mapping) និងរៀបចំព្រឹត្តិបត្រដីសម្បទានសេដ្ឋកិច្ច។
៧. រៀបចំកសាងផែនការមេរយៈពេលវែងសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មរយៈពេល២០ឆ្នាំ។
៨. រៀបចំកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨។
៩. បើកវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការថវិកាប្រចាំឆ្នាំ PB និងផែនការយុទ្ធសាស្ត្រថវិកាថ្នាក់កណ្តាល។
១០. បើកវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការថវិកាប្រចាំឆ្នាំ (PB) និងផែនការយុទ្ធសាស្ត្រថវិកា (BSP) ថ្នាក់ខេត្ត។
១១. ចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិស្រូវពូជតាមបណ្តាមន្ទីរកសិកម្មខេត្ត។
១២. ចុះតាមដាននិងវាយតម្លៃការអនុវត្តគម្រោងនិងថវិកាតាមកម្មវិធីលើទីវាល។
១៣. រៀបចំសិក្ខាសាលាវាយតម្លៃការអនុវត្តថវិកាតាមកម្មវិធីប្រចាំឆមាស។
១៤. បើកវគ្គបំពាក់បំប៉ន់ស្តីពីប្រព័ន្ធតាមដាននិងវាយតម្លៃថវិកាតាមកម្មវិធី។
១៥. រៀបចំសិក្ខាសាលាបូកសរុបលទ្ធផលនៃការអនុវត្តថវិកាតាមកម្មវិធីប្រចាំឆ្នាំ។
១៦. បោះពុម្ពរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាតាមកម្មវិធី។
១៧. រៀបចំសិក្ខាសាលាវាយតម្លៃសភាពការណ៍បង្កបង្កើនផលកសិកម្ម។
១៨. ចុះធ្វើអង្កេតស្ទង់ទិន្នផលស្រូវ។
១៩. ចុះធ្វើអង្កេតស្ទង់ទិន្នផលដំណាំអចិន្ត្រៃយ៍។
២០. ចុះធ្វើអង្កេតថ្លៃដើមផលិតកម្មដំណាំកសិកម្ម។
២១. បើកវគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្រអង្កេត/ស្ថិតិកសិកម្ម។
២២. ចងក្រងនិងបោះពុម្ពព្រឹត្តិបត្រស្ថិតិកសិកម្មប្រចាំឆ្នាំ។
២៣. ចុះប្រមូលទិន្នន័យតម្លៃកសិផលនៅទូទាំង២៥ខេត្ត រាជធានី។
២៤. ចងក្រងនិងបោះពុម្ពព្រឹត្តិបត្រព័ត៌មានតម្លៃទីផ្សារកសិកម្ម។
២៥. ផ្សព្វផ្សាយព័ត៌មានតម្លៃទីផ្សារកសិកម្មតាមរយៈ SMS & Website។
២៦. ចុះពិនិត្យតាមដានអំពីការប្រមូលព័ត៌មានតម្លៃទីផ្សារកសិកម្ម។
២៧. សិក្ខាសាលាបំពាក់បំប៉នអំពីការប្រើប្រាស់ព័ត៌មានតម្លៃទីផ្សារកសិកម្មតាមប្រព័ន្ធ SMS
២៨. ចុះសិក្សាពីចរាចរស្រូវក្នុងស្រុកនិងការនាំចេញទៅប្រទេសជិតខាង។
២៩. សិក្ខាសាលាបំពាក់បំប៉នមន្ត្រីប្រមូលព័ត៌មានទីផ្សារកសិកម្ម។
៣០. សិក្ខាសាលាបំពាក់បំប៉នអំពីសាលារៀនទីផ្សារកសិករ (FMS)។

៣១. ចុះសិក្សាពីផលិតកម្ម ទីផ្សារជំឡូងមី និងកសិផលផ្សេងទៀត។
៣២. ចុះសិក្សាពីស្ថានភាពផ្គត់ផ្គង់ និងតម្រូវការបន្លែនៅទីផ្សារភ្នំពេញ។
៣៣. បើកវគ្គបំពាក់បំប៉នអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងវិស័យកសិកម្ម។
៣៤. ចុះពិនិត្យនិងវាយតម្លៃផ្ទៃដីត្រូវរក្សាទុកនៅក្នុងដីសម្បទានសេដ្ឋកិច្ច។

## ៥-២ អនុកម្មវិធីទី២ ÷ បង្កើនប្រសិទ្ធភាពការគ្រប់គ្រងនិងការអនុវត្តថវិកា

**គោលបំណង ÷** "ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព ភាពស័ក្តិសិទ្ធក្នុងការរៀបចំថវិកា និងការអនុវត្តថវិកា" ។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១-អនុបាត (%) នៃអ្នកប្រើប្រាស់ប្រព័ន្ធគណនេយ្យ ហិរញ្ញវត្ថុក្នុងកុំព្យូទ័រ | ភាគរយ | ២០ | ៣០ | ៤០ | ៥០ | ៦០ | ៧០ |
| ២-អនុបាត (%) នៃការអនុវត្តថវិកា | ភាគរយ | ៩៣ | ៩៤ | ៩៥ | ៩៦ | ៩៧ | ៩៨ |

**គម្រោងសកម្មភាព៖**

១. បណ្តុះបណ្តាលអំពីការរៀបចំថវិកា ការអនុវត្តថវិកា នីតិវិធីលទ្ធកម្ម និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។
២. បណ្តុះបណ្តាលសមត្ថភាពមន្ត្រីនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ។
៣. ចុះត្រួតពិនិត្យ និងពង្រឹងសមត្ថភាពមន្ត្រីមន្ទីរកសិកម្មរាជធានីខេត្ត លើនីតិវិធីលទ្ធកម្ម និងនីតិវិធីអនុវត្តថវិកា។
៤. កសាងសមត្ថភាពដល់មន្ត្រីជំនាញនៅថ្នាក់ខេត្ត ស្តីពីការធ្វើវិភាគប៉ាន់ស្មានតម្លៃសម្រាប់គាំទ្រការរៀបចំថវិការបស់មន្ទីរកសិកម្មរាជធានីខេត្ត។
៥. កសាងសមត្ថភាពមន្ត្រីមន្ទីរកសិកម្មរាជធានីខេត្តលើផ្នែកគណនេយ្យ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីដាក់ជូនក្រសួងបានទៀងទាត់ទាន់ពេលវេលា។
៦. បំពាក់កម្មវិធីគ្រប់គ្រងគណនេយ្យហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាឱ្យទៅដល់មន្ទីរកសិកម្មរាជធានីខេត្ត។
៧. រៀបចំនិងបណ្តុះបណ្តាលប្រព័ន្ធគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុទាន់ហេតុការណ៍តាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ថ្នាក់កណ្តាល និងថ្នាក់ខេត្ត។
៨. ត្រួតពិនិត្យនិងពង្រឹងការគ្រប់គ្រងចំណូលដែលប្រមូលដោយថ្នាក់រាជធានីខេត្ត (មន្ទីរកសិកម្មរាជធានី ខេត្ត)។
៩. ត្រួតពិនិត្យនិងជំរុញការអនុវត្តថវិកាតាមអង្គភាពក្រោមឱវាទក្រសួង។
១០. រៀបចំនិងដាក់ឱ្យដំណើរប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុ។

១១. ចុះប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ច។
១២. ត្រួតពិនិត្យនិងផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមអង្គភាពក្រោមឱវាទក្រសួង និងរាជធានីខេត្ត។
១៣. ចុះពិនិត្យវាយតម្លៃ និងជម្រះទ្រព្យសម្បត្តិរដ្ឋ។
១៤. ចុះពិនិត្យផ្ទៀងផ្ទាត់ និងកៀរគរចំណូលតាមអង្គភាពក្រោមឱវាទក្រសួង។
១៥. ពិនិត្យផ្ទៀងផ្ទាត់កិច្ចបញ្ជិកាគណនេយ្យ ហិរញ្ញវត្ថុតាមអង្គភាពក្រោមឱវាទក្រសួង។
១៦. ចុះបិទបញ្ជីគណនេយ្យ ហិរញ្ញវត្ថុប្រចាំឆ្នាំតាមអង្គភាពក្រោមឱវាទក្រសួង។
១៧. សហការចុះពិនិត្យ និងវាយតម្លៃជាមួយគណៈកម្មការក្រសួង គណៈកម្មការអន្តរក្រសួង និងគណៈកម្មការផ្សេងៗទៀត ទៅតាមតួនាទីភារកិច្ចរបស់នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ។
១៨. ស្រាវជ្រាវ ចងក្រង និងបោះពុម្ពលិខិតបទដ្ឋាន ស្តីពីការគ្រប់គ្រងគណនេយ្យ ហិរញ្ញវត្ថុ និងចំណាយបុព្វហេតុរដ្ឋបាលផ្សេងៗ។
១៩. ស្រាវជ្រាវ ចងក្រង និងរកប្រភពចំណូលថ្មីៗពីបណ្តាអង្គភាពក្រោមឱវាទក្រសួង។
២០. សហការនិងសម្របសម្រួលការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ជាមួយអង្គភាពក្រោមឱវាទក្រសួង។
២១. ពង្រឹងការងារគ្រប់គ្រង និងអនុវត្តគម្រោងហិរញ្ញប្បទានជាមួយដៃគូអភិវឌ្ឍន៍។

## ៥.៣ អនុកម្មវិធីទី៥.៣÷ ពង្រឹងការគ្រប់គ្រងស្ថាប័ននិងអភិវឌ្ឍន៍ធនធានមនុស្ស

**គោលបំណង ÷** "លើកកម្ពស់ការងារគ្រប់គ្រងស្ថានប័ន និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយវិន័យ ប្រសិទ្ធភាព ភាពស័ក្តសិទ្ធិ តម្លាភាព និងគណនេយ្យភាព"។

**សូចនាករ ÷**

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១-ចំនួនសិក្ខាសាលាអំពីការពង្រឹងសមត្ថភាពស្ថាប័ន | វគ្គ | - | ៤ | ៤ | ៤ | ៤ |
| ២-ចំនួនការចុះពិនិត្យ និងវាយតម្លៃអំពីការគ្រប់គ្រងមន្ត្រីរាជការ/ចុះប្រមូលទិន្នន័យមន្ត្រីកសិកម្មសម្រាប់កសាង HRMIS | លើក | ២៥ | ៣៥ | ៤០ | ៤៥ | ៥០ |
| ៣-ចំនួនមន្ត្រីរាជការទទួលបានការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | នាក់ | ៤៥៣ | ៥២៥ | ៥៤៥ | ៧១៥ | ៧៣៥ |

**គម្រោងសកម្មភាព៖**

១. រៀបចំសិក្ខាសាលាស្តីពីការត្រួតពិនិត្យមុខងារ និងដំណើរការប្រព្រឹត្តទៅរបស់អង្គភាព។
២. រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការកសាងផែនការយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស។

៣. ចុះប្រមូលទិន្នន័យមន្រ្តីកសិកម្មសម្រាប់រៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមព័ត៌មានវិទ្យា។
៤. កសាងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា។
៥. បណ្តុះបណ្តាលមន្រ្តីស្តីពីការប្រើប្រាស់កម្មវិធីគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា (HRMIS)។
៦. ចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការគ្រប់គ្រងមន្រ្តីរាជការតាមអង្គភាព។
៧. បណ្តុះបណ្តាលមន្រ្តីស្តីពីការពង្រឹងនិងកសាងសមត្ថភាពមន្រ្តីរាជការ។
៨. រៀបចំបញ្ជូនមន្រ្តីរាជការទៅចូលរួមវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស។
៩. រៀបចំកសាងគោលនយោបាយនិងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ធនធានមនុស្ស។

## ៥.៤ អនុកម្មវិធីទី៥.៤÷ បង្កើនប្រសិទ្ធភាពការងារសវនកម្មផ្ទៃក្នុង

**គោលបំណង** ÷ "ជំរុញសវនដ្ឋានឱ្យបំពេញការទទួលខុសត្រូវរបស់ខ្លួន និងប្រសិទ្ធភាពការងារ តាមរយៈការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង"។

**សូចនាករ** ÷

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| អនុបាត (%) ប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍កែលម្អរបស់សវនដ្ឋាន | ភាគរយ | ៦០ | ៦៥ | ៦៧ | ៧០ | ៧៣ | ៧៥ |

**គម្រោងសកម្មភាព៖**

១. ចុះធ្វើសវនកម្មផ្ទៃក្នុងដល់អង្គភាពក្រោមឱវាទក្រសួង ដើម្បីបង្កើនប្រសិទ្ធភាពការងារ។
២. ចុះតាមដានការអនុវត្តអនុសាសន៍របស់សវនដ្ឋាន។
៣.រៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយច្បាប់ តួនាទីភារកិច្ចសវនកម្មផ្ទៃក្នុង។
៤. បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសសវនករផ្ទៃក្នុង។

## ៥.៥ អនុកម្មវិធីទី៥.៥÷ លើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពការងារសហប្រតិបត្តិការអន្តរជាតិ

**គោលបំណង** ÷ "លើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពការងារ សម្របសម្រួលរៀបចំកិច្ចប្រជុំ ត្រួតពិនិត្យគ្រប់គ្រង តាមដាននិងវាយតម្លៃកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មដោយចីរភាព "។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនកិច្ចប្រជុំក្នុងនិងក្រៅប្រទេស | លើក | ៤០ | ៧០ | ៧០ | ៧០ | ៧០ | ៧០ |
| ២. ចំនួនវគ្គបណ្តុះបណ្តាលពាក់ព័ន្ធប្រព័ន្ធទិន្នន័យ | វគ្គ | ៤ | ៥ | ៧ | ៨ | ៩ | ៩ |
| ៣. ចំនួនចុះតាមដាននិងវាយតម្លៃការអនុវត្តគម្រោងឥណទាននិង NGO | លើក | ១០ | ២៥ | ៣០ | ៣៥ | ៣៥ | ៣៥ |

**គម្រោងសកម្មភាព៖**

១. ចូលរួមកិច្ចប្រជុំក្នុងក្របខណ្ឌអាស៊ាន អាស៊ានបូក ក្របខណ្ឌ FAO និង UNCCD ព្រមទាំងក្រុមការងារបច្ចេកទេសទ្វេភាគីនិងពហុភាគី។

២. ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្នុងក្របខណ្ឌអាស៊ាន អាស៊ានបូក និងរៀបចំកិច្ចប្រជុំពិនិត្យការធ្វើពាណិជ្ជកម្មកសិកម្ម ព្រមទាំងកិច្ចប្រជុំជាមួយ NGOs និងប្រទេសដៃគូអភិវឌ្ឍន៍។

៣. រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលស្តីពីការត្រៀមលក្ខណៈចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នីតិវិធីពាណិជ្ជកម្ម ស្តង់ដារបច្ចេកទេស ទំនាក់ទំនងអន្តរជាតិ ការតាមដាននិងវាយតម្លៃគម្រោង។ល។

៤. ចុះតាមដាន និងវាយតម្លៃការអនុវត្តគម្រោងក្រោមឥណទានជំនួយ (ខ្លឹមសារមានក្នុងអនុស្សរណៈ) ពិធីសារ កំណត់ហេតុ និងកិច្ចព្រមព្រៀងអនុវត្តគម្រោងរបស់ NGOs។

៥. រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងក្រោមឥណទានជំនួយ និងកិច្ចព្រមព្រៀងអនុវត្តគម្រោងរបស់ NGOs។

៦. រៀបចំទិវា World Food Day និង World Day។

៧. បកប្រែនិងបោះពុម្ពឯកសារទាក់ទងនឹងកិច្ចការ WTO និងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាភាសាជាតិ។

## ៥.៦ អនុកម្មវិធីទី៥.៦ ៖ ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពាក់ព័ន្ធការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម

**គោលបំណង ៖** "ធានាបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវថ្នាំកសិកម្មនិងជីកសិកម្ម និងការលើកកម្ពស់សមត្ថភាពយល់ដឹងជាសាធារណៈ ក្នុងការគ្រប់គ្រងការធ្វើអាជីវកម្មប្រកបដោយសុវត្ថិភាព"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនមន្ត្រី អាជ្ញាធរដែនដី និងអាជីវករសម្ភារកសិកម្មត្រូវបានបណ្តុះបណ្តាល | នាក់ | ៥០០ | ៦៥០ | ៧៥០ | ៨៥០ | ៩៥០ | ១០០០ |
| ២. ចំនួនដេប៉ូធ្វើអាជីកម្មសម្ភារកសិកម្មក្នុងខេត្តគោលដៅចំនួន១៥ ត្រូវបានត្រួតពិនិត្យនិងណែនាំ | ដេប៉ូ | ៣៧៥ | ៤៥០ | ៦០០ | ៧១៥ | ៨០០ | ៨៧៥ |

**គម្រោងសកម្មភាព៖**

១. ការធ្វើអធិការកិច្ចលើដេប៉ូថ្នាំកសិកម្មនិងជីកសិកម្ម និងធ្វើសិក្ខាសាលាផ្សព្វផ្សាយបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅក្នុងខេត្តគោលដៅចំនួន១៥ខេត្ត។

២. សិក្ខាសាលាពង្រឹងសមត្ថភាពយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដល់មន្ត្រីអង្គភាពនីតិកម្មកសិកម្ម។

៣. សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងលិខិតបទដ្ឋានក្រោមច្បាប់នេះដល់ពាណិជ្ជករថ្នាំកសិកម្ម ឬជីកសិកម្ម។

៤. ចាក់ផ្សាយឈុតខ្លីស្តីពីការអនុវត្តទោសចំពោះពាណិជ្ជករថ្នាំកសិកម្មនិងជីកសិកម្មណាដែលមិនគោរពច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម។

៥. ធ្វើការវិភាគគុណភាពលើសំណាកជីកសិកម្មដែលបានដកហូត។

## ៥.៧ អនុកម្មវិធីទី៥.៧៖ ពង្រឹងការងាររដ្ឋបាល ការបញ្ជ្រាបយេនឌ័រ និងការអភិវឌ្ឍកុមារ

**គោលបំណង ៖** "ពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងការងារកិច្ចការរដ្ឋបាល ដើម្បីអនុវត្តការងារឲ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលា ជំរុញការបញ្ជ្រាបយេនឌ័រ និងការអភិវឌ្ឍកុមារតូចក្នុងវិស័យកសិកម្ម "។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនមន្ត្រីរាជការទទួលបានការបណ្តុះបណ្តាលក្នុងការងារកិច្ចការរដ្ឋបាលទូទៅ | នាក់ | - | - | ៣០ | ៤០ | ៦០ | ៨០ |
| ២. ចំនួនមន្ត្រីរាជការ កសិករ ទទួលបានការបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងផលិតកម្មកសិកម្មតាមខេត្ត | នាក់ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ |

**គម្រោងសកម្មភាព ៖**

១. សម្របសម្រួលសកម្មភាពរដ្ឋបាលរបស់ក្រសួងនៅថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន ចំណុះក្រសួង និងរវាងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល គ្រប់គ្រងនិងចរាចរឯកសារ រដ្ឋបាលផ្សេងៗរបស់ក្រសួង ធានាសុវត្ថិភាពរដ្ឋបាល ការពារសន្តិសុខ គ្រប់គ្រងការងារ សង្គម និងការងារពិធីការរបស់ក្រសួង។

២. រៀបចំនិងគ្រប់គ្រងការចំណាយ សម្រាប់ការងារគ្រប់គ្រង ប្រើប្រាស់អគារ យានយន្ត សម្ភារនិងបរិក្ខាររបស់អង្គភាពអមទីស្តីការក្រសួង។

៣. សរុបនិងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង រៀបចំការងារតម្កល់ ឯកសាររបស់ក្រសួង។

៤. រៀបចំការងារពង្រឹងសមត្ថភាពការងារយេនឌ័រ ការអប់រំនិងផ្សព្វផ្សាយ និងការបញ្ជ្រាប យេនឌ័រក្នុងវិស័យកសិកម្ម។

៥. អប់រំនិងផ្សព្វផ្សាយការងារអភិវឌ្ឍនិងការគាំពារកុមារតូចក្នុងវិស័យកសិកម្ម។

### ៥.៨ អនុកម្មវិធីទី៥.៨៖ បង្កើនប្រសិទ្ធភាពការងារអធិការកិច្ចក្នុងវិស័យកសិកម្ម

**គោលបំណង ៖** "ពង្រឹងនិងធ្វើឲ្យប្រសើរឡើងក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តនានា ដើម្បីឈានទៅកាត់បន្ថយភាពអសកម្ម និងបាតុភាពផ្សេងៗរបស់អង្គភាព ក្រោមឱវាទក្រសួង"។

**សូចនាករ ៖**

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. ចំនួនអង្គភាពត្រូវត្រួតពិនិត្យ | អង្គភាព | ២៤ | ២៦ | ២៨ | ៣០ | ៣២ | ៣៤ |
| ២. ចំនួនមន្ត្រីត្រួតពិនិត្យត្រូវបាន បណ្តុះបណ្តាល | នាក់ | - | ៣០ | ៣២ | ៣៤ | ៣៦ | ៤០ |
| ៣. តាមដានការអនុវត្តរបស់អង្គភាពដែលបានធ្វើការត្រួតពិនិត្យរួច | អង្គភាព | ៥ | ១៣ | ១៤ | ១៥ | ១៦ | ១៧ |

**គម្រោងសកម្មភាព ៖**

១. ចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពដែលត្រូវធ្វើអធិការកិច្ច និងចុះស្រាវជ្រាវពាក្យបណ្តឹង ក្នុងក្របខណ្ឌកសិកម្ម។

២. ចុះតាមដានការដឹកនាំគ្រប់គ្រង ការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានារបស់អង្គភាព ក្រោមឱវាទក្រសួង។

៣. រៀបចំបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចជាប្រចាំ។

៤. កសាងលិខិតណែនាំ កែលម្អ លើកសរសើរ និងចុះពង្រឹងការងារដល់អង្គភាពដែលត្រូវបានធ្វើអធិការកិច្ចរួច។

៥. ការផ្គត់ផ្គង់សេវារដ្ឋបាល ថែទាំហេដ្ឋារចនាសម្ព័ន្ធ សម្ភារ មធ្យោបាយ និងប្រេងឥន្ធនៈសម្រាប់ធ្វើអធិការកិច្ច ស្រាវជ្រាវ ណែនាំ និងកែលម្អ។

## ៥.៩ អនុកម្មវិធីទី៥.៩៖ ការគ្រប់គ្រងឯកសារនិងប្រព័ន្ធព័ត៌មានកសិកម្ម

**គោលបំណង** ៖ "ពង្រឹងការកសាងបណ្តាញព័ត៌មានវិទ្យា បណ្តុះបណ្តាលមន្ត្រីឱ្យយល់ដឹងពីវិស័យអ៊ិនធឺណេត និងប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ ដើម្បីឈានទៅដល់ការផ្សព្វផ្សាយព័ត៌មាន និងគ្រប់គ្រងឯកសារកសិកម្មតាមប្រព័ន្ធអេឡិចត្រូនិច"។

**សូចនាករ** ៖

| សូចនាករលទ្ធផល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១. ប្រព័ន្ធបណ្តាញ Network ក្នុងទីស្តីការក្រសួង | ប្រព័ន្ធ | - | ៣ | ៣ | ៣ | ៣ |
| ២. គេហទំព័រសម្រាប់អង្គភាពក្រោមឱវាទក្រសួង និងមន្ទីរកសិកម្មខេត្ត | គេហទំព័រ | - | ៦ | ៨ | ៨ | ៨ |

**គម្រោងសកម្មភាព** ៖

១. កសាងបណ្តាញអ៊ិនធឺណេត និងអ៊ិនត្រាណេត និងការទាំនៅក្នុងទីស្តីការក្រសួង។

២. បង្កើតគេហទំព័រសម្រាប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម និងថ្នាក់ខេត្ត។

៣. ចងក្រង និងថែទាំឯកសារក្នុងបណ្ណាល័យ។

៤. ពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ជាតិ និងមន្ត្រីថ្នាក់ខេត្តពីប្រព័ន្ធព័ត៌មានវិទ្យា និងគេហទំព័រ។

## ៥.១០ អនុកម្មវិធីទី៥.១០៖ ពង្រឹងគុណភាពអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សលើបច្ចេកទេសកសិកម្មនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម

**គោលបំណង** ៖ "ពង្រឹងគុណភាពបណ្តុះបណ្តាលការអនុវត្តជាក់ស្តែង និងការស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រគ្រប់កម្រិត និងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធសិក្សា"។

**សូចនាករ** ៖

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១. បណ្តុះបណ្តាលនិស្សិតគ្រប់កម្រិត | នាក់ | ៨០០ | ៨៥០ | ៩០០ | ៩៥០ | ១.០០០ |
| ២. បង្កើនចំនួនគម្រោងសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍វិទ្យាសាស្ត្រ | គម្រោង | ១០ | ១០ | ១០ | ១០ | ១០ |
| ៣. ចំនួនហេដ្ឋារចនាសម្ព័ន្ធសិក្សាត្រូវបានកសាង | ចំនួន | ១ | ១ | ១ | ១ | ១ |

**គម្រោងសកម្មភាព៖**

១. បណ្តុះបណ្តាលនិស្សិតលើជំនាញកសិកម្ម ឲ្យមានសមត្ថភាពខ្ពស់សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម រៀបចំសកម្មភាពផ្លាស់ប្តូរនិស្សិតក្នុងនិងក្រៅប្រទេស បង្កើតកម្មវិធីសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ពេញម៉ោង និងបង្កើតកម្មវិធីសិក្សាថ្នាក់បណ្ឌិត។

២. ស្រាវជ្រាវនិងផ្សព្វផ្សាយនូវរបកគំហើញថ្មី ដើម្បីបង្កើនផលិតភាពកសិកម្ម និងលើកកម្ពស់ជីវភាពជនបទ អប់រំបច្ចេកវិទ្យាសមស្របដល់អ្នកអនុវត្តផ្ទាល់។

៣. អង្កេតពីស្ថានភាពការងាររបស់និស្សិតក្រោយបញ្ចប់ការសិក្សា។

៤. រៀបចំសិក្ខាសាលាវិទ្យាសាស្រ្ត បំពាក់បំប៉នមន្ត្រី សាស្ត្រាចារ្យ គ្រូបង្រៀន។

៥. អភិវឌ្ឍន៍ផែនការធនធានមនុស្ស ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា បង្កើតកម្មវិធីបណ្តុះបណ្តាលវែងនិងខ្លី បង្កើតជំនាញឯកទេសថ្មីៗឲ្យស្របតាមទីផ្សារ និងបង្កើនការអនុវត្តផ្ទាល់របស់និស្សិតនៅតាមគ្រឹះស្ថាននានា។

៦. រៀបចំកែលម្អនិងអភិវឌ្ឍន៍សេវាកម្មគាំទ្រ បំពាក់សម្ភារបរិក្ខារសម្រាប់ការស្រាវជ្រាវនិងអនុវត្តផ្ទាល់។

៧. រៀបចំបង្កើតបរិយាកាសល្អសម្រាប់ការសិក្សារៀនសូត្ររបស់និស្សិត តាមរយៈការផ្តល់នូវសេវាកម្មគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធនានា (បំពាក់កុំព្យូទ័រ និងអ៊ីនធឺណែត បង្កើនបន្ថែមនូវចំនួនសៀវភៅសម្រាប់ស្រាវជ្រាវនៅបណ្ណាល័យ ពង្រឹងសកម្មភាពកីឡា កែលម្អនិងបំពាក់សម្ភារមន្ទីរពិសោធន៍ ពង្រឹងសេវាគាំពារសុខភាព កែលម្អសេវាអាហារដ្ឋាន សាងសង់អន្តេវាសិកដ្ឋាន សាងសង់អាគារថ្នាក់រៀនបន្ថែម ពង្រឹងប្រព័ន្ធសុវត្ថិភាពអគ្គីភ័យ ... )។

៨. បង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃសម្រាប់កិច្ចការរដ្ឋបាលនិងវិទ្យាសាស្ត្រ។

៩. បង្កើតនិងដំណើរការនូវសមាគមអតីតនិស្សិត។

១០. ពង្រឹងការផ្សព្វផ្សាយនិងទាក់ទាញនិស្សិត។

១១. បង្កើតវេទិកាផ្សព្វផ្សាយវិទ្យាសាស្រ្តដល់អ្នកប្រើប្រាស់និងពាក់ព័ន្ធ។

## ៥.១១ អនុកម្មវិធីទី៥.១១ ៖ លើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនៅសាលាជាតិកសិកម្មព្រែកលៀប

**គោលបំណង ៖** "ពង្រឹងនិងពង្រីកធនធានមនុស្សលើវិស័យកសិកម្ម វិទ្យាសាស្ត្រសង្គម និងជំនាញពាក់ព័ន្ធនានា ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម ស្រាវជ្រាវនូវបច្ចេកទេសនិងរបកគំហើញថ្មីៗ បម្រើការអប់រំគោលនយោបាយ និងការអភិវឌ្ឍកសិកម្ម"។

**សូចនាករ ៖**

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ១. ចំនួននិស្សិតបណ្តុះបណ្តាលក្នុងឆ្នាំនីមួយៗ | នាក់ | ១.២០០ | ១.២០០ | ១.២០០ | ១.២០០ | ១.២០០ |
| ២. ចំនួនមន្ត្រីរាជការបានបណ្តុះបណ្តាល ក្នុងឆ្នាំនីមួយៗ | នាក់ | ២៥ | ៣០ | ៣០ | ៣០ | ៣០ |
| ៣. គម្រោងសិក្សាស្រាវជ្រាវ | គម្រោង | ៣ | ៣ | ៤ | ៤ | ៤ |

**គម្រោងសកម្មភាព៖**

១. អនុវត្តកម្មវិធីបង្ហាត់បង្រៀននិស្សិត ជ្រើសរើសសិស្សចូលរៀនតាមឆ្នាំនីមួយៗ ដឹកនាំនិស្សិត សិក្សាស្រាវជ្រាវ រៀបចំការផ្សព្វផ្សាយដើម្បីទាក់ទាញសិស្សចូលរៀន រៀបចំដំណើរការត្រួតពិនិត្យវាយតម្លៃនិស្សិតបញ្ចប់ការសិក្សា។

២. កែលម្អកម្មវិធីសិក្សា រៀបចំការងារអនុវត្តជាក់ស្តែងក្នុងកម្មវិធីសិក្សា រៀបចំយន្តការវាយតម្លៃការសិក្សាឱ្យបានសុក្រឹត្យ។

៣. រៀបចំសិក្ខាសាលាវិទ្យាសាស្ត្រ និងរៀបចំបង្កីតបណ្តាញផ្សព្វផ្សាយ។

៤. អភិវឌ្ឍសមត្ថភាពបុគ្គលិកសិក្សានិងសាស្ត្រាចារ្យ បំពាក់សម្ភារឧបទ្ទេសបង្រៀន ផ្តល់គ្រប់វត្ថុធាតុដើម សារធាតុផ្សេងៗសម្រាប់ការងារអនុវត្ត។

៥. រៀបចំការងារសហប្រតិបត្តិការ និងចូលរួមការងារស្រាវជ្រាវ លើកគម្រោងដើម្បីពង្រីកការងារសិក្សាស្រាវជ្រាវ រៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពនិស្សិត។

៦. អប់រំ និងទ្រទ្រង់សកម្មភាពកីឡា។

៧. ចុះអង្កេតទីផ្សារការងារនិស្សិត។

៨. រៀបចំប្រព័ន្ធទំនាក់ទំនងផ្ទៃក្នុងឱ្យបានរឹងមាំ កែលម្អប្រព័ន្ធព័ត៌មានវិទ្យាក្នុងសាលាជាតិ រៀបចំលិខិតបទដ្ឋានផ្ទៃក្នុង។

៩. រៀបចំផែនការសម្រាប់ប្រើប្រាស់ក្នុងសាលាជាតិ។

១០. សាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធក្នុងសាលាជាតិ ពិសេសការកែលម្អប្រពន្ធ័ទឹក ភ្លើង។

១១. សាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅស្ថានីយ៍របស់សាលាជាតិ។

## ៥.១២ អនុកម្មវិធីទី៥.១២ ៖ ពង្រឹងគុណភាពប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលធនធានមនុស្សវិស័យកសិកម្មរបស់សាលាកសិកម្មកំពង់ចាម

**គោលបំណង** ៖ "បង្កើនប្រសិទ្ធភាពគ្រប់គ្រងដឹកនាំ និងសមត្ថភាពអប់រំបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបបានតាមតម្រូវការបណ្តុះបណ្តាល ស្របតាមទីផ្សារពលកម្មកសិកម្ម"។

## សូចនាករ ៖

| សូចនាករលទ្ធផល | ឯកតា | ២០១៣ (សម្រេចបាន) | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ១. និស្សិតបានបញ្ចប់ការបណ្តុះបណ្តាល | នាក់ | ៣២០ | ៣២០ | ៣៥០ | ៣៥០ | ៤០០ | ៤០០ |
| ២ . មន្ត្រីនិងសាស្ត្រាចារ្យបញ្ចប់ថ្នាក់អនុបណ្ឌិត | នាក់ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| ៣. មន្ត្រីនិងសាស្ត្រាចារ្យបញ្ចប់ថ្នាក់បណ្ឌិត | នាក់ | ៩ | ២ | ២ | ២ | ៣ | ៣ |
| ៤. កសិករដែលបានទទួលការបណ្តុះបណ្តាល | នាក់ | ៣៥០ | ៣៥០ | ៥០០ | ៥០០ | ៥០០ | ៥០០ |

## គម្រោងសកម្មភាព៖

១. ការបង្ហាត់បង្រៀនសិស្សតាមកម្មវិធីសិក្សា ដឹកនាំសិស្សចុះទស្សនកិច្ចសិក្សា រៀបចំគម្រោងសិក្សាពិសោធន៍ស្រាវជ្រាវនិងអនុវត្ត បណ្តុះបណ្តាលនិងបំពាក់បំប៉នអំពីការប្រើប្រាស់ព័ត៌មានវិទ្យា អនុវត្តការអប់រំកាយនិងកីឡា។

២. បណ្តុះបណ្តាលសាស្ត្រាចារ្យសម្រាប់កសាងសមត្ថភាពជំនាញឯកទេសវិជ្ជាជីវៈ បណ្តុះបណ្តាល សមត្ថភាពសាស្ត្រចារ្យ និងទេពកោសល្យបង្រៀន បង្កើនសមត្ថភាពមន្ត្រី គ្រូបង្រៀន លើភាសានិងកុំព្យូទ័រ។

៣. រៀបចំសិក្ខាសាលាស្តីពីការកែលម្អកម្មវិធីសិក្សា រៀបចំតាក់តែងឯកសារបច្ចេកទេសកសិកម្មសម្រាប់ចែកចាយនិងផ្សព្វផ្សាយ។

៤. បង្កើតគណៈកម្មការពង្រឹងគុណភាពសាស្ត្រាចារ្យ ដើម្បីធ្វើការពិនិត្យនិងវាយតម្លៃសមត្ថភាពជំនាញនិងបង្រៀន។

៥. ចាត់ចែងការងារប្រជុំក្រុមប្រឹក្សាភិបាល។

៦. ចងក្រងនិងបោះពុម្ពព្រឹត្តិបត្រព័ត៌មានបច្ចេកទេសកសិកម្ម រៀបចំកែលម្អប្រព័ន្ធព័ត៌មានវិទ្យា ផ្សព្វផ្សាយព័ត៌មានសកម្មភាពសាលាតាមរយៈ Website។

៧. រៀបចំអនុវត្តកិច្ចការការពារសុវត្ថិភាពពេលបំពេញការងារក្នុងមន្ទីរពិសោធន៍។

៨. បណ្តុះបណ្តាលបច្ចេកទេសកសិកម្មដល់កសិករ។

៩. រៀបចំវេទិកាសាធារណៈសំរាប់និស្សិត បង្កើតឲ្យមានទិវាបង្ហាញទេពកោសល្យរបស់និស្សិតក្នុងសាលាជាតិកសិកម្មកំពង់ចាម ដល់សាធារណៈជន ពិសេសនិយោជិកដែលប្រើប្រាស់ និងអ្នកបច្ចេកទេសកសិកម្ម។

១០. រៀបចំការប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្ររង រៀបចំការពារសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ។

១១. បំពាក់ទព្វសម្ភារ និងឧបករណ៍សិក្សា ពង្រឹងប្រព័ន្ធសុវត្ថិភាព បំពាក់ឧបករណ៍សម្ភារពិសោធន៍ សារធាតុគីមីនិងវត្ថុវិភាគផ្សេងៗ បំពាក់កុំព្យូទ័រសម្រាប់បង្រៀនមុខវិជ្ជាព័ត៌មានវិទ្យា។

១២. កែលម្អអគារទីចាត់ការរដ្ឋបាល ទីចាត់ការនិងអាគារសិក្សារបស់ស្ថានីយ៍ រៀបចំរបងព័ទ្ធជុំវិញស្ថានីយ៍ពិសោធន៍ចំនួនផ្ទៃដី១០ហិកតា លម្អអាគារសិក្សា អាគារកុំព្យូទ័ររៀបចំបណ្ណាល័យសិក្សាឲ្យមានលក្ខណៈសមស្រប រៀបចំអន្តេវាសិកដ្ឋានសម្រាប់ការស្នាក់នៅរបស់និស្សិតនៅស្ថានីយ៍។

១៣. រៀបចំផ្តល់មធ្យោបាយដឹកជញ្ជូននិងទំនាក់ទំនងសម្រាប់ដំណើរការស្ថានីយ៍។

### ៥.១៣ អនុកម្មវិធីទី ៥.១៣៖ ការគាំទ្ររបស់មន្ទីរកសិកម្មរាជធានី ខេត្ត សម្រាប់កម្មវិធីទី៥

អនុកម្មវិធីនេះ គឺជាការប្រមូលផ្តុំនូវចង្កោមសកម្មភាពទាំងអស់ របស់មន្ទីរកសិកម្មរាជធានី ខេត្តទាំង២៥សម្រាប់អនុវត្ត សំដៅចូលរួមចំណែកសម្រេចបាននូវគោលបំណង និងសូចនាករនៃកម្មវិធីទី-៥ *"ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងវិស័យកសិកម្ម"*។

## ឆ. ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់អន្តរវិស័យ

### (១) ក្របខណ្ឌយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម

ការប្រែប្រួលអាកាសធាតុ ជាបញ្ហាចម្បងមួយដែលបានជះឥទ្ធិពលយ៉ាងខ្លាំងលើភពផែនដី និងបានទាញនូវការចាប់អារម្មណ៍ជាសាកលពីស្ថាប័នជាតិ និងអន្តរជាតិជាច្រើនក្នុងការរៀបចំនូវយន្តការការងារដ៏មានប្រសិទ្ធភាព ដើម្បីបន្សាំទៅនឹងការវិវត្តនៃធម្មជាតិ និងកាត់បន្ថយនូវបណ្តាសកម្មភាពទាំងឡាយណា ដែលបានបង្កនូវឥទ្ធិពលអវិជ្ជមានលើបរិស្ថាន សំដៅរក្សាបាននូវនិរន្តរភាពនៃការអភិវឌ្ឍ។ យន្តការការងារត្រូវបានដាក់ចេញជាសាកល តំបន់ អនុតំបន់ និងថ្នាក់ជាតិដើម្បីស្វែងរកនូវដំណោះស្រាយរួមមួយ ក្នុងការថែរក្សានូវលំនឹងបរិស្ថានធម្មជាតិ ដែលរងនូវឥទ្ធិពលពីសកម្មភាពអភិវឌ្ឍន៍នានា ដូចដែលភស្តុតាងវិទ្យាសាស្ត្រជាច្រើនតាមរយៈការសិក្សារបស់អង្គការនានាបានបង្ហាញថា បញ្ហាដែលប្រឈមក្នុងការអភិវឌ្ឍវិស័យកសិកម្ម កសិ-ឧស្សាហកម្ម កៅស៊ូ ការចិញ្ចឹមសត្វ ព្រៃឈើ និងជលផល គឺជាបាតុភូតធម្មជាតិដែលរួមមានការប្រែប្រួលសីតុណ្ហភាព សំណើម រដូវកាល និង របបទឹកភ្លៀង គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត រញ្ជួយផែនដី ខ្យល់ព្យុះជាដើម។ ជាមួយគ្នានេះដែរ សកម្មភាពមួយចំនួនដូចជាការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ការធ្វើកសិកម្មពនេចរ ការភ្ជួររាស់លើដីជម្រាល ប្រព័ន្ធកសិកម្មមិនសមស្រប ការប្រើប្រាស់ទឹកស្រោចស្រពមិនបានត្រឹមត្រូវ ការគ្រប់គ្រងកាកសំណល់សត្វមិនបានល្អ ការប្រើប្រាស់ថ្នាំនិងជីកសិកម្មដែលមិនអនុលោមទៅតាមបទដ្ឋានបច្ចេកទេស។ល។ ក៏បានរួមចំណែកធ្វើឲ្យមានការប្រែប្រួលអាកាសធាតុផងដែរ។

ជាការឆ្លើយតបនឹងបញ្ហាដូចបានរៀបរាប់ខាងលើ សន្និសីទសហប្រជាជាតិស្តីពីការអភិវឌ្ឍបរិស្ថាន (UNCED) នាឆ្នាំ១៩៩២ បានឯកភាពដាក់ចេញនូវក្របខណ្ឌសន្និសញ្ញាសហប្រជាជាតិនៃការប្រែប្រួលអាកាសធាតុ (UNFCCC) ដើម្បីរក្សាស្ថេរភាពនៃឧស្ម័នផ្ទះកញ្ចក់ ក្នុងបរិយាកាសនូវបរិមាណកំណត់មួយដែលមិនបង្កគ្រោះថ្នាក់។ ក្នុងគោលបំណងជំរុញការអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពនៅឆ្នាំ២០០៥ ពិធីសារក្យូតូត្រូវបានដាក់ចូលជាធរមាន ដោយផ្តោតជាសំខាន់លើការកាត់បន្ថយការកើនឡើងកំដៅនៃភពផែនដី ពោលគឺត្រូវកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ៥,២% នៃកម្រិតបំភាយនៅឆ្នាំ១៩៩១ ដោយមិនគិតពីការបំភាយពីវិស័យអាកាសចរណ៍ និងនាវាចរណ៍ឡើយ។ ទន្ទឹមនឹងនេះដែរ ក្នុងក្របខណ្ឌនៃសហគមន៍អាស៊ាន ទស្សនៈវិស័យឆ្ពោះទៅកាន់ឆ្នាំ២០២០ គឺការប្រែក្លាយអាស៊ានទាំងមូលជាតំបន់ស្អាត និងបៃតង (a clean and green ASEAN) ដែលតាមរយៈនេះក្របខ័ណ្ឌពហុវិស័យស្តីពីការប្រែប្រួលអាកាសធាតុ (ASEAN Multi-Sectoral Framework on Climate Change) ត្រូវបានអនុម័តនៅឆ្នាំ២០០៩ ដើម្បីសម្របសម្រួលដល់ការរៀបចំនូវយុទ្ធសាស្ត្របន្សាំ និងការបន្ថយផលប៉ះពាល់ និងសហការអនុវត្តវិធានការចម្រុះ ក្នុងការកាត់បន្ថយនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះដែរ កម្មវិធីបរិស្ថានស្នូល (Core Environmental Program) នៃមហាអនុតំបន់មេគង្គ (GMS) បានធ្វើការវាយតម្លៃពីភាពងាយទទួលរងគ្រោះថ្នាក់ពីការប្រែប្រួលអាកាសធាតុក្នុងមហាអនុតំបន់នេះ និងបានដាក់ចេញនូវសកម្មភាពការងារ មួយចំនួនក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយនូវឥទ្ធិពលទៅលើបរិស្ថានធម្មជាតិ។

ក្នុងដំណាក់កាលដែលប្រទេសកម្ពុជា បាននិងកំពុងប្រឈមនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាអវិជ្ជមានទាំងនោះ ហើយក្នុងនាមជាភាគីនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងពិធីសារក្យូតូ កម្ពុជាក៏បានខិតខំអនុវត្តអនុសញ្ញានិងពិធីសារនេះផងដែរ។ ផែនការសកម្មភាពសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាតិ ដែលផ្តោតជាសំខាន់លើវិស័យកសិកម្ម ធនធានទឹក តំបន់ឆ្នេរ និងសុខភាពមនុស្សត្រូវបានអនុម័តនាឆ្នាំ២០០៦។ ថ្មីៗនេះដែរ ដើម្បីមានយន្តការអនុវត្តឲ្យបានពេញលេញ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយប្រកបដោយនិរន្តរភាព រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ តាមអនុក្រឹត្យលេខ៩៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ដើម្បីរៀបចំសម្របសម្រួល និងពិនិត្យលើការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ កម្មវិធីនានា សំដៅឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ រួមចំណែកការពារបរិស្ថាន ធនធានធម្មជាតិ និងសុខុមាលភាពប្រជាពលរដ្ឋ។

ដោយឡែក ក្នុងការបន្តអភិវឌ្ឍវិស័យកសិកម្ម កសិ-ឧស្សាហកម្ម កៅស៊ូ ការចិញ្ចឹមសត្វព្រៃឈើ និងជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់នូវគោលនយោបាយតម្រង់ទិសឆ្ពោះទៅរកការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងបានបង្កើតក្រុមការងារបច្ចេកទេស

មួយដើម្បីរៀបចំកសាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុ ក្នុងគោលបំណងជាសំខាន់គឺសំដៅធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីនិងគម្រោងនានា ស្តីពីការប្រែប្រួលអាកាសធាតុ ដោយរួមបញ្ចូលទាំងផែនការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យកសិកម្ម ព្រៃឈើ និងជលផល។ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនេះ នឹងចូលរួមជាវិភាគទានដ៏សំខាន់មួយ ក្នុងដំណើរការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងជំរុញការអនុវត្តផែនការសកម្មភាពនានា សំដៅបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ចក្ខុវិស័យរបស់ក្រសួងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុគឺ៖

«*វិស័យកសិកម្មកម្ពុជា បន្តកែលម្អជីវភាពរស់នៅ ធានាសន្តិសុខនិងសុវត្ថិភាពស្បៀង កំណើនសេដ្ឋកិច្ចជាតិ និងនិរន្តរភាពបរិស្ថាន តាមរយៈការអនុវត្តគោលនយោបាយវៃឆ្លាតជាមួយអាកាសធាតុ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយចីរភាព និងកាន់តែបៃតង ជាពិសេសសំដៅជួយដល់សហគមន៍ជនបទ និងក្រុមជនងាយរងគ្រោះ*»។

ផែនការយុទ្ធសាស្ត្រនេះ មានគោលដៅសំខាន់គឺ «ចូលរួមចំណែកជួយកាត់បន្ថយផលប៉ះពាល់ និងឥទ្ធិពលអវិជ្ជមានទាំងឡាយលើវិស័យកសិកម្ម ផលិតកម្មសត្វ ព្រៃឈើ និងជលផលដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ សំដៅស្តារនូវការខូចខាត និងការបាត់បង់ផលប្រយោជន៍នានា តាមរយៈការបង្កើនវិធានការបន្សាំ និងវិធានការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការឡើងកំដៅនៃភពផែនដី»។

គោលបំណងចំនួន៥ត្រូវបានកំណត់គឺ៖

ទី១. បង្កើនសមត្ថភាពស្ថាប័ន និងធនធានមនុស្សលើការការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗនៃពូជដំណាំ កៅស៊ូ ផលិតកម្មសត្វ ព្រៃឈើ និងធនធានជលផល ដែលមានលទ្ធភាពបន្សាំទៅនឹងភាពរាំងស្ងួត ទឹកជំនន់ ការកើនកំដៅ ការជ្រាបចូលនៃទឹកប្រៃ និងការបំផ្លាញពីជំងឺនិងសត្វល្អិតចង្រៃ ដែលបណ្តាលមកអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។

ទី២. បង្កើនសមត្ថភាពដល់កសិករងាយរងគ្រោះ លើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ក្នុងផលិតកម្មដំណាំនិងសត្វ ដែលអាចបន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុ ដោយជំរុញឲ្យបានខ្លាំងក្លានូវសេវាកម្មផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព និងការផ្ទេរបច្ចេកវិទ្យាទាំងឡាយ ដែលបានអភិវឌ្ឍន៍ទៅក្នុងលក្ខខណ្ឌផលិតកម្មជាក់ស្តែង ដើម្បីធានាសុវត្ថិភាពស្បៀង និងបង្កើនប្រសិទ្ធភាពអន្តរាគមន៍ជួយសង្គ្រោះ និងស្តារការខូចខាតដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

ទី៣. កាត់បន្ថយនូវការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ ពីផលិតកម្មសត្វ ផលិតកម្មដំណាំ និងការកែច្នៃបឋមនៃផលិតផលកសិកម្មពុំសមស្រប ដោយជំរុញលើកទឹកចិត្តឲ្យមានការអភិរក្ស ការគ្រប់គ្រង និងការអភិវឌ្ឍធនធនព្រៃឈើប្រកបដោយចីរភាព ជាពិសេស

សហគមន៍ព្រៃឈើ ព្រមទាំងជំរុញប្រសិទ្ធភាព នៃការប្រើប្រាស់ថាមពលកកើតឡើងវិញ (ជីវម៉ាស់ និងជីវឧស្ម័ន) និងការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មសមស្រប។

ទី៤. ជំរុញការអភិវឌ្ឍ និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យជលផល ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់ លើការកែលម្អប្រព័ន្ធអេកូឡូស៊ីទឹក ទប់ស្កាត់ការបំផ្លាញព្រៃលិចទឹកនិងព្រៃកោងកាង បង្កើនការស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មគ្រប់ប្រភេទ ព្រមទាំងពង្រឹងសមត្ថភាពគ្រប់គ្រងសហគមន៍នេសាទ ឱ្យកាន់តែមានប្រសិទ្ធភាព។

ទី៥. ជំរុញការអភិវឌ្ឍធនធានមនុស្ស សម្រាប់ជាមូលដ្ឋានគន្លឹះនៃការចូលរួមចំណែកបន្សាំ និងកាត់បន្ថយផលប៉ះពាល់ ដែលបង្កដោយការប្រែប្រួលអាកាសធាតុលើផលិតកម្មដំណាំ កៅស៊ូ សត្វ ព្រៃឈើ និងជលផល តាមរយៈការអប់រំបណ្តុះបណ្តាល ការផ្លាស់ប្តូរនិងចែករំលែកព័ត៌មាន និងការផ្សព្វផ្សាយចំណេះដឹង និងចំណេះធ្វើដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងការកើនឡើងកំដៅនៃភពផែនដី។

វិធានការគោលនយោបាយដែលត្រូវអនុវត្តគឺ៖

**(ក). វិធានការគោលនយោបាយលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម៖**

កសិកម្ម ជាវិសយ័ដែលងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុ ហើយវាក៏អាចជាអ្នកបង្កឲ្យមានការប្រែប្រួលអាកាសធាតុដែរ ដោយសារវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ នឹងកត្តាអាកាសធាតុ។ ដើម្បីសម្រេចបាននូវការអភិវឌ្ឍផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាពសេដ្ឋកិច្ច សង្គម និងបរិស្ថានក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងយន្តការអភិវឌ្ឍន៍ស្អាត វិស័យកសិកម្ម និងកសិ-ឧស្សាហកម្មត្រូវអនុវត្តយុទ្ធសាស្ត្របន្សាំជាមួយនឹងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដូចខាងក្រោម៖

ទី១. បង្កើនផលិតភាពកសិកម្មដើម្បីធានាសន្តិសុខស្បៀង លើកកម្ពស់អាហារូបត្ថម្ភ និងបង្កើនប្រាក់ចំណូល ដោយជំរុញឱ្យបាននូវកំណើនផលិតកម្មដំណាំគ្រប់ប្រភេទក្នុងកម្រិត១០%ក្នុង១ឆ្នាំ តាមរយៈការជំរុញការធ្វើប្រពលវប្បកម្ម និងពិពិធកម្មដំណាំសមស្របតាមប្រព័ន្ធក្សេត្របរិស្ថាន និងពង្រឹងសមត្ថភាពបន្សាំ ដើម្បីបង្កើនការងារ និងកសិពាណិជ្ជកម្មក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់កសិករ និងសហគមន៍ជនបទ ក្នុងដំណើរការបន្សាំជាមួយការប្រែប្រួលអាកាសធាតុ។

ទី២. ពង្រឹងសមត្ថភាពសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងរបកគំហើញ ដើម្បីអភិវឌ្ឍន៍បច្ចេកទេសថ្មីៗ និងការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ សម្រាប់ពង្រឹងសមត្ថភាពបន្សាំ និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មសម្រាប់គ្រប់ប្រព័ន្ធក្សេត្របរិស្ថាន។

ទី៣. ជំរុញការអភិវឌ្ឍដោយបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចក្នុងវិស័យកសិកម្ម តាមរយៈការគ្រប់គ្រងធនធានធម្មជាតិសម្រាប់កសិកម្ម និងស្បៀងអាហារប្រកបដោយនិរន្តរភាព និងការអនុវត្តកសិកម្មមានភាពឈ្លាសវៃជាមួយអាកាសធាតុ ដូចជាប្រព័ន្ធកសិកម្មចម្រុះ កសិរុក្ខកម្ម កសិកម្មតាមបែបអភិរក្ស ព្រមទាំងការគ្រប់គ្រងនិងប្រើប្រាស់សំណល់កសិកម្ម និងកសិ-ឧស្សាហកម្មគ្រប់ប្រភេទ សម្រាប់ការកែលម្អដីជាតិដី សំដៅរួមចំណែកដល់ការកសាងសង្គមដែលបញ្ចេញកាបូនតិច និងមានភាពធន់ទ្រាំនឹងអាកាសធាតុ។

ទី៤. ពង្រឹងសមត្ថភាពស្ថាប័នជំនាញក្នុងការសម្របសម្រួល ការធ្វើអន្តរាគមន៍គ្រោះមហន្តរាយដោយធម្មជាតិ ការអភិវឌ្ឍធនធានមនុស្ស ការកសាងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ និងការបញ្ជ្រាបការសិក្សាអប់រំលើចំណេះដឹង អំពីការប្រែប្រួលអាកាសធាតុសម្រាប់គ្រប់កម្រិតសិក្សា ព្រមទាំងលើកកម្ពស់ការបំពាក់បំប៉ន និងផ្សព្វផ្សាយចំណេះដឹងបច្ចេកវិទ្យា ដល់អ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋាន រួមមានទាំងអ្នកនយោបាយ និងកសិករផងដែរ។

ទី៥. ពង្រឹងសមត្ថភាពសហគ្រាសវិនិយោគកសិកម្ម និងកសិ-ឧស្សាហកម្ម ឲ្យមានការទទួលខុសត្រូវខ្ពស់ ចំពោះការរួមចំណែករបស់ខ្លួន ឲ្យមានការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនសមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សំដៅសម្រេចបាននូវផលប្រយោជន៍សេដ្ឋកិច្ចជាតិ ព្រមទាំងនិរន្តរភាពសង្គម និងបរិស្ថាន។

**(ខ). វិធានការគោលនយោបាយលើវិស័យកៅស៊ូ៖**

ដើម្បីសម្រេចបានតាមគោលបំណងជាយុទ្ធសាស្ត្រឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យកៅស៊ូ វិធានការគោលនយោបាយមួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

ទី១. ជំរុញការប្រើប្រាស់ក្លូនកៅស៊ូដែលអាចបន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុ ពោលគឺសំដៅដល់ការដាក់បញ្ចូលឲ្យប្រើប្រាស់នូវក្លូនកៅស៊ូដែលមានស្រាប់ និងក្លូនកៅស៊ូថ្មីនាំចូលពីបណ្តាប្រទេសផលិតកៅស៊ូនានា ជាពិសេសពីបណ្តាប្រទេសក្នុងតំបន់ ដែលអាចធន់ទ្រាំនឹងភាពរាំងស្ងួត ឬសីតុណ្ហភាពខ្ពស់សម្រាប់ដាំដុះនៅតំបន់ណាដែលងាយរងគ្រោះ។

ទី២. ជំរុញការបង្កើតក្លូនកៅស៊ូថ្មី ដែលអាចបន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងលក្ខខណ្ឌភូគព្ភបរិស្ថាននៃប្រទេសកម្ពុជា សម្រាប់ដាំដុះជំនួសឲ្យក្លូនកៅស៊ូដែលនាំចូលពីក្រៅប្រទេស។

ទី៣. ជំរុញការសិក្សាស្រាវជ្រាវពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើដំណាំកៅស៊ូ ទៅតាមតំបន់ដាំដុះ និងលទ្ធភាពទទួលបានឥណទានកាបូន (Carbon Credit) ពីដំណាំកៅស៊ូ ដែលផ្តោតការយកចិត្តទុកដាក់ស្រាវជ្រាវ តាមដាននូវកម្រិតលូតលាស់ ទិន្នផលជ័រ និងឈើកៅស៊ូ និងការរាតត្បាតនៃជំងឺផ្សេងៗ ទៅតាមប្រភេទក្លូន និងទៅតាមតំបន់ដាំដុះផ្សេងៗគ្នា ដើម្បីកំណត់បាននូវក្លូនកៅស៊ូសមស្រប តំបន់ដាំដុះសមស្រប ឬ តំបន់ងាយរងគ្រោះ និងឈានទៅរកការកំណត់បាននូវតំបន់ដាំដុះតាមពូជនិងតាមតំបន់។ លើកកម្ពស់ការយល់ដឹង និងសហការសិក្សាស្រាវជ្រាវជាមួយស្ថាប័ននានា អំពីលទ្ធភាពក្នុងការទទួលបាននូវឥណទានកាបូន (Carbon Credit) ពីដំណាំកៅស៊ូ។

ទី៤. កសាងសមត្ថភាពមន្ត្រីជំនាញ ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ លើដំណាំកៅស៊ូ ដើម្បីឆ្លើយតបបានទាន់ពេលវេលាទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការបណ្តុះបណ្តាលរយៈពេលវែង និងមធ្យមអំពីការតាមដានលើប៉ារ៉ាម៉ែត្រអាកាសធាតុ ការបង្កើតគំរូម៉ូដែលអាកាសធាតុ (Climate modeling) និងគំរូបែបផែនដាំដុះ (Crop Pattern) ទៅតាមតំបន់នីមួយៗ។

ទី៥. បង្កើនសមត្ថភាពបច្ចេកទេសដំណាំកៅស៊ូ ជំរុញការអនុវត្តកសិកម្មល្អ (GAP) ក្នុងសកម្មភាពការងារកៅស៊ូ និងបង្កើនការយល់ដឹងពីផលប៉ះពាល់ វិធានការបន្សាំ ឬកាត់បន្ថយលើការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើនសមត្ថភាពអ្នកដាំកៅស៊ូឲ្យអនុវត្តបានត្រឹមត្រូវតាមបច្ចេកទេស និងការអនុវត្តកសិកម្មល្អ ចាប់តាំងពីការរៀបចំដី ការជ្រើសរើសពូជ ការដាំដុះទាន់ពេលវេលា ការដាំដំណាំគម្របដី ការប្រើប្រាស់ជី និងថ្នាំកសិកម្មបានត្រឹមត្រូវ។

ទី៦. ជំរុញប្រសិទ្ធភាពក្នុងការប្រើប្រាស់ធាតុចូល ក្នុងផលិតកម្មកែច្នៃជ័រ និងឈើកៅស៊ូ តាមរយៈ (១). ការសន្សំឬការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នូវធាតុចូលក្នុងដំណើរការកែច្នៃ ដូចជាឥន្ធនៈ ទឹក អាស៊ីត និងធាតុគីមី (២). ការប្រើប្រាស់ថាមពលកកើតឡើងវិញ (Renewable Energy) សម្រាប់ការកែច្នៃជ័រ និងឈើកៅស៊ូ ដូចជាជីវថាមពល (Bio Energy) ចំហាយទឹក ឬឧស្ម័នបានពីកាកសំណល់រាវនៃការបង្កកជ័រកៅស៊ូ និង (៣). ការគ្រប់គ្រងសំណល់រាវពីរោងចក្របានត្រឹមត្រូវ។

## (គ). វិធានការគោលនយោបាយលើវិស័យផលិតកម្មសត្វ និង សុខភាពសត្វ៖

ដើម្បីឆ្លើយតបទៅនឹងគោលបំណងយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធផលិតកម្មសត្វ និងសុខភាពសត្វខាងលើ វិធានការគោលនយោបាយមួយចំនួន ដើម្បីរួមចំណែកក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានកំណត់ដូចខាងក្រោម៖

ទី១. ការសម្របសម្រួលផលិតកម្មសត្វ៖ ការអនុវត្តការចិញ្ចឹមសត្វត្រូវធ្វើការផ្លាស់ប្តូរដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរួមមាន ការធ្វើពិពិធកម្ម ការពង្រឹងឲ្យបានខ្លាំងក្លា និងសមាហរណកម្មនូវការគ្រប់គ្រងវាលស្មៅ និងផលិតកម្មសត្វនិងដំណាំការអភិរក្សធម្មជាតិ និងប្រព័ន្ធបរិស្ថាន (រុក្ខជាតិ ឬ សត្វនិងបរិស្ថាន) និងការបញ្ចូលនូវប្រព័ន្ធផលិតកម្មសត្វលាយគ្នានិងប្រព័ន្ធកសិកម្មចម្រុះ។

ទី២. ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា៖

**ការបង្កាត់ពូជសត្វ៖** ពូជសត្វក្នុងស្រុកជាច្រើន បានបន្សាំទៅនឹងលក្ខខណ្ឌរស់នៅដែលពិបាក ដូច្នេះបច្ចេកវិទ្យាបង្កាត់ពូជសត្វអាចជួយបង្កើនល្បឿននៃការបន្សាំរបស់សត្វទៅនឹងការប្រែប្រួលអាកាសធាតុ ដែលការបន្សាំនេះមិនត្រឹមតែអាចជួយឲ្យសត្វអាចធន់នឹងកំដៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឲ្យសត្វមានសមត្ថភាពអាចរស់រានលូតលាស់ និងបន្តពូជក្នុងលក្ខខណ្ឌដែលមានចំណីពុំសូវមានគុណភាពល្អ សត្វល្អិត និងជំងឺ ។

**ការកែលម្អចំណីសត្វ៖** ការបញ្ចូលនូវប្រភេទចំណីសត្វថ្មីៗ ដែលធន់នឹងភាពរាំងស្ងួត និងទឹកជំនន់ និងការកែច្នៃកាកសំណល់កសិកម្មជាចំណីសត្វ អាចជួយធ្វើឲ្យប្រសើរឡើងនូវបរិមាណ និងគុណភាពចំណីសត្វសម្រាប់ផ្តល់ឲ្យសត្វ។

**ការធ្វើឲ្យប្រសើរឡើងសុខភាពសត្វ៖** សុខភាពសត្វត្រូវបានការពារ តាមរយៈការអភិវឌ្ឍវិធីសាស្ត្រថ្មីៗ សម្រាប់ធ្វើរោគវិនិច្ឆ័យ ជំងឺសត្វ និងការផលិតថ្នាំវ៉ាក់សាំងការពារជំងឺសត្វ និងការពង្រឹងការត្រួតពិនិត្យចលនាសត្វនិងផលិតផលសត្វ។

ទី៣. ការពង្រឹងសមត្ថភាព និងការផ្សព្វផ្សាយ៖ ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ស្ថាប័ន ធនធានមនុស្ស និងអ្នកចិញ្ចឹមសត្វត្រូវការចាំបាច់ណាស់ ដើម្បីស្វែងយល់និងទប់ទល់ជាមួយការប្រែប្រួលអាកាសធាតុ ដែលជួយបង្កើនការយល់ដឹងលើការប្រែប្រួលអាកាសធាតុលើពិភពលោក។ បន្ថែមពីនេះ ការបណ្តុះបណ្តាលលើបច្ចេកវិទ្យា និងការអនុវត្តការចិញ្ចឹមសត្វល្អ ការបង្កាត់ពូជសត្វ ការដាំដំណាំចំណីសត្វនិងវាលស្មៅ និងការពារជំងឺសត្វនឹងចូលរួមចំណែក ក្នុងការអនុវត្តពិពិធកម្មប្រាក់ចំណូលដល់កសិករ។

ទី៤. ការឆ្លើយតបនឹងទីផ្សារសត្វ៖ ការពង្រីកទីផ្សារសត្វនិងផលិតផលសត្វ ដែលប្រជាកសិករក្រីក្រអាចជ្រៀតចូលបាន តាមរយៈការបង្កើតសហគមន៍ចិញ្ចឹមសត្វ និងការជំរុញពាណិជ្ជកម្មក្នុងតំបន់ និងផែនការឥណទាន។

ទី៥. ការអន្តរាគមន៍និងការជួយសង្គ្រោះ៖ ការបង្កើតប្រព័ន្ធព័ត៌មានឲ្យដឹងមុន លើបសុសត្វនិងការផ្តល់លើការថែរក្សាបសុព្យាបាល និងអន្តរាគមន៍សង្គ្រោះបន្ទាន់ដល់សត្វ

នៅពេលមានគ្រោះមហន្តរាយធម្មជាតិ នឹងជួយធ្វើឲ្យសុខភាពសត្វកាន់តែប្រសើរឡើង និងកាត់បន្ថយហានិភ័យដល់សត្វ។

ទី៦. ការធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងលើការផ្តល់ចំណីសត្វ៖ ការផ្តល់ចំណីដែលមានគុណភាពល្អដល់សត្វទំពារអៀងនឹងជួយបង្កើន "ប្រសិទ្ធភាពការផ្លាស់ប្តូរចំណី" របស់សត្វ ដែលនាំដល់ការកាត់បន្ថយឧស្ម័នមេតាន ដែលត្រូវបានបង្កើតក្នុងផលិតកម្មនៃមួយឯកតាសាច់ ឬទឹកដោះគោ។

ទី៧. ការគ្រប់គ្រងវាលស្មៅ៖ ការរួមចំណែកការបំភាយឧស្ម័នផ្ទះកញ្ចក់សំខាន់ពីផលិតកម្មសត្វ បណ្តាលមកពីដំណាំចំណីសត្វឬផលិតកម្មដំណាំចំណីសត្វ និងការប្រើប្រាស់ដី។ ការគ្រប់គ្រងវាលស្មៅត្រឹមត្រូវ តាមរយៈការផ្លាស់ប្តូរវេនគ្នានូវវាលស្មៅសម្រាប់សត្វ ជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត ក្នុងការទប់ស្កាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់ពីផលិតកម្មដំណាំចំណីសត្វ។ ការបញ្ចូលនូវប្រភេទពូជស្មៅ និងពពួកដំណាំបន្លែទៅក្នុងវាលស្មៅអាចជួយពង្រឹងការស្តុកកាបូន និងអាសូតនៅក្នុងដី។

ទី៨. ការកាត់បន្ថយការប្រើប្រាស់ចំណីអាហារមានប្រភពពីសត្វ៖ ការកាត់បន្ថយការប្រើប្រាស់ក្នុងបរិមាណខ្ពស់ នូវចំណីអាហារដែលមានប្រភពពីសត្វ នឹងជួយកែលម្អសុខភាពមនុស្ស និងជួយបន្ថយការខូចខាតពីការអនុវត្តផលិតកម្មសត្វ ដល់បរិស្ថាន (តាមរយៈការប្រើប្រាស់ដី ទឹក និងធនធានធម្មជាតិលើសលប់ ដែលនាំដល់ការបង្កើនកម្រិតនៃការបំភាយឧស្ម័នផ្ទះកញ្ចក់)។

ទី៩. ការគ្រប់គ្រងកាកសំណល់សត្វ៖ ការគ្រប់គ្រងកាកសំណល់សត្វ ត្រូវធ្វើឲ្យប្រសើរឡើងតាមរយៈយន្តការផ្សេងៗ ដូចជាការប្រើប្រាស់សម្ភារសម្រាប់ស្តុក និងគ្របកាកសំណល់សត្វ (លាមកនិងទឹកនោមសត្វ និងកាកសំណល់សត្វពីសត្តឃាតដ្ឋាន)។ ការស្តុក និងគ្រប់គ្រងឲ្យបានត្រឹមត្រូវ គឺមិនត្រឹមតែជួយទប់ស្កាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់ តែថែមទាំងបង្កើតឱកាស សម្រាប់ប្រើប្រាស់ថាមពលកកើតឡើងវិញទៀតផង។

ទី១០. ការពង្រឹងក្របខណ្ឌច្បាប់ និងការអនុវត្តច្បាប់៖ ការអភិវឌ្ឍក្របខណ្ឌច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ការប្រើប្រាស់ដី និងការគ្រប់គ្រងកាកសំណល់សត្វ អាចជួយរួមចំណែកកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ពីកាកសំណល់សត្វ រួមជាមួយការពង្រឹងការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់។

### (ឃ). វិធានការគោលនយោបាយលើវិស័យព្រៃឈើ

យុទ្ធសាស្ត្រសំខាន់ៗក្នុងវិស័យព្រៃឈើ ដើម្បីចូលរួមចំណែកកាត់បន្ថយ និងបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ដោយបន្តអនុវត្តកម្មវិធីព្រៃឈើជាតិ រួមមាន៖ ការកែលម្អ និងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើ ការដាំដុះស្តារព្រៃឈើឡើងវិញ ការបង្កើន

សមត្ថភាពនិងការស្រាវជ្រាវដើម្បីផ្តល់ជាព័ត៌មានវិទ្យាសាស្ត្រ ក្នុងការធ្វើសេចក្តីសម្រេចគោលនយោបាយក្នុងការអភិវឌ្ឍវិស័យព្រៃឈើឲ្យមាននិរន្តរភាព និងប្រសិទ្ធភាពខ្ពស់។

ទី១. **ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើ៖** មានកិច្ចការសំខាន់ៗមួយចំនួនដែលនឹងជួយរួមចំណែកបង្កើនប្រសិទ្ធភាព ក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព រួមមានជាអាទិ៍ ការពិនិត្យនិងកំណត់ឡើងវិញនូវព្រំប្រទល់ដែនព្រៃឈើ ការចុះបញ្ជីនិងការរៀបចំផែនការគ្រប់គ្រងអភិវឌ្ឍន៍ និងអភិរក្សឲ្យស្របតាមមុខងារ និងស្ថានភាពព្រៃតាមតំបន់នីមួយៗ។ ក្នុងន័យនេះ តំបន់មានសក្តានុពលមួយចំនួន រួមទាំងតំបន់សហគមន៍ព្រៃឈើនឹងត្រូវបានរៀបចំអនុវត្តគម្រោង REDD+ ដែលជាកិច្ចការបន្ថែមទៅលើតំបន់មួយចំនួនដែលរដ្ឋបាលព្រៃឈើបាន និងកំពុងអនុវត្តគម្រោង REDD+ (Reducing Emission from Deforestation and Forest Degradation)។ ចំណូលពីការលក់កាបូន គឺជាកម្លាំងចលករដ៏សំខាន់មួយ ក្នុងការជំរុញឲ្យភាគីពាក់ព័ន្ធនានាក្នុងវិស័យព្រៃឈើ ពិសេសប្រជាសហគមន៍ និងអាជ្ញាធរមូលដ្ឋានចូលរួមកាន់តែខ្លាំងក្លាថែមទៀត ក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។

ទី២. **ការអភិរក្សនិងការស្តារព្រៃឈើ៖** ការងារអាទិភាពមួយចំនួនទៀតក្នុងការអភិរក្ស និងគ្រប់គ្រងព្រៃឈើ ក្នុងបរិបទនៃការការប្រែប្រួលអាកាសធាតុនេះ រួមមាន៖ ការជំរុញឲ្យមានផែនការប្រើប្រាស់ដីក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច ឲ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ការបង្កើនការយល់ដឹងអំពីភ្លើងឆេះព្រៃ និងការការពារ ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ព្រមទាំងការពារ និងអភិរក្សជីវៈចម្រុះ។ ការស្តារ ការដាំដុះដើមឈើ និងព្រៃឈើឡើងវិញ ជាពិសេសផ្តោតទៅលើការស្តារគម្របព្រៃឈើតំបន់ព្រៃរេចរឹល ក៏ជាការងារចាំបាច់ផងដែរក្នុងការឆ្លើយតបនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ តាមរយៈការលើកទឹកចិត្តដល់ការដាំចម្ការឈើឯកជន សហគមន៍ និងជាលក្ខណៈចម្ការព្រៃឈើដៃគូ ដោយដាំប្រភេទឈើចម្រុះឬឈើឧស្សាហកម្ម ក្នុងគោលបំណងសម្រាប់បង្កើនជីវភាព និងបង្កើនសេវាកម្មបរិស្ថាន។ ទន្ទឹមគ្នានោះដែរ ត្រូវយកចិត្តទុកដាក់ផ្តោតលើការរៀបចំគោលនយោបាយ បទប្បញ្ញត្តិ ច្បាប់ និងឯកសារបច្ចេកទេសផ្សេងៗ សម្រាប់គាំទ្រការងារដាំឈើ និងស្តារព្រៃឈើប្រកបដោយប្រសិទ្ធភាពជាចាំបាច់។

ទី៣. **ការស្រាវជ្រាវនិងការផ្សព្វផ្សាយ៖** ការសិក្សាស្រាវជ្រាវអំពីការបន្សាំ និងយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងសកម្មភាព ក្នុងការគ្រប់គ្រងព្រៃឈើជាកត្តាចាំបាច់ណាស់ ក្នុងការរួមចំណែកក្នុងការបន្សាំ និងជម្នះក្នុងការដោះស្រាយបញ្ហា ដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ ដើម្បីធានាដល់សន្តិសុខស្បៀង ការបង្កើនជីវភាពរស់ និងការកែលម្អផ្នែកបរិស្ថាន ដែលការងារនេះអាចជួយបង្កើតប្រព័ន្ធនៃការគ្រប់គ្រង និង

អភិរក្សធនធានធម្មជាតិផងដែរ។ បង្កើនសមត្ថភាពស្ថាប័ន និងជំនាញបច្ចេកទេសក្នុងការគ្រប់គ្រងព្រៃឈើ ជាកត្តាសំខាន់ណាស់ក្នុងការចូលរួមចំណែកការគ្រប់គ្រងព្រៃឈើ សំដៅកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ការងារនេះអាចធ្វើឡើង តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល ការធ្វើទស្សនកិច្ចសិក្សា ការចូលរួមប្រជុំ សិក្ខាសាលាក្នុង និងក្រៅប្រទេស និងបន្ទប់ពិសោធន៍សម្រាប់បម្រើឲ្យការអនុវត្ត។ ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីការប្រែប្រួលអាកាសធាតុឲ្យដល់គ្រប់មជ្ឈដ្ឋានជាពិសេស អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋានជាកត្តាគន្លឹះផងដែរ។

ទី ៤ **ការពង្រឹងការអនុវត្តច្បាប់៖** សមត្ថភាពក្នុងការគ្រប់គ្រង និងការពារព្រៃឈើរបស់ស្ថាប័នជំនាញនៅមានកម្រិត ដោយសារមិនមានមន្ត្រីគ្រប់គ្រាន់ដើម្បីបំពេញការងារ និងកង្វះខាតមធ្យោបាយសម្ភារ និងបរិក្ខារក្នុងការគ្រប់គ្រង និងការពារព្រៃឈើ។ ដើម្បីចូលរួមកាត់បន្ថយការបាត់បង់ព្រៃឈើ ដែលបង្កឲ្យមានការប្រែប្រួលអាកាសធាតុនេះ ចាំបាច់ត្រូវពង្រឹងសមត្ថភាពក្នុងការអនុវត្តច្បាប់ តាមរយៈការពង្រឹងសមត្ថភាពជំនាញ និងបំពាក់មធ្យោបាយគ្រប់គ្រាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ។

ទី ៥ **ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ៖** ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ការងារបន្សាំក៏មានសារសំខាន់ ដូចការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែរ។ យុទ្ធសាស្ត្រសំខាន់ៗ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរួមមាន៖ ការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុដល់សហគមន៍ ដែលរស់នៅក្បែរ និងក្នុងតំបន់ព្រៃឈើ ការកំណត់នូវតំបន់ព្រៃ និងសហគមន៍ព្រៃឈើណា ដែលងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ ការរៀបចំផែនការកាត់បន្ថយភាពងាយរងគ្រោះ និងការស្រាវជ្រាវរក និងដាំដុះនូវប្រភេទឈើដែលស៊ូទ្រាំបានល្អ ជាមួយការប្រែប្រួលអាកាសធាតុ។

## (ង). វិធានការគោលនយោបាយលើវិស័យជលផល៖

ជលផលនិងវារីវប្បកម្ម ជាផ្នែកមួយនៃវិស័យកសិកម្មដែលងាយរងឥទ្ធិពលដោយការប្រែប្រួលអាកាសធាតុ ព្រោះវាមានទំនាក់ទំនងជិតស្និទ្ធទៅនឹងរបបទឹកភ្លៀង ភាពរាំងស្ងួត ទឹកជំនន់ និងសីតុណ្ហភាពទឹក។ ដើម្បីបន្សាំនិងកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងធានានូវការអភិវឌ្ឍធនធានជលផល និងវារីវប្បកម្មដោយនិរន្តរភាព វិស័យជលផលកំណត់វិធានការគោលនយោបាយ យុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាធាតុ ស្របទៅតាមគោលនយោបាយយុទ្ធសាស្ត្រ១០ឆ្នាំរបស់វិស័យជលផល៖

ទី១. បង្កើនផលិតភាព និងផលិតផលជលផល ដើម្បីធានាសន្តិសុខស្បៀង លើកកម្ពស់អាហាររូបត្ថម្ភ និងបង្កើនប្រាក់ចំណូល តាមរយៈការពង្រឹងការគ្រប់គ្រងជំរុញការអភិវឌ្ឍ និងអភិរក្សធនធានជលផល។ ជំរុញការធ្វើវារីវប្បកម្មគ្រប់

ប្រភេទឲ្យមានកំណើន១៥%ជារៀងរាល់ឆ្នាំ។ ជំរុញការបង្កើត និងគ្រប់គ្រងស្រះជម្រកត្រីសហគមន៍ឲ្យបាន៧៥% នៃចំនួនឃុំសរុបទូទាំងប្រទេសនៅដំណាច់ឆ្នាំ២០១៩។

ទី២. លើកកម្ពស់គុណភាព សុវត្ថិភាពផលផលិតផល និងការកែច្នៃផល ផលិតផលជលផល ដោយកំណត់យ៉ាងហោចណាស់៨០ភាគរយ នៃអ្នកកែច្នៃនឹងត្រូវបានអនុវត្តស្របតាមបទប្បញ្ញត្តិនៃការធានារ៉ាប់រងគុណភាព សុវត្ថិភាព និងស្តង់ដារនៅត្រឹមដំណាច់ឆ្នាំ២០១៩ រួមទាំងការជំរុញសកម្មភាពភូមិមួយផលិតផលជលផលមួយ ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជានេសាទនៅតាមជនបទ ក្នុងការបន្សាំនិងចូលរួមកាត់បន្ថយទៅនឹងការប្រែប្រួលអាកាសធាតុ។

ទី៣. ពង្រឹងសមត្ថភាពសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗក្នុងការភ្ញាស់ បង្កាត់ពូជ ការចិញ្ចឹម ចំណី និងវិធីសាស្ត្រកែច្នៃផល ផលិតផលជលផលថ្មីៗ ដែលមានលក្ខណៈបន្សាំទៅនឹងការប្រែប្រួលនៃអាកាសធាតុ និងមានការីកចម្រើនលូតលាស់ឆាប់រហ័ស ស្របទៅតាមតម្រូវការសេដ្ឋកិច្ចទីផ្សារ។

ទី៤. ពង្រឹងនិងពង្រីកសមត្ថភាពអង្គភាពជំនាញ និងអ្នកពាក់ព័ន្ធក្នុងការសម្របសម្រួលធ្វើអន្តរាគមន៍ ព្រមទាំងអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក្នុងវិស័យជលផល និងវិធានការបន្សាំ។

ទី៥. ពង្រឹងការគ្រប់គ្រង និងថែរក្សាដាំព្រៃលិចទឹកនិងព្រៃកោងកាង និងដាំឡើងវិញនៅតំបន់ព្រៃរេចរិលប្រកបដោយប្រសិទ្ធភាព។ ក្នុងនោះនៅត្រឹមដំណាច់ឆ្នាំ២០១៩ ផ្ទៃដីព្រៃលិចទឹកនៅតំបន់ទឹកសាបចំនួន៣៥% និងនៅតំបន់ឆ្នេរសមុទ្រចំនួន៧៥% ត្រូវបានការពារយ៉ាងល្អ តាមរយៈការកំណត់និងបោះបង្គោលព្រំប្រទល់ និង៨០%នៃកន្លែងអភិរក្ស នៅតំបន់បឹងទន្លេសាបត្រូវបានកែលម្អ។ ការពារនិងផ្សព្វផ្សាយឲ្យមានការយល់ដឹងជាសាធារណៈរួមជាមួយការជំរុញឲ្យមានការបង្កើតកន្លែងអភិរក្សធនធានជលផល នៅគ្រប់សហគមន៍នេសាទទាំងអស់ ដើម្បីធានាឲ្យបាននូវនិរន្តរភាពប្រព័ន្ធអេកូឡូស៊ីធនធានជលផល និងបង្កើននូវផលផលិតផលជលផល ដើម្បីចូលរួមបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

ទី៦. ជំរុញការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា និងផ្សព្វផ្សាយចំណេះដឹងបច្ចេកទេសវិទ្យាសាស្ត្រដល់អ្នកពាក់ព័ន្ធ ដូចជាអ្នកនេសាទ ឬអ្នកចិញ្ចឹមត្រី អ្នកកែច្នៃ និងអ្នករៀបចំគោលនយោបាយជាដើម ។

ទី៧. ជំរុញការការពារបរិស្ថាននិងប្រព័ន្ធអេកូឡូស៊ី តាមរយៈការទប់ស្កាត់ការបញ្ចេញចោលកាកសំណល់ពីនាវានេសាទ ការកាប់បំផ្លាញ ការដុត ការរានយកដី ការប្រើប្រាស់ព្រៃលិចទឹក និងព្រៃកោងកាង ការបំពុលបរិស្ថានរបស់ទឹកនានា ដើម្បីរួមចំណែកទប់ស្កាត់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយសកម្មភាពជលផលដោយផ្ទាល់។

ទី៨. យកចិត្តទុកដាក់លើកិច្ចការយេនឌ័រក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យជលផល។

## (២) ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យកសិកម្ម

ប្រទេសកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្ត ក្នុងការធានាបាននូវសមភាពយេនឌ័រតាមរយៈគោលដៅអភិវឌ្ឍជាអាទិភាពរបស់ខ្លួន ការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ការចុះហត្ថលេខាលើសេចក្តីប្រកាសនានា ការបង្កើតផែនការជាតិដើម្បីស្ត្រី ការបង្កើតគណៈកម្មាធិការលើកកម្ពស់ស្ត្រីនៅគ្រប់ក្រសួង ការផ្តល់កូតាដល់ស្ត្រីក្នុងការចូលរួមនៅក្នុងរដ្ឋបាលផ្សេងៗ។ល។ រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់ផងដែរថា ការចូលរួមរបស់ស្ត្រីនៅគ្រប់វិស័យ និងគ្រប់កម្រិត ជាពិសេសនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត គឺជាកត្តាដ៏សំខាន់មួយដែលមិនអាចខ្វះបាន ដើម្បីឈានទៅសម្រេចទិសដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ទោះបីជាច្បាប់បានចែងថាស្ត្រីនិងបុរសមានសិទ្ធិស្មើគ្នាក៏ដោយ ក៏សង្គមមិនបានផ្តល់តម្លៃការងារស្មើគ្នាចំពោះស្ត្រីទេ។ បច្ចុប្បន្នស្ត្រីមានតិចតួចណាស់នៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចនៅគ្រប់លំដាប់ថ្នាក់ក្នុងជួររាជរដ្ឋាភិបាល និងមុខងារសាធារណៈ។ ដោយឡែកក្នុងវិស័យកសិកម្មដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចរបស់ប្រទេស លទ្ធភាពរបស់ស្ត្រីក្នុងការប្រើប្រាស់ធនធានធម្មជាតិសព្វថ្ងៃនៅតែមានកម្រិតទាប នេះដោយសារតែពួកគាត់មានចំណេះដឹងទាប ជាក់ស្តែង ក្នុងចំណោមស្ត្រីកសិករទាំងអស់មានស្ត្រីពាក់កណ្តាលជាអនក្ខរជន ឬមានកម្រិតវប្បធម៌ក្រោមបឋមសិក្សា។ ម្យ៉ាងវិញទៀត ផ្នត់គំនិតសង្គមនៅតែយល់ថាការងារកសិកម្មគឺជាការងារបុរស ហើយស្ត្រីគ្រាន់តែជួយការងារនេះម្តងម្កាលប៉ុណ្ណោះ។ កត្តាទាំងនេះនាំឲ្យស្ត្រីមានឱកាសតិចតួច ក្នុងការចូលរួមក្នុងសកម្មភាពនានារបស់សហគមន៍ ការបណ្តុះបណ្តាល និងឱកាសផ្សេងទៀត ដែលជួយពង្រឹងចំណេះដឹង និងជំនាញបន្ថែមក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធាន ក៏ដូចជាឱកាសក្នុងការទទួលបាននូវសេវាកម្មសំខាន់ៗ ដូចជាសេវាផ្សព្វផ្សាយកសិកម្ម សេវាឥណទាន ព័ត៌មានទីផ្សារ និងការស្រាវជ្រាវនានា

ដែលជាធនធានដ៏សំខាន់សម្រាប់កសិករជាស្ត្រីនៅ ក្នុងការកែលម្អផលិតកម្មកសិកម្ម និងការលើកកម្ពស់គុណភាពនៃការរស់នៅរបស់ស្ត្រី។

ឆ្លើយតបទៅនឹងបញ្ហាខាងលើនេះ នៅឆ្នាំ២០០៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតនិងអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម និងចូលរួមយ៉ាងសកម្មនៅក្នុងយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រុមការងារបច្ចេកទេសបញ្ជ្រាបយេនឌ័រតាមវិស័យ សំដៅលើកកម្ពស់សមភាពយេនឌ័រ លើកស្ទួយសិទ្ធិអំណាច ក៏ដូចជាស្ថានភាពស្ត្រីនៅគ្រប់កម្រិត។

ដើម្បីបន្តរួមចំណែកអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងគ្រោងធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម បន្តពង្រឹងការយល់ដឹងពីយេនឌ័រក្នុងចំណោមមន្ត្រីរាជការនៅគ្រប់កម្រិត ពង្រឹងបណ្តាញស្ត្រីក្នុងវិស័យកសិកម្ម បង្កើនឥទ្ធិពល និងចំនួនស្ត្រីទៅក្នុងតួនាទីជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ បង្កើនលទ្ធភាពដល់ស្ត្រីក្នុងការទទួលបាន និងគ្រប់គ្រងធនធាន និងសេវាកម្មកសិកម្ម ព្រមទាំងបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចដល់ស្ត្រីជនបទ។

ទស្សនវិស័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគឺ លើកកម្ពស់សមភាពយេនឌ័រ សេចក្តីថ្លៃថ្នូរ និងផលប្រយោជន៍របស់ស្ត្រីក្នុងវិស័យកសិកម្ម ស្របតាមស្មារតីនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

គោលដៅយុទ្ធសាស្ត្រគឺ ពង្រឹងសមភាពយេនឌ័រក្នុងវិស័យកសិកម្ម តាមរយៈការសហការយ៉ាងសកម្មរបស់ស្ត្រីនិងបុរស ការផ្តល់ឱកាសក្នុងការរួមចំណែក និងទទួលបានអត្ថប្រយោជន៍ស្មើភាពគ្នាពីសកម្មភាពនៅក្នុងអនុវិស័យទាំងអស់នៃវិស័យកសិកម្ម។

ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រខាងលើ ក៏ដូចជាធានាឲ្យបាននូវប្រសិទ្ធភាពនៃការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកំណត់ទិសដៅ៥ចំណុចដូចខាងក្រោម៖

១. បច្ចុប្បន្នភាពគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។
២. បង្កើនការយល់ដឹងពីយេនឌ័រដល់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់កម្រិត។
៣. ពង្រឹងបណ្តាញស្ត្រីក្នុងវិស័យកសិកម្ម។
៤. បង្កើនឥទ្ធិពល លទ្ធភាព និងចំនួនស្ត្រីដែលមានលក្ខណសម្បត្តិទៅក្នុងតួនាទីជាអ្នកដឹកនាំគ្រប់លំដាប់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
៥. បង្កើនលទ្ធភាពក្នុងការទទួលបាន និងគ្រប់គ្រងធនធាន និងសេវាកម្មកសិកម្ម និងពង្រឹងប្រសិទ្ធភាពសេដ្ឋកិច្ចដល់ស្ត្រីជនបទ ដើម្បីរួមចំណែកលើកស្ទួយជីវភាពគ្រួសារ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

សកម្មភាពចម្បងមួយចំនួនដូចខាងក្រោម នឹងត្រូវយកមកអនុវត្តក្នុងរយៈពេល៥ឆ្នាំ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម២០១៤-២០១៨ ដើម្បីឈានទៅសម្រេចបាននូវទិសដៅដែលបានកំណត់ខាងលើ។

**<u>សកម្មភាពអាទិភាព៖</u>**

***១. បច្ចុប្បន្នភាពគោលនយោបាយនិងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម៖***

១.១. រៀបចំក្រុមការងារសម្រាប់ធ្វើបច្ចុប្បន្នភាព គោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។

១.២. វាយតម្លៃសកម្មភាពការងារ និងវិភាគលើបញ្ហាប្រឈមក្នុងការអនុវត្តកន្លងមក។

១.៣. រៀបចំសេចក្តីព្រាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។

១.៤. រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយនិងផែនការយុទ្ធសាស្ត្របច្ចុប្បន្នកម្ម។

១.៥. បោះពុម្ព និងផ្សព្វផ្សាយគោលនយោបាយ និងផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨ ដល់មន្ត្រីថ្នាក់ជាតិ និងក្រោមជាតិ។

***២. បង្កើនការយល់ដឹងពីយេនឌ័រដល់មន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់កម្រិត៖***

២.១ បើកវគ្គបណ្តុះបណ្តាលជនបង្គោលយេនឌ័រនៅអង្គភាពក្រោមឱវាទក្រសួង និងមន្ទីរកសិកម្មរាជធានី ខេត្ត។

២.២ គាំទ្រជនបង្គោលក្នុងការបើកវគ្គផ្សព្វផ្សាយចំណេះដឹងយេនឌ័រ និងខ្លឹមសារអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ) ដល់មន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

***៣. ពង្រឹងបណ្តាញស្ត្រីក្នុងវិស័យកសិកម្ម៖***

៣.១ បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ។

៣.២ ប្រមូលនិងវិភាគទិន្នន័យ។

៣.៣ បើកវគ្គបណ្តុះបណ្តាលពីការប្រើប្រាស់និងគ្រប់គ្រងទិន្នន័យ។

៣.៤ រៀបចំផែនការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។

៣.៥ ចុះពិនិត្យ តាមដាន និងវាយតម្លៃ លើសេវាកម្ម និងការអនុវត្តសកម្មភាពយេនឌ័រក្នុងវិស័យកសិកម្ម។

៣.៦ រៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពជនបង្គោលយេនឌ័រ ក្នុងការពិនិត្យ តាមដាន និងវាយតម្លៃការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។

៣.៧ រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារយេនឌ័រ។

៣.៨ រៀបចំសិក្ខាសាលាប្រចាំឆ្នាំស្តីពីការវាយតម្លៃ និងចែករំលែកបទពិសោធន៍ល្អលើការងារយេនឌ័រ។

៣.៩ រៀបចំទស្សនកិច្ចសិក្សាក្នុងនិងក្រៅប្រទេស ដើម្បីដកស្រង់បទពិសោធន៍លើការងារយេនឌ័រ។

៣.១០ បញ្ចូលសកម្មភាព និងរបាយការណ៍ការងារយេនឌ័រតាមវិស័យ ទៅក្នុងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

*៤. បង្កើនឥទ្ធិពល លទ្ធភាព និងចំនួនស្ត្រីដែលមានលក្ខណសម្បត្តិ ទៅក្នុងតួនាទីជាអ្នកដឹកនាំគ្រប់លំដាប់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖*

៤.១ សម្របសម្រួលដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងការបណ្តុះបណ្តាលផ្នែកបច្ចេកទេស។

៤.២ សម្របសម្រួលឲ្យមន្ត្រីជាស្ត្រីបានបន្តការសិក្សាដោយមិនបង់ថ្លៃ។

៤.៣ សម្របសម្រួល ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង និងភាពជាអ្នកដឹកនាំ។

៤.៤ សម្របសម្រួលឱកាសស្មើគ្នារវាងបុរសនិងស្ត្រីក្នុងការដំឡើងឋានៈតាមអង្គភាពក្រោមឱវាទក្រសួង។

៤.៥ រៀបចំកិច្ចពិគ្រោះយោបល់ជាមួយមន្ត្រីជាស្ត្រី ដើម្បីឆ្លុះបញ្ចាំងពីកង្វល់ និងឧបសគ្គរារាំងដល់ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។

*៥. បង្កើនលទ្ធភាពក្នុងការទទួលបាន និងគ្រប់គ្រងធនធាន និងសេវាកម្មកសិកម្ម និងពង្រឹងប្រសិទ្ធភាពសេដ្ឋកិច្ចដល់ស្ត្រីជនបទ ដើម្បីរួមចំណែកលើកស្ទួយជីវភាពគ្រួសារ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ៖*

៥.១ សិក្សាពីឧបសគ្គ ការប្រឈម និងតម្រូវការរបស់ស្ត្រី ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារនិងសហគមន៍។

៥.២ ផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់គ្រួសារក្រីក្រ/គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ស្តីពីកម្មវិធីនានា ដែលពាក់ពន្ធ័នឹងសន្តិសុខស្បៀង។

៥.៣ រៀបចំវគ្គបណ្តុះបណ្តាលជំនាញ (ការចិញ្ចឹមមាន់ ការចិញ្ចឹមត្រី ការដាំដំណាំកសិកម្ម ការគ្រប់គ្រងនិងប្រើប្រាស់ធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព ... ) ដល់ស្ត្រីដោយមានប្រធានបទសមស្របតាមតម្រូវការ និងការអនុវត្តផ្ទាល់។

៥.៤ លើកទឹកចិត្ត និងផ្តល់ឱកាសដល់កសិករជាស្ត្រី ឲ្យចូលរួមក្នុងក្រុម និងសហគមន៍នានា។

៥.៥ សម្របសម្រួលលទ្ធភាពដល់ស្ត្រី ក្នុងការទទួលបានសេវាឥណទាន។

៥.៦ ផ្សព្វផ្សាយព័ត៌មានទីផ្សារ និងស្ថាប័នពាក់ព័ន្ធនានាដល់ស្ត្រីជាកសិករ។

៥.៧ ជំរុញនិងលើកទឹកចិត្តស្ត្រីដែលមានកូនអាយុក្រោម៦ឆ្នាំឲ្យប្រើប្រាស់សេវាថែទាំកុមារតូចតាមសហគមន៍មូលដ្ឋាន ដើម្បីឲ្យស្ត្រីអាចចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសកម្មភាពផ្សេងៗ។

៥.៨ រៀបចំទស្សនកិច្ចសិក្សាដើម្បីលើកកម្ពស់ការយល់ដឹង និងទាក់ទាញចំណាប់អារម្មណ៍របស់កសិករជាស្ត្រីក្នុងការចូលរួមវគ្គបណ្តុះបណ្តាល និងសកម្មភាពនានា។

ដើម្បីធានានូវប្រសិទ្ធភាពនៃការលើកកម្ពស់សមភាពយេនឌ័រ ក្នុងវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតនិងតែងតាំងសមាសភាពក្រុមការងារយេនឌ័រ និងកុមារប្រចាំក្រសួងចំនួន១៧រូប ក្នុងនោះមានរដ្ឋលេខាធិការ១រូបជាប្រធាន អនុរដ្ឋលេខាធិការ១រូបជាអនុប្រធាន និងថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមួយចំនួនជាសមាជិក។ ក្រុមការងារនេះ មានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យកសិកម្ម សម្របសម្រួលការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីយេនឌ័រ ដោយសហការយ៉ាងជិតស្និទ្ធជាមួយជនបង្គោលយេនឌ័រ នៅតាមអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង និងមន្ទីរកសិកម្មរាជធានី ខេត្ត។

## (៣) ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់កិច្ចគាំពារនិងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ ក្នុងនាមជាប្រទេសហត្ថលេខីនៃអនុសញ្ញានេះរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់ចំពោះផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់កុមារ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៤៨ "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច កាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខុមាលភាពរបស់កុមារ"។

ថ្វីត្បិតតែមានកិច្ចខិតខំប្រឹងប្រែងជាច្រើនពីរាជរដ្ឋាភិបាលនិងសង្គមស៊ីវិល ក្នុងការអនុវត្តសិទ្ធិកុមារ ក៏កុមារមួយចំនួននៅតែទទួលរងនូវការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាព ជាក់ស្តែងគេសង្កេតឃើញថាមានកុមារប្រមាណ១,៥លាននាក់កំពុងធ្វើពលកម្ម ក្នុងនោះ៧៥%កំពុងធ្វើពលកម្មក្នុងវិស័យកសិកម្ម។ កុមារទាំងនោះបាននិងកំពុងប្រឈមនឹងបញ្ហាជាច្រើនដូចជា កង្វះអាហារូបត្ថម្ភ មានជំងឺសើស្បែក ផ្លូវដង្ហើម សួត។ល។ ជាពិសេស កុមារប្រមាណ៤៣០.០០០នាក់ បានបោះបង់

ការសិក្សា និងប្រមាណ៤០០.០០០នាក់ពុំមានឱកាសទទួលបានការសិក្សា។ បញ្ហាទាំងនេះបណ្ដាលមកពីកង្វះយន្តការ និងសេវាគាំពារកុមារប្រកបដោយប្រសិទ្ធភាព សមត្ថភាពមន្ត្រីពាក់ព័ន្ធនៅមានកម្រិត ការយល់ដឹងរបស់មាតាបិតានិងអាណាព្យាបាល (ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល) លើកិច្ចគាំពារនិងអភិវឌ្ឍកុមារនៅមានកម្រិតទាប ឱកាសទទួលបានព័ត៌មាន និងចំណេះដឹងជុំវិញបញ្ហាកុមារពុំទាន់បានទូលំទូលាយ ។ល។

ឆ្លើយតបទៅនឹងបញ្ហាខាងលើ រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយ និងផែនការសកម្មភាពជាតិ ក៏ដូចជាយន្តការនានាគាំពារកុមារនៅគ្រប់កម្រិតដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ។ល។

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយជាតិគាំពារនិងអភិវឌ្ឍកុមារតូច ឈានទៅសម្រេចបាននូវការកសាងធនធានមនុស្សប្រកបដោយការទទួលខុសត្រូវ និងមានការចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំបង្កើតក្របខណ្ឌច្បាប់ និងយន្តការគាំទ្រនិងអនុវត្ត កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធ លើកកម្ពស់ការយល់ដឹងពីកិច្ចគាំពារ និងអភិវឌ្ឍកុមារ ដល់មាតាបិតានិងអាណាព្យាបាល បង្កើតនិងពង្រឹងយន្តការតាមដាននិងវាយតម្លៃ ព្រមទាំងកៀរគរធនធានសម្រាប់គាំទ្រការលើកកម្ពស់កិច្ចគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព។

គោលដៅយុទ្ធសាស្ត្រគឺលើកកម្ពស់កិច្ចគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម ជាពិសេសកុមារងាយរងគ្រោះនៃគ្រួសារកសិករក្រីក្រ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រខាងលើ ក៏ដូចជាធានាឱ្យបាននូវប្រសិទ្ធភាពនៃកិច្ចគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានកំណត់ទិសដៅ៥ចំណុចដូចខាងក្រោម ៖

- ទី១. បង្កើតក្របខណ្ឌច្បាប់ និងយន្តការគាំទ្រ និងអនុវត្តការគាំពារនិងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម។
- ទី២. កសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធពីកិច្ចគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម។
- ទី៣. លើកកម្ពស់ការយល់ដឹងពីកិច្ចគាំពារ និងអភិវឌ្ឍកុមារដល់មាតាបិតា អាណាព្យាបាល និងអ្នកថែរក្សាកុមារ។
- ទី៤. បង្កើតនិងពង្រឹងយន្តការតាមដាន និងវាយតម្លៃដែលមានការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់កម្រិត។
- ទី៥. កៀរគរធនធានពីគ្រប់មជ្ឈដ្ឋានសម្រាប់គាំទ្រដល់សកម្មភាពគាំពារនិងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម។

## សកម្មភាពអាទិភាពៈ

សកម្មភាពចម្បងមួយចំនួន នឹងត្រូវយកមកអនុវត្តក្នុងរយៈពេល៥ឆ្នាំនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម២០១៤-២០១៨ ដើម្បីឈានទៅសម្រេចបាននូវទិសដៅដែលបានកំណត់ខាងលើ។ ចង្កោមសកម្មភាពជាអាទិភាពត្រូវបានកំណត់ដូចខាងក្រោមៈ

**១. បង្កើតក្របខណ្ឌច្បាប់ និងយន្តការគាំទ្រ និងអនុវត្តការគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម**

១.១ បង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

១.២ រៀបចំគោលនយោបាយគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម។

១.៣ រៀបចំសេចក្តីណែនាំសម្រាប់អនុវត្តកម្មវិធីគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម។

១.៤ រៀបចំសេចក្តីប្រកាសស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងវិស័យកសិកម្ម។

**២. កសាងសមត្ថភាពមន្ត្រីពាក់ពន្ធ័ពីកិច្ចគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម**

២.១ រៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្មដល់ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២.២ បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់សហគមន៍កសិករ ភ្នាក់ងារសុខភាពសត្វភូមិ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ សហគមន៍ចិញ្ចឹមសត្វ សហគមន៍នេសាទ សហគមន៍ព្រៃឈើ។ល។

២.៣ រៀបចំទស្សនៈកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធន៍ពីការគាំពារនិងអភិវឌ្ឍកុមារ។

**៣. លើកកម្ពស់ការយល់ដឹងពីកិច្ចគាំពារ និងអភិវឌ្ឍកុមារ ក្នុងផលិតកម្មកសិកម្មដល់មាតា បិតា អាណាព្យាបាល និងអ្នកថែរក្សាកុមារ**

៣.១ រៀបចំសម្ភារផ្សព្វផ្សាយពីសិទ្ធិកុមារ និងសារបច្ចេកទេសកសិកម្មពាក់ព័ន្ធលើអាហារូបត្ថម្ភ អនាម័យ សុខភាព និងសុវត្ថិភាពកុមារ ដល់សហគមន៍មូលដ្ឋាន។

៣.២ រៀបចំវគ្គផ្សព្វផ្សាយបន្តដល់សហគមន៍មូលដ្ឋានពីកិច្ចគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម។

**៤. បង្កើត និងពង្រឹងយន្តការតាមដាន និងវាយតម្លៃដែលមានការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់កម្រិត**

៤.១ រៀបចំផែនការពិនិត្យតាមដាននិងវាយតម្លៃ។

៤.២ ចុះពិនិត្យតាមដានការអនុវត្តសកម្មភាពគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម។

៤.៣ រៀបចំឲ្យមានជនបង្គោលសម្រាប់ការងារកុមារនៅតាមអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤.៤ រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជនបង្គោល។

៤.៥ រៀបចំកិច្ចប្រជុំវាយតម្លៃប្រចាំឆ្នាំ លើការអនុវត្តផែនការគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម។

**៥. កៀរគរធនធានពីគ្រប់មជ្ឈដ្ឋាន សម្រាប់គាំទ្រដល់សកម្មភាពគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម**

៥.១ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំក្រសួង និងមន្ទីរកសិកម្មខេត្ត ដើម្បីកំណត់បញ្ហា និងដំណោះស្រាយជួយគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម

៥.២ រៀបចំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍ ដើម្បីចលនាការគាំទ្រលើសកម្មភាពគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម។

៥.៣ បញ្ចូលសកម្មភាពគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម ទៅក្នុងផែនការសកម្មភាពជាតិនានាដើម្បីកុមារ។

៥.៤ បញ្ជ្រាបសកម្មភាពគាំពារ និងអភិវឌ្ឍកុមារទៅក្នុងអនុកម្មវិធីនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៥.៥ បញ្ចូលសកម្មភាព និងរបាយការណ៍ពាក់ព័ន្ធការងារគាំពារនិងអភិវឌ្ឍកុមារ តាមវិស័យ ទៅក្នុងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃៈ ដើម្បីធានានូវប្រសិទ្ធភាពនៃកិច្ចគាំពារ និងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូច ដែលមានអនុរដ្ឋលេខាធិការ១រូបជាប្រធាន និងថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមួយចំនួនជាសមាជិក។ គណៈកម្មាធិការនេះ មានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្ត និងលទ្ធផលគម្រោង។ គណៈកម្មាធិការនេះនឹងសហការយ៉ាងជិតស្និទ្ធ ជាមួយក្រុមការងារយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជនបង្គោលនៅតាមអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ក្នុងការអនុវត្តគម្រោងខាងលើ ជាមួយយន្តការតាមសហគមន៍មូលដ្ឋានដែលមានស្រាប់ ដូចជាសហគមន៍កសិករ ភ្នាក់ងារសុខភាពសត្វភូមិ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ សហគមន៍ចិញ្ចឹមសត្វ សហគមន៍នេសាទ សហគមន៍ព្រៃឈើ។ល។ កិច្ចប្រជុំប្រចាំត្រីមាសនិងប្រចាំឆ្នាំ ដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធក៏នឹងត្រូវរៀបចំឡើង ក្នុងគោលបំណងវាយតម្លៃពីការរីកចម្រើនរបស់គម្រោង បញ្ហាប្រឈម ដំណោះស្រាយ និងកំណត់នូវយុទ្ធសាស្ត្រសមស្របនានា សម្រាប់កែលម្អការអនុវត្តគម្រោងនាឆ្នាំបន្តបន្ទាប់។

## ជ. ផែនការថវិកាសម្រាប់ដំណើរការអនុវត្ត

ដើម្បីសម្រេចទិសដៅគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់អាទិភាពនូវកម្មវិធី/គម្រោងនានា សំដៅធ្វើវិភាជន៍ថវិកាឱ្យបានសមស្រប ដើម្បីគាំទ្រកម្មវិធី/គម្រោងទាំងនោះ សម្រាប់អនុវត្តអំឡុងឆ្នាំ២០១៤-២០១៨ និងបន្ថែមលើនេះទៀត ក្រសួងមានជំនឿជឿជាក់ថា រាជរដ្ឋាភិបាលកម្ពុជានឹងបង្កើនបន្ថែមនូវធនធានថវិកាក្នុងស្រុក ជាមួយនឹងជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុពីសហគមន៍អន្តរជាតិ ដៃគូអភិវឌ្ឍន៍ពីខាងក្រៅ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងពិសេសទៀតនោះ គឺការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសហគមន៍កសិករ សំដៅរួមគ្នាជំរុញការអភិវឌ្ឍវិស័យកសិកម្ម។

ប្រភពហិរញ្ញវត្ថុសំខាន់ៗសម្រាប់ការលើកស្ទួយអភិវឌ្ឍន៍វិស័យកសិកម្ម នឹងបានមកពីថវិកាជាតិ និងជំនួយពីដៃគូនានា។ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងនូវកម្មវិធី/គម្រោងអាទិភាពសំខាន់ៗ ទៅតាមកម្មវិធីតាមវិស័យនិងអនុវិស័យ ដោយមានវិភាជន៍កញ្ចប់ថវិកាសមស្រប ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធី/គម្រោងសកម្មភាពសម្រាប់ឆ្នាំ២០១៤-២០១៨ ដោយមានតម្រូវការថវិកាសរុបចំនួនប្រមាណជាង**៣៤៧,៥៦លានដុល្លារអាមេរិក** (ថវិកាចរន្តនិងមូលធន)។

ការចំណាយថវិកាចរន្តមានចំនួនប្រមាណ **<u>២៨៩.៦៣៣.៥៧០</u>** ដុល្លារអាមេរិក ក្នុងនោះ ថវិកាចំនួន **៧៧.៤៣០.៧៦០** ដុល្លារអាមេរិក គ្រោងសម្រាប់ការបង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ថវិកាចំនួន **៨៦.៧០១.១៣០** ដុល្លារអាមេរិក គ្រោងសម្រាប់ការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ ថវិកាចំនួន **៧២.៥៥១.១៣០** ដុល្លារអាមេរិក គ្រោងសម្រាប់ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព ថវិកាចំនួន **៥៩.៧១៤.២៤០** ដុល្លារអាមេរិក សម្រាប់ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព និងថវិកាចំនួន **៤៣.២៣៦.៣១០** ដុល្លារអាមេរិក គ្រោងសម្រាប់ការពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម។

## ឈ. ការពិនិត្យតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាតម្រូវការចាំបាច់ ដើម្បីធានាដល់ការអនុវត្តគម្រោងសកម្មភាព និងសូចនាករនានា សម្រាប់ផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលសម្រេចបាន ដែលបានកំណត់យ៉ាងសមស្រប នៅក្នុងការធ្វើផែនការ និងការរៀបចំគម្រោងសកម្មភាពនីមួយៗ។ ដូចនេះ ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាឧបករណ៍ដ៏ស័ក្តិសិទ្ធិ សម្រាប់ផ្ទៀងផ្ទាត់រាល់សូចនាករលទ្ធផល (Outcomes & Outputs) នៅពាក់កណ្តាលអាណត្តិ និងពេញអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងដើម្បីជាមូលដ្ឋានសម្រាប់វាយតម្លៃ ការអនុវត្តគោលនយោបាយតាមផ្នែក ក៏ដូចជាគោលនយោបាយថ្នាក់ជាតិ។

ទោះបីយ៉ាងណាក៏ដោយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ នឹងត្រូវបានបង្ហាញ និងបញ្ជាក់នូវសូចនាករជាច្រើន សម្រាប់ធ្វើការផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្ត។ (លម្អិតក្នុងឧបសម្ព័ន្ធ១៖ តារាងសូចនាករសំខាន់ៗ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨) ។

ដើម្បីធានាដល់ការអនុវត្តយ៉ាងពេញលេញ នូវការពិនិត្យតាមដាននិងវាយតម្លៃ នាយកដ្ឋានផែនការនិងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តសកម្មភាពតាមដាននិងវាយតម្លៃនេះ។ របាយការណ៍លទ្ធផលការងារសម្រាប់គម្រោងទាំងនោះនឹងត្រូវរៀបចំឡើងក្នុងអំឡុងពេលអនុវត្ត និងការវាយតម្លៃក្រោយពេលអនុវត្ត។ បណ្តានាយកដ្ឋានអង្គភាពជំនាញនានាដែលពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវរាយការណ៍ជូនក្រសួង (នាយកដ្ឋានផែនការនិងស្ថិតិ) ពីលទ្ធផលសម្រេចបានឱ្យបានទៀងទាត់ តាមរយៈការផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ។ របាយការណ៍អនុវត្ត និងសមិទ្ធផលសម្រេចបានក្នុងការអនុវត្តនេះ នឹងត្រូវរៀបចំបូកសរុបដោយនាយកដ្ឋានផែនការនិងស្ថិតិ ហើយត្រូវរាយការណ៍ជូនក្រសួងពិនិត្យនិងសម្រេច។ ផ្អែកលើរបាយការណ៍ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវធ្វើការបូកសរុប រួចរាយការណ៍ជូនទៅក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានរាយការណ៍ជូនរាជរដ្ឋាភិបាលកម្ពុជា។

***ប្រព័ន្ធតាមដាននិងវាយតម្លៃសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម***



## ៣. សេចក្តីសន្និដ្ឋាន

ជាការពិណាស់ថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០១៨ ដែលបាន រៀបចំនេះនឹងត្រូវបានកំណត់ជាត្រីវិស័យ ក្នុងបេសកកម្មរយៈពេល៥ឆ្នាំ ដែលសកម្មភាពការងារជា ច្រើននឹងមានការពាក់ព័ន្ធនៅក្នុងការអនុវត្ត ដល់ផ្នែកនានាក្នុងគ្រប់វិស័យ និងអនុវិស័យទាំងអស់នៅ ក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងទាមទារឱ្យមានការចូលរួមសហការអនុវត្តពី គ្រប់ស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ ព្រមទាំងផ្នែកឯកជនផងដែរ។ ការចូលរួមរបស់ ផ្នែកឯកជន ជាពិសេសនៅក្នុងផលិតកម្មកសិកម្មនិងកសិពាណិជ្ជកម្ម គឺមានសារសំខាន់ណាស់ ក្នុងការរួមចំណែកជំរុញកំណើនក្នុងវិស័យកសិកម្ម។

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តល់ការគាំទ្របន្ថែមទៀត ដល់ការអភិវឌ្ឍវិស័យកសិកម្ម ដើម្បី ធ្វើជាកម្លាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ជាមួយនឹង ការបង្កើនថវិកាវិនិយោគសាធារណៈ ព្រមទាំងបង្កើនការកៀរគរ ក៏ដូចជាការប្រើប្រាស់ធនធានជំនួយ ពីបរទេសឱ្យបានច្រើនជាងមុន សំដៅជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍវិស័យកសិកម្មនេះ។

ឯកសារនេះក៏បានបញ្ជាក់ផងដែរ នូវចំណុចដែលជាឧបសគ្គចម្បងៗ និងបានលើកឡើងនូវ បណ្តាសកម្មភាពទាំងឡាយ ដើម្បីជម្នះនូវឧបសគ្គទាំងនោះ ព្រមទាំងបានបង្ហាញលម្អិតអំពីលទ្ធផល រំពឹងទុក ជាពិសេសសូចនាករ និងលទ្ធផលដែលត្រូវសម្រេចឱ្យបាន ក្នុងកំឡុងពេលអនុវត្តផែនការ យុទ្ធសាស្ត្រនេះ និងមធ្យោបាយផ្ទៀងផ្ទាត់នៅក្នុងប្រតិបត្តិការពាក់កណ្តាល និងពេញអាណត្តិនៃ គម្រោងផែនការសកម្មភាពត្រូវអនុវត្ត ដោយបានបង្ហាញផងដែរ នូវថវិកាសម្រាប់ដំណើរការប្រតិបត្តិ ការ និងកាលវិភាគការងារដែលត្រូវសម្រេចឱ្យបានជោគជ័យ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០១៨ ពិតជាមានសារសំខាន់យ៉ាងខ្លាំង ក្នុងការបង្ហាញឱ្យឃើញអំពីទិសដៅនិងសកម្មភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលស្រប តាមការចង្អុលណែនាំក្រោមក្របខណ្ឌ «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០១៨**» និង ផ្តល់តម្លាភាព និងភាពគួរឱ្យទុកចិត្តបានសម្រាប់ដៃគូអភិវឌ្ឍន៍ ក៏ដូចជាបណ្តាប្រទេសម្ចាស់ជំនួយ ដើម្បីចូលរួមចំណែកផ្តល់ធនធានទាំងបច្ចេកទេសនិងថវិកា ក្នុងការអនុវត្តបណ្តាសកម្មភាពអាទិភាព សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម។

កត្តាអវិជ្ជមាននិងឧបសគ្គនានាដែលនឹងអាចរាំងស្ទះ ក្នុងការបង្កើនផលិតភាព ពិពិធកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ពិសេសផលិតកម្មដំណាំស្រូវ និងដំណាំដូវមានសក្តានុពលសេដ្ឋកិច្ច ខ្ពស់ គឺអាចជាកត្តាគ្រោះធម្មជាតិដែលនឹងអាចកើតមាន ដូចជា គ្រោះទឹក ជំនន់ ភាពរាំងស្ងួត កត្តា បំផ្លិចបំផ្លាញពីសត្វល្អិតចង្រៃ ។ល។ ដែលយើងមិនអាចដឹងមុន។ ប៉ុន្តែទោះជាយ៉ាងណាក្តី ឧបសគ្គ ទាំងនេះនឹងអាចកាត់បន្ថយបាន តាមរយៈការតាំងចិត្តនិងការខិតខំជម្នះ ដើម្បីទទួលបានលទ្ធផល ល្អប្រសើរក្នុងការអភិវឌ្ឍវិស័យកសិកម្មនេះ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្តេជ្ញា ចិត្តខ្ពស់ក្នុងការជំរុញការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០១៨នេះ ឱ្យ ទទួលបានលទ្ធផលផ្លែផ្កាប្រកបដោយជោគជ័យតាមការរំពឹងទុក។

--------------✍📖✍-------------

**ឧបសម្ព័ន្ធ ១: តារាងសូចនាករសំខាន់ៗ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យកសិកម្ម**

| សូចនាករសំខាន់ៗ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| ទិន្នផលស្រូវ | តោន/ហ.ត. | ៣,១៥ | ៣,១៨ | ៣,២១ | ៣,២៣ | ៣,២៥ |
| ផ្ទៃដីដាំដុះដំណាំស្រូវ | លានហ.ត. | ៣,១០ | ៣,១៥ | ៣,២០ | ៣,២៨ | ៣,៣៤ |
| បរិមាណផលស្រូវ | លានតោន | ៩,៧៦ | ១០,០១ | ១០,២៨ | ១០,៥៦ | ១០,៨៥ |
| ផលិតផលស្រូវផលិតលើស | លានតោន | ៥,២៤ | ៥,៤១ | ៥,៦០ | ៥,៧៩ | ៦,០០ |
| ផ្ទៃដីសម្រាប់ដំណាំគ្រប់ប្រភេទ (រួមទាំង ដំណាំអចិន្ត្រៃយ៍និងចម្ការ) | ហ.ត. | ៤.៨១៤.៥៣៤ | ៥.០២៤.៥៣៤ | ៥.២៣៤.៥៣៤ | ៥.៤៤៤.៥៣៤ | ៥.៦៥៤.៥៣២ |
| សហគមន៍កសិកម្ម | ចំនួន | ៤៧៥ | ៥៧៥ | ៦៧៥ | ៧៧៥ | ៨៧៥ |
| ផលិតកម្មសត្វគ្រប់ប្រភេទក្នុងកំណើន៣% | លានក្បាល | ៣៥,៨៦ | ៣៦,៩៣ | ៣៨,០៣ | ៣៩,១៧ | ៤០,៣៤ |
| សត្វដែលទទួលបានវ៉ាក់សាំង | % | ១០ | ១២ | ១៥ | ១៧ | ២០ |
| ចំនួនសត្តឃាតដ្ឋានដែលអនុវត្តអនាម័យល្អតាមបទដ្ឋានបច្ចេកទេស | ចំនួនកន្លែង | ២៥ | ៥០ | ៧៥ | ១០០ | ១២៥ |
| ផ្ទៃដីកៅស៊ូសរុប | ហ.ត. | ៣០៦.៥០០ | ៣៣៤.៥០០ | ៣៦២.៥០០ | ៣៨៤.៥០០ | ៤០៤.៥០០ |
| ទិន្នផលជ័រ | គ.ក្រ/ហ.ត | ១.២៥៧ | ១.២៨២ | ១.៣១១ | ១.៣៧៣ | ១.៣៦៨ |
| បរិមាណផលជ័រកៅស៊ូស្ងួត | តោន | ១៣៧.៥២០ | ១៨១.៥៦០ | ២៤០.៨០០ | ៣០០.៨០០ | ៣៤០.៩៣០ |
| ផលិតកម្មវារីវប្បកម្ម (កើន១៥%) | តោន | ៩៧.៨០០ | ១១២.៥០០ | ១២៩.៤០០ | ១៤៨.៨០០ | ១៧១.១៧០ |
| បរិមាណផលិតកម្មនេសាទ (ទឹកសាប សមុទ្រ និងវារីវប្បកម្ម) | ពាន់តោន | ៧៥២ | ៧៩០ | ៨២៩ | ៨៧០ | ៩១០ |
| ចំនួនសហគមន៍នេសាទត្រូវពង្រឹងសមត្ថភាព | សហគមន៍ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ |
| ផ្ទៃដីអភិរក្សសត្វព្រៃនិងព្រៃការពារ | ហ.ត | ៥០.០០០ | ៥០.០០០ | ៥០.០០០ | ៥០.០០០ | ៥០.០០០ |
| ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើត | ចំនួន | ៣២ | ៣២ | ៣២ | ៣២ | ៣២ |

ប្រភព÷ ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨